វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
*The NGO Forum on Cambodia*



# សៀវភៅណែនាំអំពីថវិកាជាតិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
២០១៦

បោះផ្សាយ និងកែសំរួលដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ខែមេសា ឆ្នាំ ២០១៦

មាតិកានៃឯកសារនេះអាចត្រូវបានដកស្រង់ និងបានផលិតឡើងវិញក្នុងគោលបំណងសម្រាប់បម្រើដល់ការអភិវឌ្ឍ ប៉ុន្តែសូមឲ្យមានការទទួលស្គាល់សិទ្ធិអ្នកបោះពុម្ពផ្សាយ

# មាតិកា

បញ្ជីតារាង រូបភាព និងប្រអប់ ........ iii
តារាងពាក្យបំព្រួញ ........ v
សេចក្តីថ្លែងអំណរគុណ ........ vii
ការកត់ចំណាំចំពោះអ្នកអាន ........ viii

**១. សេចក្តីផ្តើម ........ ១**
១.១ តើអ្វីទៅជាថវិកាជាតិ? ........ ១
១ ២.ក្របខ័ណ្ឌបទប្បញ្ញត្តិ និងគោលការណ៍ចំបងនៃថវិកាជាតិ ........ ២
១.៣ រចនាសម្ព័ន្ធនៃថវិកាជាតិ ........ ៣
១.៣.១ តើចំណូលថវិកាជាតិបានមកពីណា? ........ ៣
១.៣.២ តើថវិកាជាតិចំណាយទៅណា? ........ ៦
១.៣.៣ ឱនភាព / អតិរេក ........ ៧

**២. ដំណើរវិវត្តនៃថវិកា និងភាគីពាក់ព័ន្ធ ........ ៨**
២.១ ដំណាក់កាលទី១: ការបង្កើតថវិកា (ខែមីនា - ខែកញ្ញា) ........ ១០
២.២ ដំណាក់កាលទី២: ការអនុម័តនៃច្បាប់ស្តីពីថវិកាដោយអង្គនីតិបញ្ញត្តិ (ខែវិច្ឆិកា ដល់ខែធ្នូ) ........ ២២
២.៣ ដំណាក់កាលទី៣: ការអនុវត្តនៃច្បាប់ស្តីពីថវិកាដោយអង្គនីតិប្រតិបត្តិ (ថ្ងៃទី១ ខែមករាដល់ថ្ងៃ ទី៣១ ខែធ្នូ) ........ ២៥
២.៣.១ និតិវិធីប្រតិបត្តិថវិកា ........ ២៩
២.៣.២ ឧបករណ៍គ្រប់គ្រងការអនុវត្តន៍ ថវិកា ........ ៣២
២.៤ ដំណាក់កាលទី ៤: សវនកម្ម និងការវាយតម្លៃ ........ ៣៥

**៣. ការយល់ដឹងអំពីរចនាសម្ព័ន្ធរបស់ច្បាប់ស្តីពីថវិកាជាតិ និងឯកសារពាក់ព័ន្ធ ........ ៣៩**
៣.១ ការយល់ដឹងអំពីរចនាសម្ព័ន្ធរបស់ច្បាប់ថវិកាជាតិ ........ ៣៩
៣.១.១. ផ្នែក ១: អត្ថបទក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ ........ ៤០

៣.១.២- ផ្នែកទី II: តារាងឧបសម្ព័ន្ធ A, B, C និង D ដែលភ្ជាប់ទៅនឹងច្បាប់ថវិកា ............................ ៤៤
៣.២- ការវិភាគនៃថវិកាជាតិ.................................................................................. ៥៣
៣.៣. ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤ - ២០១៨ ............................................... ៥៥

**៤. បញ្ហាពាក់ព័ន្ធ** ............................................................................................ ៥៧
៤.១ ការភ្ជាប់ទំនាក់ទំនងរវាងថវិកាជាតិជាមួយផែនការជាតិអភិវឌ្ឍន៍ និងផែនការវិស័យ ...................៥៧
៤.២ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........................................................ ៥៨
៤.២.១- កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ១: ២០០៥-២០០៨ .............៦០
៤.២.២- កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុដំណាក់កាលទី ២: ២០០៨-២០១៥ ............................៦២
៤.៣. ទិសដៅយុទ្ធសាស្រ្តកំណែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០........................................ ៦៣

**៥. តម្លាភាពថវិកា និងការចូលរួមជាសាធារណៈ**.......................................................... ៦៤
៥.១ ស្ថានភាពបច្ចុប្បន្ននៃការចូលរួមជាសាធារណៈអំពីព័ត៌មានថវិកា និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ
សាធារណៈ .......................................................................................................... ៦៥
៥.២. ឱកាសសម្រាប់ការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា ......................................... ៦៩
៥.៣. ប្រព័ន្ធទិន្នន័យទាក់ទងនឹងថវិកាជាតិ.......................................................................... ៧២

**ឯកសារយោង** ................................................................................................... ៧៣
ឧបសម្ព័ន្ធទី ១: សទ្ទានុក្រម ..........................................................................................៧៥
ឧបសម្ព័ន្ធទី ២: ឯកសារសម្រាប់អានបន្ថែម និងគេហទំព័រដែលពាក់ព័ន្ធ និង មានប្រយោជន៍ ...............៨០
ឧបសម្ព័ន្ធ៣: តារាង A, B, C និង D ពីច្បាប់ថវិកាឆ្នាំ ២០១៥ ......................................................៨៤
ឧបសម្ព័ន្ធ៤: របាយការណ៍ TOFE នៅខែធ្នូ ២០១៤..............................................................១១៣
ឧបសម្ព័ន្ធ៥: ទំរង់ថវិកាសង្ខេបសម្រាប់ឆ្នាំ២០១៥ .............................................................. ១១៦

# បញ្ជីតារាង រូបភាព និងប្រអប់

## បញ្ជីតារាងៈ

តារាងទី១: រចនាសម្ព័ន្ធប្រាក់ចំណូលនៅក្នុងច្បាប់ស្តីពីថវិកាឆ្នាំ ២០១៥ ....................................៤
តារាងទី២: ប្រតិទិនសម្រាប់ការរៀបចំថវិកាជាតិដូចមានចែងក្នុងមាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ (២០០៨)....................................................................................៩
តារាងទី៣: តារាងប្រតិបត្តិការហិរញ្ញវត្ថុ និង សេដ្ឋកិច្ចសម្រាប់ ខែមិថុនា ឆ្នាំ ២០១៥ .............. ៣៣
តារាងទី៤: ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (ថ្នាក់ជាតិ) ឆ្នាំ ២០១៥ ថវិកាជាតិ..........................................៤២
តារាងទី៥: ការបែងចែកថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៥..................................៤៣
តារាងទី៦: អត្រាពន្ធលើប្រាក់បៀវត្សរ៍អនុម័តក្នុងច្បាប់ស្តីពីថវិកាឆ្នាំ២០១៥ (ជំពូក ៣)........... ៤៨
តារាងទី៧: ក្រសួងនានាជាមួយនឹងគម្រោងចំណាយមូលធនខ្ពស់បំផុតក្នុងឆ្នាំ២០១៥ .............. ៥២
តារាងទី៨: ផែនការសាកល្បងកំណែទម្រង់ប្រព័ន្ធថវិកា .....................................................៦៣
តារាងទី៩: វត្តមាន និងភាពគ្រប់គ្រាន់៖ គន្លឹះឯកសារថវិកាទាំងប្រាំបី ....................................៦៧
តារាងទី១០: ការកំណត់ពេលវេលាសម្រាប់ភាពអាចរកបានជាសាធារណៈ និងព័ត៌មាន មួយចំនួនដែលត្រូវ ការដើម្បីដាក់បញ្ចូលនៅក្នុងឯកសារ.............................................................................៦៧

## បញ្ជីរូបភាពៈ

រូបភាពទី១: ដំណើរការនៃច្បាប់ថវិកាជាតិ ........................................................................ ១
រូបភាពទី២: ប្រាក់ចំណូលជាតិ ...................................................................................... ៤
រូបភាពទី៣: បួនដំណាក់កាល រយៈពេល និងអ្នកចូលរួមក្នុងដំណើរវិវត្តនៃថវិកា ........................ ៩
រូបភាពទី៤: ដំណើរការបង្កើតថវិកា...............................................................................១១
រូបភាពទី៥: ដំណើរការនៃការអនុម័តច្បាប់ស្តីពីថវិកា....................................................... ២៤
រូបភាពទី៦: លំហូរនៃការចំណាយថវិកាចរន្តសម្រាប់រដ្ឋបាលថ្នាក់ជាតិ ................................. ៣១
រូបភាពទី៧: លំដាប់លំដោយនៃវេទិកាកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ................៥៩
រូបភាពទី៨: សមាសធាតុក្នុងការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា ............................៦៥

**បញ្ជីប្រអប់:**

ប្រអប់ទី១: ការយល់ដឹងពីការប៉ាន់ស្មានម៉ាក្រូសេដ្ឋកិច្ច និងការព្យាករណ៍សារពើពន្ធទំនេរ ............ ១១
ប្រអប់ទី២: សារាចរណែនាំរបស់រដ្ឋាភិបាលអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥............ ១៣
ប្រអប់ទី៣: សារាចររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥ ........................................................................១៧
ប្រអប់ទី៤:សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៥.......... ១៨
ប្រអប់ទី៥: សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអំពីសេចក្តីព្រាងច្បាប់លើការគ្រប់គ្រង ហិរញ្ញវត្ថុ (២០១៥) ...........................................................................................................២១
ប្រអប់ទី៦: សៀវភៅទាំងប្រាំមួយនៃថវិកាជាតិ ឯកសារយោងក្នុងការតាមដានថវិកាប្រកបដោយប្រសិទ្ធភាព ...........................................................................................................២៦
ប្រអប់ទី៧: របាយការណ៍សវនកម្មបោះផ្សាយក្នុងឆ្នាំ២០១១ ........................................... ៣៨
ប្រអប់ទី៨: ការលំបាកដែលប្រឈមមុខដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបែងចែកការ ចំណាយ ៥៤
ប្រអប់ទី៩: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ - តើមានអ្វីថ្មីនិងអ្វី បន្ទាប់?...៥៥
ប្រអប់ទី១០: គ្រប់គ្រងចំណូលពីប្រេង ឧស្ម័ន និងរ៉ែ.........................................................៦១

# តារាងពាក្យបំព្រួញ

| | |
|---|---|
| API | វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ |
| BSP | ផែនការយុទ្ធសាស្ត្រថវិកា |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDCF | វេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា |
| CNPA | ទីភ្នាក់ងារជាតិប្រេងកាតកម្ពុជា |
| CR | លុយរៀល |
| CRDB | ក្រុមប្រឹក្សានីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា |
| CSCQBE | អង្គការសង្គមស៊ីវិលសម្រាប់គុណភាពអប់រំមូលដ្ឋាន |
| FMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GFS | ស្ថិតិហិរញ្ញវត្ថុរបស់រដ្ឋាភិបាល |
| IBP | ភាពជាដៃគូថវិកាអន្តរជាតិ |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| LIC | ប្រទេសមានចំណូលទាប |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MIC | ប្រទេសមានចំណូលមធ្យម |
| MKSS | Mazdoor Kisan Shakti Sangathan |
| MME | ក្រសួងរ៉ែ និងថាមពល |
| MoEYS | ក្រសួងអប់រំយុវជន និងកីឡា |
| MOP | ក្រសួងផែនការ |
| NA | រដ្ឋសភាជាតិ |
| NAA | អាជ្ញាធរសវនកម្មជាតិ |
| NGO/CSOs | អង្គការមិនមែនរដ្ឋាភិបាល / អង្គការសង្គមស៊ីវិល |
| NGOF | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| OBS | ការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកា |
| OBI | សន្ទស្សន៍នៃការផ្សព្វផ្សាយព័ត៌មានថវិកា |
| ODA | ជំនួយផ្លូវការសម្រាប់ការអភិវឌ្ឍ |
| PB | ថវិកាកម្មវិធី |

| | |
|---|---|
| PETS | ការស្ទង់មតិលើការតាមដានចំណាយសាធារណៈ |
| PFM | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PFMRP | កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PIP | កម្មវិធីវិនិយោគសាធារណៈ |
| RGC | រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា |
| SDR | សិទ្ធិគំនូសពិសេស |
| SNA | រដ្ឋបាលថ្នាក់ក្រោមជាតិ |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| TOFE | តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច |
| US | សហរដ្ឋអាមេរិក |
| USD | ដុល្លារសហរដ្ឋអាមេរិក |
| VAT | ពន្ធលើតម្លៃបន្ថែម |

# សេចក្តីថ្លែងអំណរគុណ

សៀវភៅណែនាំនេះត្រូវបានបង្កើតឡើង ដោយគម្រោងថវិកាជាតិនៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ សៀវភៅណែនាំនេះ បានទទួលប្រយោជន៍ពីការផ្តល់យោបល់ដ៏មានតម្លៃពីសំណាក់ សមាជិកនៃបណ្តាញវេទិកាស្តីពីបញ្ហាអភិវឌ្ឍន៍ ព្រមទាំងអ្នកជំនាញឯករាជ្យស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ នៅកម្ពុជា។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា សូមសម្តែងនូវការកោតសរសើរយ៉ាងខ្លាំង ចំពោះបណ្តាអង្គការ និងបុគ្គលទាំងអស់ដែលបានចូលរួមចំណែកដល់ការបោះពុម្ពផ្សាយនេះ។

# ការកត់ចំណាំចំពោះអ្នកអាន

ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលមានការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីថវិកាសម្រាប់ការយល់ព្រមពីទីស្តីការ គណៈរដ្ឋមន្ត្រី ដោយបានទទួលការអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភា ហើយបានប្រកាសឱ្យប្រើ ដោយព្រះមហាក្សត្រ។ ច្បាប់ស្តីពីថវិកានេះ អនុញ្ញាតឱ្យរដ្ឋាភិបាលក្នុងការប្រមូលប្រាក់ចំណូលពន្ធ និង ក្រៅពីពន្ធ ហើយនឹងគ្រប់គ្រងការចំណាយថវិកា អនុលោមតាមកម្រិតសមស្របនៅក្នុងច្បាប់នេះ។ ប្រាក់ ចំណូលពន្ធ និងក្រៅពីពន្ធភាគច្រើនបានមកពីការបង់ប្រាក់ទៅរដ្ឋាភិបាលរបស់កម្មករ អតិថិជន ក្រុមហ៊ុនអាជីវកម្ម និងម្ចាស់អចលនទ្រព្យនៅក្នុងទំរង់ជាពន្ធ ពន្ធអាករ និងអាករពិសេស។ រដ្ឋាភិបាល ប្រមូលបានរាប់រយលានដុល្លារពីប្រាក់ចំណូលនេះ និងចំណាយទៅវិញនៅលើប្រាក់បៀវត្សរបស់មន្ត្រីរាជ ការ ការសាងសង់ និងការរក្សានូវហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសាធារណៈដូចជាសុខាភិបាល ការអប់រំ និងការបន្តកម្មវិធីកសិកម្មទូទាំងប្រទេសកម្ពុជា។

តើនរណាជាអ្នកទទួលបន្ទុកបំផុតក្នុងការគ្រប់គ្រងប្រាក់រាប់រយលានដុល្លារទាំងនេះ? យើងដែលជា ប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា គឺជាអ្នកទទួលបន្ទុក។ ពលរដ្ឋកម្ពុជាអនុវត្តសិទ្ធិត្រួតពិនិត្យ ដោយការចូលរួមក្នុងការបោះឆ្នោតសមាជិកសភា និងរដ្ឋាភិបាល ដែលជាប់ឆ្នោតឲ្យធ្វើការសម្រេចចិត្តដ៏ មានសារៈសំខាន់តំណាងអោយប្រជាពលរដ្ឋ។ ទោះបីយ៉ាងណាក៏ដោយ ក្រៅពីការចូលរួមក្នុងដំណើរ ការបោះឆ្នោត ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការថវិកាប្រចាំឆ្នាំ គឺនៅមានកំរិតនៅឡើយ ពេលបច្ចុប្បន្ននេះ។ ការចូលរួមកាន់តែច្រើននៅក្នុងដំណើរការថវិកា នឹងនាំឱ្យមានទំនាក់ទំនងដោយ ផ្ទាល់រវាងការចំណាយរបស់រដ្ឋាភិបាល និងភាពជាក់ស្តែងនៃតម្រូវការ ចំណង់ និងសេចក្តីប្រាថ្នារបស់ ប្រជាជនកម្ពុជា។ វានឹងនាំឱ្យមានការយល់ដឹងកាន់តែជ្រៅនៃប្រជាធិបតេយ្យ និងតួនាទីដែលពលរដ្ឋ កម្ពុជា អាចដើរតួក្នុងការទាមទារអោយរដ្ឋាភិបាលទទួលខុសត្រូវ លើការគ្រប់គ្រងនៃមូលនិធិ សាធារណៈ។

បច្ចុប្បន្ននេះ ចំណេះដឹងនៃថវិកាជាតិ វដ្តថវិកា និងនិន្នាការចំណូល និងចំណាយ អាស្រ័យតែលើក្រុម មួយចំនួនតូចនៃអ្នកជំនាញក្នុងរដ្ឋាភិបាល រដ្ឋសភា ស្ថាប័នស្រាវជ្រាវ និងដៃគូអភិវឌ្ឍន៍មួយចំនួន ប៉ុណ្ណោះ។ ប៉ុន្តែមន្ត្រីរដ្ឋាភិបាលជាច្រើនទៀត គឺកំពុងមានការយល់ដឹងកាន់តែប្រសើរ និងចូលរួមយ៉ាង សកម្មក្នុងដំណើរការថវិកាតាមរយៈសេចក្តីណែនាំនៃកម្មវិធីកំណែទម្រង់ថវិកាដោយរដ្ឋាភិបាល។ ផ្នែក មួយនៃបញ្ហា គឺថាមិនមានប្រភពមួយណា ដែលអាចផ្តល់ជូននូវព័ត៌មានពេញលេញអំពីដំណើរការនៃ ការរៀបចំថវិកា និងអ្វីដែលជាប្រភពនៃប្រាក់ចំណូលរបស់រដ្ឋាភិបាល និងរបៀបដែលថវិកាទាំងនេះត្រូវ បានចំណាយ។ សៀវភៅណែនាំនេះមានគោលបំណងដើម្បីបំពេញចន្លោះប្រហោងនេះ។ វាមានគោល បំណងដើម្បីជាធនធានដ៏មានប្រយោជន៍មួយសម្រាប់មនុស្សគ្រប់គ្នាដែលជាប់ទាក់ទងនឹងថវិកាជាតិ រួម ទាំងមន្ត្រីរដ្ឋាភិបាល សមាជិកនៃសភា ជំនាញផ្នែកប្រព័ន្ធផ្សព្វផ្សាយ សាស្ត្រាចារ្យ និងនិស្សិត បុគ្គលិក អង្គការក្រៅរដ្ឋាភិបាល និងប្រជាជនកម្ពុជាផ្សេងទៀតទាំងអស់។ ដោយការប្រើប្រាស់សៀវភៅណែនាំ នេះ ត្រូវបានគេសង្ឃឹមថា ភាគីពាក់ព័ន្ធ

ទាំងអស់នឹងអាចរកឃើញកន្លែងសម្រាប់ខ្លួនឯងនៅក្នុងដំណើរ ការថវិកា និងដើម្បីធ្វើការចូលរួមចំណែករបស់ខ្លួនឱ្យមានការជជែកពិភាក្សាក្នុងន័យស្ថាបនាអំពីថវិកា ជាតិ។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដូចខាងក្រោម: ជំពូកទី១ ការកំណត់ថវិកាជាតិ គោលការណ៍ ស្នូល និងរចនាសម្ព័ន្ធនៃថវិកាជាតិ។ ជំពូកទី២ រៀបរាប់អំពីដំណាក់កាលផ្សេងៗគ្នានៃវដ្តថវិកា ពេល វេលាកំណត់ និងស្ថាប័នដែលពាក់ព័ន្ធនឹងដំណើរការ និងសកម្មភាពថវិកាជាតិ។ ជំពូកទី៣ ពន្យល់អំពី រចនាសម្ព័ន្ធ និង សមាសធាតុនៃច្បាប់ស្ដីពីថវិកា ព្រមទាំងប្រភេទផ្សេងៗគ្នានៃប្រាក់ចំណូល និង ចំណាយជាពិសេស របៀបដែលច្បាប់ស្ដីពីថវិកាជាតិបានបង្ហាញក្នុងតារាងរបស់ខ្លួន។ វាបានបង្ហាញ ព័ត៌មានថវិកាផ្សេងៗទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ លើសពីនេះទៀត ជំពូកនេះណែនាំគោល ការណ៍សំខាន់ៗលើការវិភាគថវិកា និងការប្រើប្រាស់នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៤-២០១៨) ដែលជាឧបករណ៍សម្រាប់ការវិភាគថវិកា។ ជំពូកទី៤ មើលទៅលើបញ្ហាពាក់ព័ន្ធនឹងថវិកា ជាតិ។ ជំពូកទី៥ បានបង្ហាញពីបញ្ហាដែលទាក់ទងទៅនឹងការវាយតម្លៃជាសាធារណៈ ទៅលើព័ត៌មាន ទាក់ទងនឹងថវិកា ស្ថានភាពបច្ចុប្បន្ននៃតម្លាភាពថវិកា និងការចូលរួមជាសាធារណៈក្នុងដំណើរការ ថវិកា។

ឧបសម្ព័ន្ធចំនួនប្រាំ បានភ្ជាប់នៅក្នុងសៀវភៅណែនាំនេះ។ ឧបសម្ព័ន្ធទី១ រួមមានបញ្ជីនៃការពន្យល់ពាក្យបច្ចេកទេសសំខាន់ៗដែលត្រូវបានប្រើនៅក្នុងសៀវភៅណែនាំនេះ និងពាក្យគន្លឹះផ្សេងៗទៀតស្ដីពីថវិកា ជាតិ។ ឧបសម្ព័ន្ធទី២ ផ្ដល់នូវទិដ្ឋភាពទូទៅនៃឯកសារសម្រាប់អាន និងគេហទំព័រស្ដីពីថវិកាជាតិកម្ពុជា ច្បាប់ពាក់ព័ន្ធ និងទិន្នន័យផ្សេងៗទៀត ថែមទាំងព័ត៌មានទូទៅជាច្រើនទៀតស្ដីពីហិរញ្ញវត្ថុសាធារណៈ។ ឧបសម្ព័ន្ធទី៣ បង្ហាញលម្អិតអំពីតារាងA, B, C និង D នៃច្បាប់ស្ដីពីថវិកាឆ្នាំ ២០១៥។ ឧបសម្ព័ន្ធទី៤ បានបង្ហាញពីទ្រង់ទ្រាយ នៃតារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច (TOFE) ប្រចាំឆ្នាំនៅក្នុងខែធ្នូ ឆ្នាំ ២០១៤។ ឧបសម្ព័ន្ធទី៥ បង្ហាញពីទ្រង់ទ្រាយថវិកាដោយសង្ខេបសម្រាប់ប្រជាពលរដ្ឋ។

សៀវភៅណែនាំនេះ គឺជាការធ្វើបច្ចុប្បន្នភាពនៃសៀវភៅណែនាំដែលបានចេញផ្សាយដោយវេទិកានៃ អង្គការមិនមែនរដ្ឋាភិបាលស្ដីពីកម្ពុជានៅឆ្នាំ ២០០៨។ ខណៈដែលមាតិកាភាគច្រើនគឺស្រដៀងគ្នា ប៉ុន្តែ ក៏មានភាពខុសគ្នាមួយចំនួនផងដែរ។ ភាពខុសប្លែកគ្នាមួយ គឺអវត្តមាននៃការវិភាគនៃនិន្នាការថវិកាដែល ត្រូវបានធ្វើរួចទៅហើយនៅក្នុងឯកសារវិភាគថវិកាដាច់ដោយឡែក ២០០៩-២០១៤។ ភាពខុសគ្នាផ្សេង ទៀត គឺការផ្ដោតអារម្មណ៍យ៉ាងខ្លាំងលើការពន្យល់នៃរចនាសម្ព័ន្ធថវិកា និងចំណាត់ថ្នាក់ថវិកា ព័ត៌មាន ស្ដីពីថវិកាពីប្រភពផ្សេងៗគ្នា ការពិភាក្សាអំពីថវិការដ្ឋបាលថ្នាក់ក្រោមជាតិ និងការទទួលបានព័ត៌មាន ថវិកា តម្លាភាពថវិកានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ទោះបីជាសៀវភៅណែនាំនេះមិនអាចដោះស្រាយនូវ អ្វីដែលបានសង្ឃឹមទុកទាំងអស់របស់ភាគីពាក់ព័ន្ធផ្សេងៗគ្នា វាអាចត្រូវបានប្រើប្រាស់ជា មគ្គុទ្ទេសក៍លើក ដំបូងដើម្បីស្វែងយល់ពីថវិកាជាតិ។

# ១. សេចក្តីផ្តើម

## ១.១ តើអ្វីទៅជាថវិកាជាតិ?

ថវិកាជាតិ គឺជារបាយការណ៍ផែនការចំណូល និងចំណាយរបស់រដ្ឋាភិបាល និងអនុញ្ញាតឱ្យរដ្ឋាភិបាល ដើម្បីកំណត់ថា តើរដ្ឋាភិបាលមានប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយរបស់ខ្លួន នៅក្នុងឆ្នាំសារពើពន្ធ នីមួយៗ[1] ។ សៀវភៅណែនាំអំពីសហព័ន្ធថវិកាឆ្នាំ ២០០២[2] សម្រាប់ប្រជាពលរដ្ឋ បានចេញផ្សាយដោយ ការិយាល័យបោះពុម្ពពលរដ្ឋអាមេរិក បានអោយនិយមន័យដល់ថវិកាជាតិនេះថាជា *"ផែនការមួយរបស់រដ្ឋាភិបាល ក្នុងការចំណាយប្រាក់របស់អ្នក ទូទាត់រាល់សកម្មភាពរបស់ខ្លួន ខ្ចីនិងសងប្រាក់កម្ចី និងអ្វីៗ ដែលអាចធ្វើអោយប៉ះពាល់ដល់សេដ្ឋកិច្ច ហើយដែលអាចរងផលប៉ះពាល់ពីសេដ្ឋកិច្ច"*។

នៅក្នុងប្រទេសកម្ពុជា ថវិកាជាតិត្រូវបានសំដៅទៅលើច្បាប់ស្តីពីថវិកាជាតិ[3] បន្ទាប់ពីប្រតិបត្តិនៃជំហាន ប្រាំសំខាន់ៗដូចខាងក្រោម(សូមមើលក្នុងរូបភាពទី១)។ ច្បាប់ស្តីពីថវិកាជាតិ ត្រូវបានរៀបចំជារៀងរាល់ ឆ្នាំសម្រាប់អនុវត្តក្នុងឆ្នាំប្រតិទិនបន្ទាប់ (ដែលស្របពេលជាមួយឆ្នាំសារពើពន្ធ)។ ច្បាប់នេះបានផ្តល់នូវ សិទ្ធិអំណាចទៅអង្គនីតិប្រតិបត្តិដើម្បីប្រមូលប្រាក់ចំណូល និងការចំណាយក្នុងគោលបំណងដើម្បី សម្រេចបាននូវគោលដៅនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជាការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង គោលនយោបាយតាមវិស័យ។ វាគឺជាឧបករណ៍សំខាន់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តន៍គោលនយោបាយ និងកត់ត្រា តើរដ្ឋាភិបាលបានចំណាយថវិកា និងរបៀបដែលពួកគេត្រូវបានផ្តល់ហិរញ្ញប្បទានដោយរបៀបណា។

### រូបភាពទី១: ដំណើរការនៃច្បាប់ស្តីពីថវិកាជាតិ




---

[1] សូមមើល វេទិកាអង្គការមិនមែនរដ្ឋាភិបាល (២០០៧) សៀវភៅណែនាំស្តីពីថវិកាជាតិ.

[2] http://www.gpo.gov/fdsys/pkg/BUDGET-2002-CITIZENSGUIDE/pdf/BUDGET-2002-CITIZENSGUIDE.pdf

[3] ក្នុងឆ្នាំ ២០០៨ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាននិយមន័យថា «ថវិការដ្ឋឬ ជាតិសំដៅទៅលើតុល្យភាព ដែលបានគ្រោងទុកទ្រព្យសម្បត្តិនិងបំណុលអចិន្ត្រៃយ៍របស់រដ្ឋ។ ថវិការដ្ឋឬ ជាតិ រួមមានទាំងថវិកានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ថវិកាជាតិគឺជាថវិកាបស់រដ្ឋបាលថ្នាក់ជាតិ។ ថវិកាថ្នាក់ ក្រោមជាតិគឺថវិកាជាតិប្រើប្រាស់ក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិ "។

## ១.២ ក្របខ័ណ្ឌបទប្បញ្ញត្តិ និងគោលការណ៍ចំបងនៃថវិកាជាតិ

ថវិកាជាតិកម្ពុជា ត្រូវបានគ្រប់គ្រងភាគច្រើនផ្អែកទៅលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (២០០៨)[4]។ មាត្រា១ ចែងថា *"ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមានគោលបំណងក្នុងការកំណត់ គោលការណ៍ជាមូលដ្ឋានក្នុងការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈជារួម និងដើម្បីអភិវឌ្ឍន៍ច្បាប់ស្តីពី ហិរញ្ញវត្ថុ (ច្បាប់ស្តីពីថវិកាជាតិប្រចាំឆ្នាំ) ជាពិសេសរាល់ដំណាក់កាលនីមួយៗនៃការរៀបចំថវិកា អនុម័ត និងការអនុវត្តន៍ ពិនិត្យ ឡើងវិញនៃការអនុវត្តថវិកា ការកំណត់នូវតួនាទី និងការទទួលខុសត្រូវ និង ផលវិបាកនៃកំហុសនានាក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន អង្គភាព សាធារណៈស្រដៀងគ្នា គ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ"*។ រចនាសម្ព័ន្ធ និងមាតិកា សំខាន់នៃច្បាប់ស្តីពីថវិកាជាតិ ច្បាប់និងបទបញ្ញាត្តិ ព្រមទាំងបញ្ហាជាក់លាក់ក្នុងការគ្រប់គ្រងថវិកា នេះត្រូវបានកំណត់ផងដែរដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ច្បាប់ស្តីពីថវិកាជាតិក៏បានបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងខ្លាំងផងដែរសម្រាប់តម្លាភាពថវិកា។ ច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ មាត្រាទី៨៤ ចែងថា: *"...កំណត់ត្រាទាំងអស់របស់ចំណូល និងចំណាយ របស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមតារាងនៃគណនី និងនាមវលីថវិកា គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុទាំងអស់ត្រូវតែមានតម្លាភាព និងបង្ហាញជាសាធារណៈ"*។

ខណៈពេលដែលការភ្ជាប់ទំនាក់ទំនងទៅនឹងគោលនយោបាយជាតិត្រូវបានធ្វើឱ្យប្រសើរឡើង ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅឆ្នាំ២០០៨ បានផ្តល់នូវគោលការណ៍សំខាន់ៗមួយចំនួន ដែលច្បាប់ស្តីពីថវិកាជាតិត្រូវតែប្រកាន់ភ្ជាប់[5]។ គោលការណ៍ទាំងនេះមានដូចខាងក្រោម៖

- ច្បាប់ស្តីពីថវិកាជាតិត្រូវបានរៀបចំសម្រាប់គ្រប់ឆ្នាំសារពើពន្ធ (ពីថ្ងៃទី១ ខែមករា ដល់ថ្ងៃថ្ងៃទី៣១ ខែធ្នូ)
- រាល់ចំណូល និងចំណាយរបស់រដ្ឋាភិបាលទាំងអស់ត្រូវបានដាក់ជូនទៅសភានៅពេលជាមួយគ្នា ដើម្បីអនុញ្ញាតដោយការវាយតម្លៃលើ (ប្រាក់ចំណូល និងចំណាយមួយចំនួន ត្រូវបានពិភាក្សាដោយ ឡែកពីគ្នា)
- ចំណូល និងចំណាយទាំងអស់ចាំបាច់ត្រូវបានដាក់ជូនជាលក្ខណៈបុគ្គល។ ប្រាក់ចំណូលអាចនឹង មិនត្រូវទុកដោយឡែកសម្រាប់ការចំណាយជាពិសេស និងប្រាក់ចំណូលមិនអាចត្រូវបានកាត់កង នឹងការចំណាយ (ដូច្នេះមានតែតុល្យភាពត្រូវបានបង្ហាញ)
- ច្បាប់ស្តីពីថវិកាជាតិត្រូវបានឆ្លុះបញ្ចាំងពីប្រភពទាំងអស់នៃធាតុចំណូល និងចំណាយ
- គណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុទាំងអស់ត្រូវតែមានតម្លាភាព និងបង្ហាញជាសាធារណៈ[6]។

មានគោលការណ៍សំខាន់ៗចំនួន១១ ដែលបានគូសបញ្ជាក់យ៉ាងសង្ខេបក្នុងមាត្រាទី៥ នៃច្បាប់ស្តីពី ថវិកាជាតិដែលបានដាក់ឲ្យអនុវត្តយ៉ាងជាក់លាក់។ ពួកគេគឺ ១. អំណាច ២. របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ

[4] ច្បាប់នេះអាចនឹងត្រូវបានទាញយកពីវែបសាយ: www.cambodianbudget.org or http://www.cdc-crdb.gov.kh/cdc/twg_network/country_systems_cambodia/strengthening_national_systems/resources_on_rgc_reforms.htm

[5] សូមមើលជំពូកទីបីនៅក្នុង «ហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា» ដោយលោកបណ្ឌិតហង្សជួនណារ៉ុន (២០០៩)។

[6] មាត្រា៨៤ នៃច្បាប់ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

(១២ខែ) ៣. ភាពទូលំទូលាយ ៤. ឯកភាព ៥. សាកលភាព ៦. ឯកទេស ៧. តុល្យភាព ៨. ភាពមានទំនួលខុសត្រូវ ៩. តម្លាភាព ១០. ស្ថេរភាព និង ១១. ភាពអាចសំរេចបាន។ អត្ថន័យនៃពាក្យ នីមួយៗ និងកម្មវិធីរបស់ខ្លួនអាចត្រូវបានរកឃើញនៅក្នុងមាត្រាទី៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ។

## ១.៣ រចនាសម្ព័ន្ធនៃថវិកាជាតិ

### ១.៣.១ តើចំណូលថវិកាជាតិបានមកពីណា?

ជារៀងរាល់ឆ្នាំ រដ្ឋាភិបាលបានប្រមូលប្រាក់ចំណូលបានពីប្រភពក្នុងស្រុក និងប្រភពខាងក្រៅ។ ប្រាក់ចំណូលពីប្រភពក្នុងស្រុកបានមកពីការបង់ពន្ធ និងក្រៅពីពន្ធដែលប្រមូលបានតាមរយៈរតនាគារជាតិ។ ប្រភពពីខាងក្រៅ គឺបានមកពីជំនួយពីបរទេសដែលត្រូវបានប្រមូលបានតាមរយៈរតនាគារជាតិផង និង ក្រៅពីរតនាគារជាតិផង។

ចំណូលពន្ធ និងក្រៅពីពន្ធត្រូវបានចាត់ថ្នាក់ជាប្រាក់ចំណូលបច្ចុប្បន្ន ចំណែកឯជំនួយបរទេសត្រូវបាន រួមបញ្ចូលនៅក្នុងប្រាក់ចំណូលមូលធន។ ចំណូលពន្ធ ប្រមូលបានមកពីពន្ធនៃការធ្វើពាណិជ្ជកម្មទាំង ក្នុងស្រុក និងអន្តរជាតិ។ ពន្ធក្នុងស្រុកត្រូវបានប្រមូលដោយរដ្ឋាភិបាល បានពីអាជីវកម្ម និងអ្នកប្រើ ប្រាស់ដែលជាអ្នកបង់ពន្ធជាចម្បង។ ពន្ធទាំងនេះរួមមានពន្ធលើប្រាក់ចំណូល ពន្ធលើការកើនឡើងនៃ អចលនទ្រព្យ ពន្ធលើប្រាក់ចំណេញ ពន្ធលើអចលនទ្រព្យ ពន្ធ និងអាករនាំចេញ អាករលើផលរបរ ពន្ធលើការផ្តល់អាជ្ញាប័ណ្ណនាំចេញ និងការផ្តល់អាជ្ញាប័ណ្ណក្នុងស្រុក ពន្ធលើសេវាជាក់លាក់ (ពន្ធលើ កាស៊ីណូ ឆ្នោត ការភ្នាល់និងអាកាសយានដ្ឋាន) និងពន្ធប៉ាតង់។ អ្នកប្រើប្រាស់ ត្រូវបង់ពន្ធច្រើនប្រភេទ រួមមានពន្ធលើប្រាក់ចំណូល ពន្ធអចលនទ្រព្យ ពន្ធលើតម្លៃបន្ថែម (១០% នៅលើទំនិញ និងសេវាកម្ម ទាំងអស់) ពន្ធលើទំនិញជាក់លាក់ (អាករពិសេសលើផលិតផលជាក់លាក់) ពន្ធគយលើការនាំចូល និង ផលិតផលប្រេង និងពន្ធបង់បន្ថែមលើផលិតផលប្រេង។ ផ្ទុយទៅវិញ ពន្ធពាណិជ្ជកម្មអន្តរជាតិផ្តោតលើ ការបង់ពន្ធដែលទទួលបានពីការនាំចូល និងការនាំចេញដែលជាធម្មតាត្រូវបង់ដោយអាជីវកម្ម ឬវិនិយោ ទុន។ ចំណូលមិនមែនសារពើពន្ធ ទទួលបានពីការជួល និងការលក់ទ្រព្យសម្បត្តិសាធារណៈ និង សម្បទានរ៉ែ ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ ធ្វើឯកជនភាព លិខិតឆ្លងដែន ថ្លៃទិដ្ឋាការ និងថ្លៃរដ្ឋបាល។

ជំនួយបរទេស (ដែលត្រូវបានកត់ត្រានៅក្នុងប្រាក់ចំណូលមូលធន) ជាទូទៅត្រូវបានទទួលក្នុងទំរង់ជា ការផ្តល់ប្រាក់កម្ចី និងជំនួយឥតសំណងពីដៃគូអភិវឌ្ឍន៍ពហុភាគី និងទ្វេភាគី។ វាត្រូវបានគេកត់សម្គាល់ ឃើញថានៅក្នុងប្រាក់ចំណូលមូលធន ការវិនិយោគហិរញ្ញវត្ថុក្នុងស្រុករួមមានមូលនិធិគាំទ្រថវិកា កម្ចីនិង ជំនួយឥតសំណងត្រូវបានរួមបញ្ចូលផងដែរ[7]។ វិនិយោគក្នុងស្រុកទាំងនេះត្រូវបានកត់ត្រាទុកនៅក្នុង រតនាគារជាតិ[8]។

---

[7] សូមមើលវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល (ឆ្នាំ២០០៧) សេចក្តីណែនាំថវិកាជាតិ.

[8] ច្បាប់ថវិកា ឆ្នាំ ២០១៥

**រូបភាពទី២: ប្រាក់ចំណូលជាតិ**




នៅក្នុងច្បាប់ស្តីពីថវិកាជាតិឆ្នាំ២០១៥ រដ្ឋាភិបាលមានគម្រោងប្រមូលប្រាក់ចំណូល ដែលមានចំនួនប្រហែល ១៥.១៣៥.២៣០លានរៀល ឬ ៣,៧ ពាន់លានដុល្លារ។ ចំនួនសរុបទាំងនេះ ប្រហែលជា ៧៥,៦% នឹងបានមកពីការប្រាក់ចំណូលតាមរយៈរតនាគារជាតិ និង ២៤,៤% ពីប្រាក់ចំណូលក្រៅពីរតនាគារជាតិ។ ៩៧,៤% នៃប្រាក់ចំណូលសរុបតាមរយៈរតនាគារជាតិ គឺជាប្រាក់ចំណូលក្នុងស្រុក។ តារាងទី១ ខាងក្រោមនេះ បង្ហាញពីរចនាសម្ព័ន្ធទូលំទូលាយនៃប្រាក់ចំណូល។

**តារាងទី១: រចនាសម្ព័ន្ធប្រាក់ចំណូលនៅក្នុងច្បាប់ស្តីពីថវិកាឆ្នាំ ២០១៥**

| | ជាលាន រៀល | ជាលានដុល្លារ អាមេរិក | % |
|---|---|---|---|
| **ប្រាក់ចំណូលសរុប (I + II)** | ១៥.១៣៥.២៣០ | ៣.៧៣៧,១ | ១០០% |
| **I. ប្រាក់ចំណូលតាមរយៈរតនាគារជាតិ** | ១១.៤៤៨.២៣០ | ២.៨២៦,៧ | ៧៥,៦% |
| ក. ប្រាក់ចំណូលក្នុងស្រុក | ១១.១៤៨.២៣០ | ២.៧៥២,៦ | ៧៣,៧% |
| ១. ប្រាក់ចំណូលបច្ចុប្បន្ន | ១១.០១៤.៦៤៤ | ២.៧១៩,៧ | ៧២,៨% |
| ១.១. ពន្ធលើប្រាក់ចំណូល | ៩.៥៤៨.៣៩១ | ២.៣៥៧,៦ | ៦៣,១% |
| ១.១.១. ប្រាក់ចំណូលពន្ធក្នុងស្រុក | ៧.៥៨៧.៦៩១ | ១.៨៧៣,៥ | ៥០,១% |
| a. ពន្ធដោយផ្ទាល់(ពន្ធលើប្រាក់ចំណូល ពន្ធលើប្រាក់ចំណេញ ពន្ធលើកំណើនអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ) | ២.០៦៩.០០០ | ៥១០,៩ | ១៣,៧% |
| b. ពន្ធប្រយោល (ពន្ធលើចំណូល ពន្ធលើតម្លៃបន្ថែម ពន្ធលើអាជ្ញាប័ណ្ណការនាំ | ៣.៤២០.០០០ | ៨៤៤,៤ | ២២,៦% |

| | ជាលាន រៀល | ជាលានដុល្លារ អាមេរិក | % |
|---|---|---|---|
| ចេញ និង អាជ្ញាប័ណ្ណក្នុងស្រុក) | | | |
| c. ពន្ធគយ (ពន្ធលើការបង់បន្ថែមលើផលិតផលប្រេង ពន្ធគយលើការនាំចូលនិងផលិតផលប្រេង ពន្ធលើផលិតផលពិសេស) | ១.៩៥៣.៤០០ | ៤៨២,៣ | ១២,៩% |
| d. ពន្ធផ្សេងទៀត (ពន្ធលើកាស៊ីណូ ឆ្នោត ការភ្នាល់ និងអាកាសយានដ្ឋាន ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពិន័យ) | ១៤៥.២៩១ | ៣៥,៩ | ១,០% |
| ១.១.២- ពន្ធលើប្រាក់ចំណូលពាណិជ្ជកម្ម / អន្តរជាតិ | ១.៩៦០.៧០០ | ៤៨៤,១ | ១៣,០% |
| ១.២-ចំណូលមិនមែនពន្ធ | ១.៤៦៦.២៥៣ | ៣៦២,០ | ៩,៧% |
| ចំណូលមូលធន | ៤៣៣.៥៨៦ | ១០៧,១ | ២,៩% |
| ប្រាក់ចំណូលដោយផ្ទាល់ | ១៣៣.៥៨៦ | ៣៣,០ | ០,៩% |
| ប្រាក់ចំណូលបពីប្រភពខាងក្រៅ | ៣០០.០០០ | ៧៤,១ | ២,០% |
| **២. ប្រាក់ចំណូលក្រៅពីវតនាគារជាតិ** | ៣.៦៨៧.០០០ | ៩១០,៤ | ២៤,០% |
| ជំនួយឥតសំណង | ៥៣៧.០០០ | ១៣២,៦ | ៣,៥% |
| កម្ចី | ៣.១៥០.០០០ | ៧៧៧,៨ | ២០,៨% |

ប្រភព: ច្បាប់ស្ដីពីថវិកាឆ្នាំ ២០១៥ អត្រាប្ដូរប្រាក់: $១= ៤.០៥០ ដោយផ្អែកទៅលើច្បាប់ស្ដីពីថវិកា ឆ្នាំ ២០១៥។

តារាងខាងលើបានបង្ហាញយ៉ាងច្បាស់ថា ជាងពីរភាគបីនៃចំណូលបានមកពីពន្ធដារ និងចំណូលមិនមែន ពន្ធត្រូវបានប្រមូលមកពីប្រជាជនកម្ពុជាក្នុងស្រុក។ ពន្ធក្នុងស្រុកបានចូលរួមចំណែកប្រមាណ ៥០% នៃ ប្រាក់ចំណូលសរុប។ នេះគឺវាខ្ពស់ជាងប្រាក់ចំណូលពីពន្ធពាណិជ្ជកម្មអន្តរជាតិដែលត្រូវបានគេរំពឹងថា នឹងប្រមូលបានចំនួនប្រហែល ១៣%។ សមាមាត្រទាបនៃការបង់ពន្ធពាណិជ្ជកម្មអន្តរជាតិ គឺមិនមាន ការភ្ញាក់ផ្អើលទេ ដោយសារតែប្រទេសកម្ពុជាមានការប្ដេជ្ញាចិត្ត ក្នុងការចូលជាសមាជិកតំបន់ពាណិជ្ជកម្ម សេរីអាស៊ាន[9] និង អង្គការពាណិជ្ជកម្មពិភពលោក។ ជិតពាក់កណ្ដាលនៃប្រាក់ចំណូលពន្ធក្នុងស្រុក បាន មកពីពន្ធប្រយោលដែលត្រូវបានគិតពីអ្នកប្រើប្រាស់។ ពន្ធអាករលើតម្លៃបន្ថែមចូលរួមស្ទើរតែ ១០០% នៃប្រភេទពន្ធប្រយោល។ សមាសភាគមួយដ៏សំខាន់នៃប្រាក់ចំណូលពន្ធអាករលើតម្លៃបន្ថែម បានមកពី ផលិតផលប្រេងដូចជា ប្រេងសាំង ប្រេងម៉ាស៊ូត ប្រេងកាត និងប្រេងឥន្ធនៈ។ ចំពោះការវិភាគលម្អិត បន្ថែមទៀតនៃព័ត៌មានឆ្នាំមុន សូម

[9] សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

មើលការវិភាគថវិកាឆ្នាំ ២០០៩-២០១៤ ដែលបានបោះផ្សាយដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា[10]។

អាជីវកម្ម និងអ្នកប្រើប្រាស់ក៏បានបង់ប្រាក់ចំណូលមិនមែនពន្ធដល់រដ្ឋាភិបាលផងដែរ។ អាជីវកម្មនានា បង់ប្រាក់ចំណូលពីជីសម្បទាន និងការជួលដី[11] ដែលបានផ្តល់ដោយរដ្ឋាភិបាល ចំណូលពីការលក់ និង ការជួលអចលនទ្រព្យនិងសេវាកម្ម ការបង្កើតសហគ្រាស សេវាសុរិយោដីនិងសំណង់ ការត្រួតពិនិត្យ គុណភាពនៃផលិតផលនិងអនុលោមតាមស្តង់ដា និងផ្សេងៗទៀត។ ប្រាក់ចំណូលបានពីការលក់ និង ការជួលអចលនទ្រព្យនិងសេវាកម្ម គឺបានមកពីអាកាសចរណ៍ស៊ីវិល សកម្មភាពភាពយន្ត ទេសចរណ៍ សកម្មភាពជាវប្បធម៌ ប្រៃសណីយ៍និងទូរគមនាគមន៍ វិទ្យុនិងទូរទស្សន៍ និងផ្សេងៗទៀត។ ក្នុងឆ្នាំ ២០១៥ ប្រាក់ចំណូលទាំងនេះបានចូលរួមចំណែកប្រហែល ៦០% នៃប្រាក់ចំណូលមិនមែនពន្ធសរុប។ អាករលើស្ថានទូត (ថ្លៃលិខិតឆ្លងដែន និងទិដ្ឋាការ) និងសកម្មភាពទេសចរណ៍បានរួមចំណែកប្រហែល ៣៦,២% និង ១៧,៥% នៃចំណូលមិនមែនពន្ធសរុប។ ប្រាក់ចំណូលពីអាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ និងទូរគមនាគមន៍ បានរួមចំណែកប្រហែល ៦,៣% និង ៦,៩% នៃចំណូលមិនមែនពន្ធ សរុប។ ប្រាក់ចំណូលផ្សេងទៀតដូចជា ប្រាក់ចំណូលពីជីសម្បទាន និងការជួលដីបានចូលរួមចំណែក ប្រហែល ៧,៧% នៃចំណូលមិនមែនពន្ធសរុបដែលក្នុងនោះមានជាងពីរភាគបីបានមកពីការរុករករ៉ែ និង ព្រៃសម្បទាន។

## ១.៣.២ តើថវិកាជាតិចំណាយទៅណា?

មនុស្សគ្រប់គ្នាចង់ដឹងថាតើប្រាក់ចំណូលដែលប្រមូលបានត្រូវបានចំណាយដូចម្តេច។ ចំណាយរបស់ រដ្ឋាភិបាលត្រូវបានបែកចែកទៅជាពីរប្រភេទគឺ: ១) ការចំណាយចរន្ត និង ២) ការចំណាយមូលធន។

ចំណាយចរន្ត សំដៅទៅលើមូលនិធិដែលបានប្រើដើម្បីរក្សាការផ្តល់សេវារដ្ឋបាលដែលកំពុងប្រតិបត្តិការប្រចាំថ្ងៃ។ ឧទាហរណ៍ ការចំណាយលើប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ ទំនិញដែលត្រូវការដើម្បីផ្តល់ជូននូវសេវាកម្មដូចជា ថ្នាំពេទ្យ សៀវភៅ និងសេវាកម្មផ្សេងទៀត។ អ្នកផ្តល់ សេវាកម្មចម្បងដូចជា គ្រូបង្រៀន និងសេវាសុខភាព ត្រូវបានប៉ះពាល់ដោយសារការពន្យាពេលក្នុងការ ផ្តល់ប្រាក់ និងទូទាត់ចំណាយពីរតនាគារជាតិ ដែលវាបានតម្រូវឱ្យមានការធានាលើការប្រតិបត្តិចំណាយ ដើម្បីផ្តល់នូវសេវាកម្មប្រចាំថ្ងៃដល់សិស្សនិស្សិត និងអ្នកជំងឺ។ ឧទាហរណ៍ផ្សេងទៀតនៃការចំណាយ ចរន្តរួមមានការអន្តរាគមន៍ផ្នែកសង្គម ឬសេដ្ឋកិច្ច ចំណាយលើការទូទាត់ការប្រាក់ និងការចំណាយមិន បានរំពឹងទុកផ្សេងទៀត។

ការចំណាយមូលធន សំដៅទៅលើមូលនិធិដែលត្រូវបានប្រើដើម្បីបង្កើតការវិនិយោគដែលមានប្រាក់ចំណូលនាពេលអនាគត។ វាអាចរួមបញ្ចូលការធ្វើហិរញ្ញប្បទានគម្រោងវិនិយោគ ភាពជាដៃគូ និងការ រំលស់

[10] ឬតាមរយៈគេហទំព័រ: http://www.ngoforum.org.kh/index.php/en/publications-of-development-issues- programme និង www.cambodianbudget.org.

[11] ដូចជាការនេសាទ ព្រៃឈើស្របច្បាប់ រុករករ៉ែ ប្រេង និងដីដែលទំនេរ

បំណុល។ ឧទាហរណ៍ល្អនៃការចំណាយមូលធនគឺ ការចំណាយលើអាគារ និងហេដ្ឋារចនាសម្ព័ន្ធ សំណង់ប្រព័ន្ធធារាសាស្ត្រ គម្រោងអគ្គិសនី ការសាងសង់ស្ពាន និងការទិញរថយន្ត។ ការចំណាយថែទាំ ត្រូវបានរួមបញ្ចូលក្នុងការចំណាយមូលធន។ ឧទាហរណ៍ ការថែទាំស្ពាន ឬហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ខេត្ត/រាជធានី ស្រុក/ខណ្ឌ/ក្រុង និង ឃុំ/សង្កាត់ ដែលកញ្ចប់ថវិកានីមួយៗត្រូវបានអនុម័តក្នុងច្បាប់ស្តីពីថវិកាជាតិ និងការចំណាយថវិកាត្រូវទៅតាមខ្ទង់ ថវិកាតាមផែនការប្រចាំឆ្នាំរបស់ខ្លួន ដើម្បីផ្តល់សេវាកម្មជូនប្រជាជនកម្ពុជា។ ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ សង្កាត់អាចប្រើប្រាស់មូលនិធិឃុំ/សង្កាត់ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ អណ្តូងទឹក បង្គន់ អនាម័យ) និងផ្តល់សេវាផ្សេងទៀតនៅក្នុងឃុំ ដូចជាការចុះបញ្ជីសំបុត្រកំណើត និងការគាំទ្រសម្រាប់ ស្ត្រីក្រីក្រមានផ្ទៃពោះដើម្បីទទួលបានការថែទាំនៅក្នុងមណ្ឌលសុខភាព។

## ១.៣.៣ ឱនភាព / អតិរេក

ឱនភាព ឬអតិរេកបង្ហាញពីភាពខុសគ្នា រវាងប្រាក់ចំណូល និងការចំណាយនៃថវិការដ្ឋាភិបាល។ ប្រសិនបើរដ្ឋាភិបាលមានប្រាក់ចំណូលច្រើនជាងចំណាយ វាគឺជាអតិរេកថវិកា។ ផ្ទុយទៅវិញ ប្រសិនបើរដ្ឋាភិបាលមានប្រាក់ចំណូលតិចជាងចំណាយ វាគឺជាឱនភាពថវិកា។ ដូច្នេះ ភាពខុសគ្នារវាងប្រាក់ចំណូល និងការចំណាយបច្ចុប្បន្ន គឺជាឱនភាព/អតិរេកថវិកាបច្ចុប្បន្ន។ ខណៈពេលដែលភាពខុសគ្នារវាងប្រាក់ ចំណូលក្នុងស្រុកសរុប និងការចំណាយសរុប គឺជាឱនភាព/អតិរេកក្នុងថវិកាទូទៅ។

ដោយយល់ឃើញថា ប្រទេសកម្ពុជាជាប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ ថវិកាជារួមគឺនៅក្នុង ស្ថានភាពឱនភាព។ រដ្ឋាភិបាលនឹងត្រូវស្វែងរកជំនួយពីដៃគូអភិវឌ្ឍន៍ ការខ្ចីប្រាក់ពីបរទេស និងក្រៅប្រទេស ដែលអាចជាទំរង់ទ្វេភាគី (រួមមាន ប្រទេសចិន ជប៉ុន កូរ៉េខាងត្បូងជាដើម) ឬទំរង់ពហុភាគី (ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ដូចជាធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងមូលនិធិរូបិយវត្ថុ អន្តរជាតិ)។ ការខ្ចីប្រាក់ពីខាងក្រៅបន្ថែមមានន័យថា ប្រទេសយើងបង្កើនបំណុល[12] ឬយើងជំពាក់ បរទេសកាន់តែច្រើន ហើយយើងនឹងត្រូវបានតម្រូវឱ្យបង់ប្រាក់មកវិញទាំងប្រាក់ដើម និងការប្រាក់។ ការចំណាយទាំងនេះតែងតែត្រូវបានបម្រុងទុកក្នុងច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ។ នៅក្នុងច្បាប់ស្តីពីថវិកា ប្រចាំឆ្នាំ រដ្ឋាភិបាលត្រូវបានអនុញ្ញាតផងដែរឱ្យចេញប័ណ្ណបំណុលក្នុងចំនួនទឹកប្រាក់ជាក់លាក់មួយ ដើម្បីទូទាត់នឹងការខ្វះខាតសាច់ប្រាក់និង/ ឬឱនភាពថវិកា។

គណនីជំនួយពីបរទេសមានចំនួនជិតមួយភាគបីនៃចំណូលថវិកាជាតិសរុប ដែលមានចំនួនប្រហែល ២៦,៣%។ ៩២,៥% នៃប្រាក់ចំណូលនេះ ត្រូវបានយកទៅអនុវត្តក្រៅប្រព័ន្ធរតនាគារជាតិ នេះដោយយោងតាមច្បាប់ស្តីពីថវិកាជាតិឆ្នាំ ២០១៥។ ប្រហែល ១៥% នៃជំនួយពីបរទេសគឺជា ជំនួយឥតសំណង

12 សម្រាប់ការពន្យល់បន្ថែមស្តីពីបំណុល, សូមចូលទៅគេហទំព័ររបស់មូលនិធិរូបិយប័ណ្ណអន្តរជាតិ: http://www.imf.org/external/pubs/ft/dsa/pdf/2014/dsacr1433.pdf និងគេហទំព័ររបស់ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីការពិត អំពីសម្បទានបំណុលបរទេស (២០១៣) http://www.ngoforum.org.kh/index.php/en/publications-of-development-issues-programme.

និងនៅសល់ ៨៥%ទៀត នឹងទទួលបានពីប្រាក់កម្ចី/ការខ្ចីប្រាក់ពីខាងក្រៅ (សូមមើលក្នុង តារាងទី១)។ លើសពីនេះទៀត ច្បាប់ស្តីពីថវិកាជាតិឆ្នាំ ២០១៥ បានបញ្ជាក់ថារដ្ឋាភិបាលបានបង់ប្រាក់ ប្រហែល ១៧៦ លានដុល្លារ ឬប្រហែល ៤,៥% នៃថវិកាជាតិសរុបទៅអ្នកជំពាក់បំណុលខាងក្រៅ។ ការ ទូទាត់នេះរួមមាន ៦៨,២លានដុល្លារសម្រាប់ការប្រាក់ (កម្រៃហិរញ្ញវត្ថុ) និង ១០៧,៨ លានដុល្លារ អាមេរិកសម្រាប់ការសង ប្រាក់ដើម (ការទូទាត់នៃប្រាក់កម្ចី)។

# ២. ដំណើរវិវត្តនៃថវិកា និងភាគីពាក់ព័ន្ធ

ច្បាប់ស្តីពីថវិកាជាតិ គឺគ្រាន់តែជាព្រឹត្តិការណ៍មួយនៅក្នុងដំណើរការគ្រប់គ្រងជាបន្តបន្ទាប់ នៃពន្ធរបស់ រដ្ឋាភិបាល និងគោលនយោបាយការចំណាយ។ ក្នុងផ្នែកនេះ យើងនឹងពិភាក្សាអំពីដំណើរវិវត្តនៃថវិកា។ ដំណើរវិវត្តនៃថវិកា រួមមានបួនដំណាក់កាលសំខាន់ៗក្នុងការធ្វើសេចក្តីសម្រេចអំពីការបង្កើនប្រាក់ ចំណូល និងការចំណាយមូលនិធិសាធារណៈដូចដែលបានបង្ហាញនៅក្នុងរូបភាពទី៣។ លើសពីនេះ ទៀត តារាងទី២ បានបង្ហាញពីកាលវិភាគ និងឯកសារសំខាន់ដែលត្រូវទទួលបានក្នុងជំហាននីមួយៗ នៃដំណើរវិវត្តនៃថវិកា។

ដូចដែលបានបង្ហាញនៅក្នុងរូបភាពទី១ ខាងក្រោម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដើរតួនាទីស្នូល ក្នុងការរៀបចំថវិកា ការប្រតិបត្តិថវិកា និងការរៀបចំរបាយការណ៍សម្រាប់រដ្ឋសភា និងព្រឹទ្ធសភា។ សវនកម្មឯករាជ្យត្រូវបានគ្រប់គ្រងដោយច្បាប់ចំនួនពីរៈ ១) ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៨[13] និង ២) ច្បាប់ស្តីពីសវនកម្មឆ្នាំ២០០០[14]។

### រូបភាពទី៣: បួនដំណាក់កាល រយៈពេល និងអ្នកចូលរួមក្នុងដំណើរវិវត្តនៃថវិកា




[13] សូមមើលគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ និងស្ថាននិតិសម្បទានៃប្រទេសកម្ពុជា របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( http://www.cdc-crdb.gov.kh/cdc/twg_network/country_systems_cambodia/strengthening_national_systems/resources_on_rgc_reforms.htm ) ឬ គេហទំព័ររបស់ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល www.cambodianbudget.org

[14] សូមមើលគេហទំព័ររបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ និងស្ថាននិតិសម្បទានៃប្រទេសកម្ពុជា របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( http://www.cdc-crdb.gov.kh/cdc/twg_network/country_systems_cambodia/strengthening_national_systems/resources_on_rgc_reforms.htm ) ឬ គេហទំព័ររបស់ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល www.cambodianbudget.org

**តារាងទី២: ប្រតិទិនសម្រាប់ការរៀបចំនៃថវិកាជាតិដូចមានចែងក្នុងមាត្រា ៣៩ នៃច្បាប់ស្ដីពីប្រព័ន្ធ ហិរញ្ញវត្ថុសាធារណៈ (២០០៨)**

| | |
|---|---|
| **មីនា – ឧសភា** | ▪ **សប្ដាហ៍ដំបូងនៃខែមិនា:** រៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចថ្មី និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដែលជាប់ទាក់ទងគ្នាទៅនឹងគោលនយោបាយជាតិស្ដីពីការអភិវឌ្ឍន សម្រាប់ការយល់ព្រមដោយគណៈរដ្ឋមន្ត្រី។<br>▪ **សប្ដាហ៍ដំបូងនៃខែមេសា** (សូមមើលប្រអប់ទី១): សារាចរណែនាំស្ដីពីបញ្ជាសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើរបៀបដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាដែលស្របតាមគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដែលបានរៀប រាប់ពីមុន និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម។<br>▪ **សប្ដាហ៍ដំបូងនៃខែមេសាដល់ថ្ងៃទី១៥ ខែឧសភា:** រដ្ឋមន្ត្រី ប្រធាននៃស្ថាប័ន ឬ អង្គភាពសាធារណៈស្រដៀងគ្នា និងអភិបាលរាជធានី/ខេត្ត ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ថវិការបស់ខ្លួន និងដាក់ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនឱ្យហួសពីថ្ងៃទី១៥ ខែឧសភា។ |
| **មិថុនា – តុលា** | ▪ **សប្ដាហ៍ដំបូងនៃខែមិថុនា** (សូមមើលប្រអប់ទី៣): សេចក្ដីព្រាងសារាចរណែនាំស្ដីពីការរៀបចំថវិកាប្រចាំឆ្នាំត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រី (សប្ដាហ៍ដំបូងនៃខែមិថុនា សូមមើលប្រអប់ទី៣)<br>▪ **សប្ដាហ៍ដំបូងនៃខែមិថុនាដល់ថ្ងៃទី១៥ ខែកក្កដា:** រដ្ឋមន្ត្រី ប្រធាននៃស្ថាប័ន ឬ អង្គភាពសាធារណៈស្រដៀងគ្នា និងអភិបាលរាជធានី/ខេត្តត្រូវផ្ដល់សេចក្ដីលម្អិតលើប្រាក់ចំណូល និងចំណាយរបស់ពួកគេ និងផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនលើសពីថ្ងៃទី១៥ ខែកក្កដា។<br>▪ **ខែសីហា:** ពិភាក្សាជាមួយរដ្ឋមន្ត្រី ប្រធាននៃស្ថាប័ន ឬអង្គភាពសាធារណៈស្រដៀងគ្នា អភិបាលក្រុង/ខេត្តស្ដីពីសំណើរបស់ខ្លួន<br>▪ **ខែកញ្ញា:** បញ្ជាក់ចុងក្រោយនូវចំណូល និងចំណាយដែលត្រូវដាក់ចូលទៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីថវិកា<br>▪ **សប្ដាហ៍ដំបូងនៃខែតុលា:** សេចក្ដីព្រាងច្បាប់សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ ថែមទាំងកំណត់ចំណាំពន្យល់នៃច្បាប់នោះ ត្រូវបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីត្រឹមសប្ដាហ៍ដំបូងនៃខែតុលា។ |
| **វិច្ឆិកា – ធ្នូ** | ▪ **សប្ដាហ៍ដំបូងនៃខែវិច្ឆិកា:** រដ្ឋាភិបាលបានដាក់សេចក្ដីព្រាងច្បាប់ទៅរដ្ឋសភាជាតិ<br>▪ **សប្ដាហ៍ដំបូងនៃខែធ្នូ:** រដ្ឋសភាបានដាក់សេចក្ដីព្រាងច្បាប់ដើម្បីឱ្យព្រឹទ្ធសភាឲ្យយល់ព្រមឲ្យបានមុនថ្ងៃទី២៥ ខែធ្នូ។<br>▪ **មុនពេលចាប់ផ្ដើមនៃឆ្នាំសារពើពន្ធ:** ការប្រកាសឱ្យប្រើទៅជាច្បាប់ ដោយព្រះមហាក្សត្រ/ ការប្រកាសអោយមានប្រសិទ្ធភាពដោយព្រះរាជក្រឹត្យ |

ប្រភព: ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (២០០៨)

## ២.១ ដំណាក់កាលទី១: ការបង្កើតថវិកា (ខែមីនា - ខែកញ្ញា)

ផ្នែកនេះនឹងព្យាយាមឆ្លើយនឹងសំណួរ "តើរដ្ឋាភិបាលបានបង្កើតថវិកាដោយរបៀបណា?" ដែលមានបីជំហានខុសគ្នានៅក្នុងដំណើរការបង្កើតថវិការបស់កម្ពុជាដូចដែលបានបង្ហាញនៅក្នុងរូបភាពទី៤។

### រូបភាពទី៤: ការបង្កើតថវិកា

**ជំហាន១**
- ការរៀបចំនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ

**ជំហាន២**
- ការចេញសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា(BSP)

**ជំហាន៣**
- ការចេញសារាចរណែនាំស្តីពីការរៀបចំកញ្ចប់ថវិកា ឬសេចក្តីព្រាងច្បាប់ថវិកា

សម្រាប់**ជំហានដំបូង** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀបចំក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ហើយដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីអនុម័ត។ ក្របខ័ណ្ឌ នេះបង្ហាញអំពីការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចនៅក្នុងរយៈពេលមធ្យម និងម៉ាក្រូសេដ្ឋកិច្ចជារួម។ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលយកការវិភាគស្ថានភាពបច្ចុប្បន្ននៃសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការរំពឹងទុក នាពេលអនាគតរបស់ខ្លួនសម្រាប់រយៈពេលខ្លី និងមធ្យម ព្រមទាំងរាល់ឧបសគ្គនៃម៉ាក្រូសេដ្ឋកិច្ច។ គោលដៅ និងទស្សនវិស័យនៃការព្យាករណ៍កំណើនសេដ្ឋកិច្ច ផ្តល់នូវការណែនាំដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការប៉ាន់ប្រមាណប្រាក់ចំណូលដែលអាចទទួលបាន និងចំនួនដែលអាចចំណាយបាន បន្ទាប់ពីគិតពិចារណាទៅលើគោលនយោបាយសារពើពន្ធ ដែលមានផលប៉ះពាល់ដល់អតិផរណា ភាព ក្រីក្រ និងកំណើនសេដ្ឋកិច្ច។ បន្ទាប់ពីទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម **ជំហានទីពីរ** គឺការចេញសារាចរណែនាំរបស់រដ្ឋាភិបាលក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ទៅកាន់ទីភ្នាក់ងាររដ្ឋាភិបាលទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រសួងនិងស្ថាប័ននានា។ ផែនការ យុទ្ធសាស្ត្រថវិកា បន្ទាប់មកនឹងត្រូវបានដាក់ស្នើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមិនលើសពីថ្ងៃទី១៥ ខែឧសភា។

សម្រាប់ថវិកាឆ្នាំ២០១៥ សារាចរដំបូងចេញដោយរដ្ឋាភិបាល មានចំណងជើងថា: **"សេចក្តីណែនាំអំពីសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥"** ដែលជាឧបករណ៍ចំបងស្ថិតក្រោម កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ការអនុវត្តន៍នូវកម្មវិធីថវិកាក្នុងការបែងចែក ធនធានក្នុងរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រថវិកា កំណត់នៅផែនការយុទ្ធសាស្ត្រសម្រាប់ការរៀបចំថវិការបស់

ក្រសួង។ ថវិកាសម្រាប់ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំឡើង តាមរយៈកម្មវិធី និងចំណាត់ថ្នាក់សេដ្ឋកិច្ច។ សារាចរនេះត្រូវបានចែកចាយ ទៅក្រសួងពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ខេត្តដែលត្រូវបានចាត់ទុកជារដ្ឋបាលថ្នាក់ជាតិ។ សារាចរនេះ ត្រូវបានចុះហត្ថ លេខាដោយនាយករដ្ឋមន្ត្រីនៅថ្ងៃទី០២ ខែមេសា ឆ្នាំ ២០១៤ និងបានចេញផ្សាយនៅក្នុងរាជកិច្ច[15] នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។ ជំហានទីពីរនៅក្នុងដំណើរការបង្កើតថវិកា ចាប់ផ្តើមនៅពេលដែលភ្នាក់ងាររដ្ឋាភិបាលទទួលបានសារាចរ។ នៅពេលនោះ រដ្ឋមន្ត្រីនៅគ្រប់ក្រសួង ប្រធាននៃស្ថាប័នទាំងអស់ និង អង្គភាព សាធារណៈស្រដៀងគ្នាត្រូវរៀបចំ***ផែនការយុទ្ធសាស្ត្រថវិកា*** ដោយផ្អែកលើសារាចរ ចក្ខុវិស័យ គោលដៅ គោលបំណង និងអាទិភាពដែលគួរស្រប ជាមួយនឹងវិស័យអាទិភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ។ ផែនការ

**ប្រអប់ទី១: ការយល់ដឹងពីការប៉ាន់ស្មានម៉ាក្រូសេដ្ឋកិច្ច និងការព្យាការណ៍សារពើពន្ធទំនេរ**

ដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុមានភារកិច្ចដើម្បីធ្វើបច្ចុប្បន្នភាពលើម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ ជា ពិសេស គឺសំដៅទៅលើកំណើនសេដ្ឋកិច្ច ៧% បើធៀបទៅនឹងឆ្នាំសារពើពន្ធបច្ចុប្បន្ន។ វាត្រូវបានធ្វើ ឡើងដោយអគ្គនាយកដ្ឋានម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋ កិច្ច និងហិរញ្ញវត្ថុ។ នៅក្នុងការអនុវត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ាន់ប្រមាណអំពីប្រាក់ចំណូល នឹងត្រូវប្រមូលរួមមានចំនួនទឹកប្រាក់សរុបនៃពន្ធ និងមិនមែនពន្ធ ដោយផ្អែកលើការព្យាករណ៍ម៉ាក្រូ សេដ្ឋកិច្ច និងគោលដៅបន្ទាប់មកផ្តល់នូវការចំណាយថវិកាសរុប ឬការចំណាយនៃក្រសួងទាំងអស់ នៅក្នុងសារពើពន្ធចំហដែលវាត្រូវបានព្យាករសម្រាប់សារពើពន្ធប្រចាំឆ្នាំខាងមុខ។ ការបង្កើតនូវនីតិវិធី ទាំងនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសនាយកដ្ឋានថវិកានីយកម្មត្រូវបញ្ជាក់ពីលទ្ធភាព កើនឡើង និងភាពបត់បែនមួយចំនួនដែលក្រសួងនានាអាចរៀបចំថវិការបស់ខ្លួនសម្រាប់ការចរចា ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការព្យាករណ៍ទាំងនេះ អាស្រ័យលើភាពជឿជាក់នៃព័ត៌មាន សម្រាប់ប្រើប្រាស់ក្នុងការព្យាករណ៍ ដែលអាចជួយរដ្ឋាភិបាលដើម្បីរៀបចំខ្លួនអោយបានល្អប្រសើរ ជាងនេះនៅក្នុងករណីនៃអតិរេកថវិកា ឬឱនភាពថវិកា។ ជារៀងរាល់ឆ្នាំ រដ្ឋាភិបាល គឺមានឱនភាព ថវិកាសរុប ដោយសារតែមានតម្រូវការខ្ពស់សម្រាប់ការវិនិយោគសាធារណៈ ជាពិសេសសម្រាប់ ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ បណ្តាញតភ្ជាប់អគ្គិសនី និងផ្សេងៗទៀត។ នៅក្នុង ករណីនៃឱនភាពថវិកា រដ្ឋាភិបាលអាចកំណត់ជាមុននូវចំនួនទឹកប្រាក់កម្ចី ជាពិសេសប្រាក់កម្ចី សម្បទានដែលអាចបង្កើតពីការជំពាក់បំណុលទ្វេភាគី និងពហុភាគី ថែមទាំងជំនួយឥតសំណងដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍។ ចំនួនទឹកប្រាក់នៃការផ្តល់ប្រាក់កម្ចីសម្បទាន ត្រូវបានចែងនៅក្នុង ច្បាប់ស្តីពីសេចក្តីព្រាងច្បាប់ស្តីពីថវិកា ឬច្បាប់ស្តីពីថវិកាដើម្បីអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកំណត់កំរិត ជាក់លាក់មួយសម្រាប់ស្វែងរកហិរញ្ញប្បទានខាងក្រៅ ដើម្បីបំពេញចំនួនឱនភាពសារពើពន្ធសរុបរបស់ខ្លួន។ នៅក្នុងករណីនៃអតិរេកថវិកា រដ្ឋាភិបាលដាក់បញ្ញើរ ឬទុនបម្រុងទាំងនេះនៅធនាគារជាតិ នៃកម្ពុជាដើម្បីរក្សាស្ថានភាពសារពើពន្ធតាមការណែនាំដោយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ។

---

[15] ព្រះរាជកិច្ច គឺជាយន្តការនៃការបោះផ្សាយជាផ្លូវការនៃរាជរដ្ឋាភិបាល និងជាធម្មតាត្រូវបានបោះពុម្ពចំនួនបួនដងក្នុងមួយខែសម្រាប់ការលក់ក្នុងតម្លៃសមរម្យ។ ច្បាប់ចម្លងអាចត្រូវបានទទួលពីបណ្ណាល័យជាតិ និងបណ្ណាល័យសាធារណៈនៅរដ្ឋសភា និងព្រឹទ្ធសភា។

យុទ្ធសាស្ត្រថវិការបស់ក្រសួងនីមួយៗគួររួមបញ្ចូលថវិការបស់មន្ទីរ ខេត្តពាក់ព័ន្ធ។ ផែនការយុទ្ធសាស្ត្រថវិកាទាំងនេះ ត្រូវផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនឲ្យ លើសពីថ្ងៃទី១០ ខែឧសភា មុនថ្ងៃដែលតំរូវដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ផែនការ យុទ្ធសាស្ត្រថវិកាពីក្រសួងនានា ភ្នាក់ងារ និងអង្គភាពផ្សេងទៀត គឺជាឯកសារផ្ទៃក្នុងរបស់រាជរដ្ឋាភិបាល ហើយដូច្នេះមិនមានផ្សព្វផ្សាយជាសាធារណៈនោះទេ។ ប្រអប់ទី២ខាងក្រោមផ្តល់នូវទិដ្ឋភាពសង្ខេបនៃ មាតិកានៃសារាចរនេះ។

ការណែនាំផ្សេងទៀតលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្ងៃ ទី១០ ខែឧសភា ឆ្នាំ២០១៤) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់។ អភិបាលនៃរដ្ឋបាលថ្នាក់ ក្រោមជាតិទាំងអស់(ខេត្ត រាជធានី ក្រុង ស្រុក ខណ្ឌ) ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន និងដាក់ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បូកបញ្ចូលគ្នា មុនបញ្ជូនទៅអគ្គនាយកដ្ឋានហិរញ្ញវត្ថុ នៃរដ្ឋបាលថ្នាក់ក្រោមជាតិមិនឲ្យលើសពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ១០១៤។ ប្រអប់ទី៣ ខាងក្រោមផ្តល់ សេចក្តីសង្ខេបនៃមាតិកានៃការណែនាំនេះ។

<u>ប្រអប់ទី២: ***សារាចរណែនាំរបស់រដ្ឋាភិបាលការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥***</u>

រដ្ឋាភិបាលបានចេញសារាចរនេះនៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៤ និងបានចេញផ្សាយនៅក្នុងរាជកិច្ចជា ផ្លូវការនៅលើថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។ សារាចរនេះត្រូវបានចេញផ្សាយដើម្បីជូនដំណឹងដល់ ក្រសួង និងមន្ទីរតាមបណ្តាខេត្តអំពីបច្ចុប្បន្នភាពនៅក្នុងគោលការណ៍ណែនាំ និងរបៀបរៀបចំផែនការ យុទ្ធសាស្ត្រថវិកា ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សេចក្តីលម្អិតអំពីរបៀបនៃការរៀបផែនការ យុទ្ធសាស្ត្រថវិកាត្រូវបានដាក់ចេញនៅក្នុងគោលការណ៍ណែនាំផែនការយុទ្ធសាស្ត្រថវិកា។

**ជំពូកទី១: សេចក្តីផ្តើម**

"សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥" គឺជាឯកសារមាន២៧ទំព័រ (ជាភាសាខ្មែរ) រួមមានទាំងមាតិកា និងឧបសម្ព័ន្ធនៃតារាង និងគំរូឯកសារ។ វាមានការផ្លាស់ប្តូរមួយចំនួន នៅក្នុងសារាចរនេះ បើប្រៀបធៀបទៅនឹងឆ្នាំមុន។ កថាខណ្ឌស្តីពីការកំណត់កាលបរិច្ឆេទសម្រាប់ការ ដាក់ស្នើផែនការយុទ្ធសាស្ត្រថវិកាទាំងអស់ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបានគេផ្លាស់ប្តូរទៅផ្នែក ចុងក្រោយនៃសារាចរនេះ។ ផ្នែកដំបូងនៃឯកសារនេះ ជាសេចក្តីណែនាំដែលបានពន្យល់ពីតួនាទី និង ក្របខ័ណ្ឌបទប្បញ្ញត្តិពាក់ព័ន្ធនៃសារាចរ ដែលបានពន្យល់ពីសារៈសំខាន់នៃ "ផែនការយុទ្ធសាស្ត្រ ថវិកា" ដែលក្រសួងនីមួយៗ ត្រូវរៀបចំនៅលើមូលដ្ឋានប្រចាំឆ្នាំ និងសង្កត់ធ្ងន់លើសារៈសំខាន់នៃផែន ការទាំងនេះក្នុងការភ្ជាប់ថវិកាជាតិទៅនឹងគោលនយោបាយរបស់រដ្ឋាភិបាល។ កថាខណ្ឌទីបីនៃសេចក្តីណែនាំនេះ បានពន្យល់ពីផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍សម្រាប់ការ រួមបញ្ចូលការចំណាយជាប្រចាំរបស់ក្រសួង និងថវិកាមូលធន ថែមទាំងថវិកាជាតិ និងមូលនិធិដែល ផ្តល់ដោយហិរញ្ញប្បទាននៃដៃគូអភិវឌ្ឍន៍របស់រដ្ឋាភិបាល។ កថាខណ្ឌទីបួន និងចុងក្រោយនេះ ពន្យល់ អំពី ទិសដៅយុទ្ធសាស្ត្រនៃការធ្វើកំណែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០ និងកំណែទម្រង់ផ្នែក សំខាន់មួយចំនួននៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

នៅឆ្នាំ២០១៥ វាគឺជាចំណុចរបត់នៃហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា។ ក្រសួងចំនួន១០ នឹងអនុវត្ត ថវិកាកម្មវិធីពេញលេញ ខណៈពេលការសម្រេចគម្រោងថវិកានេះត្រូវបានធ្វើវិមជ្ឈការទៅជាផ្នែកទូទៅ ឬ កម្រិតនាយកដ្ឋានហៅថា អង្គភាពថវិកា។ នៅពេលជាមួយគ្នា ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងការ ចំណាត់ថ្នាក់ថវិកាថ្មីនឹងត្រូវបានអនុវត្តផងដែរ។

**ជំពូកទី២: ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ**

មានពីរផ្នែកក្នុងជំពូកទី២នេះ៖

ផ្នែកទីមួយ ផ្តល់នូវទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច។ កថាខណ្ឌនេះ បាន ផ្តល់នូវសេចក្តីណែនាំនៃការប៉ាន់ប្រមាណកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៤ និងការព្យាករណ៍ សម្រាប់ឆ្នាំ ២០១៥ ជាមួយនឹងការពន្យល់យ៉ាងទូលំទូលាយលើប្រភពនៃកំណើនសេដ្ឋកិច្ច អតិផរណា អត្រាប្តូរប្រាក់ និងឱនភាពគណនីបច្ចុប្បន្ន។

ផ្នែកទី២ ពិភាក្សាអំពីក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំនៃច្បាប់ស្តីពីថវិកាឆ្នាំ២០១៥។ វាចាប់ផ្តើមជាមួយនឹងការរាយគោលបំណងសំខាន់ៗនៃគោលនយោបាយហិរញ្ញវត្ថុ សាធារណៈឆ្នាំ២០១៥-២០១៧។ ផ្នែកនេះក៏បានភ្ជាប់ទៅនឹងការវិភាគដែលបានបង្ហាញនៅក្នុងផ្នែកទី មួយខាងលើ និងរំពឹងថាចំណូលទូទៅនឹងឡើងចំនួន១៥,៥៩% នៃផលិតផលក្នុងស្រុកសរុប(GDP)។ នេះផ្អែកទៅលើការកំណត់គោលដៅនៃកំណើនប្រាក់ចំណូលប្រចាំឆ្នាំ ០,៥% នៃផលិតផលក្នុងស្រុក សរុបសម្រាប់រយៈពេលពីឆ្នាំ២០១៥-២០១៧។ ការចំណាយជារួមត្រូវបានគេព្យាករណ៍ត្រឹម ២០,៩១ % នៃ GDP។ អតិរេកចរន្តថវិកា (៣% នៃ GDP) និងគោលដៅឱនភាពថវិកាទូទៅ (៥% នៃ GDP) ត្រូវបានកំណត់ផងដែរនៅក្នុងផ្នែកនេះ។

លើសពីនេះទៀត មានការធ្វើបច្ចុប្បន្នភាពក្នុងជំពូកទី២ ដែលគោលនយោបាយសំខាន់ត្រូវបានវាស់វែងដើម្បីពង្រឹងពន្ធគយ ពន្ធក្នុងស្រុក និងការប្រមូលចំណូលមិនមែនសារពើពន្ធត្រូវបានរាយដោយផ្អែក លើយុទ្ធសាស្ត្រការប្រមូលប្រាក់ចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ គោលបំណងសំខាន់នៃ ការចំណាយថវិកាត្រូវបានបង្ហាញនៅទីនេះផងដែរ និងរួមបញ្ចូលនូវបញ្ជីនៃគោលនយោបាយ និងការ វាស់វែងអាទិភាពនៃចំណាយសាធារណៈព្រមទាំងរាយនូវវិស័យអាទិភាព និងអនុវិស័យ (ក្នុងក្របខ័ណ្ឌ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ)។ វិស័យអាទិភាពទាំងនោះ គឺការកើនឡើងប្រាក់បៀវត្សរ៍មន្ត្រី រាជការសាធារណៈ ប្រសិទ្ធភាព និងតម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអប់រំ (ដូចជា សាលារៀន អាហារូបករណ៍សម្រាប់សិស្សក្រីក្រ) បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល (គុណភាពនៃ សេវាមន្ទីរពេទ្យ) សុវត្ថិភាពសង្គម ដី កសិកម្ម ធារាសាស្ត្រ គម្រោងទឹកស្អាត ការអភិវឌ្ឍហេដ្ឋារចនា សម្ព័ន្ធ (ផ្លូវថ្នល់ ស្ពាន ផ្លូវដែក កំពង់ផែ អគ្គិសនី) និងការអភិវឌ្ឍជនបទ។

**ជំពូកទី៣: រចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិកា**

ជំពូកទីបី និងចុងក្រោយនៃសារាចរមានចំណងជើងថា "រចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រថវិកា" បានផ្តល់គោលការណ៍ណែនាំទៅក្រសួងរដ្ឋាភិបាលនីមួយៗ និងភ្នាក់ងារដើម្បីបង្កើតផែនការយុទ្ធសាស្ត្រ ថវិកាសម្រាប់ឆ្នាំ ២០១៥-២០១៧។ វាត្រូវបានរៀបចំឡើងដូចមាតិកានៅក្នុងជំពូកនេះ ហើយត្រូវបាន ប្រើ

ប្រាស់ទៅតាមគំរូដែលបានភ្ជាប់ទៅនឹងសារាចរនេះ។ ផែនការយុទ្ធសាស្ត្រថវិកានីមួយៗត្រូវដាក់ជូន ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយត្រូវតែគ្រប់ដណ្តប់ប្រាំមួយចំនុចដូចខាងក្រោម៖

**១. សេចក្តីផ្តើម:** បញ្ជាក់អំពីតួនាទី ភារកិច្ច ការទទួលខុសត្រូវ និងអាណត្តិរបស់ក្រសួង/ ភ្នាក់ងារ ផ្តល់ ជូននូវរបាយការណ៍ស្ថានភាព (ផ្តោតលើការរីកចម្រើននៃសូចនាករ) កាលពីឆ្នាំមុន (២០១៣) ការព្យាករណ៍នៃការអនុវត្តន៍ឆ្នាំសារពើពន្ធបច្ចុប្បន្ន (២០១៤) និងការរំពឹងទុកសម្រាប់ឆ្នាំអនាគត ពន្យល់ពីទំនាក់ទំនង និងការចូលរួមចំណែករបស់ខ្លួនដើម្បីសម្រេចបាននូវយុទ្ធសាស្ត្រចតុកោណ និងផែនការ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

**២. គោលបំណងគោលនយោបាយ:** ផ្តល់នូវគោលបំណងគោលនយោបាយរយៈពេលមធ្យម និងវែង (៣-៥ឆ្នាំ) ដែលបានកំណត់ដោយក្រសួង/ភ្នាក់ងារ ដើម្បីរួមចំណែកដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ។

**៣. កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព:** កំណត់កម្មវិធីចំណាយជាអាទិភាព សម្រាប់ថវិកាកម្មវិធីតាមក្រសួង / យុទ្ធសាស្ត្រសម្រាប់មិនមែនជាថវិកាកម្មវិធីក្រសួង ដើម្បីសម្រេចបាននូវគោលដៅគោលនយោបាយ រយៈពេលវែង និងមធ្យម ដែលអាចរួមមានអនុកម្មវិធី គម្រោង និងសកម្មភាព។ វាក៏ពន្យល់អំពីការ បែងចែកភារកិច្ចរវាងក្រសួង និងមន្ទីរខេត្ត និងការពាក់ព័ន្ធរបស់ខ្លួនទៅនឹងអនុកម្មវិធី។ តារាង១.១ ១.២ ២.១ និង ២.២ នៃសារាចរនេះបានផ្តល់នូវគំរូក្នុងការប្រើប្រាស់ដើម្បីចង្អុលបង្ហាញពីផែនការ ការចំណាយ រចនាសម្ព័ន្ធកម្មវិធី និងការទទួលខុសត្រូវរបស់នាយកដ្ឋាន/ នាយកដ្ឋានទូទៅ (អង្គភាព ថវិកា ឬអង្គភាពអនុវត្តគម្រោង) និងប្រភពនៃការផ្តល់មូលនិធិទាំងពីថវិកាជាតិ ឬហិរញ្ញប្បទានកិច្ច សហប្រតិបត្តិការអភិវឌ្ឍន៍។

**៤. ការកំណត់សូចនាករ និងគោលដៅ:** ស្នើឱ្យមានសូចនាករ និងគោលដៅ គឺដើម្បីវាស់ស្ទង់នូវការ អនុវត្តន៍នៃកម្មវិធីអាទិភាព/ យុទ្ធសាស្ត្រដែលរួមចំណែកដល់ការអនុវត្តន៍នៃទិសដៅគោលនយោបាយ ក្រសួង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ។ សម្រាប់ការវាស់ប្រសិទ្ធភាព នៃកម្មវិធី និងយុទ្ធសាស្ត្រអាទិភាពទាំងលទ្ធផល(តិចជាងមួយឆ្នាំ) និងសូចនាករលទ្ធផល(ច្រើនជាង មួយឆ្នាំ) ត្រូវបានបង្កើតឡើង។ វឌ្ឍនភាពនៃសូចនាករកំណត់សម្រាប់ឆ្នាំ២០១៣ និងឆ្នាំ២០១៤ នឹង ត្រូវបានរាយការណ៍ និងសូចនាករអាចនឹងត្រូវបានកែប្រែ លុបចោល ឬបន្ថែម ប្រសិនបើចាំបាច់ សម្រាប់ឆ្នាំ២០១៥។ តារាង ៣.១ និង៣.២ ក្នុងគំរូឯកសារដែលភ្ជាប់នៅក្នុងសារាចរនេះ គឺត្រូវបានប្រើ សម្រាប់ការបង្ហាញសូចនាករ និងគោលដៅ។

**៥. ចំណាយនៃធនធាន:** ការចំណាយត្រូវបានផ្អែកទៅលើតម្រូវការពិតប្រាកដនៃកម្មវិធី និងយុទ្ធសាស្ត្រសម្រាប់រយៈពេលបីឆ្នាំ(២០១៥-២០១៧) និងត្រូវបានផ្អែកទៅលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ។ វាក៏ត្រូវបានចាត់ថ្នាក់ដោយការចែកចំណាត់ ថ្នាក់ថវិកា និងប្រភពមូលនិធិ (ថវិកាជាតិ ឬហិរញ្ញប្បទានកិច្ចសហប្រតិបត្តិការអភិវឌ្ឍ)។ តារាង ៤.១ និង៤.២ ក្នុងគំរូឯកសារដែលភ្ជាប់នៅក្នុងសារាចរនេះ គឺសម្រាប់ការចំណាយ។ ចំពោះ ក្រសួងទាំងឡាយណាដែលមានភារកិច្ចក្នុងការប្រមូលប្រាក់ចំណូល ប្រាក់ចំណូលសម្រាប់រយៈពេល បីឆ្នាំ (២០១៥-២០១៧) ត្រូវបានធ្វើការព្យាករណ៍ដោយរួមបញ្ចូលទាំងគោលនយោបាយថ្មី និងការ វាយតម្លៃផែនការសម្រាប់គ្រប់គ្រងការប្រមូលប្រាក់ចំណូល។ តារាង៥.១ និង៥.២ ក្នុងគំរូឯកសារដែល ភ្ជាប់នៅក្នុង

សារាចរនេះ គឺសម្រាប់ប្រាក់ចំណូល។ ទាំងការចំណាយ និងប្រាក់ចំណូល ត្រូវរួមបញ្ចូល នៅក្នុងរបាយការណ៍នៃឆ្នាំសារពើពន្ធឆ្នាំចុងក្រោយ ការព្យាករណ៍នៃឆ្នាំសារពើពន្ធបច្ចុប្បន្ន និងក្នុងឆ្នាំ សារពើពន្ធក្រោយទៀត។

**៦. សេចក្ដីសន្និដ្ឋាន**: កំណត់ចេញនូវសេចក្ដីសន្និដ្ឋាននៃផែនការយុទ្ធសាស្រ្តថវិកា ទិសដៅ និងគោលនយោបាយកម្មវិធីអនាគត គឺសម្រាប់វាយតម្លៃដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្រ្តថវិកា។

**ជំពូកទី៤: សេចក្ដីសន្និដ្ឋាន**

នៅក្នុងសេចក្ដីសន្និដ្ឋាននេះ រដ្ឋាភិបាលបានបង្ហាញអំពីបញ្ហាសំខាន់ៗដែលទាក់ទងទៅនឹងការផ្លាស់ប្ដូររបស់កម្ពុជាពីប្រទេសដែលមានប្រាក់ចំណូលទាប(LIC) ទៅជាប្រទេសមានចំណូលមធ្យម(MIC) នៅក្នុងបរិបទនៃការធ្វើសមាហរណកម្មតំបន់អាស៊ាន និងសាកលភាវូបនីយកម្ម ហើយនឹងការកើន ឡើងនៃការប្រកួតប្រជែងក្នុងចំណោមបណ្ដាប្រទេសផ្សេងៗ។ ប្រទេសកម្ពុជា មានការផ្លាស់ប្ដូរការ ផ្ដោតអារម្មណ៍របស់ខ្លួនពីបរិមាណទៅគុណភាព និងពង្រឹងគុណភាពធនធានមនុស្សរបស់ខ្លួន។ កថា ខណ្ឌពីរចុងក្រោយនេះ ពន្យល់ពីរបៀបដែលក្រសួងនានាធ្វើការប្រៀបធៀបផែនការយុទ្ធសាស្រ្តថវិកា ពីមន្ទីរខេត្ត និងសេចក្ដីណែនាំនៃគំរូថ្មីដើម្បីកែលម្អគុណភាពនៃផែនការយុទ្ធសាស្រ្តថវិកា។ វាបាន កំណត់កាលបរិច្ឆេទនៃការដាក់ផែនការយុទ្ធសាស្រ្តថវិកាទៅឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រឹមថ្ងៃ ទី១០ ខែឧសភា ឆ្នាំ២០១៤។ សារាចរនេះត្រូវបានចុះហត្ថលេខាដោយលោកនាយករដ្ឋមន្រ្តី ហើយត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយតាមរយៈរដ្ឋាភិបាល រដ្ឋសភា ព្រះរាជកិច្ចជាផ្លូវការ និងបណ្ណសាររបស់ រដ្ឋាភិបាល។ ភ្ជាប់ទៅនឹងសារាចរនេះ គឺជាតំរូវការនៃគំរូឯកសារដែលត្រូវបំពេញដោយក្រសួងទាំងអស់ និងភ្នាក់ងារដើម្បីរៀបចំផែនការយុទ្ធសាស្រ្តថវិការបស់ខ្លួន។ ពួកគេ គឺមានភាពខុសគ្នារវាងក្រសួង/ ស្ថាប័នអនុវត្តថវិកាកម្មវិធី និងក្រសួង/ស្ថាប័នមិនអនុវត្តថវិកាកម្មវិធី។ ក្រសួងដែលអនុវត្តថវិកា កម្មវិធីនឹងបង្ហាញផែនការយុទ្ធសាស្រ្តថវិការបស់ខ្លួន នៅក្នុងលំហូរសមហេតុផលនៃគោលបំណង គោលនយោបាយ កម្មវិធី និងអនុកម្មវិធីតាមរយៈសូចនាករ គោលដៅ និងថ្លៃក្នុងកម្រិតនីមួយៗ។ ក្រសួងមិនអនុវត្តថវិកាកម្មវិធី នឹងបង្ហាញផែនការយុទ្ធសាស្រ្តថវិការបស់ខ្លួននៅក្នុងលំហូរ និងរចនា សម្ព័ន្ធស្រដៀងគ្នា ប៉ុន្តែប្រើប្រាស់ចំណងជើងខុសគ្នាពីគោលបំណងរបស់គោលនយោបាយ អាទិភាព យុទ្ធសាស្រ្ត និងចង្កោមសកម្មភាព។ មន្ទីរថ្នាក់ខេត្តក៏ត្រូវរៀបចំផែនការយុទ្ធសាស្រ្តថវិកា ដោយប្រើ ទម្រង់/ គំរូដូចគ្នា ប៉ុន្តែពួកគេមានការទទួលខុសត្រូវសម្រាប់អនុកម្មវិធី ឬចង្កោមសកម្មភាព។

ប្រភព: រាជកិច្ច លេខ ៣២, ឆ្នាំ១៤ នៅសប្ដាហ៍ទី៤ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។

**ប្រអប់ទី ៣: សារាចរចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥**

សារាចរនេះត្រូវបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ និងចុះផ្សាយនៅក្នុងរាជកិច្ចជាផ្លូវការនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។ ស្របជាមួយនឹងកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការ និងមាត្រា ៣៥ នៃច្បាប់ស្តីពីរបបសារពើពន្ធ និងការគ្រប់គ្រងទ្រព្យសកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំមួយសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន។ សារាចរនេះបានស្នើឱ្យអភិបាលខេត្ត និងស្រុកឲ្យរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយផ្អែកលើផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខ្លួន ផែនការវិកិលការវិនិយោគរយៈពេលបីឆ្នាំ និងគម្រោងចំណាយរយៈពេលមធ្យម បន្ទាប់ពីទទួលបានការជូនដំណឹងលើកម្មវិធី និងចំនួនថវិការបស់ខ្លួន ហើយដាក់ជូនទៅក្រុមប្រឹក្សាខេត្ត និងស្រុក ដើម្បីធ្វើការត្រួតពិនិត្យ ពិភាក្សា និងអនុម័ត។ ផែនការយុទ្ធសាស្ត្រថវិកាដែលបានអនុម័ត ត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តសម្រាប់បូកបញ្ចូលគ្នា ដោយផ្អែកលើឧបសម្ព័ន្ធតារាងទី១ និងទី២។ ផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានដាក់ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមួយឯកសារភ្ជាប់នៃផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខេត្ត និងស្រុក ហើយជាមួយនឹងគម្រោងវិនិយោគវិកិលបីឆ្នាំ មិនឲ្យលើសពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤។ ការណែនាំនេះត្រូវបានចេញផ្សាយនៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ ដោយរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សេចក្តីលម្អិតទាក់ទងនឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានដាក់ចេញនៅក្នុងគោលការណ៍ណែនាំផែនការយុទ្ធសាស្ត្រថវិកា ដែលត្រូវបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ប្រភព: រាជកិច្ច លេខ៣២, ឆ្នាំ១៤ នៅសប្តាហ៍ទី៤ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។

នៅក្នុងបរិបទនៃការរៀបចំគម្រោងថវិកាឆ្នាំ២០១៥ ការអភិវឌ្ឍន៍ដូចខាងក្រោមនេះគួរត្រូវកត់សម្គាល់:

១. ក្រសួងចំនួន១០ នឹងអនុវត្ត ថវិកាកម្មវិធីទាំងអស់។ ក្រសួងទាំង១០រួមមាន: ១- ក្រសួងអប់រំយុវជន និងកីឡា ២- ក្រសួងសុខាភិបាល ៣- ក្រសួងកិច្ចការនារី ៤- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ៥- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៦- ក្រសួងអភិវឌ្ឍន៍ជនបទ ៧- ក្រសួងសាធារណការ និងដឹកជញ្ជូន ៨- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៩- ក្រសួងយុត្តិធម៌ និង ១០- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២. ការអនុវត្តន៍ចំណាត់ថ្នាក់ថវិកាសេដ្ឋកិច្ចថ្មី និងការអនុវត្តជាលំដាប់នៃផ្នែក/ចំណាត់ថ្នាក់ថវិកា ៥ ផ្សេងទៀត (សូមមើលសេចក្តីលម្អិតនៅក្នុងជំពូកបន្ទាប់)។ នៅឆ្នាំ២០១៥ ចំណាត់ថ្នាក់ថវិកា ៣ ត្រូវបានប្រើនៅក្នុងការបង្កើតថវិកា និងការអនុវត្តន៍ សេដ្ឋកិច្ច រដ្ឋបាល និងកម្មវិធី។

៣. ការអនុវត្តន៍នៃប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ (FMIS)។

គោលបំណងសំខាន់ពីររបស់កម្មវិធីថវិកាគឺ (ក) ដើម្បីភ្ជាប់គោលនយោបាយ និងការបែងចែកធនធាន ឲ្យកាន់តែមានតម្លាភាព (ខ) ចែកចាយសេវារដ្ឋាភិបាលឲ្យមានប្រសិទ្ធិភាព ដោយធ្វើការតាមដាន និងវាយតម្លៃ រូបវន្តនិងការចំណាយថវិកាប្រៀបនឹងការស្នើសុំ។

**ជំហានទីបី** គឺការចេញសារាចរណែនាំរបស់រដ្ឋាភិបាលស្តីពី "*ការរៀបចំកញ្ចប់ថវិកា*"[16] ឬសេចក្តីព្រាងច្បាប់ស្តីពីថវិកាក្នុងសប្តាហ៍ដំបូងនៃខែមិថុនា ដល់ភ្នាក់ងាររដ្ឋាភិបាលទាំងអស់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (មើលប្រអប់ទី ៤ និងទី៥)។ សេចក្តីព្រាងកញ្ចប់ច្បាប់ថវិកា នឹងត្រូវ ដាក់ជូនទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនៅចុងខែកញ្ញា។ នៅដើមខែមិថុនា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងចេញសេចក្តីព្រាងសារាចរផ្សេងទៀត(លើកទីពីរ) ស្តីពីបច្ចេកទេសក្នុងការរៀបចំគម្រោង ថវិកាដោយបញ្ជាក់ពីបែបបទ និងនីតិវិធីនៃការបង្កើតថវិការួមគ្នា ជាមួយនឹងកំណត់ត្រា ពន្យល់/សេចក្តី ថ្លែងការណ៍។ សារាចរណែនាំនេះត្រូវតែអនុម័តដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅសប្តាហ៍ ដំបូងនៃខែ មិថុនា។ បន្ទាប់មកសារាចរ នឹងត្រូវបានផ្ញើទៅគ្រប់ក្រសួងទាំងអស់របស់រដ្ឋាភិបាល ភ្នាក់ងារ និង អង្គភាពសាធារណៈស្រដៀងគ្នានៅថ្នាក់ជាតិ ដើម្បីឱ្យពួកគេអាចរៀបចំគម្រោងថវិកាចំណូល និង ចំណាយលម្អិតរបស់ខ្លួន និងដាក់ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រឹមថ្ងៃទី ១៥ ខែកក្កដា។ ដើម្បីគាំទ្រដល់ដំណើរការបង្កើតថវិកា និងការអនុវត្តក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានចេញប្រកាស ស្តីពីការណែនាំអំពីការអនុវត្តន៍ និងការរៀបចំ នៃការអនុវត្តន៍ថវិកាកម្មវិធីក្នុងឆ្នាំ២០១៤។

បន្ថែមទៅលើសារាចរទី២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំផ្សេងទៀតទៅលើ នីតិវិធីបច្ចេកទេសសម្រាប់ធ្វើសេចក្តីព្រាងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ (មើលប្រអប់លេខ ៥)។ សារាចរមានគោលបំណងដើម្បីបង្កើតក្រុមការងារជាថ្នាក់រដ្ឋធានី/ខេត្តអចិន្ត្រៃយ៍ដើម្បីជួយដល់ការរៀបចំការងារថវិកានៅបីចំណាត់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ: ខេត្ត/រដ្ឋធានី ស្រុក ក្រុងនិងខណ្ឌ ឃុំ/សង្កាត់។ នៅឆ្នាំ២០១៦ វាត្រូវបានគេរំពឹងទុកថា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងចេញកម្មវិធី រៀបចំគម្រោងថវិកា និងគោលការណ៍ណែនាំការអនុវត្តន៍សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (សូមមើល បន្ថែមនៅក្នុងផ្នែកទី៤)។

**ប្រអប់ទី៤: សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ ២០១៥**

សារាចរនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤ ដោយនាយករដ្ឋមន្ត្រី និងចុះផ្សាយនៅក្នុងរាជកិច្ចនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៤។ សារាចរនេះមានចំនួន ៧១ ទំព័រ (ជាភាសាខ្មែរ) រួមទាំងតារាងឧបសម្ព័ន្ធ និងគំរូឯកសារ ហើយមានទាំងអស់បួនផ្នែកដាច់ដោយឡែកពីគ្នា។ កំណែថ្មីដែលបានចេញផ្សាយនៅក្នុងរាជកិច្ចផ្លូវការ មិនបានរួមបញ្ចូលឧបសម្ព័ន្ធ តារាង និងគំរូឯកសារទេ ហើយមានតែ១៩ ទំព័រប៉ុណ្ណោះ។

***ជំពូកទី១: សេចក្តីផ្តើម*** កថាខណ្ឌទីមួយផ្តល់នូវបរិបទនៃការធ្វើសេចក្តី ព្រាងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈសម្រាប់ឆ្នាំ២០១៥។ វាបង្ហាញអំពីរចនាសម្ព័ន្ធច្បាប់ដែលពាក់ព័ន្ធសម្រាប់ក្រសួង និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំថវិកា ប្រាក់ចំណូល និងចំណាយ។ កថាខណ្ឌទីពីរផ្តល់នូវបរិបទសង្ខេបនៃសេដ្ឋកិច្ចសង្គម និងនយោបាយ ព្រមទាំងកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ នៅក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ និងបញ្ហាប្រឈមដែលបានជួបប្រទះដោយរដ្ឋាភិបាលនៅក្នុងរយៈពេលចុងក្រោយនេះ។ កថាខណ្ឌទីបីផ្តោតលើការផ្លាស់ប្តូររបស់កម្ពុជាពី ប្រទេសមានប្រាក់ចំណូលទាប ទៅ ជាប្រទេសមានប្រាក់ចំណូលមធ្យម និងការប្តេជ្ញាយ៉ាងខ្លាំងរបស់រដ្ឋាភិបាលដើម្បីធ្វើកំណែទម្រង់។ កថាខណ្ឌទីបួនបានបង្ហាញពីទស្សនវិស័យសេដ្ឋកិច្ចនៅកម្រិតតំបន់ និងសកល និងផលប៉ះពាល់របស់វាមកលើ

[16] មាត្រា៣៩ ឆ្នាំ២០០៨ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

សេដ្ឋកិច្ចកម្ពុជា។ កថាខណ្ឌទីប្រាំបង្ហាញពីហានិភ័យ និងផលវិបាកសេដ្ឋកិច្ចផ្សេងៗ និង កថាខណ្ឌទីប្រាំមួយបូកសរុបផ្នែកសេចក្តីណែនាំ។

***ជំពូកទី២. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៥***

ផ្នែកនេះបង្ហាញពីក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសាធារណៈសម្រាប់ឆ្នាំ២០១៥។ ផ្នែក (ក) នៅក្នុងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៥ រួមមានការអនុវត្តន៍ ម៉ាក្រូសេដ្ឋកិច្ច ឆ្នាំ២០១៣ ដោយមានការពន្យល់តាមវិស័យ និងវិស័យគន្លឹះ ការព្យាករណ៍នៃការអនុវត្តន៍ ម៉ាក្រូសេដ្ឋកិច្ចឆ្នាំ២០១៤ និងឆ្នាំ២០១៥ ជាមួយនឹងការពន្យល់តាមវិស័យ និងវិស័យគន្លឹះ អតិផរណា អត្រាប្តូរប្រាក់ និងឱនភាពថវិកានាពេលបច្ចុប្បន្ន។ ជាចម្បង វាមានគោលបំណងដើម្បីរក្សាបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព (៧% ក្នុងមួយឆ្នាំ) និរន្តរភាពបំណុល និងអតិផរណា (៥%ក្នុងមួយឆ្នាំ) និងគោលដៅអត្រាប្តូរប្រាក់។ ផ្នែក ខ លើក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកាឆ្នាំ ២០១៥ បានបង្ហាញនូវការប្តេជ្ញាចិត្តទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ និងគន្លឹះទាំងប្រាំបី នៃកម្មវិធីកំណែទម្រង់ និងគោលនយោបាយ។ វាបានបង្ហាញពីគោលដៅជាក់លាក់មួយចំនួនសម្រាប់ការប្រមូលចំណូល និងចំណាយ។ រដ្ឋាភិបាលបានធ្វើឱ្យវាច្បាស់ណាស់ថា វានឹងមិនមានការកើនឡើងពន្ធ និងគ្មានពន្ធថ្មីលើកលែងតែសម្រាប់ផលិតផល និងសេវាកម្មដែលកំពុងបង្កផលប៉ះពាល់ដល់សុខភាព និងបរិស្ថាន។ គោលនយោបាយវាយតម្លៃសម្រាប់ពង្រឹងការប្រមូលប្រាក់ចំណូល ពីពន្ធគយ ពន្ធ និងចំណូលក្រៅពីពន្ធ ត្រូវផ្អែកលើយុទ្ធសាស្ត្រប្រមូលប្រាក់ចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ គោលបំណងសំខាន់នៃចំណាយថវិកា ក៏ត្រូវបានយកមក បង្ហាញនៅទីនេះផងដែរ រួមបញ្ចូលនូវបញ្ជីគោលនយោបាយសាធារណៈ និងវិធានការចំណាយ អាទិភាព ព្រមទាំងបញ្ជីនៃវិស័យអាទិភាព និង វិស័យរង (ក្នុងក្របខ័ណ្ឌនៃផែនការយុទ្ធសាស្ត្រអភិ វឌ្ឍន៍ជាតិ)។ វិស័យអាទិភាពទាំងនោះរួមមានការ តម្លើងប្រាក់បៀវត្សមន្ត្រីរាជការសាធារណៈ ប្រសិទ្ធ ភាព និងតម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអប់រំ (សាលារៀន អាហារូបករណ៍សម្រាប់ សិស្សនិស្សិតក្រីក្រ) បណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល (គុណភាពនៃសេវា មន្ទីរពេទ្យ) សុវត្ថិភាព សង្គម ដី កសិកម្ម ប្រព័ន្ធធារាសាស្ត្រ ទឹកស្អាត អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ(ផ្លូវ ថ្នល់ ស្ពាន ផ្លូវដែក កំពង់ផែ អគ្គិសនី) និងការអភិវឌ្ឍជនបទ។ គោលដៅអតិរេកថវិកាចរន្ត (២,៧៧% នៃ GDP) និង ឱនភាពថវិកាសរុប(៤,៩៧% នៃ GDP) ត្រូវបានកំណត់ផងដែរសម្រាប់ឆ្នាំ២០១៥ ក្នុងផ្នែកនេះ។

**ជំពូកទី៣** ស្តីពីនីតិវិធី និងបច្ចេកទេសនៃថវិកាឆ្នាំ២០១៥ ផ្តល់នូវការណែនាំទៅកាន់ក្រសួង/ភ្នាក់ងារ និងមន្ទីរខេត្ត/ក្រុងដើម្បីរៀបចំថវិការបស់ខ្លួន និងរួមបញ្ចូលទាំងប្រាក់ចំណូល(ផ្នែក ក) និងការចំណាយ (ផ្នែក ខ)។ សារាចរនេះបានស្នើឱ្យក្រសួងពាក់ព័ន្ធផ្តោតទៅលើប្រសិទ្ធភាពនៃកម្មវិធី និងអនុកម្មវិធីរបស់ខ្លួន ទិន្នផលនិងលទ្ធផល ហើយនឹងទំនាក់ទំនង និងការចូលរួមចំណែកដល់ការសំរេចគោលបំណង និងគោលដៅនៃគោលនយោបាយ។ សារាចរនេះក៏បានផ្តល់នូវការណែនាំសម្រាប់ ក្រសួងដែលអនុវត្តថវិកាកម្មវិធីនិងក្រសួងដែលមិនអនុវត្តថវិកាកម្មវិធី និងមន្ទីរខេត្ត ដើម្បីផ្តល់សេចក្តីលម្អិតអំពីចំណាយថវិការបស់ខ្លួននៅក្នុងជំពូកទាំងអស់ ថែមទាំងត្រឹមកម្រិតគណនី និងគណនីរង ដោយផ្អែកលើការចំណាត់ថ្នាក់ថវិកាសេដ្ឋកិច្ចថ្មី រួមទាំងការភ្ជាប់នូវការពន្យល់ទៅលើជាតុតាមជួរនីមួយៗ។ សារាចរក៏បានកំណត់គោល

ការណ៍ និងវិធានការ (គោលដៅ) សម្រាប់ជំពូកថវិកានីមួយៗផងដែរ។ ផ្នែក (គ) ផ្តល់នូវការកំណត់កាលបរិច្ឆេទជាក់លាក់សម្រាប់ការរៀបចំថវិកាចំណូល និងចំណាយឆ្នាំ២០១៥ នៅដំណាក់កាលផ្សេងៗគ្នាពីគម្រោងថវិកាដែលបានចរចារួច (ថ្ងៃទី១ ខែសីហា ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥) ដើម្បីដាក់ស្នើទៅក្រុមប្រឹក្សារដ្ឋមន្ត្រី រដ្ឋសភា និងព្រឹទ្ធសភា ដើម្បីអនុម័ត និងយល់ព្រមមុនថ្ងៃទី២៥ ខែធ្នូ។ គំរូនៃចំណូល និងចំណាយដែលនឹងត្រូវប្រើប្រាស់ដោយគ្រប់ក្រសួង មន្ទីរខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងសារាចរនេះ។

**ជំពូកទី៤** មានចំណងជើងថា "ការសន្និដ្ឋាន"។ វាបានរំលឹកឡើងវិញពីសារៈសំខាន់នៃការភ្ជាប់ទំនាក់ទំនងនៃគោលបំណងគោលនយោបាយក្រសួង កម្មវិធី អនុកម្មវិធី និងសកម្មភាពដើម្បីសម្រេចបាននូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣នេះ។ ផ្នែកនេះផងដែរក៏បានអំពាវនាវឱ្យមានការប្តេជ្ញាចិត្តពីសំណាក់គ្រប់ក្រសួង ទីភ្នាក់ងារ និងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តន៍សារាចរ តាមកាលបរិច្ឆេទ ដែលបានកំណត់សម្រាប់ដាក់សំណើរនូវផែនការលម្អិតនៃប្រាក់ចំណូលនិងចំណាយ (ដោយប្រើទម្រង់បែបបទ និងគំរូភ្ជាប់ទៅនឹងសារាចរ) មិនឲ្យលើសពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានអំពាវនាវឱ្យមានការអនុលោមតាមច្បាប់យ៉ាងតឹងរឹងទៅនឹងកាលបរិច្ឆេទកំណត់ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិធ្វើការចរចាពីថវិកានៅកម្រិតបច្ចេកទេស និងនយោបាយ។

សារាចរដោយមានភ្ជាប់មកជាមួយទម្រង់ តារាង និងគំរូ ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រីនៅថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៤។ ទម្រង់បែបបទ តារាង និងគំរូដែលភ្ជាប់ជាមួយនេះ គឺសម្រាប់ទាំង កម្មវិធី និងក្រសួងមិនមានថវិកាកម្មវិធី និងមន្ទីរខេត្ត។ ក្រសួងដែលអនុវត្តថវិកាកម្មវិធី និងក្រសួងមិនអនុវត្តថវិកាកម្មវិធី និងមន្ទីរខេត្ត ពួកគេត្រូវបំពេញតារាង ចំណូល និងចំណាយដោយផ្អែកទៅលើការចាត់ថ្នាក់ថវិកាសេដ្ឋកិច្ចនៃច្បាប់ស្តីពីថវិកាកាលពីឆ្នាំមុន និងការប៉ាន់ស្មាននៃការអនុវត្តន៍ និងច្បាប់ស្តីពីថវិកាថ្មី(ឆ្នាំ២០១៥)។ ចំពោះចំណាយថវិកា វាគំរូឲ្យមានការបំបែកថវិកា នៅក្នុងជំពូកថវិកានីមួយៗ(៦០, ៦១, ៦២, ៦៣, ៦៤, និង ៦៥) អោយកាន់តែលម្អិតបន្ថែមទៀត ជាគណនី និងគណនីរង។ តារាងនៃការចំណាយមូលធន ឬគម្រោងវិនិយោគសាធារណៈ បញ្ជីរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ (សម្រាប់ជំពូកទី៦៤) ក៏ត្រូវបានតម្រូវសម្រាប់ចំណាយថវិកា។ សម្រាប់ថវិកាកម្មវិធីរបស់ក្រសួង ពួកគេត្រូវបានទាមទារឲ្យធ្វើការបំពេញនៅក្នុងតារាងនៃកម្មវិធី អនុកម្មវិធី សកម្មភាព សូចនាករ គោលដៅ និងអ្នក/ នាយកដ្ឋានទទួលខុសត្រូវ។ ថវិកាកម្មវិធីមន្ទីរខេត្ត ត្រូវបានតម្រូវឲ្យបំពេញនៅក្នុងតារាងនៃ អនុកម្មវិធី និងសកម្មភាពស្របនឹងកម្មវិធី និងគោលបំណងនយោបាយរបស់ក្រសួង។

ប្រភព: រាជកិច្ច លេខ ៤៤, ឆ្នាំ១៤ នៅសប្តាហ៍ទី២ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៤។

**ប្រអប់ទី៥: សារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីសេចក្តីព្រាងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (២០១៥)**

សារាចរបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤ និងការចុះផ្សាយនៅក្នុងរាជកិច្ចផ្លូវការនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៤ ដែលរួមប្រាំមួយផ្នែក និងបែកចែកជាបីតំណាក់ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ផ្នែក ក**: ការធ្វើផែនការប្រាក់ចំណូល។ វាមានពីរអនុផ្នែកគឺ: អនុផ្នែក ក១: ប្រាក់ចំណូលចរន្ត និងអនុផ្នែក ក២: ប្រាក់ចំណូលចរន្តសម្រាប់ចំណាយរាជធានីភ្នំពេញ។

**ផ្នែក ខ**: ការធ្វើផែនការចំណាយក្នុងបីថ្នាក់: មូលធន/ការធ្វើផែនការថវិកាថ្នាក់ខេត្ត ការធ្វើផែនការថវិកាថ្នាក់ស្រុក ខណ្ឌ និងក្រុង និងការធ្វើផែនការថវិកាថ្នាក់ឃុំ/សង្កាត់។ ផ្នែកនេះពន្យល់អំពីការធ្វើផែនការចំណាយការប្រើប្រាស់ចំណាត់ថ្នាក់ថវិកាសេដ្ឋកិច្ចធម្មតា ត្រូវបានចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងឆ្នាំ២០១៣។

**ផ្នែក គ**: ការរៀបចំផែនការចំណាយ។ ផ្នែកនេះពន្យល់អំពីការរៀបចំការចំណាយថវិកាកាន់តែលម្អិតនៅក្នុងកម្រិតជំពូកសម្រាប់ចំណាយចរន្ត និងមូលធន។

**ផ្នែក ឃ**: វិធីសាស្ត្រក្នុងការរៀបចំប្រាក់ចំណូល និងផែនការចំណាយនៅក្នុងកម្រិតបីថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ វាមានពីរផ្នែករង ដូចជាការធ្វើផែនការប្រាក់ចំណូល និងចំណាយ។

**ផ្នែក ង**: កាលបរិច្ឆេទនៃការរៀបចំថវិកា និងការអនុវត្តន៍នៅបីកម្រិតនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

**ផ្នែក ច**: យន្តការដើម្បីគាំទ្រដល់ការរៀបចំថវិកានៅកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ។

ប្រភព: រាជកិច្ច លេខ ៥១, ឆ្នាំ១៤ នៅសប្តាហ៍ទី២ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៤។

បន្ទាប់ពីទទួលបាននូវសំណើផែនការចំណូល និងចំណាយទាំងអស់ពីក្រសួង ស្ថាប័ន អង្គភាពសាធារណៈ ខេត្ត និងក្រុង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចងក្រង និងបូកបញ្ចូនគ្នានូវផែនការចំណូល និងចំណាយទាំងអស់។ ពាក់កណ្តាលនៃខែកក្កដា ខែសីហា និងខែកញ្ញា គឺត្រូវធ្វើការចរចាថវិកា និងការរៀបចំនៃសេចក្តីព្រាងច្បាប់ស្តីពីថវិកា។ រដ្ឋមន្ត្រីមកពីក្រសួងពាក់ព័ន្ធទាំងអស់ នាយកនៃស្ថាប័នរដ្ឋឯករាជ្យទាំងអស់ និងអភិបាលខេត្ត/ក្រុងត្រូវបានអញ្ជើញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិភាក្សា និងការជជែកដេញដោលថវិការបស់ខ្លួន។ នៅក្នុងខែកញ្ញា បន្ទាប់ពីការពិភាក្សា និងការជជែកដេញដោលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធ្វើការសម្រេចចុងក្រោយនូវចំនួន ប្រាក់ចំណូល និងចំណាយទៅតាមកម្រិតសមរម្យដោយផ្អែកទៅលើការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ច ឬគោលដៅ។ សេចក្តីព្រាងច្បាប់ស្តីពីថវិកា ត្រូវបានរៀបចំនៅក្នុងទំរង់ជាសេចក្តីព្រាង។ រចនាសម្ព័ន្ធ និងព័តមានលម្អិតក្នុងសេចក្តីព្រាងច្បាប់ស្តីពីថវិកា នឹងត្រូវបានពិភាក្សានៅក្នុងជំពូកបន្ទាប់។

ក្នុងអំឡុងសប្តាហ៍ទីមួយនៃខែតុលា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្ញើសេចក្តីព្រាងច្បាប់ស្តីពីថវិកាមួយទៅគណៈរដ្ឋមន្ត្រី ដែលជាអ្នកបញ្ជូនបន្តទៅសភានីតិបញ្ញត្តិនៅក្នុងសប្តាហ៍ដំបូងនៃខែវិច្ឆិកាសម្រាប់ត្រួតពិនិត្យ

និងអនុម័ត។ បន្ថែមពីលើសេចក្តីព្រាងច្បាប់ប្រចាំឆ្នាំស្តីពីថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានរៀបចំសេចក្តីថ្លែងការពន្យល់មួយនៅលើសេចក្តីព្រាងច្បាប់ស្តីពីថវិកានេះ។

នៅពេលដែលសេចក្តីព្រាងច្បាប់ប្រចាំឆ្នាំស្តីពីថវិកា បានផ្ញើទៅដល់រដ្ឋសភាជាតិ វានឹងជាកម្មសិទ្ធិរបស់រដ្ឋសភាជាតិក្នុងការបោះពុម្ពផ្សាយជាសាធារណៈទៅតាមមណ្ឌលបោះឆ្នោតតាមខេត្តនានារបស់ពួកគេ ដោយសារតែពួកគេតំណាងឲ្យអ្នកបោះឆ្នោតរបស់ពួកគេ។ ដំណាក់កាលទី២ នៃដំណើរការថវិកាក៏ចាប់ផ្តើមឡើងនៅពេលរដ្ឋសភាជាតិទទួលបានសេចក្តីព្រាងច្បាប់ប្រចាំឆ្នាំស្តីពីថវិកា។

*តួនាទីរបស់ប្រជាពលរដ្ឋអង្គការសង្គមស៊ីវិល / អង្គការមិនមែនរដ្ឋាភិបាល*

ទោះបីជាការបង្កើតថវិកាប្រចាំឆ្នាំ នៅតែមានការបិទជិតសម្រាប់សង្គមស៊ីវិលដើម្បីចូលរួមដោយផ្ទាល់ ប៉ុន្តែវានៅតែមានឱកាសសម្រាប់ការវិភាគ និងការតស៊ូមតិរបស់អង្គការក្រៅរដ្ឋាភិបាល/ អង្គការសង្គមស៊ីវិលដែលកំពុងធ្វើការនៅក្នុងដំណាក់កាលនេះ។ ឧទាហរណ៍ អង្គការ/ អង្គការសង្គមស៊ីវិលអាចបង្កើតនូវការវិភាគបញ្ហាដែលព្រួយបារម្ភ និងរាយការណ៍ពីការបង្កើតថវិកា ដល់ភាគីពាក់ព័ន្ធសម្រាប់ការពិចារណា ឬត្រូវបានផ្តល់អាទិភាព (Sapiro, ២០០១) ។ របាយការណ៍នេះប្រហែលជាអាចមានឥទ្ធិពលលើគម្រោងថវិកាដែលត្រូវបានរៀបចំឡើង។ លើសពីនេះទៀត វាក៏ជាឱកាសមួយសម្រាប់អង្គការក្រៅរដ្ឋាភិបាល/ អង្គការសង្គមស៊ីវិលដើម្បីបង្កើតបណ្តាញនៃការទំនាក់ទំនងជាមួយនឹងក្រុមមន្ត្រីរៀបចំថវិកា។

## ២.២ ដំណាក់កាលទី២: ការអនុម័តនៃច្បាប់ស្តីពីថវិកាដោយអង្គនីតិបញ្ញត្តិ (ខែវិច្ឆិកា ដល់ខែធ្នូ)

រដ្ឋសភាបានទទួលសេចក្តីព្រាងច្បាប់ស្តីពីថវិកា ពីទីស្តីការគណៈរដ្ឋមន្ត្រីក្នុងអំឡុងពេលសប្តាហ៍ដំបូង នៃខែវិច្ឆិកា[17]។ សេចក្តីព្រាងច្បាប់ស្តីពីថវិកា[18] ត្រូវបានពិនិត្យឡើងវិញ និងពិភាក្សានៅក្នុងគណៈកម្មាធិការទីពីរនៃរដ្ឋសភាជាតិផ្នែកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ដែលជាអ្នកធ្វើការពិភាក្សាបន្ថែមទៀតអំពីសេចក្តីព្រាងច្បាប់ប្រចាំឆ្នាំស្តីពីថវិកា ជាមួយនឹងមន្ត្រីរដ្ឋាភិបាល ជាន់ខ្ពស់ពីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការពិភាក្សាទាំងនេះ គឺនៅបច្ចុប្បន្នមិនបើកចំហជាសាធារណៈ ហើយមិន មានការចូលរួមពីសង្គមស៊ីវិលឡើយ។ នៅចុងខែវិច្ឆិកា រដ្ឋសភាធ្វើការជជែកពិភាក្សា ដែលវាជាការ ពិភាក្សា ជជែកដេញដោល ការស្នើធ្វើវិសោធនកម្មបើចាំបាច់ ហើយចុងក្រោយព្រមព្រៀងលើថវិកា មុន នឹងផ្ញើជូនព្រឹទ្ធសភា។ បន្ទាប់ពីការអនុម័តដោយរដ្ឋសភា សេចក្តីព្រាងច្បាប់ស្តីពីថវិកាដែលបាន អនុម័ត នោះ ត្រូវបានបញ្ជូនទៅព្រឹទ្ធសភាដើម្បីធ្វើការពិនិត្យ និងផ្តល់អនុសាសន៍ក្នុងសប្តាហ៍ដំបូងនៃខែធ្នូ។ បើព្រឹទ្ធសភាអនុម័ត សេចក្តីព្រាងច្បាប់ស្តីពីថវិកានេះនឹងត្រូវបានបញ្ជូនដោយផ្ទាល់ទៅព្រះមហាក្សត្រ សម្រាប់ប្រកាសឱ្យប្រើប្រាស់។ ទោះជាយ៉ាងណា បើសិនព្រឹទ្ធសភា

[17] ក្រៅពីនេះ ការអនុវត្តនៅក្នុងប្រទេសកម្ពុជាគឺថាគណៈកម្មការទីពីរនៃរដ្ឋសភាទទួលបានច្បាប់ចម្លងមួយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅពេលដែលវាបានផ្ញើសេចក្តីព្រាងច្បាប់ស្តីពីថវិកាទៅទីស្តីការគណៈរដ្ឋមន្ត្រីនៅសប្តាហ៍ដំបូងនៃខែតុលា។ មូលហេតុចម្បងគឺដើម្បីផ្តល់នូវពេលវេលាខ្លះទៅគណៈកម្មការទីពីរដើម្បីរៀបចំសម្រាប់ការពិនិត្យឡើងវិញនៃសេចក្តីព្រាងច្បាប់ថវិកា។

[18] វាត្រូវបានកត់សម្គាល់ឃើញថាកិច្ចពិភាក្សាទាំងនេះទាក់ទងទៅនឹងផ្នែកថវិកាសំខាន់រៀបចំដោយក្រសួង។ ការវិភាគលម្អិតគឺជាការទទួលខុសត្រូវរបស់អ្នកប្រតិបត្តិ (សូមមើលដំណាក់កាលទី៣ នៃវដ្តថវិកាសម្រាប់ព័ត៌មានបន្ថែម)។

សុំឱ្យមានការកែប្រែ សេចក្តីព្រាង ច្បាប់ស្តីពីថវិកា ត្រូវបានបញ្ជូនត្រឡប់ទៅកាន់រដ្ឋសភា។ រដ្ឋសភាជាតិនឹងធ្វើការពិនិត្យមើលការកែប្រែ ដែលស្នើឡើងដោយព្រឹទ្ធសភា និងសម្រេចចិត្តថាតើត្រូវទទួលយក ឬច្រានចោលទាំងអស់ឬមួយចំនួន នៃការកែប្រែទាំងនោះ។ ដំណើរការនៃការបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីថវិកាត្រលប់ទៅវិញទៅមករវាងរដ្ឋសភា និងព្រឹទ្ធសភាមិនអាចលើសពី ១០ថ្ងៃឡើយ។ បន្ទាប់ពីការអនុម័តច្បាប់ដោយរដ្ឋសភា និងព្រឹទ្ធសភា មហាក្សត្រនឹងឡាយព្រះហស្ថលេខា និងប្រកាសអោយប្រើច្បាប់ស្តីពីថវិកាដែលបាន អនុម័ត[19] ហើយ (សូមមើលរូបភាពទី៥)។

ប្រតិទិនសម្រាប់ការរៀបចំគម្រោងថវិកា គឺច្បាស់លាស់ណាស់។ យ៉ាងណាក្តី ដូចដែលមានចែងនៅក្នុងមាត្រា៥០ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រសិនបើសេចក្តីព្រាងច្បាប់ស្តីពីថវិកាប្រចាំឆ្នាំមិនត្រូវបានអនុម័តមុនថ្ងៃទី១ ខែមករានៃឆ្នាំហិរញ្ញវត្ថុថ្មី ថវិកាកាលពីឆ្នាំមុន (ចំណូលនិងចំណាយ) នឹងបន្តជាផ្លូវការ លើកលែងតែកាតព្វកិច្ចបំណុលសាធារណៈ រំលស់ និងសមាជិកភាពរបស់កម្ពុជានៅក្នុងស្ថាប័នអន្តរជាតិ និងក្នុងរដ្ឋាភិបាល។ ចំពោះការចំណាយបច្ចុប្បន្ន គួរតែអនុវត្តដោយផ្អែកលើថវិកាកាលពីឆ្នាំមុនដោយប្រើវិធីសាស្រ្តបណ្តោះអាសន្ននៃ ១/១២ សម្រាប់ខែនីមួយៗរហូតដល់ការអនុម័តនៃគម្រោងថវិកាថ្មី។ នេះមានន័យថាប្រតិទិនថ្មីនេះមិនបានស្នើ ឱ្យមានពេលវេលាជាក់លាក់សម្រាប់រដ្ឋមន្រ្តី ធ្វើការកែប្រែសេចក្តីព្រាងច្បាប់ នៅក្នុងករណីនៃការបោះឆ្នោតអវិជ្ជមានដោយរដ្ឋសភាឡើយ។

### *តួនាទីរបស់ប្រជាពលរដ្ឋអង្គការសង្គមស៊ីវិល / អង្គការមិនមែនរដ្ឋាភិបាល*

ដោយសារមិនមានការពិភាក្សាជាសាធារណៈ និងការចូលរួមក្នុងការអនុម័តថវិកា អង្គការមិនមែនរដ្ឋាភិបាល/អង្គការសង្គមស៊ីវិលអាចត្រូវបានចូលរួមបានតែនៅក្នុងដំណើរការនេះតាមរយៈការផ្សព្វផ្សាយនៃការវិភាគថវិការបស់ខ្លួន។ ប្រព័ន្ធផ្សព្វផ្សាយ អាចជួយអង្គនីតិបញ្ញត្តិដើម្បីទទួលបានព័ត៌មានបន្ថែមមុនពេលធ្វើការសម្រេចចិត្ត (*Shapiro*, ២០០១)។

[19] មាត្រាទី៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

## រូបភាពទី៥: ដំណើរការនៃការអនុម័តច្បាប់ស្តីពីថវិកា



## ២.៣ ដំណាក់កាលទី៣: ការអនុវត្តន៍ នៃច្បាប់ថវិកាដោយអង្គនីតិប្រតិបត្តិ (ថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ)

បន្ទាប់ពីថវិកាជាតិត្រូវបានអនុម័តជាច្បាប់ រដ្ឋាភិបាលចាប់ផ្ដើមដំណាក់កាល នៃការប្រតិបត្តិថវិកា។ ដំណាក់កាលនេះរួមមានការអនុវត្តន៍ ច្បាប់ស្ដីពីថវិកា ការតាមដានការអនុវត្តន៍ ថវិកា និងការត្រួតពិនិត្យ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើរតួនាទីយ៉ាងសំខាន់ក្នុងដំណាក់កាលនេះ។ ច្បាប់ថវិកាមានតែចំនួនទឹកប្រាក់សរុបនៃថវិកាបំរុងទុករបស់ខ្លួនតាមរយៈប្រភព និងប្រភេទនៃប្រាក់ចំណូល និង ថ្នាក់ជាតិ (ក្រសួងមជ្ឈិមនិងមន្ទីររាជធានី/ខេត្ត) និងចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត/រាជធានី ក្រុង ខណ្ឌនិងស្រុក ហើយនឹងឃុំ/សង្កាត់)។

ដើម្បីគាំទ្រដល់ការអនុវត្តន៍ ការតាមដាន និងការត្រួតពិនិត្យថវិកាក្នុងអំឡុងឆ្នាំសារពើពន្ធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ទៅនាយករដ្ឋមន្ត្រីនូវអនុក្រឹត្យចំនួនពីរ (មួយសម្រាប់ប្រាក់ចំណូល និងមួយផ្សេងទៀតសម្រាប់ការចំណាយ) ដែលជាបញ្ចប់នៃការបែងចែកលម្អិតនៃថវិការបស់ខ្លួនតាមជំពូក និងប្រហែលជាអាចតាមកម្មវិធីនៃក្រសួងនីមួយៗ។ ការបម្រុងថវិកាមួយចំនួន (ក្នុងបរិមាណសរុប) នៅក្នុងផ្នែកថវិកាដែលមិនទាន់បែងចែកនៃឧបសម្ព័ន្ធ ៥ ក្នុងច្បាប់ស្ដីពីថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ត្រូវដាក់ចេញនូវអនុក្រឹត្យសម្រាប់ការផ្ទេរឥណទានថវិកាទៅ នាយករដ្ឋមន្ត្រីសម្រាប់ការអនុម័ត។ បន្ទាប់ពីនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចេញនូវប្រកាស ៣: ១. ប្រកាសស្ដីពីការផ្ទេ ការប្រមូលប្រាក់ចំណូលក្នុងថវិកាជាតិ ទៅរាល់ក្រសួងពាក់ព័ន្ធទាំងអស់ រដ្ឋលេខាធិការ និងអភិបាលខេត្ត/រដ្ឋធានី ២. ប្រកាសស្ដីពីការបែងចែកការចំណាយឥណទាន ក្នុងថវិកាជាតិតាមជំពូកនៅក្នុងក្រសួងនីមួយៗ ទៅក្នុងគណនី និងគណនីរងសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ (ឆ្នាំ២០១៤) និង៣. ប្រកាសនៃការផ្ទេរឥណទានថវិកាទៅក្នុងគណនី និងគណនីរងដោយផ្អែកទៅលើអនុក្រឹត្យនៃការផ្ទេរថវិកាខាងលើនេះ។ អនុក្រឹត្យ និងប្រកាសស្ដីពីការបែងចែកថវិកានិងថវិកាបំរុងទុក ផ្ដល់សេចក្ដីលម្អិតនៃចំនួនថវិកាដែលត្រូវបែងចែកតាមជួរគណនីនីមួយៗ ដោយផ្អែកលើចំណាត់ថ្នាក់ថវិកាសេដ្ឋកិច្ច ដែលបម្រើជាមូលដ្ឋានសម្រាប់ការស្នើសុំថវិកា ប្រតិបត្តិ និងការទូទាត់។ នីតិវិធីនៃការស្នើសុំថវិកាប្រតិបត្តិ និងការទូទាត់ ត្រូវបានបញ្ជាក់នៅក្នុងសេចក្ដីណែនាំសម្រាប់ការចំណាយ និងនីតិវិធីត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់ថវិកាចរន្ត ជាតិ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

មុនពេលការអនុវត្តន៍ ថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្ដីពីការអនុវត្តន៍ ច្បាប់ថវិកា(២០១៤)។ សារាចរនេះមានចំនួនប្រាំពីរផ្នែក:

១- សេចក្ដីណែនាំ

២- លក្ខខណ្ឌ និងវិធានក្នុងការអនុវត្តន៍ ការប្រមូលចំណូល និងចំណាយថវិកាឆ្នាំ២០១៤

៣- ការត្រួតពិនិត្យ តាមដាន និងរាយការណ៍: ផ្នែកនេះតម្រូវបណ្ដាក្រសួង និងមន្ទីរខេត្តធ្វើការដាក់ជូនរបាយការណ៍នៃការអនុវត្តន៍ថវិកាប្រចាំខែ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ទៅនាយកដ្ឋានទូទៅនៃថវិកាផ្អែកលើកាលបរិច្ឆេទដែលបានកំណត់។

៤- វិធានការដើម្បីពង្រឹងការគ្រប់គ្រងអចលនទ្រព្យរបស់រដ្ឋ

៥- វិធានការដើម្បីរក្សាតុល្យភាពថវិកា និងប្រសិទ្ធភាព
៦- ការផ្តន្ទាទោស និងទំនួលខុសត្រូវរបស់មន្ត្រីសាធារណៈ
៧- សេចក្តីសន្និដ្ឋាន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺទទួលខុសចំពោះការប្រេបាច់បញ្ចូលគ្នានៃថវិកាជាតិលម្អិត។ ថវិកាលម្អិតនេះ គឺជាការវិភាគបន្ថែមទៀតនៃចំនួនថវិកានៅក្នុងច្បាប់ស្តីពីថវិកាដោយផ្អែកទៅលើចំណាត់ថ្នាក់ថវិកាពីរហូតដល់ឆ្នាំ២០១៤: រដ្ឋបាល និងសេដ្ឋកិច្ច។ ចំណាត់ថ្នាក់ថវិកាជារដ្ឋបាល ត្រូវបានចាត់ថ្នាក់ដោយ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល ចេញជាថ្នាក់ជាតិ (ក្រសួងមជ្ឈិម និងមន្ទីរខេត្ត/រដ្ឋធានី) និរដ្ឋបាលថ្នាក់ក្រោមជាតិ (ខេត្ត រដ្ឋធានី ក្រុង ខណ្ឌ ស្រុក ឃុំ/សង្កាត់)។ ចំណាត់ថ្នាក់ថវិកាជាសេដ្ឋកិច្ចត្រូវបានបែងថ្នាក់ជាក្រុម ថ្នាក់ ប្រភេទ ជំពូក គណនី និងគណនីរង ដែលមានរហូតដល់ទៅ ៨ ខ្ទង់នៃកូដថវិកា។ ចំណាត់ថ្នាក់ថវិកាជាសេដ្ឋកិច្ច ត្រូវបានប្រើជាឧបករណ៍សំខាន់សម្រាប់ការបង្កើតថវិកា ការចរចា ការប្រតិបត្តិ ការទូទាត់ និងការកត់ត្រា និងប្រតិបត្តិការគណនេយ្យសាធារណៈ។ វាមានសរុបទាំងអស់ ៨ ចំណាត់ថ្នាក់ឬផ្នែកនៃថវិកា ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រោងនឹងអនុវត្តន៍នៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទៅតាមតំបន់នៃភូមិសាស្ត្រ មុខងារ កម្មវិធី រដ្ឋបាល សេដ្ឋកិច្ច ប្រភពនៃមូលនិធិ គម្រោង និងអង្គភាពប្រតិបត្តិការ (ព្រឹត្តិប័ត្រ FMIS ខែសីហា ឆ្នាំ២០១៤)។

សម្រាប់ថវិកាឆ្នាំ២០១៥ នេះតទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងបន្ថែមកម្មវិធីចំណាត់ថ្នាក់ថវិកាជាប្រភេទមួយផ្សេងទៀតដោយផ្តល់ថវិកាលម្អិត ទៅដល់គ្រប់កម្រិតកម្មវិធី អនុកម្មវិធី និងសកម្មភាព។ វាត្រូវបានណែនាំទៅឱ្យក្រសួងទាំងនោះ ដែលត្រូវអនុវត្តថវិកាកម្មវិធីពេញលេញនៅក្នុងឆ្នាំ២០១៥។ នៅពេលដែលធ្វើសេចក្តីព្រាងណែនាំនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញគំរូ និងតារាងសម្រាប់ថវិកាកម្មវិធីទៅក្រសួងពាក់ព័ន្ធ។ វាត្រូវបានភ្ជាប់ទៅនឹងសារាចរណែនាំរបស់រដ្ឋាភិបាលលើការរៀបចំនៃ សេចក្តីព្រាងច្បាប់ថវិកាឆ្នាំ២០១៥ (សូមមើលប្រអប់ទី២ និងទី៤ ខាងលើ)។

ចំណាត់ថ្នាក់ថវិកាលម្អិត គឺជាឯកសារសាធារណៈដែលត្រូវបានធ្វើឡើងតាមការស្នើសុំ បោះពុម្ពចេញជាសៀវភៅថវិកា ដែលមាន ៦ លេខ ។ សៀវភៅទាំងនោះអាច ទទួលបានពីនាយកដ្ឋានរៀបចំថវិកានៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាធម្មតាសៀវភៅនេះវត្តមាននៅក្នុងត្រីមាសដំបូងនៃឆ្នាំសារពើពន្ធដែលអាស្រ័យទៅ លើល្បឿននៃការបញ្ចប់ការវិភាគថវិកា និងការបោះពុម្ព។ វារៀបរាប់អំពីថវិកាជាតិ ផ្តល់សេចក្តីលម្អិតបន្ថែមទៀតលើរបៀបដែល ថវិកាត្រូវបានបម្រុងទុកដោយផ្អែកទៅលើ ចំណាត់ថ្នាក់ថវិកាខាងលើនេះ។ ប្រអប់ទី៦ ផ្តល់នូវសេចក្តីសង្ខេបនៃ សៀវភៅថវិកាជាតិឆ្នាំ២០១៤ ដែលមាន ៦ លេខ ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សៀវភៅថវិកា ជាការបែងចែកដ៏សំខាន់នៃថវិកាបំរុងទុក និងត្រូវបានប្រើដោយរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនៅក្នុងការប្រតិបត្តិថវិការបស់ខ្លួន ក្នុងអំឡុងឆ្នាំសារពើពន្ធ។

**ប្រអប់ទី៦: សៀវភៅទាំង ៦ ស្ដីពីថវិកាជាតិ ឯកសារយោងក្នុងការគ្រប់គ្រងថវិកា ប្រកបដោយប្រសិទ្ធភាព**

នៅត្រីមាសទីមួយឆ្នាំ២០១៤ និងដូចជាសេចក្ដីយោងសម្រាប់ ប្រតិបត្តិការថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបោះផ្សាយថវិកាបស់រដ្ឋាភិបាលចេញជា ៦ លេខ។ សៀវភៅទាំងប្រាំមួយនេះ គឺពន្យល់យ៉ាងពិស្ដារនៃថវិកាជាតិដែលផ្ដល់មូលនិធិដោយរដ្ឋាភិបាល ដោយមិនរាប់បញ្ចូលគម្រោងវិនិយោគជាសាធារណៈដែលផ្ដល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍។ នាយកដ្ឋានរៀបចំថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្ដល់នូវសៀវភៅចំនួនប្រាំមួយក្បាលដោយឥតគិតថ្លៃ ដែលអាចទទួលបានតាមរយៈការស្នើសុំរបស់អង្គការក្រៅរដ្ឋាភិបាល និងភាគីពាក់ព័ន្ធផ្សេងៗទៀត។ វាមានបរិមាណកំណត់នៃច្បាប់ចម្លងនេះ។

**សៀវភៅទី១: ច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធ**

ថវិកាជាតិរួមមានច្បាប់ថវិកាជាតិទាំងមូលត្រូវបានអនុម័តដោយរដ្ឋសភា។ លើសពីនេះទៅទៀត វា បានរួមបញ្ចូលសារាចរជាមួយនឹងការណែនាំអំពីការរៀបចំនៃផែនការយុទ្ធសាស្ត្រថវិកា (សូមមើលប្រអប់ទី២ និងទី៣) សារាចរស្ដីពីការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងហិរញ្ញវត្ថុ (សូមមើលប្រអប់ទី៤ និងទី៥) សារាចរស្ដីពីការអនុវត្តន៍ ថវិកា ប្រកាស និងអនុក្រឹត្យស្ដីពីការផ្ទេរឥណទានថវិកានិងឧបករណ៍ច្បាប់ផ្សេងទៀត ដែលបានចេញផ្សាយក្នុងឆ្នាំទាក់ទងទៅនឹងបញ្ហាគ្រប់គ្រងថវិកា។

**សៀវភៅទី២ : ថវិកាថ្នាក់ជាតិ: ក្រសួង និងស្ថាប័ន**

ការបែងចែកថវិកាសម្រាប់ក្រសួងទាំងមូលដែលបានបង្ហាញលម្អិតអំពីការបែងចែកថវិកា ចំណូល និងចំណាយរបស់ក្រសួងនីមួយៗដោយថ្នាក់មជ្ឈិម និងថ្នាក់ខេត្ត និងសម្រាប់ខេត្តនីមួយៗជាមួយនឹងវត្តមានរបស់ស្ថាប័ន ក្រសួង និងមន្ទីរខេត្ត។ ប្រាក់ចំណូលត្រូវបានចាត់ថ្នាក់ដោយក្រុម ប្រភេទ ជំពូកគណនី និងគណនីរង។ ការចំណាយក៏ត្រូវបានចាត់ថ្នាក់បន្ថែមទៀតតាមប្រភេទចំណាយផ្សេងៗ "ជំពូក គណនី និងគណនីរង"។ សៀវភៅទាំងនោះរៀបរាប់តែពី ប្រាក់ចំណូល និងការចំណាយចរន្តរបស់រដ្ឋាភិបាល។ ចំពោះចំណាយមូលធន មានតែចំនួនទឹកប្រាក់សរុបដែលបានបង្ហាញនៅក្នុងចំនួនមានកំណត់របស់ក្រសួងដូចដែលបានបង្ហាញនៅក្នុងតារាង ខ នៃច្បាប់ថវិកា។

**សៀវភៅទី៣: ថវិកាថ្នាក់ជាតិ: នាយកដ្ឋានបច្ចេកទេសរាជធានី និងខេត្ត**

ការបែងចែកថវិកាដោយខេត្ត ដែលរៀបរាប់លម្អិតអំពីប្រាក់ចំណូល និងការបែងចែកតាមនាយកដ្ឋាន។ ជាថ្មីម្ដងទៀត វាគ្របដណ្ដប់តែប្រាក់ចំណូល និងការចំណាយចរន្ត ប៉ុណ្ណោះ។

**សៀវភៅទី៤: ថវិការាជធានី និងខេត្តសម្រាប់ការគ្រប់គ្រងថវិកាប្រចាំឆ្នាំ**

ការបែងចែកថវិកាទៅអាជ្ញាធរខេត្ត និងរាជធានី ជាធម្មតាត្រូវបានគេស្គាល់ថាថវិកាសាលាខេត្ត និង រាជធានី រៀបរាប់លម្អិតដោយ (ភ្នំពេញ) រាជធានី និងខេត្ត។ សៀវភៅថវិកានេះបង្ហាញទាំងការប្រមូលប្រាក់ចំណូល និងការចំណាយការប្រើប្រាស់ ថ្នាក់ថវិកាសេដ្ឋកិច្ចនៃរាជធានីភ្នំពេញ និងខេត្តនីមួយៗ។ សម្រាប់ខណ្ឌនៅក្នុងរាជធានីភ្នំពេញ ថវិការបស់ខ្លួនត្រូវបានកត់ត្រាក្រោមថវិការាជធានីភ្នំពេញ។ នៅក្នុងផ្នែកនៃការចំណាយ វារួមបញ្ចូលទាំង ចំណាយចរន្ត និងមូលធន នៃខេត្តមួយចំនួន ដែលភាគច្រើនជា រាជធានីភ្នំពេញ និងបណ្ដាខេត្តដែលមានសក្ដានុពលសម្រាប់ទាក់ទាញភ្ញៀវទេសចរណ៍។

**សៀវភៅទី៥: ថវិកាស្រុក ក្រុង និងខណ្ឌសម្រាប់ការគ្រប់គ្រងថវិកាប្រចាំឆ្នាំ (១ និង ២)**

សៀវភៅថវិកានេះមានព័ត៌មានអំពីថវិកាចំណូល (ប្រភពផ្ទាល់ខ្លួន ដែលភាគច្រើនជាចំណូលមិនមែន

សារពើពន្ធ និងការឧបត្ថម្ភធនពីរដ្ឋាភិបាលជាតិ) និងការបែងចែកទៅស្រុកតាមបណ្ដាខេត្ត ក្រុង និងខណ្ឌនីមួយៗក្រោមក្រុង និងរាជធានី។ ការបែងចែកថវិកាភាគច្រើនទៅស្រុក គឺជាថវិកាចរន្ត និងមិនមានថវិកាមូលធនទេ ទោះជាយ៉ាងណា ខណ្ឌ និងក្រុងមានការបែងចែកថវិកាមូលធនដែលភាគច្រើនសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ។

**សៀវភៅ ទី៦: ថវិកាឃុំ/សង្កាត់សម្រាប់ការគ្រប់គ្រងថវិកាប្រចាំឆ្នាំ**

ការបែងចែកថវិកាដល់ឃុំទាំងអស់ (១៦៣៣ ត្រឹមឆ្នាំ២០១៤) នៅទូទាំងប្រទេសកម្ពុជា។ សៀវភៅនេះផ្ដល់នូវ ថវិកាសរុបលម្អិត ទៅក្នុងចំណាយថវិការដ្ឋបាល និងការអភិវឌ្ឍ នៃឃុំ/សង្កាត់ដែលបានដាក់ជាក្រុមក្រោមបណ្ដាខេត្ត និងក្រុង។ សូមមើលការពន្យល់លម្អិតស្ដីពីការចាត់ថ្នាក់ថវិកានៅក្នុងជំពូកបន្ទាប់។

ប្រភព: សៀវភៅថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឆ្នាំ២០១៤

នៅពេលដែលច្បាប់ថវិកាត្រូវបានអនុម័ត រដ្ឋមន្ត្រី ប្រធានស្ថាប័ន និងប្រធានអង្គភាពសាធារណៈស្រដៀងគ្នា (ប្រធាននាយកដ្ឋានខេត្ត និងអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ) គឺជាអ្នកគ្រប់គ្រងថវិការបស់ខ្លួនទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រោមការទទួលខុសត្រូវ និង វិស័យរៀងៗខ្លួននៅក្នុងបណ្ដាខេត្តនីមួយៗ។ អ្នកគ្រប់គ្រងទាំងនេះ គឺជាមន្ត្រីដែលទទួលបានការអនុញ្ញាត និងទទួលខុលត្រូវទាំងការរកប្រាក់ចំណូល និងការចំណាយដូចមានចែងនៅក្នុងថវិកាជាក់លាក់របស់ខ្លួន។ តាមរយៈប្រកាសក្រសួង និងប្រធាននៃភ្នាក់ងារសាធារណៈ ផ្ទេរសិទ្ធិអំណាចដល់ អភិបាលខេត្ត ក្រុង និងមន្ទីរដែលមានសមត្ថភាព សម្រាប់ប្រតិបត្តិការហិរញ្ញវត្ថុនៃថវិកា នៅក្នុងការទទួលខុសត្រូវក្នុងតំបន់ និងឯកទេស និងភូមិសាស្ត្រដែលខ្លួនគ្រប់គ្រង (មាត្រា ៦៣ នៃឆ្នាំ២០០៨ ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។

ការកែប្រែថវិកាទាំងនេះ អាចជាការចាំបាច់ និងអាចត្រូវបានធ្វើឡើងដោយយោងទៅតាមគោលការណ៍ "*អ្នកណាដែលបានមានសិទ្ធិអំណាច គឺជាអ្នកធ្វើការកែប្រែ*"។ នេះមានន័យថា ការកែប្រែក្នុងការបែងចែក ឬការផ្ទេរគណនីថវិកាពីក្រសួងមួយទៅក្រសួងមួយផ្សេងទៀត តម្រូវឲ្យមានការបោះឆ្នោតដោយរដ្ឋសភាជាតិ (ដែលត្រូវបានធ្វើឡើងដោយឆ្លងកាត់ច្បាប់និយ័តកម្មថវិកាដូចមានចែងក្នុងមាត្រា៦២ នៃ ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។ ការកែប្រែក្នុងថវិការបស់បណ្ដាក្រសួង ត្រូវបានកំណត់ជាពីរប្រភេទនៃការផ្លាស់ប្ដូរ។ ប្រភេទដំបូង គឺការផ្ទេរពីជំពូកមួយទៅមួយផ្សេងទៀត ហើយវាអាចត្រូវបានធ្វើឡើងដោយអនុក្រឹត្យ។ ប្រភេទទីពីរ ទាក់ទងនឹងការផ្ទេរពីគណនីមួយ និងគណនីរងមួយទៅគណនីរងផ្សេងទៀត ហើយនេះអាចត្រូវបានធ្វើដោយប្រកាសរបស់រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅក្នុងជំពូកថវិកាដូចគ្នានៃក្រសួងទាំងអស់[20]។ ការផ្ទេរបន្ថែមនៃថវិការបស់ក្រសួងនានា អាចត្រូវបានធ្វើឡើងតាមរយៈអនុក្រឹត្យនៃការផ្ទេរគណនីថវិកាដែលបាន មកពីការចំណាយដែលមិនបានរំពឹងទុក (ជំពូកទី ៩) នៅក្នុងថវិកាមិនទាន់បែងចែកដោយផ្អែកលើលក្ខខណ្ឌថា វាមិនបានគ្រោងទុកក្នុងអំឡុងពេល នៃការបង្កើតថវិកា និងសម្រាប់ចំណាយពិសេសរបស់រដ្ឋាភិបាល[21]។ ដំណើរការនៃការផ្ទេរថវិកាពីខ្ទង់មួយទៅមួយទៀត ត្រូវបានហៅថា "និយ័តកម្ម" (សូមមើល

[20] សម្រាប់ព័ត៌មានបន្ថែមសូមមើល: ជំពូកទីប្រាំមួយ (ណារ៉ុន ឆ្នាំ២០០៩) ឬ ផ្នែកទី១ នៃឆ្នាំ ២០០៨ ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមាត្រា៥៥, ៥៦ និង៥៧ នៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

[21] សូមមើលអត្ថបទ២៥, ៥៨ និង ៦១ ក្នុងច្បាប់ឆ្នាំ២០០៨ ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

និយមន័យនៅក្នុងសទ្ទានុក្រម)។ ក្នុងករណីកម្រ ការផ្តល់ឥណទានថវិកាបន្ថែម អាចត្រូវបានបន្ថែមទៅក្រសួងពាក់ព័ន្ធ តាមរយៈអនុក្រឹត្យ នៅក្នុងករណីសង្គ្រោះបន្ទាន់ និងគ្រោះមហន្តរាយធម្មជាតិដែលប៉ះពាល់ដល់ផលប្រយោជន៍ជាតិ។

នៅក្នុងក្រសួងផ្សេងគ្នា និងស្ថាប័នសាធារណៈ ការត្រួតពិនិត្យនៃការអនុវត្តន៍ ថវិកា ត្រូវបានធ្វើឡើងដោយនាយកដ្ឋានកិច្ចការហិរញ្ញវត្ថុ គណនេយ្យករសាធារណៈនៅរតនាគារជាតិ និងការគ្រប់គ្រងហិរញ្ញ-វត្ថុដោយផ្អែកលើក្រសួងនីមួយៗ។

## ២.៣.១ និតិវិធីប្រតិបត្តិថវិកា

ក្នុងការអនុវត្តន៍ ការប្រតិបត្តិថវិកាត្រូវអនុវត្តតាមនីតិវិធី ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយផ្អែកលើប្រកាស និងគោលការណ៍ណែនាំខុសគ្នា។ ឯកសារមួយដ៏សំខាន់ក្នុងកំឡុងពេលប្រតិបត្តិថវិកា គឺគោលការណ៍ណែនាំស្តីពីការប្រតិបត្តិគម្រោងថវិកាដែលបានចេញផ្សាយដោយនាយក ដ្ឋានកិច្ចការហិរញ្ញវត្ថុនៃអគ្គនាយកដ្ឋានថវិកានៅឆ្នាំ២០១៣។ គោលការណ៍ណែនាំនេះ ពន្យល់ពីជំហាននិងឯកសារដែលបានទាមទារដើម្បីទទួលបានសាច់ប្រាក់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (រតនាគារជាតិនិងខេត្ត) ទៅក្រសួងនានា រាជធានី និងមន្ទីរខេត្ត និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីអនុវត្តច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (២០០៨) ឯកសារបីសំខាន់ (អនុក្រឹត្យលេខ៨១ ៨២ និង ១០៥) ជាមួយនឹង បទប្បញ្ញត្តិគាំទ្ររបស់ក្រសួងផ្សេងទៀត ដែលត្រូវបានអភិវឌ្ឍន៍ និងប្រើដើម្បីណែនាំដំណើរការនៃប្រតិបត្តិថវិកា។ វាត្រូវបានពិពណ៌នាពីក្របខ័ណ្ឌច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងលក្ខ ខណ្ឌនៃការប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យ។ បទប្បញ្ញត្តិមួយចំនួនមានដូចខាងក្រោមៈ

- អនុក្រឹត្យលេខ៨២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ លើបទប្បញ្ញត្តិទូទៅសម្រាប់គណនេយ្យសាធារណៈ ។
- អនុក្រឹត្យលេខ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ លើការត្រួតពិនិត្យស្ថាប័នហិរញ្ញវត្ថុចំណាយថវិកា រដ្ឋាភិបាលនៅក្រសួង រាជធានី/ខេត្ត និងអង្គភាពរដ្ឋបាលសាធារណៈស្រដៀងគ្នាផ្សេងៗទៀត។
- អនុក្រឹត្យលេខ១០៥ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីនីតិវិធីលទ្ធកម្មសាធារណៈ។ នៅឆ្នាំ២០១២ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈត្រូវបានអនុម័ត និងប្រកាសឱ្យប្រើដើម្បីជំនួសអនុក្រិត្យ[22]។
- អនុក្រឹត្យលេខ១០ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ លើប្រាក់ឧបត្ថម្ភចិញ្ចឹមជីវិតប្រចាំថ្ងៃក្នុងស្រុកនិងក្រៅប្រទេស ដែលត្រូវបានជំនួសដោយអនុក្រិត្យ២១៦ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ លើប្រាក់ឧបត្ថម្ភចិញ្ចឹមជីវិតប្រចាំថ្ងៃក្នុងស្រុក និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- អនុក្រឹត្យលេខ១៥៥ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីនីតិវិធីទូទាត់សាច់ប្រាក់បុរេប្រទានសម្រាប់ចំណាយការវិនិយោគចរន្ត និងសាធារណៈ។
- សារាចរណែនាំលេខ០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពី នីតិវិធីក្នុងការទូទាត់សាច់ប្រាក់តូចតាច។
- សារាចរណែនាំបន្ថែមលេខ០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ ២០០៧ ស្តីពីនីតិវិធីក្នុងការទូទាត់សាច់ប្រាក់តូចតាច (សម្រាប់ថវិកាកម្មវិធី)។

---

[22] សូមមើលគេហទំព័ររបស់ថវិការបស់ប្រទេសកម្ពុជាៈ www.cambodianbudget.org

- សារាចរណែនាំលេខ០០៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុ។
- ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ០៣០ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០៣ ស្តីពី ការមិនផ្តោតអារម្មណ៍នៃការត្រួតពិនិត្យហិរញ្ញវត្ថុ។
- ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលេខ១៤១៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ លើការ ប្រគល់សិទ្ធិអំណាចចុះហត្ថលេខាទៅ អ្នកគ្រប់គ្រងហិរញ្ញវត្ថុដោយមានមូលដ្ឋាននៅតាមបណ្តា ក្រសួង និងទីភ្នាក់ងារកណ្តាលក្នុងការត្រួតពិនិត្យ និងចេញទិដ្ឋាការលើលិខិតធានា លើការចំណាយ និងអាណត្តិទូទាត់។

ច្បាប់និងបទប្បញ្ញត្តិខាងលើនេះ ព្រមទាំងបទប្បញ្ញត្តិថវិកាលើវិស័យជាក់លាក់ផ្សេងទៀតអាចត្រូវបានរកឃើញនៅក្នុងសេចក្តីណែនាំសម្រាប់ការចំណាយ និងនីតិវិធីត្រួតពិនិត្យហិរញ្ញវត្ថុសម្រាប់ថវិកាជាតិចរន្តក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជំហានសំខាន់នៃការប្រតិបត្តិគម្រោងថវិកា គឺត្រូវបានបង្ហាញនៅក្នុងរូបភាពខាងក្រោមនេះ៖

**រូបភាពទី ៦: លំហូរនៃចរន្តចំណាយថវិកាសម្រាប់រដ្ឋបាលថ្នាក់ជាតិ**




ប្រភព: គោលការណ៍ណែនាំស្តីពីចរន្តចំណាយថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាតិនិងនិតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ (២០១៣)

ប្រព័ន្ធប្រតិបត្តិគម្រោងថវិកាបន្ទាប់ពីមានការអនុម័តត្រូវបែងចែកជាបីដំណាក់កាលអនុវត្តៈ

១. ដំណើរការនៅក្នុងក្រសួងៈ បន្ទាប់ពីទទួលបានសំណើថវិកាពីនាយកដ្ឋានក្រោមបង្គាប់ របស់ក្រសួងនីមួយៗ ប្រធានផ្នែកថវិកា/ប្រធានភ្នាក់ងារចំណាយ ធ្វើការពិនិត្យលើវត្តមានថវិកាដែលសមរម្យ បន្ទាប់មកបញ្ជូនសំណើថវិកាជាមួយ នឹងឯកសារពាក់ព័ន្ធទៅកាន់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ មុននឹងបញ្ជូនសំណើទៅ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរបស់ក្រសួងនីមួយៗ មានសិទ្ធិផ្តល់ទិដ្ឋាការលើសំណើថវិកាផ្អែកលើចំនួនដែលត្រូវចំណាយ តាមគោលការណ៍សិទ្ធិអំណាច ណែនាំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (លើកឡើងក្នុងប្រកាសខាងលើទាក់ទង នឹងការគ្រប់គ្រងហិរញ្ញវត្ថុ)។ បើសិនជាទទួលបានទិដ្ឋាការ ប្រធានផ្នែកថវិកា/ប្រធានភ្នាក់ងារចំណាយ អាចបញ្ជូនសំណើថវិកានេះទៅកាន់ អគ្គនាយកដ្ឋានរតនាគារជាតិរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ សំណើផ្សេងទៀតត្រូវបញ្ជូនទៅកាន់អគ្គនាយកកិច្ចការហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២. ដំណើរការនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុៈ បន្ទាប់ពីទទួលបានសំណើថវិកាពីក្រសួងនានា អគ្គនាយកកិច្ចការ ហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យថាតើសំណើនេះអនុលោមតាមគោលការណ៍ និងនិតិវិធី និងវត្តមានឥណទានថវិកាសម្រាប់ចំណាយមួយនឹងឬទេ បន្ទាប់មកនឹងធ្វើការកាត់ត្រាសំណើនេះទៅ ក្នុងសៀវភៅតាមដានលើការធានាចំណាយថវិកា ឬក៏សៀវភៅតាមដានការចាយវាយថវិកា (បើសិនជាសំណើ សុំធ្វើការទូទាត់) រួចសុំការអនុម័តពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងការចេញនូវទិដ្ឋាកាធានាលើថវិកា។ បើសិនជាមានការខ្វះខាតនៅចំណុចណាមួយ សំណើថវិកា ឬសំណើសុំទូទាត់ នឹងត្រូវបញ្ជូនត្រលប់ទៅក្រសួងដែលដាក់សំណើមកវិញ និង បើសិនជាក្រសួងនោះមិនយល់ព្រមកែសំរួលលើសំណើនោះទេក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តែមួយគត់ដែលមានសិទ្ធិអនុម័តលើសំណើថវិកានិងការ ទូទាត់។

៣. ដំណើរការនៅរតនាគារជាតិៈ មានតួនាទីជាបេឡាករ និងគណនេយ្យករឯករាជ្យ របស់រដ្ឋាភិបាល អគ្គនាយកដ្ឋាន រតនាគារជាតិ នឹងធ្វើការផ្ទៀងផ្ទាត់អនុលោមភាពនៃ អ្នកគ្រប់គ្រងថវិកា ឬលក្ខណៈនៃការផ្ទេរសិទ្ធិរបស់អ្នកគ្រប់គ្រងថវិកា វត្តមានឥណទានថវិកា ភាពត្រឹមត្រូវនៃការបែងចែកថវិកាក្នុងអនុគណនី គណនីនិងជំពូក និងស្ថានភាពចែកចាយទំនិញនិងសេវាកម្ម ជាមួយនឹងទិដ្ឋាការដែលចេញដោយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ។

ដើម្បីបញ្ចប់នូវដំណើរការដូចបានរៀបរាប់ខាងលើ ប្រើពេលប្រហែលជា ២ ទៅ ៣ ខែ។ ការប៉ាន់ស្មានធនាគារពិភពលោកក្នុងឆ្នាំ ២០១៤ បានបង្ហាញថា មានជាង២០០ ជំហានត្រូវធ្វើដើម្បីអាចដកប្រាក់ពីរតនាគារជាតិបាន។

## ២.៣.២ ឧបករណ៍គ្រប់គ្រងការអនុវត្តន៍ ថវិកា

ឧបករណ៍ចំបងរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងការអនុវត្តន៍ ថវិកា គឺតារាងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដែលតែងតែហៅថា តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច[23]។ តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច គឺ

[23] T E គឺជាពាក្យកាត់របស់ “*តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច*” ដែលបង្កើតឡើងរាល់ខែ។

ជាការបូកបង្គរនៃប្រាក់ចំណូល និងការចំណាយ នៃថវិកាប្រចាំខែ (សូមមើលក្នុងតារាងទី ៣) និងបានចេញផ្សាយជាទៀងទាត់នៅលើគេហទំព័ររបស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ[24]។ ទំរង់ឯកសាររបស់តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច សម្រាប់ប្រើប្រាស់ប្រចាំឆ្នាំគឺ ដូចគ្នានឹងទំរង់ឯកសារប្រើប្រាស់ប្រចាំខែដែរ (សូមមើលឧបសម្ព័ន្ធទី៤)។ ក៏ប៉ុន្តែទំរង់ឯកសារទាំងពីរគួរតែបែងចែកអោយដាច់ពីគ្នា និងបង្ហាញដាច់ដោយឡែកស្របតាមការស្តង់ដារអន្តរជាតិ។

បន្ថែមពីលើតារាងតួលេខ តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ក៏មានជារបាយការណ៍ពន្យល់ខ្លីៗ ដែលរួមមាន សេចក្តីផ្តើម ចំណូល ចំណាយ តុល្យភាពសារពើពន្ធ និងការសន្និដ្ឋាន និងក្រាហ្វិកដើម្បីប្រៀបធៀបសារពើពន្ធបច្ចុប្បន្នទៅនឹងសារពើពន្ធកាលពីឆ្នាំមុន។ ក៏ប៉ុន្តែ ព័ត៌មានដែលផ្សាយក្នុង តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច គឺនៅជាទំរង់បែបបទសរុប និងមិនអាចផ្តល់នូវការវិភាគគ្រប់ជ្រុងជ្រោយ និងការត្រួតពិនិត្យលើក្រសួងពាក់ព័ន្ធនិងថវិការដ្ឋបាលថ្នាក់ក្រោមជាតិបានឡើយ។ ជាមួយនឹង តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋ រដ្ឋាភិបាលអាចធ្វើការតាមដានចំណូល ដែលទទួលបាននិងចំណាយដែលបានចាយដោយក្រសួងទាំងអស់ ដោយកាត់ត្រាបែងចែកតាមសេដ្ឋកិច្ច។ វាក៏បង្ហាញ អោយឃើញថាតើ ជារួមចំណូលនិងចំណាយអនុលោមតាមច្បាប់ថវិកា ជាឱនភាព ឬអតិរេកនៃថវិកា។

បន្ថែមពីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានណែនាំស្ថិតិហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដូចជារបាយ ការណ៍ប្រតិបត្តិការរបស់រដ្ឋាភិបាល។ របាយការណ៍នេះរួមមាន ចំណូល ចំណាយ ទ្រព្យនិងបំណុល (ជំពាក់) តាំងពីឆ្នាំ ២០១៣ មក។ ជាការចាប់អារម្មណ៍មួយ ស្ថិតិហិរញ្ញវត្ថុរបស់រដ្ឋាភិបាល នេះបានបង្ហាញនូវ ប្រាក់ចំណូលឬការចំណាយលំអិត ជាពិសេសព័ត៌មានរបស់ធាតុអនុស្សរណៈដែលមាន ដូចជា: ១) របាយការណ៍ចំណូលចំណាយប្រចាំខេត្តដែលមានសារៈសំខាន់សម្រាប់ក្រុមការងារកំណែទម្រង់វិមជ្ឈការនិងសហវិមជ្ឈការ និង ២) របាយការណ៍ចំណូលដែលបានមកពី ឧស្សាហកម្ម និស្សារណកម្ម ដែលជាចំណាប់អារម្មណ៍របស់ក្រុមតស៊ូមតិ ទាមទារអោយមានតម្លាភាពលើការ ចាយ វាយរបស់ក្រុមហ៊ុន និងចំណូលរបស់រដ្ឋាភិបាលបានពីក្រុមហ៊ុន ប្រេង ឧស្ម័ន និងរ៉ែ។

តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ជាមួយនឹងតួលេខបណ្តោះអាសន្ន[25] លើថវិកាប្រតិបត្តិរបស់ក្រសួងនានា គឺមានលក់នៅនាយកដ្ឋានស្ថិតិនៃអគ្គនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

---

[24] សូមមើលលើផ្នែកផ្សព្វផ្សាយរបស់គេហទំព័ណ http://www.mef.gov.kh

[25] យោងតាមតួរលេខនៅក្នុង តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ដែលមិនទាន់បានអនុម័តនៅឡើយទេ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ការចេញផ្សាយជាសាធារណៈ។

តារាងទី ៣: តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ខែមិថុនា ឆ្នាំ ២០១៥

| ពាន់លានរៀល | ច្បាប់ស្ដីពីថវិកាឆ្នាំ ២០១៥ | ការអនុវត្តន៍ ពី ខែមករា ដល់ខែមិថុនា ឆ្នាំ២០១៥ = ៥០% | |
|---|---|---|---|
| **I. ចំណូលក្នុងស្រុក** | **១១.១៤៨,២៣** | **៥៣,៤%** | **៥.៩៤៩,៣៨** |
| ១. ចំណូលចរន្ត | ១១.០១៤,៦៤ | ៥៣,៧% | ៥.៩១២,៥៣ |
| ក. ចំណូលពន្ធ (បែងចែកចេញជាអនុប្រភេទ) | ៩.៥៤៨,៣៩ | ៥៦,៩% | ៥.៤៣៦,៦៦ |
| ខ. ចំណូលក្រៅពីពន្ធ (បែងចែកចេញជាអនុប្រភេទ) | ១.៤៦៦,២៥ | ៣២,៥% | ៤៧៥,៨៧ |
| ២. ចំណូលមូលធន | ១៣៣,៥៩ | ២៧,៦% | ៣៦,៨៥ |
| **II. ចំណាយថវិកា** | **១៤.៥៩៨,៦៦** | **២៤,៦%** | **៣.៥៩១,៧៤** |
| ១. ចំណាយចរន្ត | ៩.២៧៥,១៦ | ៣០,១% | ២.៧៩៤,៥០ |
| ក. ប្រាក់ខែ (បែងចែកចេញជាអនុប្រភេទ ២) | ៤.៥៦៦,៤១ | ៤១,២% | ១.៨៨០,៩០ |
| ខ. ចំណាយមិនមែនជាប្រាក់ខែ (បែងចែកចេញជាអនុប្រភេទ) | ៤.៧០៨,៧៥ | ១៩,៤% | ៩១៣.៦០ |
| ២. ចំណាយមូលធន (បែងចែកចេញជាអនុប្រភេទ) | ៥.៣២៣.៥០ | ១៥,០% | ៧៩៧,២៤ |
| ៣. ការកែតំរូវចំណាយ | | | (៨៧៥,៣៣) |
| ឱនភាព / អតិរេកបច្ចុប្បន្ន | ៣១៤,៨៧ | ៣១៤,៨៧ | ៣១៤,៨៧ |
| ឱនភាព / អតិរេកសរុប | **(៣.៤៥០,៤៣)** | **៤៣,០%** | **១.៤៨២,៣១** |
| **III. ហិរញ្ញប្បទាន** | **៣.៤៥០,៤៣** | **-៤៣,០%** | **(១.៤៨២,៣១)** |
| ១. ហិរញ្ញប្បទានអន្តរជាតិ (ជាមួយនឹងលក្ខណៈពិសេស) | ៣.៥៥០,៤៣ | ៧,២% | ២៥៧,០៩ |
| ២. ហិរញ្ញប្បទានជាតិ | ១០០,០០ | -២.០៣៨,៦% | (២.០៣៨,៦១) |
| ៣. ប្រតិបត្តិការដែលនៅសល់ | | | ២៩៩,២១ |
| ធាតុអនុស្សរណៈ | | | |
| ចំណូលប្រចាំខេត្ត (ជាមួយនឹងការបញ្ជាក់បន្ថែម) | | | ៣១៤,៨៧ |
| ចំណាយប្រចាំខេត្ត (ជាមួយនឹងការបញ្ជាក់បន្ថែម) | | | ២១៤,៣៤ |
| សមតុល្យប្រចាំខេត្ត (ជាមួយនឹងការបញ្ជាក់បន្ថែម) | | | ៧,៩០ |
| វិស័យអទិភាពទាំង ៨ | ៣.២០៧,៥២ | ២២,៣% | ៧១៥,៤៨ |

ឧបករណ៍តាមដានសំខាន់មួយទៀត គឺច្បាប់ស្តីពីប្រតិបត្តិថវិកា មានសេចក្តីលំអិតដូចនៅក្នុង ច្បាប់ថវិកាដែរ។ ទោះបីជាយ៉ាងណា ច្បាប់នេះមានវត្តមានយ៉ាងតិចបំផុតមួយឆ្នាំ បន្ទាប់ពីសារពើពន្ធ ដែលមិនអាចអោយយើងធ្វើការត្រួតពិនិត្យទាន់ពេលវេលាបាន។ ច្បាប់នេះប្រើប្រាស់ដោយរដ្ឋសភាជាតិ ជាការដាក់បន្ទុកឱ្យរដ្ឋាភិបាលទទួលខុសត្រូវ ដោយហេតុថាអាជ្ញាធរសវនកម្មជាតិ ដាក់របាយការណ៍សវនកម្មឯករាជ្យទៅកាន់រដ្ឋសភាជាតិដើម្បីពិភាក្សាអំពីការប្រតិបត្តិថវិកាទាំងនោះ។ ក្នុងករណីដែលការដាក់ស្នើមានភាពយឺតយ៉ាវក្នុងការដាក់របាយការណ៍ វានឹងមានផលពិបាកដល់ រដ្ឋសភាក្នុងការពិភាក្សាអោយបានគ្រប់ជ្រុងជ្រោយ និងប្រើបទពិសោធន៍កន្លងមកក្នុងប្រតិបត្តិថវិកា ដើម្បីកែតំរូវលើឆ្នាំសារពើពន្ធបច្ចុប្បន្ន។
មាត្រា៨៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានចែងយ៉ាងច្បាស់ថា "...របាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍គណនេយ្យទាំងអស់ ត្រូវតែផ្សាយជាសាធារណៈ។" តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ចដែលផ្សាយក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនមានភាពលម្អិតគ្រប់គ្រាន់ដូចច្បាប់ថវិកាឡើយ ហើយសរសេរជាភាសាអង់គ្លេស ដែលរឹតតែធ្វើអោយមានផលលំបាក សម្រាប់ប្រជាជន និងអង្គការសង្គមស៊ីវិល ក្នុងការយល់ច្បាស់ពីលទ្ធផលក្នុងការប្រើប្រាស់ថវិកាជាតិ។ តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ចជាភាសាខ្មែរ ជាមួយនឹងនិយមន័យរបស់ពាក្យបច្ចេកទេស គួរតែមានសម្រាប់ប្រជាជនធម្មតា អាចអាននិងយល់បានលើ តួលេខទាំងអស់។ មិនទាន់ច្បាស់ថានៅពេលដែលអគ្គនាយកដ្ឋានម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ នឹងបោះពុម្ពផ្សាយតារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ជាភាសាខ្មែរ ដែលតួលេខលម្អិតផ្សេងៗទៀត យ៉ាងហោចណាស់ដូចគ្នាទៅនឹងច្បាប់ថវិកា។ របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលឆ្នាំ ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរាយការណ៍ទៅរដ្ឋសភាជាតិ គឺមិនតំរូវអោយផ្សព្វផ្សាយជាសាធារណៈទេ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុធ្លាប់បានបោះពុម្ពផ្សាយរបាយការណ៍ត្រួតពិនិត្យពាក់កណ្តាលឆ្នាំ[26] ម្តងក្នុងឆ្នាំ ២០១០ ក្នុងគេហទំព័ររបស់ខ្លួន។ ទោះយ៉ាងណា របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលឆ្នាំមិនត្រូវបានបោះពុម្ពទៀតទេចាប់តាំងពីពេលនោះមក។

### *តួនាទីរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល / អង្គការក្រៅរដ្ឋាភិបាល*

ក្នុងកំឡុងពេលប្រតិបត្តិថវិកា អង្គការសង្គមស៊ីវិល/អង្គការក្រៅរដ្ឋាភិបាល អាចបង្ហាញនូវចំណាប់អារម្មណ៍យ៉ាងច្បាស់របស់ពួកគេ ទៅលើប្រព័ន្ធត្រួតពិនិត្យដែលមានប្រសិទ្ធភាព និងតម្លាភាព។ អង្គការសង្គមស៊ីវិល/អង្គការក្រៅរដ្ឋាភិបាល ក៏អាចធ្វើការតស៊ូមតិលើកំណែទំរង់ថវិកាដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងថវិកា។ បន្ថែមពីនេះ ពួកគេក៏អាចចូលរួមក្នុងសកម្មភាពត្រួតពិនិត្យខ្លះៗផងដែរ។ ឧទាហរណ៍អង្គការក្រៅរដ្ឋាភិបាលអាចផ្តោតទៅលើការតាមដានថាតើ ចំនួនហិរញ្ញប្បទាន ដែលបានពីដៃគូរបស់រដ្ឋាភិបាលសម្រាប់ផ្ទើតគម្រោងណាមួយដូចជាសាងសង់សាលា ឬធ្វើផ្លូវ បានប្រើប្រាស់សម្រាប់គោលបំណងនោះដែរឬទេ។ ពួកគេក៏អាចពិនិត្យ វាយតម្លៃលើគុណភាពនៃចំណាយ ដើម្បីបញ្ជាក់ថា តើគោលដៅគោលនយោបាយផ្សារភ្ជាប់ជាមួយនឹងការបែងចែកថវិកានេះកំពុងត្រូវបានអនុវត្ត និងថាតើថវិការបស់រដ្ឋាភិបាលកំពុងតែប្រើប្រាស់ដោយមានប្រសិទ្ធភាពដែរឬទេ។

[26] មាត្រាទី ៣៦ និង ៣៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (២០១២)

## ២.៤ ដំណាក់កាលទី ៤: សវនកម្ម និងការវាយតម្លៃ

ដំណាក់កាលចុងក្រោយនៃវដ្តថវិកា រួមបញ្ចូលសកម្មភាពមួយចំនួនដែលមានគោលដៅវាស់វែង ថាតើមានការប្រើប្រាស់ ធនធានសាធារណៈដោយមានប្រសិទ្ធភាពដែរឬទេ។ មានរចនាសម្ព័ន្ធនានារបស់រដ្ឋាភិបាលដែលពាក់ព័ន្ធនឹងសវនកម្មដែលមានដូចជា: អគ្គនាយកដ្ឋានអធិការកិច្ច (ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានអធិការកិច្ច/អគ្គនាយកដ្ឋាននៃក្រសួងពាក់ព័ន្ធ និងនាយកដ្ឋានសវនកម្មផ្ទៃក្នុង/អគ្គនាយកដ្ឋាននៃក្រសួងពាក់ព័ន្ធ។ សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ហាក់ដូចជាមានភាពជាន់គ្នានៃតួនាទី និងការទទួលខុសត្រូវក្នុងក្រសួងនីមួយៗ[27]។ តួនាទីរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច គឺដើម្បីជួយឱ្យក្រសួងពាក់ព័ន្ធមានការគ្រប់គ្រងធនធាន និងលទ្ធផលរបស់ខ្លួនដោយមានប្រសិទ្ធភាព។ របាយការណ៍សវនកម្មនៃស្ថាប័នទាំងអស់មិនត្រូវបានផ្សព្វផ្សាយដល់សាធារណជនឡើយ។ ព័ត៌មានបន្ថែមស្តីពីរចនាសម្ព័ន្ធទាំងអស់នោះមានសសេរនៅក្នុងជំពូកទី ១០ របស់សៀវភៅ *"ហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសកម្ពុជា"* (Naron, ២០០៩)។

ក្រៅពីប្រព័ន្ធផ្ទៃក្នុងរបស់រដ្ឋាភិបាល អាជ្ញាធរសវនកម្មជាតិបានដើរតួនាទីកណ្តាលនៅក្នុងដំណាក់កាលនេះ។ អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នឯករាជ្យមួយ បង្កើតឡើងក្នុងឆ្នាំ ២០០០។ អាជ្ញាធរសវនកម្មជាតិ មានថវិកាដោយឡែកពីគេ ដែលផ្តល់ដោយថវិកាជាតិ ដែលមានទំនួលខុសត្រូវលើការអនុវត្តន៍មុខងារជាសវនកម្មឯករាជ្យរបស់រដ្ឋាភិបាល និងរាយការណ៍ទៅកាន់រដ្ឋសភា (និងរដ្ឋាភិបាលទុកជាព័ត៌មាន)។ ចំណូល និងចំណាយរបស់ អាជ្ញាធរសវនកម្មជាតិ គ្រប់គ្រងដោយច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ យុត្តាធិការរបស់អាជ្ញាធរសវនកម្មជាតិ រួមមាន:

- ក្រសួងពាក់ព័ន្ធ និងមន្ត្រីរបស់ពួកគេ;
- មន្ត្រីជាន់ខ្ពស់នៃធនាគារជាតិ;
- គ្រឹះស្ថានហិរញ្ញវត្ថុសាធារណៈ និងក្រុមហ៊ុនហិរញ្ញវត្ថុសាធារណៈបណ្តាក់ទុនរួមគ្នា
- សហគ្រាស និងគ្រឹះស្ថានរដ្ឋ; និង
- បណ្តាខេត្ត និងក្រុងទាំងអស់។

អគ្គសវនករមានសិទ្ធិធ្វើសវនកម្មលើបញ្ជីគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការ និងកម្មវិធីរបស់ស្ថាប័នរដ្ឋាភិបាល អនុលោមតាមស្តង់ដាសវនកម្មទទួលស្គាល់ជាទូទៅ និងស្តង់ដាសវនកម្មរបស់រដ្ឋាភិបាល[28]។ សវនកម្មឯករាជ្យរួមមានការអនុវត្តន៍ នូវប្រភេទសវនកម្មដូចខាងក្រោម:

- សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ;
- សវនកម្មលើការគ្រប់គ្រងនៃគម្រោងឥណទានហិរញ្ញប្បទានផ្តល់ដោយប្រភពខាងក្រៅ;
- សវនកម្មលើប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការនានារបស់គ្រប់ស្ថាប័នទាំងអស់;
- សវនកម្មលើការវាយតម្លៃប្រសិទ្ធភាព និងប្រសិទ្ធភាពនៃការប្រតិបត្តិការ;

[27] សូមមើលរបាយការណ៍ EAP (២០១២)

[28] មាត្រា ១ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣ ខែមិនា ឆ្នាំ ២០០០

- សវនកម្មលើអង្គការមិនមែនរដ្ឋាភិបាល សមាគម គណបក្សនយោបាយ និងសហគ្រាសវិនិយោគឯកជន; និង
- សវនកម្មតាមការស្នើសុំពិសេស។

ដំណើរការសវនកម្ម ត្រូវបានដឹកនាំដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ យោងតាមច្បាប់នេះរាជរដ្ឋាភិបាល (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) មានកាតព្វកិច្ចផ្តល់ឯកសារនៃការទូទាត់ថវិកាប្រចាំឆ្នាំ (សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកា) ជូនរដ្ឋសភា និងព្រឹទ្ធសភា ដើម្បីពិនិត្យ និងអនុម័ត។ របាយការណ៍ទាំងនេះក៏ត្រូវដាក់ជូនអាជ្ញាធរសវនកម្មជាតិផងដែរ ក្នុងរយៈពេលប្រាំបួនខែក្រោយពេលបិទឆ្នាំហិរញ្ញវត្ថុ។ អាជ្ញាធរសវនកម្មជាតិផ្ទៀងផ្ទាត់របាយការណ៍ទាំងនោះ និងរៀបចំរបាយការណ៍សវនកម្ម និងដាក់ជូនរដ្ឋសភា និងព្រឹទ្ធសភា សម្រាប់ពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកា។ រដ្ឋសភាបញ្ចប់ដំណើរការសវនកម្ម ដោយមធ្យោបាយអនុម័តច្បាប់ទូទាត់ថវិកា។ សេចក្តីសន្និដ្ឋានធ្វើឡើង ដើម្បីបញ្ជាក់ថាការអនុវត្តន៍ ថវិកាបានល្អ ឬមិនគួរឱ្យពេញចិត្ត។

សេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកា បានប្រកាស់ដោយរាជកិច្ចបន្ទាប់ពីបានការអនុម័ត ដោយសភានីតិបញ្ញត្តិ និងមានវត្តមាននៅបណ្ណាល័យជាតិ និងបណ្ណាល័យសាធារណៈនៅក្នុងរដ្ឋសភា និងព្រឹទ្ធសភា។ សេចក្តីព្រាងច្បាប់នេះតាក់តែងឡើងមានលក្ខណៈដូចគ្នាទៅនឹងច្បាប់ថវិកាជាតិ និង "ទូទាត់" ដោយបន្ថែមជួរ។ ច្បាប់ស្តីពីការទូទាត់ថវិកានេះផ្តល់នូវតារាងមួយដែលបង្ហាញ ពីការបែងចែកថវិកា (ដោយក្រសួងនីមួយៗ) តាមចំនួនដែលអនុម័តដំបូង ការកែប្រែនានា និងការចំណាយជាក់ស្តែង។ ច្បាប់ស្តីពីការទូទាត់ថវិកា គួរតែដាក់ជូនរដ្ឋសភា មុនពេលចុងឆ្នាំ ផ្អែកលើឆ្នាំដែលចំណាយកើតឡើង (ឧទាហរណ៍ ច្បាប់ស្តីពីការទូទាត់ថវិកាឆ្នាំ ២០១០ ត្រូវដាក់ជូនសភាជាតិមុនពេលចុងឆ្នាំ ២០១១)។

ក្រៅពីការបង្កើតនៃសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកានេះ អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មជាក់លាក់មួយ នៅក្នុងអាណត្តិរបស់ខ្លួនតាមច្បាប់ស្តីពីការធ្វើសវនកម្ម និងការធ្វើវិសោធនកម្មផ្សេងៗទៀត ដែលធ្វើឡើងក្នុងឆ្នាំ ២០០០។ ទោះជាមាត្រា ២៩ ក្នុងច្បាប់នេះដែលបានបញ្ជាក់ថា របាយការណ៍ដែលចេញដោយអគ្គសវនករ គួរតែចាត់ទុកជាឯកសារសាធារណៈ របាយការណ៍ទាំងនោះមិនទាន់បានចេញផ្សាយរហូតដល់ឆ្នាំ ២០០៩ ទោះបីជាបានដាក់ជូនរដ្ឋសភាហើយក៏ដោយ។ មានការរីកចម្រើនមួយចំនួនចាប់តាំងពីឆ្នាំ ២០០៩ ដោយសារ អាជ្ញាធរសវនកម្មជាតិ ចេញផ្សាយរបាយការណ៍សវនកម្ម ឆ្នាំ ២០០៦ ឆ្នាំ ២០០៧ និងរបាយការណ៍ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៩ ឆ្នាំ ២០១១ និងឆ្នាំ ២០១៤។ របាយការណ៍ទាំងអស់អាចធ្វើការទាញយកពី គេហទំព័ររបស់ អាជ្ញាធរសវនកម្មជាតិ: www.naa.gov.kh។ របាយការណ៍សវនកម្មទាំងនោះ ផ្តោតលើបញ្ហាផ្សេងៗ នៅក្នុងឆ្នាំសារពើពន្ធនីមួយៗ និងបង្ហាញពីមាតិកាខុសៗគ្នាពីឆ្នាំមួយទៅឆ្នាំមួយផ្សេងទៀត។ ជាទូទៅការអនុវត្តន៍ នេះត្រូវបានទទួលការស្វាគមន៍ពីសំណាក់ អ្នកសង្កេតការណ៍ក្រុមអ្នកវិភាគ និងក្រុមមិនមែនរដ្ឋាភិបាល ថាជាជំហានវិជ្ជមានមួយ។ សេចក្តីសង្ខេបលើការវាយតម្លៃរបាយការណ៍សវនកម្មជាតិឆ្នាំ២០០៨ ត្រូវបានផ្តល់ជូនប្រអប់លេខ ៧ ខាងក្រោម៖

**ប្រអប់លេខ ៧: របាយការណ៍សវនកម្មចេញផ្សាយក្នុងឆ្នាំ ២០១១**

អាជ្ញាធរសវនកម្មជាតិ ត្រូវបានបង្កើតឡើងនៅក្នុងខែមីនាឆ្នាំ ២០០០ កើតចេញពីឆន្ទៈនិងការប្តេជ្ញាចិត្តយ៉ាងខ្លាំងរបស់រាជរដ្ឋាភិបាលកម្ពុជា (RGC) រដ្ឋសភា និងព្រឹទ្ធសភា ក្នុងការតាមដាន ត្រួតពិនិត្យវាយតម្លៃ និងការរាយការណ៍អំពីសមិទ្ធិផលរបស់ក្រសួង និងស្ថាប័នរដ្ឋាភិបាល អនុលោមតាមការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ក្នុងអំឡុងឆ្នាំសារពើពន្ធនីមួយៗ។ យោងតាមច្បាប់ស្តីពីសវនកម្មនៃរាជរដ្ឋាភិបាលកម្ពុជា ចេញផ្សាយឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិ មានកាតព្វកិច្ចក្នុងការបង្កើតនិងបញ្ចេញរបាយការណ៍សវនកម្មចាំបាច់ដល់សាធារណជន។

របាយការណ៍សវនកម្មឆ្នាំ ២០១១ គឺជារបាយការណ៍សវនកម្មដែលបានចេញផ្សាយលើកទីបួនដែលអាជ្ញាធរសវនកម្មជាតិ បានបង្កើតឡើង ហើយបានចេញផ្សាយជាសាធារណៈជាមួយនឹងរបាយការណ៍ឆ្នាំ ២០០៩ និង ២០១០ ។

របាយការណ៍សវនកម្មនេះត្រូវបានរៀបចំឡើងចេញជា ៥ ផ្នែក។ ផ្នែកទាំងប្រាំរួមមាន សេចក្តីផ្តើមការគ្រប់គ្រងថវិកា លទ្ធផលសវនកម្មសម្រាប់រដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ការកែតំរូវលើចំនុចខ្វះខាតផ្អែកលើរបាយការណ៍សវនកម្ម កាលពីឆ្នាំមុន និងការសន្និដ្ឋាន។ ផ្នែកសេចក្តីផ្តើម បង្ហាញពីទំហំនូវសវនកម្ម និងគោលបំណងក្នុងការផ្សព្វផ្សាយ។ ផ្នែកគ្រប់គ្រងថវិកា ផ្តោតលើក្របខ័ណ្ឌច្បាប់ស្តីពីការអនុវត្តន៍ថវិកា និងរបាយការណ៍ថវិកាសរុបសម្រាប់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ផ្នែកលទ្ធផលសវនកម្ម បូកសរុបការសំរេចបាន និងការវាយតម្លៃនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយផ្តោតលើបញ្ហាជាក់លាក់នៅក្នុងការប្រមូលប្រាក់ចំណូលនិងការគ្រប់គ្រងការចំណាយនៅរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (ខេត្តនិងរាជធានីស្រុក/ខណ្ឌ/ក្រុងឃុំ/សង្កាត់)។ មានការកត់សម្គាល់ឃើញថាបញ្ហាធំៗមួយចំនួនដែលរកឃើញបន្ទាប់ពីការធ្វើសវនកម្មរួច ជាចម្បងទាក់ទងទៅនឹងការគ្រប់គ្រងប្រាក់ចំណូលរបស់រដ្ឋាភិបាលចំណាយទ្រព្យសម្បត្តិរដ្ឋ និងការងារគណនេយ្យ។ ភាពមិនប្រក្រតីមួយចំនួនត្រូវបានបង្ហាញផងដែរនៅក្នុងរបាយការណ៍សវនកម្ម និងត្រូវបានដាក់ជាអនុសាសន៍ដែលត្រូវដោះស្រាយដោយរដ្ឋាភិបាល។

ប្រភព: របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០០៨ របស់ អាជ្ញាធរសវនកម្មជាតិ (NAA)

នេះជាការចេញផ្សាយលើកទីបីនៃលទ្ធផលសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយអាជ្ញាធរសវនកម្មជាតិ (ទោះបីជាយឺតខ្លាំងក៏ដោយ) បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងការអនុវត្តន៍ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រោះវាបានបង្ហាញឱ្យឃើញពីចន្លោះ ប្រហោងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាលពីឆ្នាំសារពើពន្ធមុន និងផ្តល់នូវអនុសាសន៍សម្រាប់ការកែលម្អលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុទាន់ពេលវេលា ពោល គឺយ៉ាងហោចណាស់ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីឆ្នាំសារពើពន្ធ[29] នឹងផ្តល់ដល់សាធារណៈជន អង្គការសង្គមស៊ីវិល និង

[29] ការអនុវត្តល្អកម្រិតអប្បបរមាដែលនៃណាំដោយដៃគូថវិកាអន្តរជាតិគឺគួរតែអនុវត្តសម្រាប់រយៈពេលពីរឆ្នាំ ប៉ុន្តែការអនុវត្តន៍បានល្អនៅក្នុងបណ្តាប្រទេស OCDE តម្រូវឱ្យអនុវត្តក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីឆ្នាំសារពើពន្ធ។

ប្រព័ន្ធផ្សព្វផ្សាយជាមួយនឹងមូលដ្ឋានសម្រាប់ការសង្កេត ការត្រួតពិនិត្យ និងការផ្តល់នូវមតិស្ថាបនាឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើង ក្នុងការអនុវត្តន៍ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានទាន់ពេលវេលា។ របាយការណ៍នេះក៏អាចជួយធ្វើឱ្យរដ្ឋាភិបាលមានការទទួលខុសត្រូវចំពោះការប្រើប្រាស់ថវិការបស់ខ្លួន។ ឧទាហរណ៍ការរៀបចំគម្រោងថវិកា និងការអនុម័តថវិកាឆ្នាំ ២០១៦ និងរបាយការណ៍សវនកម្មសម្រាប់ការអនុវត្តន៍ ថវិកាឆ្នាំ ២០១៤ គួរតែត្រូវបានបោះពុម្ពសម្រាប់ការត្រួតពិនិត្យជាសាធារណៈ និងអង្គនីតិប្បញ្ញត្តិមុនពេលអនុម័តនៃថវិកាឆ្នាំសារពើពន្ធបន្ទាប់ ដោយសមាជិកសភាជាតិ និងឡាយប្រហស្តលេខាដាក់អោយប្រើប្រាស់ដោយព្រះមហាក្សត្រ។

### *តួនាទីរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល / អង្គការក្រៅរដ្ឋាភិបាល*

ឯកសារនៅដំណាក់កាលនេះគ្រាន់តែបង្ហាញនូវ ព័ត៌មានតិចតួចប៉ុណ្ណោះសម្រាប់តែការក្រុមអ្នកតាមដាន។ នេះដោយសារតែពេលវេលាមិនគ្រប់គ្រាន់ក្នុងការប្រមូលព័ត៌មានដែលមានប្រសិទ្ធភាពជាពិសេស អំពីអង្គភាពប្រើប្រាស់ ជូនអាជ្ញាធរគណនេយ្យជាតិនិងសភានីតិបញ្ញត្តិ។ ទោះយ៉ាងណា ការបោះពុម្ពនិងផ្សព្វផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុង ២០០៩ ដល់ ២០១១ ក្នុង ខែមិនាឆ្នាំ ២០១៥ ផ្តល់សញ្ញាអោយយើងឃើញថា ដំណាក់កាលនេះអាចជាដំណាក់កាលសំខាន់មួយនាពេលអនាគត។ ទោះបីជាការរកឃើញនេះ ដូចជាយូរបន្តិចក្តី ក្រុមអ្នកតាមដានអាចធ្វើការវាយតម្លៃថាតើអង្គការនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ បានឆ្លើយតប យ៉ាងសមស្របទៅនឹងការរកឃើញនៃរបាយការណ៍សវនកម្មហើយឬនៅ។ ទាំងនេះជាព័ត៌មានមានប្រយោជន៍ជំនួយដល់ កិច្ចប្រឹងប្រែងកំណែទម្រង់របស់រដ្ឋាភិបាល។

# ៣. ការយល់ដឹងអំពីរចនាសម្ព័ន្ធរបស់ច្បាប់ស្តីពីថវិកាជាតិ និងឯកសារពាក់ព័ន្ធ

## ៣.១ ការយល់ដឹងអំពីរចនាសម្ព័ន្ធរបស់ច្បាប់ថវិកាជាតិ

ជំពូកនេះផ្តល់នូវទិដ្ឋភាពទូទៅនៃរចនាសម្ព័ន្ធនៃច្បាប់ថវិកាបានអនុម័តហើយ[30] បណ្តុំព័ត៌មានដែលមាននៅក្នុងច្បាប់នេះ និងកិច្ចពិភាក្សាអំពីទិដ្ឋភាពទូទៅទាក់ទងនឹងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ និងតារាងបង្ហាញពីធាតុរបស់ចំណូល និងចំណាយទាំងអស់សម្រាប់ការគ្រប់គ្រងកម្រិតជាតិនិងថ្នាក់ក្រោមជាតិ។

ច្បាប់ថវិកាដែលបានអនុម័តដោយរដ្ឋសភាជាតិ គឺជាឯកសារសាធារណៈមួយដែលអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រះរាជកិច្ចផ្លូវការរបស់រដ្ឋាភិបាល[31] និងគេហទំព័ររដ្ឋសភាជាតិ។ ច្បាប់នេះមានផ្នែកសំខាន់ពីរគឺ: ១) អត្ថបទច្បាប់ជាមួយនឹងចំនួនសរុបនៃថវិកា និងតុល្យភាព និង ២) តារាងឧបសម្ព័ន្ធ A, B, C និង D និង (សូមមើលតារាងលម្អិតនៃ A, B, C និង D ក្នុងឧបសម្ព័ន្ធទី៣) ។ ក្នុងការអនុវត្តន៍ជាក់ស្តែង មានការយល់ច្រឡំយ៉ាងច្រើនក្នុងការបកស្រាយ និងការប្រើប្រាស់តួលេខ និងតារាងក្នុងច្បាប់ស្តីពីថវិកា ចេញផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយ អ្នកកាសែត អង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។

### ៣.១.១. ផ្នែក ១: អត្ថបទក្នុងច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ[32]

ផ្នែកនេះចែកចេញជា ៦ ជំពូកសម្រាប់ច្បាប់ថវិកាឆ្នាំ ២០១៥ ដែលរៀបរាប់ដូចខាងក្រោម៖

- ជំពូកទី I: គម្រោងថវិកាថ្នាក់ជាតិ
  អត្ថបទក្នុងជំពូកនេះ បង្ហាញយ៉ាងល្អិតល្អន់នូវកម្រិតចំណូល និងចំណាយ ដែលច្បាប់អនុញ្ញាតឱ្យរដ្ឋាភិបាលប្រមូលយក និងចំណាយ ឱនភាពនិងអតិរេកនៃថវិកាហិរញ្ញវត្ថុ ថវិកាជាប់សន្យានិងការទូទាត់។ អត្ថបទនេះអាចមើលឃើញយ៉ាងច្បាស់ក្នុងតារាងឧបសម្ព័ន្ធនៅក្នុងច្បាប់ថវិកា។
- ជំពូកទី II: ឥណទាន និងលិខិតធានារបស់រដ្ឋាភិបាល
  ផ្នែកនេះកំណត់នូវកំរិតហិរញ្ញប្បទាន សម្រាប់រដ្ឋាភិបាលក្នុងការស្វែងរកការផ្តល់ហិរញ្ញប្បទានពីខាងក្រៅជាពិសេស គឺការផ្តល់ប្រាក់កម្ចីដោយមានលក្ខខណ្ឌសម្បទានដើម្បីបំពេញឱនភាពថវិកាប្រចាំឆ្នាំ។ ចំនួន

[30] ថវិកាលម្អិត រៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អត្ថបទទាំង ៤ លេខដែលបានចេញផ្សាយនៅក្នុងខែមីនា / ខែឧសភា ដែលបានរាយរាប់ក្នុងប្រអប់ X នៅក្នុងជំពូកមុន។ ហេតុផលដែលមិនរួមបញ្ចូលនៃទិដ្ឋភាពទូទៅទៅក្នុងអត្ថបទដែលបានចេញផ្សាយទាំង ៤ នោះ គឺថាព័ត៌មានស្តីពីការអនុវត្តរបស់ពួកគេគឺមិនបានផ្សព្វផ្សាយជាសាធារណៈឡើយ។

[31] រាជកិច្ច ដែលបានបោះពុម្ពជារៀងរាល់សប្តាហ៍ ដែលរួមមានច្បាប់និងបទប្បញ្ញត្តិដែលបានអនុវត្តតាមដោយព្រះបរមរាជវាំង រដ្ឋសភានិង រដ្ឋាភិបាល។ បោះពុម្ពផ្សាយនូវរាជកិច្ចផ្លូវការទាំងនេះ គឺបានកំណត់នៅក្នុងច្បាប់ស្តីពីតួនាទីនិងមុខងាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី (1993) អនុក្រឹត្យលេខ ៤១ លើរចនាសម្ព័ន្ធនិងមុខងារនៃអគ្គនាយកដ្ឋានរាជកិច្ចនិងសេវាកុំព្យូទ័រ (ឆ្នាំ ២០០៤ ដែលស្ថិតនៅក្រោមការិយាល័យនៃក្រុមប្រឹក្សានៃគណៈរដ្ឋមន្ត្រី), សារាចររបស់រដ្ឋាភិបាលលេខ 12 លើកាតព្វកិច្ចក្នុងការបោះពុម្ពរាជកិច្ច (២០០៤), និងសេចក្តីសម្រេចលេខ 55 របស់ការិយាល័យនៃក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការបង្កើតក្រុមការងារគម្រោងកែលម្អ រាជកិច្ចផ្លូវការ។

[32] នេះគឺជាចំណងជើងនៃច្បាប់មួយ; ប៉ុន្តែជាទូទៅពាក្យថា "ច្បាប់ថវិកា " អាចត្រូវបានប្រើជំនួសគ្នាបាន

ទឹកប្រាក់កម្ចីនេះត្រូវបានប្រើជាសិទ្ធិពិសេស (SDR) និងដោយរូបិយប័ណ្ណរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ក្នុងឆ្នាំ ២០១១ ច្បាប់នេះបានអនុម័តអោយរដ្ឋាភិបាល បង្កើតឥណទានថវិកាពិសេសរហូតដល់ចំនួន ៧៥ពាន់លានរៀលសម្រាប់មូលនិធិគាំទ្រ និងការអភិវឌ្ឍវិស័យកសិកម្ម ៣០ពាន់លានរៀលសម្រាប់ជាមូលធនបន្ថែមក្នុងធនាគារអភិវឌ្ឍន៍ជនបទ និង ១០៥ពាន់លានរៀលសម្រាប់មូលនិធិឥណទានជានា ការគាំទ្រ និងការជានាលើប្រាក់កម្ចីពីធនាគារពាណិជ្ជសម្រាប់ឈ្មួញជួញស្រូវអង្ករ។

- ជំពូកទី III: ការបង្កើតពន្ធថ្មីនិងការធ្វើវិសោធនកម្មលើច្បាប់ស្តីពីពន្ធ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ផ្សេងៗទៀតដែលទាក់ទងទៅនឹង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ នៅឆ្នាំ ២០១០ ពន្ធលើអចលនទ្រព្យ (0,១% នៃតម្លៃអចលនទ្រព្យលើសពី ១០០ លានរៀល) ត្រូវបានអនុវត្ត។ នៅក្នុងឆ្នាំ ២០១៣ ច្បាប់ស្តីពីពន្ធប្រថាប់ត្រាត្រូវបានធ្វើវិសោធនកម្ម។ នៅឆ្នាំ ២០១៤ អត្រាពន្ធលើយានយន្តត្រូវបានកែប្រែបន្ទាប់ពីវាត្រូវបានអនុម័តនៅក្នុងច្បាប់ថវិកាឆ្នាំ ២០១០ ហើយនៅឆ្នាំ ២០១៥ អត្រាពន្ធលើប្រាក់បៀវត្សក្នុងច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានធ្វើវិសោធនកម្ម។
- ជំពូកទី IV: ការកែតំរូវដើម្បីបន្ថែមថវិកាទៅក្នុងច្បាប់ថវិកាឆ្នាំ ២០១៤(២០១៤)
  ការកែតំរូវ លើ ថវិកា បន្ថែមដូចបានចែងក្នុងមាត្រាទី ៦១ ក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ អនុញ្ញាតឱ្យរដ្ឋាភិបាលអាចធ្វើសំណើទៅរដ្ឋសភាជាតិ ដើម្បីសុំការកែប្រែគម្រោងថវិកាដែលត្រូវការចាំបាច់។ នៅក្នុងសេចក្តីព្រាងច្បាប់ថវិកាជាតិឆ្នាំ ២០១៥ រដ្ឋាភិបាលបានស្នើឱ្យសភាជាតិអនុម័តលើការសុំបន្ថែមថវិកា ដើម្បីអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោះស្រាយតុល្យភាពនៃសាច់ប្រាក់បុរេប្រទាន ចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ ២០១៤។ មានករណីគួរអោយចាប់អារម្មណ៍ជាច្រើនដែលតំរូវអោយមានថវិកាបន្ថែមក្នុងអំឡុងឆ្នាំសារពើពន្ធ ដែលត្រូវបានស្នើឡើងសម្រាប់ការអនុម័តដោយរដ្ឋសភា។
- ជំពូក V: រដ្ឋបាលថ្នាក់ក្រោមជាតិ
  ផ្នែកនេះ ផ្តោតតាមមាត្រាទី ៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងមាត្រាទី ៣៥ និង ៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុរបស់ការគ្រប់គ្រងថ្នាក់ក្រោមជាតិ(SNA)។ ផ្នែកនេះ បានបញ្ជាក់ពីចំនួនសរុបនៃប្រាក់ចំណូលនិងចំណាយ ដែលអាចទទួលបានរៀងរាល់ឆ្នាំសារពើពន្ធ។ នៅក្នុងឆ្នាំ ២០១៥ ចំនួនប្រាក់ចំណូល និងចំណាយសរុប នៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិគឺ ១.១០៧.១៩៦ លានរៀល។ ជំពូកនេះបង្ហាញពីចំនួនសរុបនៃប្រាក់ចំណូលនិងចំណាយ (ទ្រព្យនិងមូលធន) ដែលអាចទទួលបានក្នុងកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជានៅរាជធានី / ខេត្តស្រុក / ខណ្ឌ / ក្រុងនិងឃុំ / សង្កាត់ ឧបត្ថម្ភធនពីថវិកាថ្នាក់ជាតិ (មើលតារាងទី ២ ខាងក្រោម)។ ថវិកាលម្អិត ដែលបែងចែកជាលក្ខណៈ សេដ្ឋកិច្ច ពោលគឺរួមមាន ជំពូក គណនី និងគណនី នៃនីមួយរាជធានី ខេត្ត ស្រុក ខណ្ឌ ក្រុង និងឃុំសង្កាត់ នឹងចេញជាប្រកាសដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបន្ទាប់ពីមានកិច្ចព្រមព្រៀងជាមួយក្រសួងមហាផ្ទៃ។ ថវិការបស់ខណ្ឌត្រូវបានរួមបញ្ចូលនៅក្នុងថវិការាជធានី ហើយសង្កាត់ត្រូវបានរួមបញ្ចូលនៅក្នុងថវិកាក្រុងនិងរាជធានី។ សាលារាជធានី និងបណ្តាខេត្តអាចទទួលបានប្រាក់ចំណូលបច្ចុប្បន្ន (ប្រាក់ពន្ធនិងមិនមែនពន្ធ) និងសល់ពីនេះត្រូវបានផ្តល់ជូនដោយថវិកាកម្រិតថ្នាក់ជាតិ។ បណ្តាស្រុកនិងក្រុងត្រូវបានអនុញ្ញាតឱ្យប្រមូលតែចំណូលមិនមែនពន្ធ (ទ្រព្យ) តែប៉ុណ្ណោះ។ មូលនិធិឃុំ / សង្កាត់ទាំងអស់ ផ្តល់ហិរញ្ញប្បទានដោយថវិការបស់រដ្ឋាភិបាលថ្នាក់ជាតិ។

- ជំពូក VI: ចំនុចចុងក្រោយដែល ជំពូកនេះលើកឡើងគឺទាក់ទងនឹងភាពបន្ទាន់និង អាទិភាពនៃច្បាប់ថវិកា។

ចំណូល ចំណាយ និងតុល្យភាពថវិកា ការផ្តល់ហិរញ្ញប្បទានថ្នាក់ជាតិ គឺបង្ហាញនៅក្នុងតារាងទី ១ ក្នុងច្បាប់ស្តីពីថវិកា ដែលជាធម្មតាមានលើកឡើងក្នុងពីរ ឬបីទំព័រដំបូងនៃច្បាប់ថវិកា។ តារាងដែលភ្ជាប់ជាមួយនឹងប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ បានផ្តល់នូវទិដ្ឋភាពទូទៅសរុប ហើយវាក៏បានបង្ហាញថាតើ រដ្ឋាភិបាលមានចំណូល គ្រប់គ្រាន់សម្រាប់ការចំណាយដែលរំពឹងទុករបស់ខ្លួននៅក្នុងឆ្នាំដែរឬទេ។ ឧទាហរណ៍តារាង៤ ខាងក្រោមបង្ហាញថាក្នុងឆ្នាំ២០១៥ រដ្ឋាភិបាលបានរំពឹងថានឹងអាចរកចំណូលបាន ២.៧៥២,៦ លានដុល្លារអាមេរិកពីប្រភពក្នុងស្រុក ហើយរំពឹងថានឹងចំណាយថវិកាអស់ ៣.៦០៤,៦ លានដុល្លារអាមេរិកនៅកំរិតថ្នាក់ជាតិ[33] ដោយមិនរាប់បញ្ចូលចំណូលនិងចំណាយក្នុងកម្រិតរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងតារាង ៥ ឡើយ។ ចំនួនខុសគ្នារវាងថវិកាប្រភេទទាំងពីរនេះ គឺជាឱនភាពថវិការំពឹងទុករបស់រដ្ឋាភិបាល ដែលមានចំនួន ៨៥២ លានដុល្លារអាមេរិក។ ឱនភាពនេះ នឹងបំពេញដោយការផ្តល់ហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា ដែលហៅថា "មូលនិធិថវិកាគាំទ្រពីដៃគូ អភិវឌ្ឍន៍" (ចំនួន ៧៤,១ លានដុល្លារអាមេរិក) និង "មូលនិធិវិនិយោគសាធារណៈ" (៩១០,៤ លានដុល្លារសហរដ្ឋអាមេរិក)។ នៅក្នុងច្បាប់ស្តីពីថវិកាឆ្នាំ ២០១៥ ត្រូវបានព្យាករណ៍ទុកថាចំនួន ២៤,៧ លានដុល្លារសហរដ្ឋអាមេរិកពីទុនបម្រុងរបស់រដ្ឋាភិបាលនៅធនាគារកណ្តាល នឹងត្រូវប្រើប្រាស់ដើម្បី បំពេញនូវឱនភាពថវិកានេះ។

**តារាងទី ៤: ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (ថ្នាក់ជាតិ) ឆ្នាំ ២០១៥ ថវិកាជាតិ**

| ប្រតិបត្តិការ/ការបែងចែកថវិកាបំរុងទុកថ្នាក់ជាតិ | ចំនួន | | សមតុល្យ /ហិរញ្ញប្បទាន: អតិរេក (+)/ឱនភាព (-) | |
|---|---|---|---|---|
| | ពាន់លានរៀល | លានដុល្លារអាមេរិក | ពាន់លានរៀល | លានដុល្លារអាមេរិក |
| **I. ប្រាក់ចំណូលក្នុងស្រុក** | **១១.១៤៨.២៣០** | **២.៧៥២,៦** | | |
| ១. ប្រាក់ចំណូលនាពេល បច្ចុប្បន្ន | ១១.០១៤.៦៤៤ | ២.៧១៩,៧ | | |
| ២. ប្រាក់ចំណូលមូលធនក្នុងស្រុក | ១៣៣.៥៨៦ | ៣៣ | | |
| **II. ការចំណាយសរុប** | **១៤.៥៩៨.៦៦១** | **៣.៦០៤,៦** | | |
| ១. ប្រាក់ចំណាយនាពេល បច្ចុប្បន្ន | ៩.២៧៥.១៦១ | ២.២៩០,២ | | |
| ២. ប្រាក់ចំណាយមូលធន (លើកលែងប្រាក់សងបំណុល) | ៥.៣២៣.៥០០ | ១.៣១៤,៤ | | |

[33] រួមបញ្ចូលថវិកាបស់គ្រប់ក្រសួងនិងមន្ទីរ។

| ប្រតិបត្តិការ/ការបែងចែកថវិកាបំរុងទុកថ្នាក់ជាតិ | ចំនួន | | សមតុល្យ /ហិរញ្ញប្បទាន: អតិរេក (+)/ឱនភាព (-) | |
|---|---|---|---|---|
| | ពាន់លានរៀល | លានដុល្លារអាមេរិក | ពាន់លានរៀល | លានដុល្លារអាមេរិក |
| + ហិរញ្ញប្បទានវិនិយោគសាធារណៈ ក្នុងស្រុក | ១.៦៣៦.៥០០ | ៤០៤,១ | | |
| • ថវិកាដែលផ្តល់ដោយមូលនិធិជាតិ | ១.៣៣៦.៥០០ | ៣៣០ | | |
| - គម្រោងវិនិយោគផ្ទាល់ | ១.០១៩.៧០០ | ២៥១,៨ | | |
| - មូលនិធិសមភាគី | ៣១៦.៨០០ | ២៥១,៨ | | |
| • វិនិយោគដោយមូលនិធិថវិកាគាំទ្រដោយ ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ | ៣០០.០០០ | ៧៤,១ | | |
| +ការវិនិយោគហិរញ្ញប្បទានសាធារណៈខាងក្រៅ | ៣.៦៨៧.០០០ | ៩១០,៤ | | |
| **អតិរេកថវិកាបច្ចុប្បន្ន(I.១ – II.១)** | | | ១.៧៣៩.៤៨៣ | ៤២៩,៥ |
| **ឱនភាពថវិកាទូទៅ (I-II)** | | | -៣.៤៥០.៤៣១ | -៨៥២ |
| **III. ការផ្តល់ហិរញ្ញប្បទាន** | | | ៣.៤៥០.៤៣១ | ៨៥២ |
| ១. ផ្តល់ហិរញ្ញប្បទានពីខាងក្រៅ | | | ៣.៥៥០.៤៣១ | ៨៧៦,៦ |
| - មូលនិធិគាំទ្រថវិកាពីដៃគូអភិវឌ្ឍន៍ | | | ៣០០.០០០ | ៧៤.១ |
| - មូលនិធិវិនិយោគសាធារណៈពីខាងក្រៅ | | | ៣.៦៨៧.០០០ | ៩១០,៤ |
| - ការទូទាត់ប្រាក់បំណុល | | | -៤៣៦.៥៦៨ | -១០៧,៨ |
| ២. ការធ្វើហិរញ្ញប្បទានក្នុងស្រុក | | | -១០០.០០១ | -២៤,៧ |
| -ប្រាក់បញ្ញើរដ្ឋាភិបាល (នៅធនាគារជាតិ) | | | -១០០.០០១ | -២៤,៧ |

ប្រភពពី: ច្បាប់ថវិកាជាតិឆ្នាំ ២០១៥

តារាងទី ៥: ការបែងចែកថវិកាបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៥

| ការបែងចែកថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | រាជធានី / ខេត្ត | ស្រុក /សាលាក្រុង | ឃុំ / សង្កាត់ |
|---|---|---|---|
| ចំណូលសរុប | ៧៥៣.៩៤០ | ៨១.៣០២ | ២៧១.៩៥៤ |
| ចំណូលសកម្មសរុប | ៦៦០.៦៩៩ | ៣.៦០១ | |
| ចំណូលពន្ធ | ៦៣២.៣០០ | | |
| ចំណូលមិនមែនពន្ធ | ២៨.៣៩៩ | ៣.៦០១ | |
| ប្រាក់ចំណូលឧបត្ថម្ភធនពីថ្នាក់ជាតិសរុប | ៩៣.២៤១ | ៧៧.៧០១ | ២៧១.៩៥៤ |
| ប្រាក់ចំណូលរបស់សង្កាត់ក្រោមខេត្តសរុប | | | ១៨.០៧៧,៥៣ |
| ប្រាក់ចំណូលរបស់សង្កាត់ក្រោមរដ្ឋធានីសរុប | | | ២១.៣២១,៩៧ |
| ប្រាក់ចំណូលរបស់ឃុំសរុប | | | ២៣២.៥៥៤,៥ |
| ប្រាក់ចំណាយសរុប | ៧៥៣.៤៤០ | ៨១.៣០២ | ២៧១.៩៥៤ |
| ចំណាយសកម្មសរុប | ៦២១.០៧៩ | ៨១.៣០២ | |
| ចំណាយមូលធនសរុប | ១៣២.៨៦១ | | |
| ប្រាក់ចំណាយរបស់សង្កាត់ក្រោមខេត្តសរុប | | | ១៨.០៧៧,៥៣ |
| ប្រាក់ចំណាយរបស់សង្កាត់ក្រោមរដ្ឋធានី | | | ២១.៣២១,៩៧ |
| ប្រាក់ចំណាយរបស់ឃុំសរុប | | | ២៣២.៥៥៤,៥ |

ប្រភពពី: ច្បាប់ថវិកាជាតិឆ្នាំ ២០១៥

## ៣.១.២- ផ្នែកទី II: តារាងឧបសម្ព័ន្ធ A, B, C និង D ដែលភ្ជាប់ទៅនឹងច្បាប់ថវិកា

តាមកត់សម្គាល់បង្ហាញថាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបែងចែកថវិកាជាបីថ្នាក់: តាមរដ្ឋបាល តាមសេដ្ឋកិច្ច និងតាមកម្មវិធី។ ចំណាត់ថ្នាក់ថវិកាតាមសេដ្ឋកិច្ច ជាចំណាត់ថ្នាក់ចម្បងសម្រាប់ការគុណតូរនិងការអនុវត្តន៍ នៃច្បាប់ស្តីពីថវិកានិងថវិកានៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ច្បាប់ថវិកាបង្ហាញពីប្រាក់ចំណូលទាំងអស់ដែលបានគ្រោងទុករបស់រដ្ឋាភិបាល (តាមប្រភព) និងការចំណាយ (តាមក្រសួង) សម្រាប់ឆ្នាំសារពើពន្ធនីមួយៗ។ ប្រាក់ចំណូល និងការចំណាយរបស់រដ្ឋាភិបាលក្នុងច្បាប់ស្តីពីថវិកាឆ្នាំ ២០១៥ ត្រូវបានបង្ហាញក្នុងតារាងប្រាំដូចខាងក្រោម:

- ***តារាង A: ចំណូលថវិកាថ្នាក់ជាតិ*** តារាងនេះបង្ហាញលម្អិត នៃប្រភពប្រាក់ចំណូលរដ្ឋ/ថ្នាក់ជាតិ។ វាបង្ហាញចំណូលថវិកាសរុប (ប្រាក់ចំណូលទាំងចរន្តនិងមូលធន ក៏ដូចជាប្រាក់ចំណូលពីប្រភពក្នុងស្រុកនិងខាងក្រៅស្រុក)។ តារាងនេះរាយនូវប្រាក់ចំណូលដែលរំពឹងទុក ចេញជាក្រុម ជំពូក គណនី និងគណនីរង ដែលផ្តោតលើ "ការចាត់ថ្នាក់ថវិកាតាមសេដ្ឋកិច្ច"[34]។ តួលេខក្នុងតារាងនេះ គិតជាលានរៀល។ ក្នុងច្បាប់

[34] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចេញប្រកាសក្នុងការអនុវត្តន៍ចំណាត់ថ្នាក់សេដ្ឋកិច្ចថ្មី សម្រាប់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងឆ្នាំ ២០១៣។ ប្រកាសនេះអាចទាញយកបានពីគេហទំព័ររបស់អគ្គនាយកដ្ឋានរតនាគារជាតិ www.treasury.gov.kh

ស្តីពីថវិកាឆ្នាំ ២០១៥ តារាង A រួមមានបីទំព័រ ហើយត្រូវបានពិភាក្សាបន្ថែមនៅក្នុងផ្នែក ៤.២ នៃសៀវភៅនេះ។

- ***តារាង B: ចំណាយថវិកាថ្នាក់ជាតិ*** តារាងនេះបង្ហាញនូវចំណាយថវិកាជាទូទៅរបស់រដ្ឋ ថ្នាក់ជាតិរួមបញ្ចូលទាំងថវិកាចរន្ត និងមូលធន។ នៅក្នុងច្បាប់ថវិកាឆ្នាំ ២០១៥ តារាងនេះមាន ៣ ទំព័រ។ តារាងនេះរួមមានព័ត៌មានចរន្តថវិការបស់រដ្ឋាភិបាល ចាត់ថ្នាក់តាមប្រភេទ និងក្រសួង ព្រមទាំងបង្ហាញនូវចំណាយពីរផ្សេងគ្នា រវាងរដ្ឋបាលកណ្តាលនិងរដ្ឋបាលខេត្ត/ក្រុង និងថវិកាមូលធនសម្រាប់ក្រសួងមួយចំនួន។ តារាងនេះមាន ១៣ បន្ទាត់ដែលបង្កើតចេញជាចំណាត់ថ្នាក់ជា "ការចំណាយមិនទាន់បែងចែកជាមួយនឹងការចំណាយបានត្រៀមទុក[35]" ។ តារាង B ត្រូវបានពិភាក្សាបន្ថែមទៀតនៅក្នុងផ្នែក ៤.៣។
- ***តារាង C១: ចំណាយមូលធនហិរញ្ញប្បទានពីខាងក្រៅ*** តារាងនេះរៀបរាប់លម្អិតអំពី ចំណាយហិរញ្ញប្បទានមូលធននៃថវិកាទូទៅរបស់រដ្ឋ/ថ្នាក់ជាតិ។ តារាងទាំងនេះបានរាយគ្រប់គម្រោងទាំងអស់របស់ក្រសួងផ្សេងៗគ្នា។ គម្រោងទាំងអស់ត្រូវបានរាយតាមលំដាប់លេខរបស់គម្រោង និងថវិកាសម្រាប់គម្រោងនីមួយៗ ហើយត្រូវបានបង្ហាញដោយចំណាយទាំងអស់របស់គម្រោងប្រចាំឆ្នាំ និងសម្រាប់ពេលបីឆ្នាំទៅមុខទៀត។ គម្រោងទាំងនោះត្រូវបានចាត់ថ្នាក់ជាពីរប្រភេទ: "មានហិរញ្ញប្បទាន" និង "មិនមានហិរញ្ញប្បទាន/ ស្វែងរកការផ្តល់ហិរញ្ញប្បទាន»។ ដោយសារតែតារាងនេះផ្តល់ថវិកាសរុបនិងឈ្មោះនៃគម្រោងវិនិយោគទាំងអស់ វាមានដល់ទៅ ១៣ ទំព័រក្នុងច្បាប់ស្តីពីថវិកាឆ្នាំ ២០១៥ ។ តារាង C១ បង្ហាញតួលេខគិតជាលានរៀល។ តារាងនេះត្រូវបានពិភាក្សានិងលើកឡើងនៅក្នុងផ្នែក ៤.៤ នេះ។
- ***តារាង C២: ចំណាយមូលធនហិរញ្ញប្បទានពីខាងក្រៅ កម្មវិធីឥណទាន និងថវិកាជាប់សន្យា*** មួយទំព័រដែល សង្ខេបនៃដើមទុនវិនិយោគសរុបសម្រាប់ក្រសួងនីមួយៗក្នុងឯកតាជាលានរៀល និងមិនមានបរិយាយបន្ថែមក្នុងផ្នែកផ្សេងទៀតទេ ក្នុងសៀវភៅណែនាំនេះ។ តាមជួរឈរតារាងនេះបំបែកថវិកាតាមក្រសួង និងវិស័យនីមួយៗ។ តាមជួរផ្តេក វាបង្ហាញអំពីកម្មវិធីឥណទាន ឥណទានជាប់សន្យា ដែលរំពឹងទុកថានឹងទទួលបាន មូលធនគម្រោង ពីសំណាក់ម្ចាស់ជំនួយ និងគម្រោងតាមរយៈហិរញ្ញប្បទាន និងគម្រោងមិនមានហិរញ្ញប្បទាន/ស្វែងរកការផ្តល់ហិរញ្ញប្បទាន។ ថវិកា ឥណទានជាប់សន្យានេះ បែងចែកជា ៣ ប្រភេទផ្សេងៗគ្នារួមមាន: i) កំពុងបន្ត ii) យល់ព្រមហើយ និង iii) កំពុងតែពិភាក្សា។ ថវិកាដែលបានអនុម័តរួច គឺជាការបូកនៃចំនួនទឹកប្រាក់នៃការចំណាយគម្រោងដោយមានហិរញ្ញប្បទាន និងភាគរយប៉ាន់ប្រមាណ (ឧទាហរណ៍គឺ ៣០%) នៃចំណាយគម្រោងដែលនឹងត្រូវស្វែងរកហិរញ្ញប្បទាន ឬមិនមានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍/អ្នកផ្តល់ជំនួយ [ថវិកាជាប់សន្យាស្មើរ (១) បូក (២) គុណនឹង ៣០%] របស់ក្រសួងនីមួយៗដូចក្នុងតារាង C១ ។ នៅក្នុងតារាងដដែលនេះ កម្មវិធីឥណទាន គឺជាការបូកចូលគ្នានៃគម្រោងចំណាយថវិកាទាំងអស់រួមមាន គម្រោងចំណាយ ដែលមានហិរញ្ញប្បទាន និងចំណាយគម្រោងមិនមានហិរញ្ញប្បទាន/ ស្វែងរកការផ្តល់ហិរញ្ញប្បទានរបស់ក្រសួងនីមួយៗដូចក្នុងតារាង C១ [(១) បូកនឹង (២)] ។

---

[35] នៅក្នុងច្បាប់ថវិកាឆ្នាំ ២០១៥ ចំណងជើងនេះត្រូវបានបន្ថែមដើម្បីជៀសវាងការបកស្រាយខុសគ្នាលើការចំណាយដែលបានរាយនៅក្រោម ចំណាត់ថ្នាក់ក្រុមនេះនិងជាបានស្នើដោយដៃគូអភិវឌ្ឍន៍ជាច្រើនដែលគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កាលពីមុនវាត្រូវបានគេដែលមានចំណងជើងថា "ការចំណាយមិនទាន់បែងចែក" ដែលវិវត្តពី "ការចំណាយដែលមិនរំពឹងទុក" ចាប់តាំងពីឆ្នាំ ១៩៩៦ មក ។

- ***តារាង D: ចំណាយថវិកាមូលធនថ្នាក់ជាតិ*** តារាងនេះរៀបរាប់អំពី ចំណាយឥណទានមូលធន របស់ រដ្ឋ/ថ្នាក់ជាតិដែលជាប់សន្យាឥណទាន និងឥណទានទូទាត់។ តារាងនេះបង្ហាញតួលេខចំណាយមូលធនសរុប គិតឯកតាជាលានរៀល។ តាមជួរឈរ តារាងនេះបំបែកថវិកាតាមក្រសួងនិងវិស័យនីមួយៗ។ តាមជួរផ្តេក វាបង្ហាញអំពីឥណទាននិងការទូទាត់ ជាប់សន្យា ចំណាយថវិកាមូលធនក្នុងស្រុក បែងចែកតាមប្រភពរបស់ជំនួយ (ឥណទានជាប់សន្យា ស្មើនឹង ឥណទានទូទាត់: គម្រោងវិនិយោគ មូលនិធិសមភាគីសម្រាប់ការវិនិយោគសាធារណៈ និងមូលនិធិថវិកាគាំទ្រ), ហិរញ្ញប្បទានចំណាយថវិកាមូលធនពីប្រភពខាងក្រៅ បែងចែកថែមទៀតទៅជា ឥណទានជាប់សន្យា ស្មើរនឹង ឥណទានទូទាត់, និងការទូទាត់ប្រាក់កម្ចី (ឥណទានជាប់សន្យា ស្មើរនឹង ឥណទានទូទាត់)។ ក្នុងច្បាប់ថវិកាឆ្នាំ ២០១៥ តារាង D សរសេរចេញជា មួយទំព័រ និងមិនធ្វើការពិភាក្សាបន្ថែមក្នុងផ្នែកណាមួយផ្សេងទៀតទេ នៅក្នុងសៀវភៅណែនាំនេះ។

### A. តារាង A: ចំណូលថវិកាថ្នាក់ជាតិ

ប្រើប្រាស់ច្បាប់ថវិកាឆ្នាំ ២០១៥ ជាឧទាហរណ៍មួយ ផ្នែកនេះពន្យល់អំពីប្រភេទរបស់ប្រាក់ចំណូលដែលបានចុះបញ្ជីនៅក្នុងច្បាប់ថវិកាជាតិ។ ច្បាប់ថវិកាឆ្នាំ២០១៥ ត្រូវបានគេជ្រើសរើសជាឧទាហរណ៍ ដោយ សារតែមានការផ្លាស់ប្តូររចនាសម្ព័ន្ធ និងការចាត់ថ្នាក់ និងកូដនៃគណនីប្រាក់ចំណូល ក្នុងតារាង A ។ ហេតុនេះហើយ ទំរង់បែបបទនេះអាចជា ឯកសារយោងដ៏មានប្រយោជន៍ ពេលដែលពិនិត្យឡើងវិញលើ សេចក្តីព្រាងច្បាប់ស្តីពីថវិកានិងច្បាប់ថវិកានាពេលអនាគត ដែលនឹងអាចមានទំរង់បែបបទដូចគ្នា។ ការផ្លាស់ប្តូររចនាសម្ព័ន្ធនៃតារាង A នេះអាចនឹងធ្វើឱ្យវាមានការលំបាកក្នុងការប្រៀបធៀបនិន្នាការនៃប្រាក់ចំណូលពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសជាមួយនឹងច្បាប់ស្តីពីថវិកាប្រចាំឆ្នាំ រហូតដល់ទៅឆ្នាំ ២០១៤។ យោងលើភាព ស្មុគស្មាញនៃរចនាសម្ព័ន្ធប្រាក់ចំណូលនេះ សៀវភៅណែនាំនេះ អាចនឹងកំណត់អត្តសញ្ញាណនិងបង្ហាញពីការផ្លាស់ប្តូរលើរចនាសម្ព័ន្ធនិងភាពខុសគ្នានៅក្នុងឆ្នាំ ២០១៥ និងឆ្នាំមុនៗ។ ភាពខុសគ្នាបែបនេះអាចត្រូវបានពន្យល់ឬបង្ហាញនៅក្នុងការវិភាគគម្រោងថវិកាឆ្នាំ ២០១៥។

ដោយផ្អែកលើការបែងចែកថវិកាបែបសេដ្ឋកិច្ច គេរំពឹងទុកថាតួលេខចំណូល និងចំណាយនឹងត្រូវបានបែងចែកយ៉ាងច្បាស់លាស់ ជាប្រភេទ ក្រុម ប្រភេទ ជំពូក គណនី និងគណនីរង។

ច្បាប់ថវិកាឆ្នាំ ២០១៥ បានប៉ាន់ប្រមាណថា ប្រាក់ចំណូលថវិកាសរុបរបស់រដ្ឋាភិបាលក្នុងឆ្នាំ ២០១៥ គឺប្រហែលជា ១៥.១៣៥.២៣០លានរៀល (៣.៧៣៧,១លានដុល្លារអាមេរិក) ក្នុងនោះមានប្រាក់ចំណូលកត់ត្រាតាមរយៈរតនាគារជាតិមានចំនួន ១១.៤៤៨.២៣០លានរៀល (២.៨២៦,៧ លានដុល្លារអាមេរិក)។ រតនាគារជាតិ[36] បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចុះបញ្ជី និងការគ្រប់គ្រងប្រាក់ចំណូលទាំងអស់នេះ។ ក្នុងតារាង A នៃថវិកាជាតិ អ្នកអាចមើលឃើញថា ប្រាក់ចំណូលភាគច្រើនរបស់រដ្ឋាភិបាលត្រូវបានកត់ត្រាដោយរតនាគារជាតិ (៧៥,៦ ភាគរយនៅក្នុងច្បាប់ថវិកាឆ្នាំ២០១៥ សូមមើលបន្ទាត់ I)។ ប្រាក់ចំណូល

[36] រតនាគារជាតិគឺអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាបេឡា និង គណនេយ្យករសាធារណៈ តែមួយគត់របស់រដ្ឋាភិបាល សម្រាប់ព័ត៌មានបន្ថែម, សូមមើលគេហទំព័រ: http://www.treasury.gov.kh/

របស់រដ្ឋាភិបាលដែលមិនបានកត់ត្រាដោយរតនាគារជាតិអាចត្រូវបានរកឃើញ នៅក្នុងបន្ទាត់ II និងរួមបញ្ចូលប្រាក់ចំណូលពីប្រភពខាងក្រៅៈ មូលនិធិវិនិយោគពីខាងក្រៅ គាំទ្រដោយដៃគូអភិវឌ្ឍន៍ទ្វេភាគី និងប្រាក់កម្ចីពហុភាគីពីក្រៅប្រទេស។

ដូចបានឃើញនៅក្នុងបន្ទាត់ទីប្រាំ/ ជំពូកទី ៧០ ប្រាក់ចំណូលភាគច្រើនរបស់រដ្ឋាភិបាល (៦៣,១ ភាគរយ / ប្រភេទទី១) បានមកពីការប្រមូលពន្ធ[37]។ ពន្ធប្រមូលបានក្នុងស្រុកមានប្រមាណ ៥០,១ ភាគរយ (ជំពូកទី ៧០) នៃប្រាក់ចំណូលសរុបរបស់រដ្ឋាភិបាល ខណៈពេលដែលពន្ធនាំចូល/ចំណូលបានមកពីពាណិជ្ជកម្មអន្តរជាតិ មានចំនួន ១៣ ភាគរយនៃប្រាក់ចំណូលសរុប (ជំពូកទី ៧១)។ ពន្ធប្រមូលបានក្នុងស្រុក បានបំបែកជាពន្ធផ្ទាល់ (រួមមាន ពន្ធប្រាក់ចំណេញ ពន្ធប្រាក់ខែ ពន្ធលើអចលនទ្រព្យ។ល។) ពន្ធប្រយោល (ពន្ធលើការលក់ ពន្ធលើអាករបន្ថែម ។ល។) ពន្ធលើទំនិញពិសេស (ប្រាក់ពន្ធ) ពន្ធលើការសេវាកម្មពិសេស ពន្ធលើទំនិញសេវាកម្មនិងសកម្មភាពផ្សេងៗ និងចំណូលពន្ធដទៃទៀត។

*ពន្ធផ្ទាល់: គណនីលេខ ៧០០១ ដែលមានចំនួន ៥១០,៨ លានដុល្លារអាមេរិក ឬប្រហែល ១៣,៧% នៃចំណូលសរុប និង ២៧,៣% នៃចំណូលពន្ធក្នុងស្រុកសរុប។ ទំហំចំណូលពន្ធផ្ទាល់ប្រមូលបាន ក្នុងប្រទេសកម្ពុជា គឺនៅមានកំរិតតិចជាងប្រទេសដទៃ[38] ទៀតក្នុងតំបន់។*

*ពន្ធលើប្រាក់ចំណេញ* គឺបានមកពីសហគ្រាសសាធារណៈ និងក្រុមហ៊ុនឯកជន (គណនីរងលេខ ៧០០១២) ហើយមានចំនួនជាង ៣៨៦,៤ ដុល្លារអាមេរិក ក្នុងច្បាប់ថវិកាឆ្នាំ ២០១៥។ ពន្ធលើប្រាក់ចំណេញ មានភាពខុសគ្នាតាមវិស័យ និងការលើកលែងពន្ធអាចផ្តល់អោយបានដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់គម្រោងវិនិយោគខ្លះៗដែល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាទទួលស្គាល់និង អនុម័ត។ អត្រាពន្ធលើប្រាក់ចំពេញមានដូចជា[39]៖

- ២០% សម្រាប់សហគ្រាស (៣០% សម្រាប់ក្រុមហ៊ុនរុករកប្រេងនិងឧស្ម័នធម្មជាតិ ឬ ធនធានធម្មជាតិ;
- ៩% ចំពោះ "គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" អនុម័តដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់រយៈពេល ៥ ឆ្នាំ; និង
- ០% សម្រាប់ "គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" ក្នុងរយៈពេលកំណត់ដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា[40]។

*ពន្ធលើប្រាក់ខែ* (ឬក៏ពន្ធលើប្រាក់ចំណូល) គឺជាគណនីរងលេខ ៧០០១៣ ហើយមានចំនួន ៩៥ លានដុល្លារក្នុងច្បាប់ថវិកាឆ្នាំ ២០១៥។ ចំណាយពន្ធនេះនាយកដិក នឹងកាត់ចេញពីប្រាក់ខែរបស់បុគ្គលិក និងប្រមូលសរុបប្រចាំខែដើម្បីបង់ទៅកាន់អគ្គនាយកដ្ឋានពន្ធដារ។ ពន្ធលើប្រាក់ចំណូលគិតទៅលើប្រាក់ឈ្នួល

[37] សូមមើលជំពូកទីពីរនៅក្នុងការរ៉ុន (២០០៩) សម្រាប់ព័ត៌មានបន្ថែមស្តីពីប្រព័ន្ធពន្ធដាររបស់ប្រទេសកម្ពុជា។

[38] សូមមើល ធនាគារពិភពលោក (២០១៤)។ បច្ចុប្បន្នភាពនៃសេដ្ឋកិច្ចកម្ពុជា។

[39] សូមមើលជំពូកទីពីរ ក្នុងការរ៉ុន (២០០៩)

[40] ធនាគារពិភពលោក ឆ្នាំ ២០០៩ (ទំព័រទី៨៧) សំគាល់ឃើញថា រាជរដ្ឋាភិបាលកម្ពុជា វាយតម្លៃលើចំណាយអនុញ្ញាតពន្ធបច្ចុប្បន្ន ថាមានប្រហែល ជា ៦% នៃផលិតផលក្នុងស្រុកសរុប ដែលប្រហែលជា ៥៥% នៃចំណូលសរុបរាជរដ្ឋាភិបាលអាចប្រមូលបាន។

ប្រាក់រង្វាន់ ប្រាក់ថែមម៉ោង អត្ថប្រយោជន៍ បន្ថែម និងអត្ថប្រយោជន៍ផ្សេងៗទៀត។ តារាងទី ៦ ខាងក្រោម បង្ហាញពីអត្រាពន្ធលើប្រាក់ចំណូល។

**តារាងទី ៦: អត្រាពន្ធដែលបានអនុម័តក្នុងច្បាប់ថវិកាឆ្នាំ ២០១៥ (ជំពូក ៣)**

| ចំណូលជាប់ពន្ធប្រចាំខែ | | | អត្រាពន្ធ |
|---|---|---|---|
| ចាប់ពី 0 រៀល | រហូតដល់ | ៨00.000 រៀល | 0% |
| ចាប់ពី ៨00.00១ រៀល | រហូតដល់ | ១.២៥0.000 រៀល | ៥% |
| ចាប់ពី ១.២៥0.00១ រៀល | រហូតដល់ | ៨.៥00.000 រៀល | ១0% |
| ចាប់ពី ៨.៥00.000 រៀល | រហូតដល់ | ១២.៥000.000 រៀល | ១៥% |
| | | លើសពី ១២.៥00.000 រៀល | ២0% |

ប្រភព: ច្បាប់ថវិកាឆ្នាំ ២០១៥

***ពន្ធប្រយោល***: គណនីលេខ ៧០០២ ដែលមានចំនួន ៨៤៤,៤ លានដុល្លារអាមេរិក ឬប្រហែលជា ២២,៦% នៃចំណូលសរុប និង ៤៥,១% នៅចំណូលពន្ធក្នុងស្រុកសរុប។

***ពន្ធតម្លៃបន្ថែម*** (គណនីរងលេខ ៧០០២២ ៧០០២៥ ៧០០២៦ និង ៧០០២៧) គឺជាប្រភពចំណូលដ៏សំខាន់មួយ របស់រដ្ឋាភិបាល ដែលមានចំនួន ៨៣៦,៣ ដុល្លារអាមេរិក ឬប្រហែលជា ២២,៤% នៃចំណូលសរុប (ឬ ៤៥% នៃចំណូលពន្ធសរុប) ក្នុងច្បាប់ថវិកាឆ្នាំ ២០១៥។ វាជាពន្ធដែលរដ្ឋាភិបាលប្រមូលបានច្រើនជាងគេមកដល់ពេលនេះ។ ពន្ធតម្លៃបន្ថែម គឺបង់ដោយក្រុមហ៊ុនផ្គត់ផ្គង់ទំនិញ និងផ្តល់សេវាកម្ម ដែលអ្នកប្រើប្រាស់ចុងក្រោយជាអ្នកបង់។ ពន្ធតម្លៃបន្ថែមនេះ អនុវត្តសម្រាប់ក្រុមហ៊ុនដែលមានចំណូលប្រចាំឆ្នាំចាប់ពី ៥០០ លានរៀលសម្រាប់ការផ្គត់ផ្គង់ទំនិញ និង ចំណូលប្រចាំឆ្នាំចាប់ពី ២៥០ លានរៀល សម្រាប់ការផ្តល់សេវា និង ១២៥ លានរៀលចំពោះក្រុមហ៊ុនជាប់កិច្ចសន្យាជាមួយនឹងរដ្ឋាភិបាល។ អត្រាពន្ធបន្ថែមនេះមានចំនួន ១០% លើគ្រប់ប្រភេទទំនិញ ឬសេវាទាំងអស់ លើកលែងតែប្រភេទទំនិញដែល មានការលើកលែង។

***ពន្ធអាករលើទំនិញនិងសេវាពិសេស*** (គណនីលេខ ៧០០៣) គឺជាប្រភពចំណូលដ៏សំខាន់មួយដែររបស់រដ្ឋាភិបាល ដែល មានចំនួន ៤៨២,៣ លានដុល្លារអាមេរិក ឬប្រហែលជា ១២,៩% នៃចំណូលពន្ធសរុប (២៥,៧% នៃចំណូលពន្ធក្នុងស្រុក) ក្នុងឆ្នាំ ២០១៥។

***ពន្ធលើសេវាកម្មកំណត់/ពិសេស*** (គណនីលេខ ៧០០៤) រួមមានពន្ធលើកាស៊ីណូ និងឆ្នោតផ្សេងៗ។ ចំនួនសរុបគឺមានតិចតួច គឺត្រឹមតែ ២៣,៥ លានដុល្លារអាមេរិក ឬប្រហែល ០,៦% នៃចំណូលសរុប និង ១,៣% នៃចំណូលពន្ធក្នុងស្រុក។

***ចំណូលពីពាណិជកម្មអន្តរជាតិ*** (សូមមើលជំពូកទី ៧១) ដែលមានចំនួន ៤៨៤,១ លានដុល្លារអាមេរិក ឬប្រហែលជា ១៣% នៃចំណូលសរុប។ វាជាប្រភពចំណូលសំខាន់មួយទៀតសម្រាប់រាជរដ្ឋាភិបាល ក្នុងឆ្នាំ ២០១៥។ ពន្ធទាំងនេះប្រមូលដោយអគ្គនាយកដ្ឋានពន្ធដារ និងពន្ធគយ[41] នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ពន្ធនាំចូលនិងពន្ធគយគឺជាចំណូលសំខាន់ជាងគេនៅក្នុងផ្នែកនេះជាមួយនឹងចំនួន ៤១២,៧ លានដុល្លារ ឬប្រហែលជា ១១%នៃចំណូលសរុបដែលរំពឹងទុកថា នឹងប្រមូលបានក្នុងឆ្នាំ ២០១៥។

នៅពេលដែលទំនិញដឹកមកដល់ព្រំប្រទល់ប្រទេសកម្ពុជា មន្ត្រីគយនិងពិនិត្យប្រភេទ និងអត្រាពន្ធផ្អែកលើប្រភេទទំនិញនោះ។ ពន្ធលើការនាំចូលត្រូវបង់ជាមុនសិន មុននឹងអនុញ្ញាតអោយបញ្ចេញពីមន្ទីរគយ លើកលែងតែទំនិញដែលមានឯកសិទ្ធិពិសេសយោងទៅតាមច្បាប់និងបទប្បញ្ញត្តិ, ដែលពន្ធគយរបស់ពួកគេត្រូវបានលើកលែង។ អត្រាពន្ធទាំងអស់មាន:

- 0 ភាគរយសម្រាប់ទំនិញ ដូចជាវត្ថុធាតុដើមសម្រាប់វិជ្ជសាស្ត្រ និងការអប់រំ
- ៧ ភាគរយសម្រាប់ទំនិញមិនទាន់សំរេច និង វត្ថុធាតុដើម
- ១៥ ភាគរយសម្រាប់ទំនិញមូលធន ម៉ាស៊ីន និងឧបករណ៍ ដែលវត្ថុធាតុដើមមានស្រាប់ក្នុងស្រុក
- ៣៥ ភាគរយសម្រាប់ផលិតផលសំរេច ស្រាបៀរ ផលិតផលប្រេងឥន្ធនៈ យានយន្ត និងដែកនិងត្បូងមានតម្លៃ

***ចំណូលមិនមែនពន្ធ*** (សូមមើលផ្នែកទី២) ជាគោលដៅ ដែលមានសារៈសំខាន់សម្រាប់ការប្រមូលចំណូលមិនមែនពន្ធក្នុងឆ្នាំ២០១៥ ដែលមានចំនួន ៣៦២ លានដុល្លារអាមេរិក និងបែងចែកចំណូលថវិកាជា ៦ ជំពូក។ ជំពូកទាំង ៦ នេះរួមមាន ចំណូលបានពីអចលនទ្រព្យ ចំណូលពីការលក់ និងជួល អចលនទ្រព្យ និងសេវា ចំណូលមកពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម ជំនួយឧបត្ថម្ភធនឥតសំណង ប្រាក់ចំណូលហិរញ្ញវត្ថុ និងប្រាក់ចំណូលផ្សេងៗទៀត និងចំណូលពិសេស។ ចំណូលពីការលក់និងជួលអចលនទ្រព្យ និងសេវាកម្ម បានផ្តល់នូវចំណូលមិនមែនពន្ធច្រើនជាងគេ រហូតដល់ ៣០៩,៩ ដុល្លារអាមេរិក ឬក៏ស្មើនឹង ៨,៣% នៃចំណូលសរុប។ ចំណូលបានពីការជួលអចលនទ្រព្យរបស់រដ្ឋ ច្រើនតែបានពី ការជួលដី និងដីសម្បទាន ដែលមានចំនួនតិចតួចត្រឹមតែ ២៨ លានដុល្លារអាមេរិក ឬក៏ស្មើនឹង ០,៨% នៃចំណូលសរុប។ ចំណូលនេះភាគច្រើនបង់ជូនរដ្ឋាភិបាលលើការ នេសាទ ព្រៃឈើ សម្បទានការរុករករ៉ែ និងប្រេង និងការជួលដីទំនេរ (តែដីប៉ុណ្ណោះ)។

ចំណូលបានពីសហគ្រាសសាធារណៈ ប្រតិបត្តិការរដ្ឋបាល និងសេវាកម្ម (ដើម្បីប្រាក់ចំណេញ) ក្នុងគណនីលេខ ៧៣០០ និងចំណូលពីការគ្រប់គ្រងរដ្ឋបាលក្នុងគណនីលេខ ៧៣០២ គឺជាប្រភពចំណូលធំៗពីររបស់ចំណូលពីការលក់និងជួលនៃអចលនទ្រព្យ និងសេវាកម្ម។ ប្រភពចំណូលចំបងសម្រាប់គណនីលេខ ៧៣០០ គឺបានពីអាកាសចរណ៍ស៊ីវិល សកម្មភាពទាក់ទងនឹងទេសចរណ៍ សកម្មភាពទាក់ទងនឹងវប្បធម៌

[41] សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅគេហទំព័រ: http://www.customs.gov.kh/។ អត្រាខ្លះរបស់ពន្ធទាំងនោះ គិតផ្អែកលើកិច្ចសន្យារបស់រដ្ឋាភិបាល ជាមួយនឹង អង្គការពាណិជ្ជកម្មពិភពលោក និង តំបន់ពាណិជ្ជកម្មសេរីរបស់អាស៊ាន។

និង ប្រៃសណីយ៍និងទូរគមនាគមន៍[42]។ សម្រាប់គណនី លេខ ៧៣០២ អ្នកនឹងមើលឃើញថា "ពន្ធលើស្ថានទូត(លិខិតឆ្លងដែននិងថ្លៃសេវាទិដ្ឋាការ)" គឺជាកត្តារួមចំណែកធំមួយទៅក្នុងប្រភេទចំណូលនេះ ដែលរំពឹងថានឹងបាន ១៣០,៩ លានដុល្លារសហរដ្ឋអាមេរិក (គណនីរងលេខ ៧៣០២១) នៅក្នុងឆ្នាំ ២០១៥ នេះជាមួយនឹង "ចំណូលពីការត្រួតពិនិត្យគុណភាពនិងស្តង់ដារផលិតផល" ដែលមានចំនួន ២៣,៦លានដុល្លារអាមេរិក (គណនីរងលេខ ៧៣០២៧)។

ចំពោះចំណូលមូលធនតាមរយៈរតនាគារជាតិ ក្នុងជំពូកទី៥០ និងមានគណនីលេខ ៥០០២ បង្ហាញតួលេខដែលរដ្ឋាភិបាលគ្រោងនឹងខ្ចី *បំណុល និងបំណុលស្រដៀងគ្នា* ក្នុងឆ្នាំ ២០១៥។ ចំនួនទឹកប្រាក់ ៥១,៨ លានដុល្លាសហរដ្ឋអាមេរិក គឺជាចំនួនដែលរដ្ឋាភិបាលរំពឹងថានឹងខ្ចីពីអង្គការពហុភាគី និងត្រូវទូទាត់សងវិញជាមួយនឹងចំនួនការប្រាក់នៅពេលក្រោយ។ ការគាំទ្រវិនិយោគពីសំណាក់ទ្វេភាគី និងពហុភាគី (ជំពូក ៧៥) ចំនួនទឹកប្រាក់ ២២,២ លានដុល្លារគឺរំពឹងថានឹងបានគាំទ្រពីសំណាក់ម្ចាស់ជំនួយ។

***ចំណូលក្រៅពីរតនាគារជាតិ*** គឺជាចំណូលមួយភាគបួននៃចំណូលរបស់រដ្ឋាភិបាល និងរំពឹងថានឹងបាន ៩១០,៤ លានដុល្លារក្នុងឆ្នាំ ២០១៥ (សូមមើលផ្នែកទី២ : ចំណូលពីប្រភពខាងក្រៅ និងប្រភពខាងក្រោម)។ ចំណូលទាំងនោះ បានមកពីដៃគូអភិវឌ្ឍន៍របស់រដ្ឋាភិបាល ដែលចំនួន ១៣២,៦ លានដុល្លារអាមេរិកបានមកពីប្រាក់ជំនួយឥតសំណង (ផ្នែក ៧៥ និងគណនីលេខ ៧៥១៤) និង ៧៧៧,៨ លានដុល្លារអាមេរិកបានមកពីប្រាក់កម្ចី (ផ្នែកទី ៥០ និងគណនីលេខ ៥០០២)។

ព័ត៌មានបន្ថែម សូមមើលច្បាប់ថវិកាជាតិឆ្នាំ ២០១៥ ដែលអាចធ្វើការទាញយកបានពី គេហទំព័ររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (www.mef.gov.kh) និង គេហទំព័រថវិកាកម្ពុជា (www.cambodianbudget.org)។

សេចក្តីលំអិតដូចបង្ហាញក្នុងតារាង A របស់ច្បាប់ថវិកា ផ្តល់នូវព័ត៌មានគួរអោយចាប់អារម្មណ៍អំពី សមាជិកសភាជាតិ អ្នកបង្កើតច្បាប់ និងអ្នកវិភាគ។ ទោះបីជាសេចក្តីលំអិតនេះ មិនបានផ្តល់នូវចំលើយ លើសំណួរថាតើចំណូលប៉ុន្មានដែល រំពឹងថានឹងទទួលបានពីការលក់សំបុត្រ ចូលទស្សនាប្រសាទអង្គរវត្ត ចំណូលពីការប្រមូលថ្លៃផ្លូវជាតិលេខ ៤ពីយានជំនិះ ។ល។

### B. តារាង B: ការចំណាយថវិកា (ចរន្ត) ថ្នាក់ជាតិ

ក្នុងឆ្នាំ ២០១៥ ចំណាយសរុបរបស់រដ្ឋាភិបាលថ្នាក់ជាតិ (មិនរួមបញ្ចូលរដ្ឋបាលថ្នាក់ក្រោមជាតិ) គឺប៉ាន់ស្មានប្រហែលជា ១៥.០៣៥.២២៩ លានរៀល (៣.៧១២,៤ លានដុល្លារអាមេរិក)។ សូមមើលឧបសម្ព័ន្ធទី៣ ដែលជាសម្រង់ពីតារាងB ពីក្នុងច្បាប់ថវិកាជាតិឆ្នាំ ២០១៥។ វាបង្ហាញពីចំណាយសរុប របស់រដ្ឋាភិបាល

[42] ចំណូលពីវិទ្យុនិងទូរទស្សន៍ (គណនីរងលេខ ៧៣០០៥) និងចំណូលពីការផ្គត់ផ្គង់ទឹកនិងអគ្គិសនី (គណនីរង ៧៣០០៧) គឺមានចំនួនតូចណាស់។

ដោយបញ្ជាក់បន្ថែមលើប្រភេទចំណាយចរន្តផងដែរ។ តារាងនេះមានជួរឈរសំខាន់ៗ ចំនួន៤ គឺ ជួរទី ១: ក្រសួងនិង ភ្នាក់ងារ ជួរទី ២: ចំណាយសរុប ជួរទី ៣: ចំណាយចរន្ត និងជួរទី ៤: ចំណាយមូលធន។

**ចំណាយចរន្ត** សំដៅលើថវិកាប្រើប្រាស់សម្រាប់រក្សានូវដំណើរការងារប្រចាំថ្ងៃ។ នេះរួមមាន ប្រាក់ខែរបស់មន្ត្រីរដ្ឋាភិបាល ប្រេងសាំង ការសាងសង់និងការជួសជុលអគារ អគ្គិសនី ទូរស័ព្ទ និងទំនិញប្រើប្រាស់ដើម្បីផ្តល់សេវា (ដូចជាថ្នាំពេទ្យ និងសៀវភៅសិក្សា) និងសេវាកម្មផ្សេងៗទៀត។ ឧទាហរណ៍ ផ្សេងទៀតទាក់ទងនឹងចំណាយចរន្តរួមមាន ការអន្តរាគមន៍លើ កិច្ចការសង្គម និងសេដ្ឋកិច្ច ការប្រាក់ និងការចំណាយមិនបានគ្រោងទុកផ្សេងទៀត។ ចំណាយចរន្តថ្នាក់ជាតិសម្រាប់ឆ្នាំ២០១៥ គឺប៉ាន់ ប្រមាណចំនួន ៩.២៧៥.១៦១ លានរៀល (២.២៩២,២ លានដុល្លាអាមេរិក)។ ក្នុងជួរឈទី ៣ នៃចំណាយចរន្ត ចែកចេញជា ៥ប្រភេទ: ប្រភេទទី១: មធ្យោបាយនិងសេវា ប្រភេទទី២: ចំណាយ ហិរញ្ញវត្ថុ (ការបង់ការប្រាក់) ប្រភេទទី៣: កិច្ចអន្តរាគមន៍សាធារណៈ ប្រភេទទី៤: ចំណាយផ្សេងៗ និង ប្រភេទទី ៥: ចំណាយមិនបានព្រាងទុក។ ក្នុងជួរឈទី៤ នៃចំណាយមូលធន ត្រូវបានចែកជា ២ប្រភេទ: ប្រភេទទី១: ការទូទាត់បំណុល និងការជំពាក់ផ្សេងៗទៀត និង ប្រភេទទី២: ទ្រព្យអសកម្ម។

ថវិកាសម្រាប់គ្រប់ក្រសួងទាំងអស់ គឺជាចំនួនសរុបសម្រាប់ក្រសួង ស្ថាប័ន និងចំនួនសរុបនេះត្រូវ បានបែងចែកបន្ថែមទៀតចេញទៅ តាមនាយកដ្ឋានបច្ចេកទេសកណ្តាល ខេត្ត/ក្រុង និងការហិរញ្ញវត្ថុវិនិយោគសាធារណៈពីខាងក្រៅ។

ការទូទាត់លើ បំណុល ចំណាយហិរញ្ញវត្ថុ និងការចំណាយមិនបានគ្រោងទុក គឺគ្រប់គ្រងដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ។

**ចំណាយមូលធន** រួមមានការវិនិយោគសម្រាប់អត្ថប្រយោជន៍នាពេលអនាគត គម្រោងហិរញ្ញប្បទានវិនិយោគប្រាក់រំលស់ មូលនិធិដៃគូនិងបំណុល។ ឧទាហរណ៍មួយអំពីចំណាយមូលនិធិ រួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជាផ្លូវថ្នល់ ស្ពាន វារីអគ្គិសនី និងទូរគមនាគមន៍។ នៅក្នុងថវិកាថ្នាក់ជាតិរបស់កម្ពុជា ការជួសជុលនៃហេដ្ឋារចនាសម្ព័ន្ធសាធារណៈ គឺបញ្ចូលទៅក្នុងថវិកាចរន្តដែលភាគច្រើននៅក្រោមថវិការបស់ក្រសួងក្នុងកិច្ចការសាធារណៈនិងដឹកជញ្ជូន[43]។ ច្បាប់ថវិកាឆ្នាំ ២០១៥ បានបែងចែកទឹកប្រាក់ចំនួន ៥.៧៦០.០៦៨ លានដុល្លារ (១.៤២២,២ លានដុល្លារអាមេរិក) សម្រាប់ចំណាយមូលធន។ មានក្រសួងមួយចំនួនប៉ុណ្ណោះដែលទទួលបានការបែងចែកនូវថវិកាមូលធនពី រដ្ឋាភិបាល (សូមមើលជួរទី ៤ ចំណាយថវិកាមូលធនសរុប)។ ក្រសួងទាំងនោះរួមមាន រដ្ឋបាលទូទៅនៃក្រសួងមហាផ្ទៃ ក្រសួងអប់រំយុវជននិងកីឡា ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ក្រសួងអភិវឌ្ឍន៍ ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងធនធានទឹកនិងឧត្តុនិយម។

[43] កាលពីមុន ថវិកាត្រូវបានបម្រុងទុកសម្រាប់ចំណាយដែលមិនបានទំពឹងទុក ហើយត្រូវបានរាប់បញ្ចូលទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជារៀងរាល់ឆ្នាំ ដែលធ្វើឱ្យថវិកាបស់ខ្លួនច្រើនជាង តួលេខ ដែលបានអនុម័តដំបូង , ប៉ុន្តែចាប់ផ្តើមពីឆ្នាំ ២០១៥ វាត្រូវបានរួមបញ្ចូលទៅក្នុងថវិការបស់ក្រសួងសាធារណៈការនិងដឹកជញ្ជូន ដែលបានធ្វើឱ្យថវិកាដែលក្រសួងនេះធំជាងមុនច្រើនបើប្រៀបធៀបទៅនឹងឆ្នាំ ២០១៤ ។

**C. តារាង C១: ហិរញ្ញប្បទានវិនិយោគសាធារណៈផ្តល់ដោយហិរញ្ញប្បទានក្រៅ (ម្ចាស់ជំនួយ)**

លក្ខណៈសំខាន់មួយនៃថវិកាជាតិកម្ពុជា គឺមានលក្ខណៈពីរបែប។ នេះមានន័យថាការចំណាយចរន្ត និងការចំណាយមូលធនត្រូវបានបង្ហាញដោយឡែកពីគ្នា ដូចដែលបានរៀបរាប់ខាងដើមនៅក្នុងការរៀបរាប់នៃតារាងផ្សេងគ្នានៅក្នុងច្បាប់ថវិកានេះ។ តារាង C ក្នុងច្បាប់ថវិកាជាតិ ផ្តល់ជូននូវទិដ្ឋភាពទូទៅនៃគម្រោងទាំងអស់របស់ក្រសួងនីមួយៗ រួមជាមួយនឹងតួលេខនៃការចំណាយសរុបរបស់គម្រោង និងការចំណាយរបស់គម្រោងប្រចាំឆ្នាំនៅក្នុងរយៈពេលបីឆ្នាំខាងមុខទៀត ដែលជាសង្ខេបក្នុងតារាងនេះបង្ហាញនៅក្នុងឧបសម្ព័ន្ធទី៣ ។ ច្បាប់ថវិកាឆ្នាំ ២០១៥ រួមមានគម្រោងទាំងអស់ដែលមានហិរញ្ញប្បទាន និង មិនមានហិរញ្ញប្បទាន/ស្វែងរកហិរញ្ញប្បទាន បែងចែកតាមក្រសួង និងភ្នាក់ងាររដ្ឋាភិបាលផ្សេងៗគ្នា។ គម្រោងទាំងអស់ ខុសគ្នាគួរអោយកាត់សំគាល់តាមទំហំ ដែលគម្រោងធំបំផុតអាចចំណាយរហូតដល់រាប់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ និងតូចបំផុតចំណាយត្រឹមតែប្រហែល មួយម៉ឺនដុល្លារតែប៉ុណ្ណោះ។

**តារាងទី៧ : ស្ថាប័នក្រសួងជាមួយគំរោងចំណាយមូលធនខ្ពស់បំផុតក្នុងឆ្នាំ ២០១៥**

| លេខ | ក្រសួង | ចំណាយមូលធនក្នុងឆ្នាំ ២០១៥ |
|---|---|---|
| ១ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន | ១.៣២៥.៨៦៨ លានរៀល/ ៣២៧,៤ លានដុល្លារអាមេរិក |
| ២ | ក្រសួងរ៉ែនិងឧស្សាហកម្ម | ៧៣៧.៣៥១ លានរៀល/ ១៨២,១ លានដុល្លារអាមេរិក |
| ៣ | ក្រសួងសុខាភិបាល | ២៧៤.៩១១ លានរៀល/ ៦៨,១ លានដុល្លារអាមេរិក |
| ៤ | ក្រសួងធនធានទឹក និងឧត្តុនិយម | ១.០១៣.១២៤ លានរៀល/ ២៥០,២ លានដុល្លារអាមេរិក |
| ៥ | ក្រសួងអភិវឌ្ឍន៍ជនបទ | ២១២.៥៦៨ លានរៀល/ ៥២,៥ លានដុល្លារអាមេរិក |
| ៦ | ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ១៧៨.៨១៨ លានរៀល/ ៤៤,២ លានដុល្លារអាមេរិក |
| ៧ | ក្រសួងអប់រំយុវជននិងកីឡា | ២១៩.៩៤៣ លានរៀល/ ៥៤,៣ លានដុល្លារអាមេរិក |
| ៨ | ទីស្តីការគណៈរដ្ឋមន្ត្រី | ១៧៩.៩០៦ លានរៀល/ ៤៤,៤ លានដុល្លារអាមេរិក |
| ៩ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១៩៦.៤២០ លានរៀល/ ៤៨,៥ លានដុល្លារអាមេរិក |

ចំនួនទឹកប្រាក់ទាំងនេះរួមបញ្ចូលទាំងគម្រោងដែលមានហិរញ្ញប្បទាន និងមិនមានហិរញ្ញប្បទាន។ ការចំណាយមូលធនសរុបដែលបានគ្រោងទុកក្នុងបរិមាណឆ្នាំ ២០១៥ មានចំនួន ៤.៩១៣.៨៦០ លានរៀល/ ១.២១៣,៣ លានដុល្លារអាមេរិក (សូមមើលការបូកសរុប តារាងC1)។ ក្នុងនេះគម្រោងដែលមានហិរញ្ញប្បទាន មានចំនួន ៣.១៦១.២០៣ / ៧៨០,៥ លានដុល្លារអាមេរិក និងគម្រោងមិនមានហិរញ្ញប្បទាន មានចំនួន ១.៧៥២.៦៥៨ លានរៀល / ៤៣២.៨ លានដុល្លារអាមេរិក។ ជួរទី៣ ជាមួយនឹងចំណាយគម្រោងសរុប ផ្តល់ទិដ្ឋភាពទូទៅនៃ ចំណាយសរុបរបស់គម្រោង រៀបរាប់ក្រោមក្រសួងពាក់ព័ន្ធនីមួយៗ។ ដោយសារតែគម្រោងខ្លះប្រើពេលយូរក្នុងការអនុវត្តន៍ (ហើយប្រហែលជាចាប់ផ្តើមពីរបីឆ្នាំ មកហើយ), ការបែងចែកក្នុងបីជួរចុងក្រោយ សម្រាប់ឆ្នាំ ២០១៥ ២០១៦ និង ២០១៧ ប្រហែលជាតិចជាងចំណាយគម្រោងសរុប។

វាគឺជាការគួរឱ្យកត់សម្គាល់ផងដែរថា ជួរទីបួនជាមួយនឹងការចំណាយព្យាករណ៍សម្រាប់ឆ្នាំមុននេះមិន ត្រូវបានបូកបញ្ចូលនៅក្នុងច្បាប់ថវិកាចាប់តាំងពីឆ្នាំ ២០១០ ឡើយ។ ការព្យាករណ៍លើការចំណាយមូលធនក្នុងជួរនេះ គឺច្បាស់ណាស់ជាព័ត៌មានដែលមានសារៈប្រយោជន៍សម្រាប់សាធារណជន អ្នកចងក្រងច្បាប់ និងអ្នកវិភាគ ដើម្បីបង្ហាញពីដំណើរការរបស់គម្រោងក្នុងឆ្នាំសារពើពន្ធ។ ជាការកត់សម្គាល់ មាន ព័ត៌មានពីរប្រភពដែលអាចត្រូវបានប្រើដើម្បីបង្កើតព័ត៌មាននៃការអនុវត្តន៍គម្រោង ឬស្ថានភាពការចំណាយ។ ប្រភពពីរនោះគឺព័ត៌មានជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) (*http://cdc.khmer.biz/*)[44] និង កម្មវិធីវិនិយោគសាធារណៈ (PIP)[45]។ ទិដ្ឋភាពទូទៅច្បាស់លាស់បន្ថែមទៀតនៃការចំណាយមូលធនដោយក្រសួងនានា ក្នុងច្បាប់ថវិកាឆ្នាំ ២០១៥ មាននៅក្នុងឧបសម្ព័ន្ធ ៣ នៃសៀវភៅណែនាំនេះ។

## ៣.២- ការវិភាគនៃថវិកាជាតិ

ផ្នែកនេះមានគោលបំណងណែនាំអំពីឧបករណ៍មួយចំនួននៅក្នុងការវិភាគថវិកា និងការវិភាគថវិកាដែលគួរឱ្យចាប់អារម្មណ៍ និងការស្រាវជ្រាវបាយការណ៍ បានចេញផ្សាយដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា (NGO Forum) និងដៃគូអភិវឌ្ឍន៍អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នដទៃទៀតក្នុងប្រទេសកម្ពុជា។ វាចាប់ផ្តើមជាមួយនឹងផ្នែក មួយស្តីពី ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផ្តល់នូវសេចក្តីសង្ខេបលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ ដែលត្រូវបានអនុម័តដោយរដ្ឋសភាជាតិកាលពីខែមិថុនា ឆ្នាំ២០១៤ មួយចំនួន[46]។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ជាយានយន្តរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលបង្ហាញពីគោលដៅអាទិភាព និងមហិច្ឆតារបស់រដ្ឋាភិបាល។ គោលនយោបាយនិងផែនការ ដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ត្រូវបានភ្ជាប់ទៅនឹងថវិកាជាតិដើម្បី ក្លាយជាប្រតិបត្តិការមួយ ដូច្នេះការបែងចែកធនធានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺក្លាយជាក្របខ័ណ្ឌសម្រាប់ការពិភាក្សាខ្លះៗស្តីពីនិន្នាការនៅក្នុងថវិកាជាតិ។ ទោះបីយ៉ាងណារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានផលលំបាកខ្លះៗក្នុងការបែងចែកចំណាយ (សូមមើលប្រអប់លេខ ៨)។

ដើម្បីវិភាគថវិកាជាតិ តម្រូវឱ្យមានការយល់ដឹងល្អអំពីឯកសារពាក់ព័ន្ធ និងដំណើរការនៃថវិកា ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការរបស់វិស័យនីមួយៗ។ ការវិភាគបឋមអាចចាប់ផ្តើមជាមួយនឹងការកំណត់នៃគោលនយោបាយឥទ្ធិភាព និងការបែងចែកថវិកាទៅថ្នាក់ក្រោម និងថ្នាក់ស្មើគ្នា ដើម្បីវិភាគលើការចែករំលែក និងនិន្នាការថ្នាក់ជាតិ ថ្នាក់ក្រសួង និងថ្នាក់កម្មវិធី។ បន្ទាប់មកតួលេខទាំងនោះ នឹងបំបែកទៅជាតួលេខ លំអិតទៅតាមក្រសួងនីមួយៗ។ ទោះបីយ៉ាងណា ការវិភាគថវិកាអាចធ្វើទៅបានដោយល្អ គឺទាមទារវត្តមាននូវព័ត៌មានទាក់ទងនឹងថវិកាគ្រប់គ្រាន់។ ក្នុងឆ្នាំ២០១៥ រដ្ឋាភិបាល

[44] អាចទាញយកបានតាមរយៈគេហទំព័រ: www.cdc-crdb.gov.kh

[45] នេះអាចស្នើរសុំបានពីក្រសួងផែនការ ឬទាញយកតាមរយៈគេហទំព័រ: www.mop.gov.kh

[46] សូមមើលលទ្ធផលលើការអនុវត្ត: http://www.national-assembly.org.kh/

បានផលិត និងបោះពុម្ពផ្សាយនូវកម្មវិធីបែងចែក ថ្នាក់ថវិកាលើកទី៣ ជាពិសេស សម្រាប់ក្រសួងទាំង ១០ ដែលអនុវត្តថវិកាកម្មវិធី។ ការបែងចែកថវិកាក្នុងកំរិតកម្មវិធីនេះ សំរួលដល់អ្នកវិភាគ អ្នកចងក្រងគោលនយោបាយ និងអង្គការសង្គមស៊ីវិល អាចយល់និងអាចវិភាគបានវិតតែល្អ លើតម្រឹមការបែកចែកថវិកាទៅនឹងគោលនយោបាយឥទ្ធិភាព។

គេហទំព័រ ស្ដីពីគម្រោងថវិកាអន្តរជាតិ ដ៏មានសារៈសំខាន់ ទៅនឹងឧបករណ៍សម្រាប់វិភាគថវិកាអាចទាញយកបានតាមរយៈ: www.internationalbudget.org។ ដើម្បីទទួលបាននូវមូលដ្ឋានសម្រាប់ការវិភាគថវិកាជាពិសេសសម្រាប់អ្នកមិនមានចំណេះដឹងផ្នែកសេដ្ឋកិច្ច យ៉ាងហោចណាស់ ត្រូវចូលរួមវគ្គបណ្ដុះបណ្ដាលលើការ វិភាគថវិកាជាមូលដ្ឋាន។

**ប្រអប់ទី ៨: ផលវិបាកប្រឈមដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការបែងចែកចំណាយ**

ដំណើរការក្នុងការបង្កើតថវិកា ដើម្បីដាក់នូវគោលនយោបាយទៅជាសកម្មភាពអនុវត្ត និងដើម្បីសំរេចបាននូវលទ្ធផល និងគោលដៅដែលរដ្ឋាភិបាលចង់បាន គឺមានភាពស្មុគស្មាញ និងទាមទារការវិភាគយ៉ាងស៊ីជំរៅមួយ។ ជាមួយនឹងធនធាន មានកំរិត រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវធ្វើការជ្រើសរើសរវាង ការវិនិយោគផ្នែករដ្ឋបាល ផ្នែកសេដ្ឋកិច្ច (កសិកម្ម ដឹកជញ្ជូន ការងារសាធារណៈ និងការអភិវឌ្ឍជនបទ) និងផ្នែកសង្គម (ការអប់រំ សុខាភិបាល ការពារសង្គម និងសេវាកម្មសង្គមផ្សេងៗទៀត)។

ដូចបានបង្ហាញដោយធនាគារពិភពលោក(២០០៧) ផ្ដល់អនុសាសន៍ អំពីអ្វីដែលជាការបែងចែកចំណាយដ៏ល្អប្រសើរបំផុតសម្រាប់ការចំណាយរបស់រដ្ឋាភិបាល គឺជាការលំបាក។ ហេតុផលមួយគឺថា ការបង្កើននូវចំណាយមូលធន (សាងសង់ផ្លូវ/សាលារៀន/មន្ទីរពេទ្យ) អាចធ្វើបានគ្រប់គ្រាន់បាន បើសិនជារដ្ឋាភិបាលមានបុគ្គលិកគ្រប់គ្រាន់ដើម្បីអនុវត្តគម្រោងនេះ ដែលមានន័យថា ការចំណាយចរន្តបន្ថែមទៀត (ប្រាក់ខែ/ចំណាយប្រតិបត្តិការ) គឺមានភាពចាំបាច់។ ដូច្នេះហើយ មិនមានភាពច្បាស់ លាស់ភ្លាមៗថាតើចំណាយមូលធន មានភាពប្រសើរជាងការចំណាយចរន្ត។ បញ្ហាមួយទៀតគឺការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ ដែលអាចបំពេញលើចំណាយសង្គមបាន។ ដូចនេះហើយ ដើម្បីពង្រឹង អត្រាចុះឈ្មោះចូលរៀនរបស់សិស្ស ការសាងសង់ផ្លូវជនបទបន្ថែមមួយទៀត អាចជួយបានច្រើនជាងការសាងសង់សាលារៀនមួយទៀត។ ជាលទ្ធផល មិនមានភាពច្បាស់លាស់ភ្លាមៗទេ ថាតើវិស័យណាមួយគួរតែទទួលបានសិទ្ធិអាទិភាពដើម្បីសម្រេចបាននូវគោលដៅសង្គមមួយជាក់លាក់។

ទោះបីជាមានការលំបាកទាំងនេះ ទាំងរដ្ឋាភិបាលនិងរដ្ឋសភាជាតិ ត្រូវការសម្រេចចិត្តលើការថវិកាបែងចែកថវិការៀងរាល់ឆ្នាំ។ ក្នុងគោលបំណងដើម្បីធ្វើការសម្រេចចិត្តដែលមានផលវិជ្ជមានបំផុត ទាំងរដ្ឋាភិបាល និងរដ្ឋសភាជាតិគួរ តែប្រមូលអោយបាននូវព័ត៌មានកាន់តែច្រើនតាមតែអាចធ្វើបាន។ ហេតុនេះហើយ ការស្ដាប់នូវតម្រូវការរបស់ប្រជាពលរដ្ឋតាមរយៈការពិគ្រោះយោបល់ និងការចូលរួមជាមួយអង្គការសង្គមស៊ីវិល អាចធ្វើឱ្យមានភាពល្អប្រសើរឡើងក្នុងការចាត់ចែងថវិកាក្នុងបរិបទសេដ្ឋកិច្ច ។

## ៣.៣. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០១៤ - ២០១៨

ដើម្បីណែនាំក្នុងការប្រើប្រាស់ធនធាន រដ្ឋាភិបាលបានបង្កើតផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលមានរយៈពេលប្រាំឆ្នាំ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ននេះ គឺចាប់ពីឆ្នាំ ២០១៤ ដល់ឆ្នាំ ២០១៨ និងត្រូវបានអនុម័តដោយសភានៅក្នុងខែមិថុនា ឆ្នាំ២០១៤ (សូមមើលប្រអប់លេខ៩)។ ផែនការនេះផ្តល់នូវទិដ្ឋភាពទូទៅនៃការអភិវឌ្ឍន៍ជាអាទិភាពរបស់រដ្ឋាភិបាល គោលដៅ និងសូចនាករនៃគោលនយោបាយតាមវិស័យ ការបែងចែកថវិកាចរន្តច្បាស់លាស់ និងការបែងចែកថវិកាមូលធនក្នុងរយៈពេលនៃផែនការនេះ។ ធនធានរបស់រាជរដ្ឋាភិបាលនេះត្រូវបានគេភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តាមរយៈក្របខ័ណ្ឌចំណាយរយៈពេលមធ្យមសម្រាប់ការបែងចែកចំណាយចរន្ត និងចំណាយមូលធនរបស់ខ្លួន (សូមមើលព័ត៌មានលម្អិត សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨: តារាង ៣.៤ និងតារាង ៥.១ តាមលំដាប់)[47]។ ទំនាក់ទំនងបន្ថែមទៀតរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងថវិកាជាតិ គឺជាផែនការយុទ្ធសាស្ត្រថវិការៀបចំដោយក្រសួង/ស្ថាប័នពាក់ព័ន្ធ (ប្រអប់ ២ នៅក្នុងជំពូកទី១ សូមមើល) ដែលជាឧបករណ៍របស់រដ្ឋាភិបាលសម្រាប់ការរួមបញ្ចូលនៃថវិកាចរន្តនិងមូលធន។

**ប្រអប់ ៩: ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ – តើមានអ្វីថ្មី និងអ្វីដែលជាបន្ទាប់?**

**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ បានអនុម័តដោយសភាជាតិក្នុង ខែមិថុនា ឆ្នាំ ២០១៤**

***អនុសាសន៍ពីអង្គការក្រៅរដ្ឋាភិបាល លើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨***

មានអង្គការក្រៅរដ្ឋាភិបាលជាច្រើនផ្តល់នូវអនុសាសន៍ដល់ក្រសួង/ភ្នាក់ងារ និងក្រសួងមជ្ឈិម ក្នុងដំណើរការរៀបចំនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨។ ទោះបីជា ការសន្ទនាគ្នាលើមាតិការនៃឯកសារនេះ មានតិចតួចដោយសារ តែការបញ្ជាប្រយមក្នុងយន្តការក្រុមការងារបច្ចេកទេស (និងក្រុមការងារដែលបានតែងតាំង)។ សេចក្តីសង្ខេបពេញលេញនៃអនុសាសន៍និងយោបល់ពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ ដែលអាចទាញយកបានពីគេហទំព័ររបស់វេទិកានៃអង្គការមិនមែនរដ្ឋាបាលស្តីពីកម្ពុជា:
http://www.ngoforum.org.kh/index.php/en/publications-of-development-issues-programme

***តើមានអ្វីថ្មីនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ និងអ្វីបន្ទាប់?***

ដូចផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិពីមុនដែរ បច្ចុប្បន្នភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៩-២០១៣ ដើរតាមទំរង់បែបបទដូចជា យុទ្ធសាស្ត្រចតុកោណដែរ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ អាចទាញចេញបានពីគេហទំព័រ របស់ក្រសួងផែនការ www.mop.gov.kh។ ជារួមមានភាពប្រសើរឡើងយ៉ាងខ្លាំង នៅក្នុងកំណែលើកនេះ ជាពិសេសនៅក្នុងបរិបទនៃដំណាក់កាល អភិវឌ្ឍន៍របស់ប្រទេសកម្ពុជា ដែលផ្លាស់ប្តូរពីប្រទេសមានប្រាក់ចំណូលទាប ទៅជាប្រទេសដែលមានចំណូល

[47] កថាខណ្ឌទី 583 ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលតារាងលេខ ២៥ ក៏បង្ហាញពីធនធានដើម្បីឆ្លើយតបលើ "*ការចំណាយលើការវិធានការពិសេសដើម្បីកាត់បន្ថយផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុពិភពលោក និងការធ្លាក់ចុះសេដ្ឋកិច្ចនៅលើសេដ្ឋកិច្ចពិតនិងជន ងាយរងគ្រោះនិងជនក្រីក្រ*"

មធ្យម។

ការផ្លាស់ប្តូរនេះគឺមានក្នុងជំពូកទី ១ ២ ៣ និង ៦ ដែលព័ត៌មានបន្ថែមទៀត ឬថ្មីលើកំណែមុន និងផ្តល់នូវសូចនាករគន្លឹះ សូចនាករស្នូលក្នុងការត្រួតពិនិត្យ និងសូចនាករពាក់ព័ន្ធបន្ថែមទៀត។ សូចនាករបន្ថែមរបស់កំណែមុន ត្រូវបានប្រើរហូតដល់ការបង្កើតនៃ MTR របស់បច្ចុប្បន្នភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៩-២០១៣ ដោយសារតែភាព យឺតយ៉ាវក្នុងការបញ្ចប់ នៃបញ្ជីសូចនាករបន្ថែម។ ផ្នែកបន្ថែម គឺប្រវត្តិសាស្ត្រអភិវឌ្ឍន៍នៃការធ្វើផែនការរបស់ប្រទេសកម្ពុជា ដែលណែនាំដោយគោលនយោបាយ និងរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិផ្ទាល់ (ជំពូកទី ១), ការវិភាគពីភាពក្រីក្រ និងគោលដៅនយោបាយសំខាន់ ឆ្លើយតបនឹងបញ្ហានានាទិសដៅគោលនយោបាយទូទៅ / គោលដៅរបស់ផែនការ និងយុទ្ធសាស្ត្រចតុកោណអំឡុងឆ្នាំ២០១៤-២០១៨ និងក្របខ័ណ្ឌលទ្ធផល។

**ជំពូកទី១**: សេចក្តីផ្តើម

នេះរួមបញ្ចូលទាំងព័ត៌មានសង្ខេបអំពីប្រវត្តិនៃផែនការអភិវឌ្ឍន៍ ក្នុងប្រទេសកម្ពុជា បន្តដោយគោលនយោបាយណែនាំ និងរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

**ជំពូកទី២:** សមិទ្ធផលនិងបញ្ហាប្រឈមធំៗ នៅក្នុងការអនុវត្តន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្ននេះ ២០០៩-២០១៣។ រួមមានទាំងផ្នែក បកស្រាយអំពីអត្រាភាពក្រីក្រនិងបញ្ហាប្រឈមក្នុងការវាស់វែងនៃភាពក្រីក្រ។

**ជំពូកទី ៣:** ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨ គោលដៅនយោបាយសំខាន់នៃគោលនយោបាយសារពើពន្ធ យុទ្ធសាស្ត្រលើវិស័យរូបិយវត្ថុ និង ហិរញ្ញវត្ថុ ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងវិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុងផែនការនេះ។ ចំពោះគោលនយោបាយសារពើពន្ធ ប្រាក់ចំណូលគោលដៅគិតជាភាគរយនៃផលិតផលក្នុងស្រុកសរុប គឺ ១៦,៩% (ទិសដៅដែលល្អគឺ ១៨%)។ ចំពោះការចំណាយ រដ្ឋាភិបាលនឹងបន្តផ្សារភ្ជាប់ សំខាន់ខ្លាំងទៅនឹងវិស័យសេដ្ឋកិច្ចសង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធ រូបវន្តនិងការកែលម្អសមត្ថភាព និងជីវភាពរស់នៅរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធនិងវិស័យសំខាន់ៗទៀតដូចជាការអប់រំ និងសុខាភិបាល មានគោលដៅច្បាស់លាស់នៃការបែងចែកថវិកាដោយមិនអោយ តិចជាង ៣% និង ២% មុនឆ្នាំ ២០១៨ ។ ក្របខ័ណ្ឌលទ្ធផលនេះ បង្ហាញពីការផ្លាស់ប្តូរយ៉ាងច្បាស់លាស់និងសំខាន់ នៃគំរូផែនការប្រែក្លាយ ពីការកាត់បន្ថយភាពក្រីក្រ ឆ្ពោះទៅការកសាងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច។ នៅក្នុងការត្រួតពិនិត្យនិងការវាយតម្លៃក្នុងជំពូកទី (៤) បង្ហាញពីបញ្ហាប្រឈមនិងសកម្មភាពសំខាន់យ៉ាងច្បាស់ដែលត្រូវធ្វើការកែលម្អលើការតាមដាននិងវាយតម្លៃនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ជំពូកនេះក៏បង្ហាញពីការបែងចែកថវិកាចរន្តផងដែរ ដោយក្រសួង និង ភ្នាក់ងារ រដ្ឋាភិបាល សម្រាប់ឆ្នាំ ២០១៤-២០១៨ ផងដែរ។

បន្ថែមទៅនឹងទិសដៅរួមនៃផែនការ ឆ្ពោះទៅរកគោលដៅកំណើនសេដ្ឋកិច្ច និងទិសដៅអភិវឌ្ឍន៍សេដ្ឋកិច្ច ជាសញ្ញាបង្ហាញការផ្តោតអារម្មណ៍ឆ្ពោះទៅរកការរៀបចំនៃការផ្លាស់ប្តូររបស់ប្រទេសកម្ពុជា ពីប្រទេសដែលមានប្រាក់ចំណូលទាបទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យម។ បន្ទាប់មក ក្របខ័ណ្ឌលទ្ធផលមួយកាន់តែច្បាស់ នឹងអនុវត្តដើម្បីធ្វើការភ្ជាប់ទំនាក់ទំនងរវាងសង្គម សេដ្ឋកិច្ច នយោបាយ និងគោលនយោបាយ ក្នុងគោលបំណងសម្រេចបាននូវគោលដៅរួម។ ជំពូកនេះបានកំណត់យ៉ាងច្បាស់វិស័យអាទិភាពនិងតំបន់គោលនយោបាយសារពើពន្ធ និងស្ថាប័នរដ្ឋាភិបាលសំខាន់ៗផ្សេងទៀត និងគោលនយោបាយឆ្លងវិស័យ (យុទ្ធសាស្ត្រវិស័យរូបិយវត្ថុនិងហិរញ្ញវត្ថុ ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម និងការវិមជ្ឈការ

និងវិសហមជ្ឍការ)។ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរួមបញ្ចូលនៅក្រោមផ្នែកនយោបាយសារពើពន្ធផងដែរ។

**ជំពូកទី ៦:** ការតាមដាននិងវាយតម្លៃ

ដើម្បីកាន់តែមានភាពច្បាស់លាស់ថែមទៀត ទាមទារអោយមានការកំណត់ពីតួនាទីនិងភារកិច្ចរបស់ក្រសួងផែនការ និងក្រសួងពាក់ព័ន្ធ ក្នុងការតាមដាននិងវាយតម្លៃ និងការរួមចំណែកដល់ក្របខ័ណ្ឌលទ្ធផល។ នេះក៏បានពន្យល់អំពីប្រភេទផ្សេងៗគ្នានៃសូចនាករ និងឋានានុក្រមនៃសូចនាករជាមួយនឹងទំនាក់ទំនងរបស់វាទៅនឹងក្របខ័ណ្ឌលទ្ធផល រួមជាមួយនឹងការតាមដាននិងវាយតម្លៃនៅថ្នាក់ក្រោមជាតិ និងការបង្កើតទិន្នន័យ និងការប្រមូលការគាំទ្រមុខងាររបស់ ការតាមដាននិងវាយតម្លៃរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ បញ្ហាប្រឈមវិធីសាស្ត្រ និងអាទិភាព ដែលមានភាពច្បាស់លាស់និងជាក់លាក់ អាចធ្វើអោយយើងឆ្ពោះទៅរកការអភិវឌ្ឍប្រព័ន្ធតាមដាននិងវាយតម្លៃជាតិ និងការពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាលនៅក្នុងកិច្ចការនេះបាន។

# ៤. បញ្ហាពាក់ព័ន្ធ

## ៤.១ ការភ្ជាប់ទំនាក់ទំនងរវាងថវិកាជាតិជាមួយផែនការជាតិអភិវឌ្ឍន៍ និងផែនការវិស័យ

ដូចដែលបានបង្ហាញនៅក្នុងជំពូកមុនទំនាក់ទំនងរវាងថវិកាជាតិ និងគោលនយោបាយរបស់ប្រទេសកម្ពុជា បានរៀបរាប់អំពីតម្រូវការក្នុងការពង្រឹង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ភាពទន់ខ្សោយនៃទំនាក់ទំនងបច្ចុប្បន្ន រវាងផែនការនិងថវិកា ត្រូវបានទទួលស្គាល់ដោយរដ្ឋាភិបាលនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ទំនាក់ទំនងនេះក៏បានបង្ហាញ ក្នុងបច្ចុប្បន្នភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងកំណែមុន ២០០៩-២០១៣ (កថាខណ្ឌ ៣២៨) ដែលចែងថា មានតម្រូវការបន្ទាន់ក្នុង *«ការពង្រឹងការសម្របសម្រួលក្នុងចំណោមស្ថាប័នមជ្ឈឹមចំនួនបួន ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាសាអភិវឌ្ឍន៍ និងស្ថាននិតិសម្បទាកម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិក្នុងការធ្វើផែនការ ការធ្វើថវិកា និងការបែងចែកធនធានដែលអាចរកបានសម្រាប់ការអភិវឌ្ឍន៍ពីប្រភពទាំងអស់»*។

ការកែលម្អទំនាក់ទំនងរវាងការធ្វើផែនការ និងថវិកា មានសក្តានុពលក្នុងការកែលម្អនៃការចែកថ្នាក់និងចំណាយនៃធនធានសាធារណៈ។ ទាំងនេះគួរតែត្រូវគ្នាជាមួយគោលបំណងកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលក្នុងការបង្ហាញនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០១៤-២០១៨។ ដើម្បីពង្រឹងការទំនាក់ទំនងនេះ រដ្ឋាភិបាលត្រូវ:

១. បន្តធ្វើការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ;

២. ផ្តួចផ្តើមបង្កើតនូវ ក្រុមការងារធ្វើសមាហរណកម្មថវិកាដែលរួមមានភ្នាក់ងារមជ្ឈឹម ចំនួនបួន: ក្រសួងផែនការ សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាសាអភិវឌ្ឍន៍និងស្ថាននិតិសម្បទាកម្ពុជា / ក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ;

៣. ផ្តោតការយកចិត្តទុកដាក់លើសកម្មភាព និងលទ្ធផលក្នុងការពង្រឹងការបង្កើតផែនការនិងថវិកា។

## ៤.២ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) នៅឆ្នាំ ២០០៤ ដោយប្រើប្រាស់វិធីសាស្ត្រវេទិកា។ វាជាកម្មវិធីកំណែទម្រង់ដែលមានភាពទូលំទូលាយនិងរយៈពេលយូរ ជាមួយនឹងទស្សនៈវិស័យដែលមានមហិច្ឆតា ក្នុងការកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសកម្ពុជាទៅដល់កម្រិតស្តង់ដាអន្តរជាតិតាមរយៈវេទិកាបួន: (i) ការធ្វើឱ្យប្រសើរឡើងនូវទំនួលខុសត្រូវលើថវិកា (ii) ការបង្កើនទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុ (iii) ការលើកកំពស់ទំនាក់ទំនងគោលនយោបាយថវិកា និង (iv) បង្កើនទំនួលខុសត្រូវនៃការអនុវត្តន៍ ។

វិសាលភាពនៃកម្មវិធីនេះគ្រប់គ្រងសកម្មភាពដែលរួមបញ្ចូលទាំង វិធីសាស្ត្រក្នុងការបង្កើតថវិកា និងការប្រតិបត្តិ ការតាមដាននិងការវាយតម្លៃលើថវិកា គោលនយោបាយប្រាក់ចំណូលនិងរដ្ឋបាល និង ការអភិវឌ្ឍធនធានមនុស្សនិងការគ្រប់គ្រង។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចាប់ផ្តើមនៅក្នុងឆ្នាំ ២០០៥ និងបានបែងចែកទៅជាបួនវេទិកា ដូចបង្ហាញនៅក្នុងរូបភាពលេខ ៧។ ដំបូងឡើយ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានគោលដៅបញ្ចប់នៅក្នុងឆ្នាំ ២០១៥។ ប៉ុន្តែត្រូវបានលើកទៅឆ្នាំ ២០២៥ វិញ ដោយផ្អែកលើការរីកចំរើននិងបញ្ហាប្រឈមដួបប្រទះក្នុងការធ្វើ កំណែទម្រង់រយៈពេលប្រាំបីឆ្នាំចុងក្រោយ (២០០៥-២០១៣)។

- ដំណាក់កាលទី ១: ២០០៥-២០០៨
- ដំណាក់កាលទី ២: ២០០៨-២០១៥
- ដំណាក់កាលទី ៣: ២០១៦-២០២០
- ដំណាក់កាលទី ៤: ២០២១-២០២៥

**រូបភាពទី ៧: លំដាប់លំដោយនៃវេទិកា កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**




ភាពរីកចំរើននៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានត្រួតពិនិត្យដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួងនេះបានរាយការណ៍ពីការរីកចម្រើន នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដល់ដៃគូអភិវឌ្ឍន៍របស់ខ្លួន ដែលជាសមាជិករបស់ក្រុមការងារបច្ចេកទេសស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[48]។ រាល់មួយឆ្នាំម្តង ក្រុមអ្នកត្រួតពិនិត្យឯករាជ្យនៃការរីកចំរើន កម្មវិធីកំណែទម្រង់ការ

[48] វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា គឺជាអ្នកអង្កេតការណ៍ក្នុងក្រុមការងារបច្ចេកទេសនៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធ្វើការការត្រួតពិនិត្យឡើងវិញ និងក៏មានការពិភាក្សារវាង រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ផងដែរ។

លើសពីនេះទៀត ដើម្បីពង្រឹងការផ្លាស់ប្តូរប្រកបដោយជោគជ័យ និងសមិទ្ធផលនៃវេទិកាបន្ទាប់ រដ្ឋាភិបាល/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានណែនាំ ឯកសារទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការធ្វើកំណែទម្រង់ប្រព័ន្ធថវិការបស់ប្រទេសកម្ពុជា ឆ្នាំ ២០១៣-២០២០។ ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តក្នុងការធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ឆ្ពោះទៅរកការទទួលស្គាល់ ដោយ ស្តង់ដាអន្តរជាតិ។ នេះគឺជាការផ្លាស់ប្តូរបន្តិចម្តងៗ ពីប្រព័ន្ធផ្អែកលើទន្និន័យមូលដ្ឋាននិងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធផ្អែកលើលទ្ធផលនៃការអនុវត្តន៍ និងវិមជ្ឈការ។ សម្រាប់ព័ត៌មានបន្ថែម ចំពោះកម្មវិធី កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានវត្តមាន នៅគេហទំព័រ: http://www.pfm.gov.kh ឬ គេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, http://www.mef.gov.kh។ មានឯកសារស្តីពីប្រធានបទនេះច្រើន ដែលមានក្នុងគេហទំព័រ http://www.cambodianbudget.org[49]។

## ៤.២.១- កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ១: ២០០៥-២០០៨

គោលបំណងនៃការធ្វើឱ្យថវិកាកាន់តែគួរឱ្យទុកចិត្តជាងនេះ ក្នុងវេទិកា/ដំណាក់កាលទី ១ សម្រេចបានយ៉ាងល្អ និងជាគ្រឹះសម្រាប់ដំណាក់កាលទី 2 (រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ២០០៨)។ ឧទាហរណ៍ ការធ្វើអោយប្រសើរឡើងលើការប្រមូលចំណូល បានទទួលជោគជ័យរួចហើយ (សូមមើល ច្បាប់ថវិកាពីឆ្នាំមួយទៅឆ្នាំមួយក្នុងគេហទំព័ររបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ)។ រដ្ឋាភិបាលបានអនុម័តយុទ្ធសាស្ត្រចល័ត ក្នុងការប្រមូលប្រាក់ចំណូលដែលមានគោលដៅ គាំទ្រដល់គោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិស្តីពីការប្រមូលប្រាក់ចំណូល។ ប្រអប់ទី ១០ ខាងក្រោម បង្ហាញពីយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងប្រាក់ចំណូលពីប្រេង ឧស្ម័ន និងរ៉ែ។ ទោះយ៉ាងណា បញ្ហាមួយចំនួននៅតែមានពីវេទិកាទីមួយហើយត្រូវបានដោះស្រាយនៅក្នុងដំណាក់កាលទី ២ (Nelmes ២០០៨) ដូចជា:

- ប្រមូលប្រាក់ចំណូលចល័ត ដោយរួមបញ្ចូលទាំងការគ្រប់គ្រងប្រាក់ចំណូលសក្តានុពលពីវិស័យរុករករ៉ែ និងប្រេង;
- ការធ្វើសមាហរណកម្មពេញលេញជាងនេះ នៃថវិកាមូលធននិង ចរន្ត ជាពិសេសលើប្រាក់ឈ្នួលនិងការចំណាយលើការវិនិយោគដែលមានហិរញ្ញប្បទានពីក្រៅប្រទេស;
- ព័ត៌មានស្តីពីថវិកាកាន់តែទូលំទូលាយបន្ថែមទៀត;
- លើកកំពស់ការកាត់ត្រា និងរបាយការណ៍គណនេយ្យរបស់រដ្ឋាភិបាល ជាពិសេសសម្រាប់ការចំណាយវិនិយោគក្នុងស្រុក;
- ការកែលម្អការគ្រប់គ្រងសាច់ប្រាក់ និងការពង្រឹងការរួមគ្នានៃគណនីធនាគាររបស់រដ្ឋាភិបាល;
- បង្កើនវិធានការកសាងសមត្ថភាព;
- មុខងារលើការរៀបចំការពិនិត្យ និង កែប្រែរចនាសម្ព័ន្ធ នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឆ្លើយតបបានល្អប្រសើរលើការវិវត្តន៍នៃភាពស្មុគស្មាញរបស់បញ្ហាប្រឈម។

[49] នៅពេលដែលសរសេរអត្ថបទនេះ, កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺលែងមាននៅក្នុងគេហទំព័រក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៀតទេ។

**ប្រអប់ទី ១០:** ***ការគ្រប់គ្រងចំណូលពី ប្រេង ឧស្ម័ន និងរ៉ែ***

ប្រទេសកម្ពុជាជាប្រទេសសម្បូរទៅដោយធនធានធម្មជាតិដូចជា រ៉ែ ប្រេង និងឧស្ម័ន។ ខណៈពេលដែលក្រុមហ៊ុនភាគច្រើននៅក្នុងដំណាក់កាលរុករក សេចក្តីលម្អិតអំពីទំហំនៃការដាក់បញ្ញើរ និងតម្លៃរបស់របស់វាមិនទាន់បានដឹងនៅឡើយ។ នៅក្នុងបទបង្ហាញទៅកាន់រដ្ឋសភាជាតិ ដែលជាមន្ត្រីជាន់ខ្ពស់នៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ បានផ្តល់ទិដ្ឋភាពទូទៅនូវប្រាក់ចំណូលដែលអាចប្រមូលបានរួមមាន:

- **ចំណូលពីពន្ធ**: ពន្ធផ្ទាល់ (ប្រាក់ចំណេញ / ប្រាក់ខែ) ពន្ធប្រយោល (អាករលើតម្លៃបន្ថែម ពន្ធពិសេស) និងពន្ធផ្សេងទៀត (ពន្ធលើប៉ាតង់ពន្ធ នាំចេញ)
- **ចំណូលមិនមែនពន្ធ:** ដូចជាសួយសារ ប្រាក់រង្វាន់ចុះហត្ថលេខា ថ្លៃជួល ប្រាក់រង្វាន់ផលិតកម្ម ថ្លៃសម្រាប់បន្តកិច្ចសន្យា ឧស្ម័នមិនមានតម្លៃ មូលនិធិបោះបង់ចោល។

ប្រាក់ចំណូលដែលរដ្ឋាភិបាល ទទួលបានពីវិស័យប្រេង ឧស្ម័ន និង រ៉ែ ត្រូវបានប្រមូលដោយក្រសួងស្ថាប័នផ្សេងៗគ្នា។ ឧទាហរណ៍:

- ក្រសួងរ៉ែនិងថាមពល (MME) ប្រមូលប្រាក់សួយសារប្រមូលបានពីក្រុមហ៊ុនរុករករ៉ែ លោហៈ ថ្មមានតម្លៃ។ល។
- ទីភ្នាក់ងារប្រេងកាតជាតិកម្ពុជា (CNPA) នៅក្រោមក្រសួង រ៉ែ និងថាមពល ប្រមូលថ្លៃសម្រាប់សេវារដ្ឋបាលនិងផ្តល់លិខិតអនុញ្ញាតឱ្យក្រុមហ៊ុនរុករក / ចំរាញ់យក ប្រេងនិងឧស្ម័ន;
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) ប្រមូលពន្ធសាជីវកម្ម។

សេចក្តីលម្អិតនៃការឈ្នួល កម្រៃ និងពន្ធនៅក្នុងវិស័យប្រេង ឧស្ម័ននិង រ៉ែ គឺមិនអាចប្រើបានជាសាធារណៈដែលធ្វើអោយមានភាពស្មុគស្មាញ ដល់ការត្រួតពិនិត្យជាសភា និងជាសាធារណៈនៅលើវិស័យនេះ។ បច្ចុប្បន្ននេះ ព័ត៌មានជាមូលដ្ឋានដូចខាងក្រោមគឺមិនមាននៅក្នុងដែនសាធារណៈទេ៖

- បញ្ជីឈ្មោះក្រុមហ៊ុនដែលមានអាជ្ញាប័ណ្ណ ឬកំពុងស្ថិតក្នុងការពិភាក្សាអនុម័ត លើការធ្វើអាជីវកម្មប្រេង ឧស្ម័ន រ៉ែ និងនិស្សារណកម្មធនធានធម្មជាតិផ្សេងទៀត;
- តើកម្រៃនិង ការគិតកម្រៃ ជំពាក់ទៅស្ថាប័នរាជរដ្ឋាភិបាលមួយណាក្នុងដំណាក់កាលផ្សេងៗ គ្នានៅក្នុងដំណើរការរុករករ៉ែ?
- តើចំណូលរំពឹង ពីវិស័យ ប្រេង ឧស្ម័ននិង រុករករ៉ែ សម្រាប់មួយឆ្នាំខាងមុខ? (នេះមិនត្រូវបានរួមបញ្ចូលនៅក្នុងច្បាប់ថវិកាទេ)។

ផ្អែកលើសារៈសំខាន់នៃវិស័យទាំងនេះ សម្រាប់ការអភិវឌ្ឍនាពេលអនាគតរបស់ប្រទេសកម្ពុជា បង្កើនតម្លាភាពក្នុងវិស័យនេះគួរជាចំនុចអាទិភាពខ្ពស់សម្រាប់រយៈពេល ២០១៤-២០១៨។ ខណៈពេលដែលការទាញយករ៉ែនិង ការធ្វើអាជីវកម្មធនធានធម្មជាតិនៅក្នុងវិស័យនេះធ្លាប់បានកើតឡើងកន្លង មក រដ្ឋាភិបាលមិនធ្លាប់បានរាយការណ៍ពីប្រាក់ចំណូលសរុបពីវិស័យប្រេង ឧស្ម័ន និងរ៉ែនៅ តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ចឡើយ។ ប្រាក់ចំណូលទាំងនេះត្រូវបានគេរាយការណ៍នៅក្នុងតារាង ប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច[50] ឆ្នាំ ២០០៩។

[50] សូមមើលផ្នែកទិន្នន័យក្នុងគេហទំព័រ www.mef.gov.kh

ខណៈពេលដែល ការវាយទំហំតម្លៃនៃប្រាក់ចំណូលទាំងនេះនៅតែមិនទាន់ច្បាស់ សារៈសំខាន់នៃឱកាសដែលទទួលបានចំណូលពី ប្រេង ឧស្ម័ន និងរ៉ែនេះ មិនអាចត្រូវប៉ាន់ស្មានអោយទាបបាន ឡើយ។ ការវិចរិលនៃធនធានរ៉ែ គួរត្រូវបានទូទាត់ជាមួយនឹងការកែលម្អរបស់សូចនាករសេដ្ឋកិច្ច សង្គម។ វិស័យ នេះអាចផ្តល់នូវមូលនិធិចាំបាច់សម្រាប់ការផ្តល់ហិរញ្ញប្បទាន ដែលត្រូវការចាំបាច់ ខ្លាំងដល់ការអភិវឌ្ឍ សង្គម និងសេដ្ឋកិច្ច របស់ប្រទេសកម្ពុជា។ ការគ្រប់គ្រងដោយមានតម្លាភាពនៃវិស័យនេះ គឺជាការគិតទុកជាមុន ប៉ុន្តែមិនមែនជាគ្រាប់កាំភ្លើងវេទមន្តទេ។ អ្នកនយោបាយ មន្ត្រីរាជការស៊ីវិលនិងតំណាងសង្គមស៊ីវិល របស់ប្រទេសកម្ពុជា ចែករំលែកការទទួលខុសត្រូវនៃការធានាថាមូលនិធិដែលបង្កើតឡើងដោយវិស័យទាំងនេះត្រូវបានចំណាយអោយបានល្អបំផុត ដើម្បីធ្វើឱ្យជីវិតប្រជាជន នាពេលបច្ចុប្បន្ននិងនាពេលអនាគតប្រសើរឡើង កាត់បន្ថយភាពក្រីក្រ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គមអោយបាន។

## ៤.២.២- កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុដំណាក់កាលទី ២: ២០០៨-២០១៥

បច្ចុប្បន្ននេះ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ គឺស្ថិតនៅក្នុងដំណាក់កាលទីពីរ (២០០៨-២០១៥) ដែលមានឈ្មោះថា "*ការកសាងជំនឿចិត្តលើថវិកា ឆ្ពោះទៅរកភាពល្អប្រសើរជាងមុនលើទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុ*" និងកំពុងស្ថិតនៅក្នុងការឆ្លងទៅដំណាក់កាលទីបីនៅឆ្នាំ ២០១៥។ រដ្ឋាភិបាលកម្ពុជានៅតែបន្តដោះស្រាយបញ្ហាដែលនៅសេសសល់សំខាន់ៗ មួយចំនួនពីវេទិកាទី ១ និងអនុវត្តសកម្មភាពថ្មីៗ ដើម្បីសម្រេចបាននូវវេទិកានេះបន្ថែមទៀត ដែលមានគោលបំណងពីរ នៃការពង្រឹងទំនួលខុសត្រូវហិរញ្ញវត្ថុអោយកាន់តែប្រសើរឡើង។ សកម្មភាពសំខាន់ៗត្រូវបានសង្ខេបដូចខាងក្រោម:

### A- វេទិកាទី ១ សកម្មភាពដែលត្រូវពង្រឹងក្នុងដំណាក់កាលទី ២

- ការកែលម្អគោលនយោបាយការគ្រប់គ្រងប្រាក់ចំណូល និងរដ្ឋបាលបន្ថែមទៀត
- ការកែលម្អការគ្រប់គ្រងបំណុលបន្ថែមទៀត
- ការកែលម្អការគ្រប់គ្រង ជាគណនីសាច់ប្រាក់និង គណនីធនាគារបន្ថែមទៀត
- ការកែលម្អលទ្ធកម្មសាធារណៈបន្ថែមទៀត

### B- វេទិកាទី ២ សកម្មភាពដែលត្រូវពង្រឹងក្នុងដំណាក់កាលទី ២

- កែលម្អនៃការទំនួលខុសត្រូវដោយបញ្ជាក់ពីតួនាទីមុខងារ និងការទទួលខុសត្រូវក្នុងកម្រិត ផ្សេងៗគ្នារបស់រដ្ឋាភិបាលនិងក្នុងស្ថាប័នដែលការចំណាយទាំងអស់
- កែលម្អឧបករណ៍សម្រាប់លើកទឹកចិត្ត ឱ្យមានការទទួលខុសត្រូវលើការគ្រប់គ្រងហិរញ្ញវត្ថុ និងពង្រឹងទំនួលខុសត្រូវ
- ការកែលម្អបន្ថែមទៀតលើការអនុវត្តន៍ នៃការចាត់ថ្នាក់ថវិកាថ្មី និងតារាងគណនីថ្មី
- កែលម្អការប្រតិបត្តិនិងដំណើរការប្រតិបត្តិការថវិកា
- កែលម្អគណនេយ្យ របាយការណ៍ហិរញ្ញវត្ថុ និងតម្លាភាព

- កែលម្អសវនកម្មផ្ទៃក្នុង/ការត្រួតពិនិត្យ និងការឆ្លើយតបទៅនឹង/ការប្រើប្រាស់នៃការរកឃើញពីការធ្វើសវនកម្ម / ការត្រួតពិនិត្យ
- ពង្រឹង និងអភិវឌ្ឍន៍គោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការសារពើពន្ធ
- កសាងសមត្ថភាពស្ថាប័ន និងវិធានការលើកទឹកចិត្ត
- កែលម្អ និងពង្រីកការអនុវត្តន៍ ន៍ថវិកាកម្មវិធី
- ការកែលម្អអត្ថន័យលំអិត និងការធ្វើសមាហរណកម្មនៃថវិកាបន្ថែមទៀត

ដោយផ្អែកលើរបាយការណ៍ប្រចាំឆ្នាំ ២០១៤ នៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ដំណាក់កាលទី ២ បានបង្ហាញថា ផែនការនៅក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ លើកទី II នេះត្រូវបានអនុវត្តយ៉ាងរលូន និងជោគជ័យ (អគ្គលេខាធិការដ្ឋាន ២០១៥) (ចំពោះសមិទ្ធផលលម្អិត អាចចូលទៅគេហទំព័រ www.pfm.gov.kh )។

## ៤.៣. ទិសដៅយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០

ទំនាក់ទំនងរបស់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ទៅកំណែទម្រង់ប្រព័ន្ធថវិកាដែលបានកំណត់គោលដៅនៃការកម្មវិធីអនុវត្តថវិការបស់រដ្ឋាភិបាលទាំងមូល ចាប់ពី ២០១៣-២០២០។ ក្នុងឆ្នាំ ២០១៨ គ្រប់ក្រសួងនិងទីភ្នាក់ងារដែលជាអង្គភាពប្រើប្រាស់ថវិកា នឹងអនុវត្តថវិកាកម្មវិធីនេះ នឹងបញ្ចប់ដោយការផ្លាស់ប្តូរពីមូលដ្ឋាន បញ្ចូលព័ត៌មានទៅផ្អែកលើមូលដ្ឋានអនុវត្តកម្មវិធី / គ្រប់គ្រងលទ្ធផល មុនឆ្នាំ ២០២០។ តារាងលេខ៨ បង្ហាញថាផែនការសាកល្បងលើការអនុវត្តន៍ កម្មវិធីផ្តោតលើថវិការបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងលិខិតលេខ ២២៦៩ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០១៥។

តារាងទី៨: កំណែទម្រង់ប្រព័ន្ធថវិកាក្នុងការតម្រង់ទិសផែនការ

| | |
|---|---|
| ២០១៥ | ក្រសួងចំនួន ១០ ដែលបានអនុវត្ត គម្រោងថវិកា និងអង្គភាពថវិកា។ ពួកគេគឺជា ១-ក្រសួងសុខាភិបាល ២-ក្រសួងអប់រំយុវជននិងកីឡា ៣-ក្រសួងយុត្តិធម៌ ៤-ក្រសួងកិច្ចការនារី ៥-ក្រសួងអភិវឌ្ឍន៍ជនបទ ៦-ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ៧-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ៨-ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ៩-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិង ១០-ក្រសួងសាធារណការនិងដឹកជញ្ជូន។ |
| ២០១៦ | មានក្រសួង/ភ្នាក់ងារចំនួន ១៥ ដែលអនុវត្តគម្រោងថវិកា និងអង្គភាពថវិកា។ ក្រសួងទាំងនោះរួមមាន តុលាការកំពូល តុលាការបណ្តឹងឧទ្ធរណ៍ អគ្គលេខាធិការដ្ឋានសភាជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អាជ្ញាធរសវនកម្មជាតិ អង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងទេសចរណ៍ ក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងព័ត៌មាន រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ |
| ២០១៧ | មានក្រសួង/ភ្នាក់ងារចំនួន ១១ អនុវត្ត គម្រោងថវិកា និងអង្គភាពថវិកា។ ទាំងនោះរួមមាន ក្រសួងព្រះបរមរាជវាំង ក្រុមប្រឹក្សាធម្មនុញ្ញ ព្រឹទ្ធសភានិងទំនាក់ទំនងរដ្ឋសភា និងអធិការកិច្ច ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែ និងថាមពល ក្រសួងធម្មការនិងសាសនា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រសួងផែនការ និងក្រសួងសេវាកម្មស៊ីវិល។ |
| ២០១៨ | ក្រសួង ៣ ទៀត នឹងអនុវត្ត គម្រោងថវិកា និងអង្គភាពថវិកា ដូចជា ការិយាល័យគណៈរដ្ឋមន្ត្រីនិងអង្គភាពពាក់ព័ន្ធ ក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ (រដ្ឋបាលសាធារណៈនិងសន្តិសុខសាធារណៈ) ។ |
| ២០១៧-២០១៨ | រដ្ឋបាលថ្នាក់ក្រោមជាតិជាពិសេសនៅថ្នាក់រដ្ឋធានី និងខេត្ត នឹងអនុវត្តកម្មវិធី និងអង្គភាពថវិកា និងចាប់ផ្តើមបង្កើតថវិកានេះឡើងនឹង ឆ្នាំ ២០១៦។ |
| ត្រឹម ២០២០ | រដ្ឋសភាជាតិនឹងអនុម័តកម្មវិធីថវិការបស់រដ្ឋាភិបាលទាំងមូល។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានធ្វើវិសោធនកម្មមុនឆ្នាំ ២០២០ ដើម្បីអនុវត្តប្រព័ន្ធថវិកាកម្មវិធីពេញលេញនិងការអនុវត្តន៍ ដែលផ្អែកលើលទ្ធផល និងវិមជ្ឈការនិងសហវិមជ្ឈការនឹងចាប់ផ្តើមពីឆ្នាំ ២០២០ ទៅ។ |

គ្រប់ក្រសួងទាំងអស់ត្រូវបង្កើតនូវអង្គភាពថវិកា[51] ជាពិសេសក្រសួងដែលអនុវត្តនូវកម្មវិធីនិងអនុកម្មវិធី។ ផែនការថវិកាយុទ្ធសាស្ត្រនឹងបន្តជាឧបករណ៍គោលនយោបាយថវិកាដ៏ មានសារៈសំខាន់ក្នុងការផ្សារភ្ជាប់ ដូចបានបញ្ជាក់ក្នុងដំណើរការវិលជុំ ក្នុងជំពូកទី ២។ ខាងក្រោមនេះគឺជាកាលវិភាគរបស់ក្រសួង ពាក់ព័ន្ធក្នុងការបង្កើត និងអនុវត្តថវិកាកម្មវិធី។

[51] គឺជាការផ្តល់សិទ្ធអនុញ្ញាតក្នុងការចំណាយពីសំណាក់រដ្ឋមន្ត្រី ទៅកាន់អ្នកគ្រប់គ្រងកម្មវិធីឬ កម្មវិធីរង។

# ៥. តម្លាភាពថវិកា និងការចូលរួមជាសាធារណៈ

ការទទួលបានព័ត៌មាន និងការចូលរួមជាសាធារណៈក្នុងថវិកាជាតិ គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការអភិវឌ្ឍរបស់ប្រទេសកម្ពុជា ដែលជាប្រទេសប្រជាធិបតេយ្យ។ ជាមួយនឹងការទទួលបានព័ត៌មានស្តីពីថវិកាបន្ថែម ប្រជាពលរដ្ឋនឹងអាចចូលរួមបានល្អប្រសើរជាងមុន ឧទាហរណ៍ក្នុងការអនុវត្តន៍ ការត្រួតពិនិត្យថវិកា ហើយដូច្នេះធ្វើឱ្យរដ្ឋាភិបាលមានទំនួលខុសត្រូវនិងបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ។ នាពេលថ្មីៗនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានបង្កើតឲមានការចូលរួមពីដៃគូអភិវឌ្ឍន៍ និង ភាគីពាក់ព័ន្ធដទៃទៀត ក្នុងដំណើរការរៀបចំថវិកាតាមរយៈការរៀបចំនៅវេទិកាសាធារណៈទៅលើក្របខ័ណ្ឌផែនការម៉ាក្រូសេដ្ឋកិច្ចវត្តមធ្យម និង ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកា។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានអញ្ជើញដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល សិស្សានុសិស្សពីសាកលវិទ្យាល័យដែលជាប់ទាក់ទង និង អ្នកធ្វើការស្រាវជ្រាវដែលជាប់ពាក់ព័ន្ធ ដើម្បីផ្តល់មតិយោបល់លើក្របខ័ណ្ឌផែនការម៉ាក្រូសេដ្ឋកិច្ច និង ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រថវិកា និង ធាតុចូលជាអាទិភាព ខាងគោលនយោបាយដទៃទៀត សម្រាប់ការធ្វើអន្តរាគមន៍គោលនយោបាយតាមវិស័យ និងការបែងចែក ធនធាន ដើម្បីអនុវត្តវិស័យ អាទិភាពទាំងនោះ។

## ៥.១ ស្ថានភាពបច្ចុប្បន្ននៃការចូលរួមជាសាធារណៈអំពីព័ត៌មានថវិកា និងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្នុងឆ្នាំ ២០០៨ ច្បាប់ស្តីពីហិរញ្ញវត្ថុសាធារណៈ រដ្ឋាភិបាលបានទទួលស្គាល់អំពីសារៈសំខាន់នៃការទទួលបានព័ត៌មានអំពីថវិកាជាសាធារណៈ។ មាត្រាទី ៨៤ នៃច្បាប់នេះចែងថា: "*កំណត់ត្រាទាំងអស់លើចំណូល និងចំណាយរបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមតារាងនៃគណនី និងនាមវលីថវិកា និងគណនេយ្យទាំងអស់ និងរបាយការណ៍ហិរញ្ញវត្ថុត្រូវតែមានតម្លាភាព និងអាចផ្សព្វផ្សាយជាសាធារណៈ*"។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងដំណើរការឆ្ពោះទៅបែបនេះ និងមានការរួមបញ្ចូលទាំងការប្តេជ្ញាចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវការបញ្ចេញព័ត៌មានស្តីពីថវិកា[52]។ នេះត្រូវបានចែងនៅក្នុងគោលបំណង ២៥.៤ នៅលើដំណាក់កាលទី ២ នៃកម្មវិធីកំណែទម្រង់ការគ្រប់ គ្រងហិរញ្ញវត្ថុសាធារណៈ "*កែលម្អទម្រង់នៃរបាយការណ៍ និងការទំនាក់ទំនងជាមួយសាធារណៈជន*»។ សូចនាករសំខាន់ៗ ក្រោមការអនុវត្តសកម្មភាពនេះរួមមាន: ព័ត៌មានគន្លឹះដែលអាចរកក្នុងឆ្នាំសារពើពន្ធ: i) ឯកសារថវិកា ii) របាយការណ៍ថវិកាប្រចាំឆ្នាំ iii) របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ iv) របាយការណ៍សវនកម្មឯករាជ្យ v) កិច្ចសន្យាកុងត្រា និង vi) ធានធនដែលមានសម្រាប់ផ្នែកសេវាកម្មបឋម ដែលផ្តល់នូវពេលវេលាច្បាស់លាស់ ដែលរដ្ឋាភិបាលនឹងត្រូវធ្វើការបោះពុម្ពផ្សាយនូវឯកសារពាក់ព័ន្ធនឹងថវិកា ទោះបីជាវាមិនមានភាពច្បាស់លាស់អំពីព័ត៌មានលំអិតរបស់វា។ ឧទាហរណ៍:

---

[52] សូមមូលទំព័រទី ៣៨ ក្នុងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់ព័ត៌មានលំអិត ថាតើឯកសារណាមួយគួរត្រូវ បោះពុម្ពផ្សាយ។

- ២០០៨: យ៉ាងហោចណាស់ ត្រូវមានវត្តមាន របាយការណ៍ ៣ ផ្សេងគ្នា
- ២០០៩: យ៉ាងហោចណាស់ ត្រូវមានវត្តមាន របាយការណ៍ ៤ ផ្សេងគ្នា
- ២០១០: យ៉ាងហោចណាស់ ត្រូវមានវត្តមាន របាយការណ៍ ៥ ផ្សេងគ្នា

ផ្ទុយមកវិញ, ការធ្វើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមិនផ្តល់នូវព័ត៌មានលើ:

- កម្រិតលម្អិត ដែលត្រូវបានរួមបញ្ចូលនៅក្នុងឯកសារសាធារណៈ។ នេះគឺជាឧទាហរណ៍នៃបញ្ហាមួយក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ដែលកំណែសម្រាប់សាធារណៈ ត្រូវបានបូកសរុបចូលគ្នា។
- ឆ្នាំដែលរបាយការណ៍បង្ហាញ។ នេះជាបញ្ហាមួយ ព្រោះរបាយការណ៍ពីអាជ្ញាធរសវនកម្មជាតិ ចេញផ្សាយយឺតពេក ហើយជាលទ្ធផល គឺមិនអាចជាព័ត៌មានដែលមានប្រយោជន៍ខ្លាំង សម្រាប់ការបង្កើតនៃថវិកាឆ្នាំ ២០១៥ ។ ទោះបីជាយ៉ាងណា របាយការណ៍សវនកម្ម មានប្រយោជន៍ សម្រាប់អ្នកតាក់តែងច្បាប់ អ្នកសរសេរគោលនយោបាយក្នុងក្រសួង និងក្រុមអ្នកវិភាគ។ ដូច្នេះហើយ វាអាចនឹងមានប្រយោជន៍ ប្រសិនបើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បង្ហាញពីកាលកំណត់សម្រាប់ធ្វើការបោះពុម្ពផ្សាយរបាយការណ៍សវនកម្មពាក់ព័ន្ធនីមួយៗ។

ដោយផ្អែកលើភាពជាដៃគូនៃថវិកាអន្តរជាតិ (២០១៥) ដែលជាការស្រាវជ្រាវនេះធ្វើឡើងដោយ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល[53] បង្ហាញថាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈនៅក្នុងប្រទេសកម្ពុជា គឺនៅតែមានកម្រិតទាបបើប្រៀបធៀបនឹងប្រទេសដទៃទៀត។ ពិន្ទុនៃតម្លាភាពថវិការបស់កម្ពុជាបានធ្លាក់ចុះពីពន្ទុ ១៥ នៅឆ្នាំ ២០១២ ទៅពន្ទុ ៨ ក្នុងឆ្នាំ ២០១៥។ លទ្ធផលនេះបង្ហាញថាប្រទេសកម្ពុជា បានផ្តល់ព័ត៌មានតិចតួចប៉ុណ្ណោះទៅឱ្យសាធារណជន ដោយសារតែមានតែឯកសារ ២ ក្នុងចំណោម ៨ ប៉ុណ្ណោះដែលបានចេញផ្សាយទាន់ពេលវេលា (សូមមើលនៅក្នុងតារាងទី ៩) ខណៈពេលដែលឯកសារ ២ ផ្សេងទៀត (របាយការណ៍ប្រចាំខែ និងរបាយការណ៍ប្រចាំឆ្នាំ) ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុធ្លាប់បានបោះពុម្ព បានចេញផ្សាយយឺត ឬមិនបានបោះចេញផ្សាយតែម្តង។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញផ្សាយឯកសារគន្លឹះហៅថា "ថវិកាសង្ខេប» (សូមមើលក្នុងឧបសម្ព័ន្ធទី ៥) ចាត់ទុកថា ឯកសារសំខាន់មួយសម្រាប់ថវិកាប្រជាពលរដ្ឋ ចាប់តាំងពីឆ្នាំ ២០១៤ មក។ ឯកសារនេះត្រូវបានផ្សព្វផ្សាយយឺតពីរបីថ្ងៃនៃពេលវេលាកំណត់ ដែលជាលក្ខណៈល្អ របស់អន្តរជាតិ (សូមមើលតារាងលេខ ១០)។ ថវិកាដោយសង្ខេប រួមមានព័ត៌មានមូលដ្ឋានក្នុងការជួយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពីថវិកាជាតិ ទោះបី ជាមានភាពខ្វះព័ត៌មានលំអិតមួយចំនួនក៏ដោយផ្អែកលើមូលដ្ឋាន ស្តង់ដារថវិកាពលរដ្ឋល្អ។

[53] ការស្រាវជ្រាវសម្រាប់សន្ទស្សន៍ផែនការថវិកាត្រូវបានអនុវត្តជារៀងរាល់ពីរឆ្នាំម្តង។ បច្ចុប្បន្នភាពនៃព័តមាននេះអាចរកបាននៅលើ គេហទំព័រ www.openbudgetindex.org និង www.cambodianbudget.org.

តារាងទី ៩: ការទទួលបាននិងភាពគ្រប់គ្រាន់: ឯកសារថវិកាគន្លឹះចំនួនប្រាំបី តាមពេលវេលា



ឯកសារថវិកាដែលអាចរកបានគ្រប់ពេលវេលា

| ឯកសារ | ២០០៨ | ២០១០ | ២០១២ | ២០១៥ |
|---|---|---|---|---|
| របាយការណ៍មុនថវិកា | 🟡 | 🟢 | 🟢 | 🟢 |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល | 🟡 | 🟡 | 🟡 | 🟡 |
| ថវិកាដែលបានអនុម័ត | 🟢 | 🟢 | 🟢 | 🟢 |
| របាយការណ៍ថវិកាសម្រាប់ប្រជា | 🔴 | 🔴 | 🔴 | 🔴 |
| របាយការណ៍ក្នុងឆ្នាំ | 🟢 | 🟢 | 🟢 | 🔴 |
| របាយការណ៍ពាក់កណ្ដាលឆ្នាំ | 🟡 | 🟡 | 🟡 | 🟡 |
| របាយការណ៍បំណាច់ឆ្នាំ | 🟢 | 🟢 | 🔴 | 🔴 |
| របាយការណ៍សវនកម្ម | 🟡 | 🟡 | 🟡 | 🔴 |

ប្រភព: IBP, ២០១៥

ការស្ទង់មតិ វាយតម្លៃឯកសារជាសាធារណៈ និងចំនួនទឹកប្រាក់នៃព័ត៌មានចេញផ្សាយនៅក្នុងឯកសារថវិកាគន្លឹះទាំង៨ ដែលរដ្ឋាភិបាលគួរតែបង្កើត យ៉ាងហោចណាស់នៅថ្នាក់កណ្ដាល បង្ហាញនៅក្នុងតារាង១០ ខាងក្រោម។

**តារាងទី១០: ការកំណត់ពេលវេលាសម្រាប់ភាពអាចរកបានជាសាធារណៈ និងព័ត៌មានមួយចំនួនដែលត្រូវការដើម្បីដាក់បញ្ចូលនៅក្នុងឯកសារ**

| លេខ | ប្រភេទឯកសារ | កាលប្បវត្តិ |
|---|---|---|
| ១ | លិខិតស្នើសុំថវិកា | ឯកសារនេះ គួរតែត្រូវបានចេញផ្សាយយ៉ាងហោចណាស់មួយខែមុនពេលដាក់សំណើថវិកា ប្រតិបត្តិជូនទៅសភាដើម្បីពិចារណា។ ឯកសារនេះគួរតែផ្ដល់សូចនាករម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយសារពើពន្ធ និងសេដ្ឋកិច្ចរយៈពេលយូរក៏ដូចជាការរំពឹងទុកសម្រាប់ប្រភេទពន្ធ និងប្រាក់ចំណូលធំ។ |
| ២ | ការអនុម័តដំណើរថវិកា | ឯកសារនេះគួរតែត្រូវបានចេញឱ្យប្រើជាសាធារណៈ ខណៈពេលដែលសភាកំពុងពិចារណាវា ហើយមុនពេលដែលសភាបានអនុម័ត។ ឯកសារនេះគួរតែផ្ដល់ការពន្យល់ បានលម្អិតនៃប្រាក់ចំណូល ការចំណាយ /ការបែកចែកថវិកាសម្រាប់ឆ្នាំហិរញ្ញវត្ថុក្រោយ និងទ្រព្យសកម្ម ហិរញ្ញវត្ថុកាន់កាប់ដោយរដ្ឋាភិបាល។ |

| លេខ | ប្រភេទឯកសារ | កាលប្បវត្តិ |
| --- | --- | --- |
| ៣ | ថវិកាដែលបានអនុម័ត | ឯកសារនេះបានឆ្លុះបញ្ចាំងពីថវិកា ដែលបានបោះឆ្នោតគាំទ្រដោយសភា។ វាត្រូវតែចេញផ្សាយជាសាធារណៈ មិនលើសពីបីខែបន្ទាប់ពីការអនុម័ត។ ព័ត៌មានសំខាន់របស់ឯកសារនេះ គឺជាកម្មវិធីចម្បងដែលមានចំណូលនិងចំណាយ ការពន្យល់នៃគម្លាតរវាងថវិកា សំណើ និងថវិកាប្រតិបត្តិ ព័ត៌មានអំពីបំណុល និងការពិភាក្សាស្តីពីផលប៉ះពាល់នៃថវិកាដែលបានអនុម័តលើទ្រព្យសកម្ម និងបំណុលរបស់រដ្ឋាភិបាល ប្រាក់សោធននិវត្តន៍បុគ្គលិក និងបំណុលជាយថាភាព។ |
| ៤ | ថវិការបស់ពលរដ្ឋ | ឯកសារនេះអនុលោមតាមពេលវេលាកំណត់ នៃការចេញផ្សាយឯកសារថវិកា ដែលបានធ្វើសាមញ្ញភាពសម្រាប់ប្រជាពលរដ្ឋហើយវាគួរតែត្រូវបោះផ្សាយជាសាធារណៈជូន មិនលើសពីបីខែបន្ទាប់ពីឯកសារនីមួយៗបានអនុម័ត។ ឧទាហរណ៍: ប្រសិនបើជាឯកសារ កំណែសាមញ្ញភាពនៃថវិកាដែលបានអនុម័តនេះ វាត្រូវតែចេញផ្សាយមិនលើសពីបីខែបន្ទាប់ពីថវិកាបានអនុម័ត។ |
| ៥ | របាយការណ៍ប្រចាំខែ | ទាំងនេះគួរតែត្រូវបានចេញឱ្យប្រើជាសាធារណៈ មិនលើសពីបីខែបន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍បានបញ្ចប់។ ឯកសារនេះបង្ហាញវឌ្ឍនភាពនៃការអនុវត្តន៍ ថវិកា ដែលបង្ហាញពីចំនួនប្រាក់ ចំណូលនិងចំណាយ ក្នុងខែនីមួយៗ និងចំនួនតួលេខបូកបន្តដល់ខែដែលចេញរបាយការណ៍ រួមទាំងព័ត៌មានពីសកម្មភាពនៃការខ្ចីប្រាក់រដ្ឋាភិបាល។ |
| ៦ | របាយការណ៍ពាក់កណ្តាលឆ្នាំ | របាយការណ៍នេះគួរតែត្រូវបានបោះពុម្ពដល់សាធារណជន មិនឱ្យលើសពីបីខែបន្ទាប់ពីបញ្ចប់កាលបរិច្ឆេទនៃរបាយការណ៍។ វាគួរតែផ្តល់នូវបច្ចុប្បន្នភាព លើទស្សនៈរបស់រដ្ឋាភិបាលចំពោះទស្សនវិស័យនៃថវិកាកំណែលើការពិនិត្យឡើងវិញនៃការសន្មត់សេដ្ឋកិច្ចណាមួយ និងការចង្អុលបង្ហាញនៃ ដំណាក់កាលនៃការអនុវត្តន៍ ថវិកានៅពាក់កណ្តាលឆ្នាំនៃក្រមថវិកានីមួយៗ។ |
| ៧ | របាយការណ៍ប្រចាំឆ្នាំ | របាយការណ៍នេះគួរតែត្រូវបានចេញផ្សាយ មិនលើសពីមួយឆ្នាំក្រោយ ពីដំណាច់ឆ្នាំសារពើពន្ធ។ វាគួរតែផ្តល់ឱ្យអ្នកនូវរូបភាពលម្អិតនៃការចំណាយ និងចំណូលរបស់រដ្ឋាភិបាលនិងតុល្យភាពថវិការួម និងការផ្តល់ហិរញ្ញប្បទានរបស់ខ្លួន។ |
| ៨ | របាយការណ៍សវនកម្ម | ឯកសារនេះគឺជារបាយការណ៍របស់ការិយាល័យសវនកម្មជាតិ បង្ហាញថាតើ រដ្ឋាភិបាលបានអនុវត្តថវិកាដែលបានអនុម័តដោយសភាដែរឬទេ។ ឯកសារនេះត្រូវបានចេញផ្សាយជាសាធារណៈមិនលើសពី ១៨ ខែក្រោយពីដំណាច់ឆ្នាំសារពើពន្ធ។ |

ប្រភព: IBP, ២០១៥

## ៥.២. ឱកាសសម្រាប់ការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា

បើទោះជាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់រដ្ឋាភិបាល បានផ្តល់នូវឱកាសសម្រាប់ការចូលរួមជាសាធារណៈ ការចូលរួមជាសាធារណៈក្នុងដំណើរការថវិកាជាតិនៅតែមានកម្រិតនៅឡើយ។ ដោយផ្អែកលើការអង្កេតលើការផ្សព្វផ្សាយព័ត៌មានថវិកាឆ្នាំ ២០១៥ (OBS) ពិន្ទុនៃការចូលរួមជាសាធារណៈគឺមានតែ ៨ នៅលើ ១០០ ប៉ុណ្ណោះ។ នេះមានន័យថារដ្ឋាភិបាលនៃប្រទេសកម្ពុជា បានផ្តល់ ឱកាសតិចតួចសម្រាប់សាធារណៈជនចូលរួមក្នុងដំណើរការថវិកា និងការត្រួតពិនិត្យថវិកាជាតិ។

រូបភាពទី ៨: សមាសធាតុនៃការចូលរួមជាសាធារណៈក្នុងដំណើរការថវិកា




ប្រភព: IBP, ២០១៥

***ការរៀបចំនូវថវិកាជាតិ*** គឺជាដំណើរការផ្ទៃក្នុងរបស់រដ្ឋាភិបាល ដូចនេះប្រជាពលរដ្ឋ និងក្រុមអង្គការមិនមែនរដ្ឋាភិបាលមិនមានសិទ្ធិជាផ្លូវការ ទាក់ទងនឹងការសំរេចចិត្តរបស់មន្ត្រីជាន់ខ្ពស់នៅក្នុងដំណើរការនេះ។ នៅក្នុងវិស័យមួយចំនួន (ការអប់រំនិង អភិវឌ្ឍន៍ជនបទ) សេចក្តីព្រាងថវិការបស់រដ្ឋាភិបាលបានធ្វើលើកមកពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍តាមរយៈនឹងក្រុមការងារបច្ចេកទេស។ ទោះជាយ៉ាងណា ការពិភាក្សាភាគច្រើនបំផុត គឺធ្វើឡើងក្នុងកម្រិតជំពូក។ កិច្ចសហប្រតិបត្តិការជិតស្និទ្ធរវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ជាធម្មតានាំឱ្យមានការសន្ទនាមួយលើវិភាគទានហិរញ្ញវត្ថុ(ចំនួន និងអ្វីដែលត្រូវចំណាយ) របស់រដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍។ ខណៈពេលដែល មានតិចតួច ឬស្ទើរតែមិនមានតួនាទីជាផ្លូវការ សម្រាប់អង្គការសង្គមស៊ីវិល/អង្គការក្រៅរដ្ឋាភិបាលនៅដំណាក់កាលនេះ ការកែលម្អប្រាស្រ័យទាក់ទង និងការងារទំនាក់ទំនងរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងក្រសួងពាក់ព័ន្ធនានា គួរតែអាចធ្វើទៅបាន។ ឧទាហរណ៍ ក្នុងអំឡុងពេលរៀបចំច្បាប់ថវិកាឆ្នាំ ២០១០ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានលើកឡើងថាវិស័យកសិកម្ម និងការអភិវឌ្ឍន៍ជនបទគួរតែត្រូវបានផ្តល់អាទិភាពបន្ថែមទៀត។ នេះត្រូវបានធ្វើតាមរយៈការវិភាគ នៅក្នុងថវិកាជាសង្ខេបដែលត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់អ្នកតាក់តែងច្បាប់ មន្ត្រី រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ហើយបានបង្ហាញពីការអនុវត្តន៍ យឺតនៃគម្រោងរបស់ម្ចាស់ជំនួយក្នុងវិស័យទាំងនេះ។ ថវិកាជា

សង្ខេបនេះ ត្រូវបានអមដោយកម្មវិធីសន្ទនាតាមវិទ្យុនិងបានបន្តការត្រួតពិនិត្យលើវិស័យទាំងនេះនៅក្នុងច្បាប់ថវិកាជាតិ។

### *ការអនុម័តថវិកាដោយសភា*

នៅពេលនោះរដ្ឋសភាជាតិបានទទួលសេចក្តីព្រាងច្បាប់ស្តីពីថវិកា ពីទីស្តីការគណៈរដ្ឋមន្ត្រីកាលពីខែវិច្ឆិកា សវនាការជាបន្តបន្ទាប់រវាងសមាជិក និងតំណាងជាន់ខ្ពស់របស់សភាជាតិ មិនត្រូវបើកចំហជាសាធារណៈទេ។ នៅពេលដែលសេចក្តីព្រាងច្បាប់ថវិកា ដាក់ពិភាក្សានៅក្នុងសម័យប្រជុំពេញអង្គរបស់រដ្ឋសភា ប្រព័ន្ធផ្សព្វផ្សាយ និងអង្គការសង្គមស៊ីវិល/ អង្គការមិនមែនរដ្ឋាភិបាល អាចឃើញនៃដំណើរការនីតិវិធី[54] នៅលើអេក្រង់វីដេអូដែលផ្សាយផ្ទាល់ពីអគាររដ្ឋសភា។

ខណៈពេលដែលសេចក្តីព្រាងច្បាប់ថវិកា មិនទាន់ក្លាយជាឯកសារសាធារណៈផ្លូវការ ប្រធានគណៈកម្មាធិការទី២ របស់រដ្ឋសភាអាចចែករំលែក សេចក្តីព្រាងច្បាប់ថវិកាជាមួយក្រុមការងារមិនមែនរដ្ឋាភិបាលនៅក្នុងគោលបំណង ដើម្បីជំរុញការពិភាក្សាជាសាធារណៈ។ នៅក្នុងឆ្នាំ ២០០៩ និងឆ្នាំ ២០១០ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល បានរៀបចំសិក្ខាសាលាសម្រាប់ អ្នកតាក់តែងច្បាប់ទាំងអស់ ដើម្បីពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីថវិកា ដោយមានអ្នកតំណាងមកពីអង្គការសង្គមស៊ីវិល មុនពេលសម័យប្រជុំពេញអង្គរបស់រដ្ឋសភា។ នៅក្នុងសិក្ខាសាលា គំនិតនិងការយល់ឃើញពីសំណាក់ក្រុមការងារផ្សេងៗគ្នា ត្រូវបានចែករំលែកដល់អ្នកតាក់តែងច្បាប់ ដែលអ្នកទាំងនោះអាចយកមកពិចារណាបាន។ ចាប់តាំងពីឆ្នាំ ២០១២ មក សេចក្តីព្រាងច្បាប់ថវិកា រដ្ឋសភាមិនបានផ្តល់ជូន វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល។ ក្នុងឆ្នាំ ២០១៥ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល រួមជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មួយចំនួនទៀតត្រូវបានអញ្ជើញឱ្យ ចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់របស់សភា ស្តីពីច្បាប់ថវិកាឆ្នាំ ២០១៥។ ទោះជាយ៉ាងណា សេចក្តីព្រាងច្បាប់ថវិកានេះមិនត្រូវបានចែករំលែកដល់អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ សម្រាប់ការចូលរួមចំណែកក្នុងការពិភាក្សាប្រកបដោយផ្លែផ្កាឡើយ។ បុគ្គលនិងអង្គការសង្គមស៊ីវិលដែលចាប់អារម្មណ៍ ក្នុងការចូលរួមក្នុងសិក្ខាសាលាប្រចាំឆ្នាំនេះ អាចធ្វើការទំនាក់ទំនងមកក្រុមការងារគំរោងថវិការបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងខែ តុលា/វិច្ឆិកា ដើម្បីទទួលបានព័ត៌មានបន្ថែមពីទីតាំង និងកាលបរិច្ឆេទនៃសិក្ខាសាលានេះ។

### *ការអនុវត្តន៍ នៃច្បាប់ថវិកា ដោយអ្នកប្រតិបត្តិ*

ទោះបីជាព័ត៌មានលើការប្រតិបត្តិថវិកា នៅមានកំរិត ឧទាហរណ៍ដូចជា តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច (សូមមើលឧបសម្ព័ន្ធទី ៤ សម្រាប់ព័ត៌មានបន្ថែមពី តារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច)មានគំនិតផ្តួចផ្តើមមួយចំនួនដែលអង្គការសង្គមស៊ីវិល/ អង្គការមិនមែនរដ្ឋាភិបាល អាចតាមដានលើការអនុវត្តន៍ថវិការបស់រដ្ឋាភិបាល។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានត្រួតពិនិត្យការចំណាយក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ច និងការចំណាយដែលបានព្រាងទុក និងសេចក្តីព្រាងសង្ខេបស្តីពីគម្រោងប្រតិបត្តិថវិការបស់រដ្ឋាភិបាល។ព័ត៌មានទាំងនេះមានវត្តមាននៅក្នុងគេហទំព័រ www.cambodianbudget.org។ នៅក្នុងគេហទំព័រនេះ ការងារដែលបានមកពីអ្នកសង្កេតការ និងក្រុមអ្នក

[54] ដើម្បីទទួលបានការអនុម័តពីគណៈកម្មការទី ២ ក្រុមការងារមិនមែនរដ្ឋាភិបាល ត្រូវដាក់សំណើមួយទៅលោកអគ្គលេខាធិការរបស់រដ្ឋសភា។

វិភាគផ្សេងៗទៀតត្រូវបានចុះផ្សាយផងដែរ។ បុគ្គលនិងក្រុមធ្វើការងារទាក់ទង នឹងថវិកា ក៏អាចប្រើគេហទំព័រនេះដើម្បីចែករំលែកការងាររបស់ពួកគេទៅឱ្យសាធារណជនច្រើនជាងនេះផងដែរ។

មានការស្ទង់មតិ២ លើការតាមដានការចំណាយសាធារណៈ (PETS) ដែលធ្វើឡើងដោយអង្គការក្រៅ រដ្ឋាភិបាល។ ពួកគេ គឺជាការតាមដាន ការចំណាយសាធារណៈ នៅលើការប្រតិបត្តិថវិការបស់សាលា ធ្វើឡើងក្នុងឆ្នាំ ២០១៣ ដោយអង្គការដៃគូរសម្រាប់ការអប់រំ និង ការតាមដានការចំណាយសាធារណៈនៅលើការអប់រំកុមារតូចៗនៅក្នុងប្រទេសកម្ពុជា ដែលធ្វើឡើងក្នុងឆ្នាំ ២០១២ ដោយ វិទ្យាស្ថានតស៊ូមតិលើគោលនយោបាយ (API) ។ របាយការណ៍ចំនួន ២ ត្រូវបានទទួលស្គាល់ដោយមន្ត្រីក្រសួងអប់រំនិងត្រូវបានប្រើដោយដៃគូអភិវឌ្ឍន៍ ដើម្បីជះឥទ្ធិពលលើការពិភាក្សាលើការគ្រប់គ្រងដំណើរការអនុវត្តថវិកាក្នុងសាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា។

> ការបោះផ្សាយនូវសៀវភៅ "ប្រាក់របស់យើង, ការទទួលខុសត្រូវរបស់យើង" ដោយអង្គការភាពជាដៃគូថវិកាអន្តរជាតិ (www.internationalbudget.org) រួមមានករណីសិក្សាលើការផ្តួចផ្តើមរបស់សង្គមស៊ីវិលក្នុងការត្រួតពិនិត្យ ប្រតិបត្តិការថវិការបស់រដ្ឋាភិបាល។ ឧទាហរណ៍ ដូចជា ចលនាសង្គមរបស់ប្រទេសឥណ្ឌា ដែលមានឈ្មោះថា Mazdoor Kisan Shakti Sangathan (MKSS) ដែលវិភាគលើចំណាយរបស់រដ្ឋាភិបាលនៅថ្នាក់សហគមន៍ និងធ្វើការទាមទារអោយទីភ្នាក់ងាររដ្ឋាភិបាលទទួលខុសត្រូវក្នុងការចាយវាយនេះ។
>
> ឧទាហរណ៍មួយទៀត គឺជាការងាររបស់ក្រុមសង្គមស៊ីវិលនៃម៉ាឡាវី ដែលជាសម្ព័ន្ធសង្គមស៊ីវិលសម្រាប់គុណភាពអប់រំជាមូលដ្ឋាន (CSCQBE) ដែលបានប្រើក្នុងការស្ទង់មតិ ដើម្បីវាស់វែង គុណភាពនៃការអប់រំ និងទំហំនៃ "ការលេចធ្លាយ" នៃ ថវិកាអប់រំ ដោយសារមូលនិធិ បានផ្ទេរពីមួយកម្រិតទៅមួយកម្រិតទៀតក្នុងជួររដ្ឋាភិបាល។

### *សវនកម្ម និងការវាយតម្លៃ*

តាមរយៈការបោះពុម្ពផ្សាយរបាយការណ៍សវនកម្មឆ្នាំ ២០០៦ ២០០៧ និងឆ្នាំ ២០០៨ នៅក្នុងឆ្នាំ ២០០៩ ឆ្នាំ ២០១១ និងឆ្នាំ ២០១៤ រដ្ឋាភិបាលបានឱ្យសញ្ញាថាដំណាក់កាលនេះត្រូវបានចាត់ទុកជាដំណាក់កាលមួយសំខាន់។ អង្គការមិនមែនរដ្ឋាភិបាល អាចប្រើប្រាស់នូវរបាយការណ៍សវនកម្មនេះ ដើម្បីធ្វើឱ្យការវាយតម្លៃថាតើ នីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិសាខា បានឆ្លើយតបសមស្របទៅនឹងការរកឃើញនៃរបាយការណ៍សវនកម្មដែរឬទេ។ ការវាយតម្លៃទាំងនេះអាចជាព័ត៌មានដ៏មានប្រយោជន៍លើកិច្ចប្រឹងប្រែងលើការកំណែទម្រង់របស់រដ្ឋាភិបាល។ របាយការណ៍សវនកម្មថ្មីបំផុតអាចរកបានពីអាជ្ញាធរសវនកម្មជាតិ។

ការបោះផ្សាយនូវសៀវភៅ "ប្រាក់របស់យើង, ការទទួលខុសត្រូវរបស់យើង" ដោយអង្គការភាពជាដៃគូថវិកាអន្តរជាតិ (www.internationalbudget.org) រួមមានករណីសិក្សាចំនួន ៤ នៃការផ្តួចផ្តើមរបស់សង្គមស៊ីវិល ទាក់ទងទៅនឹងដំណាក់កាលនេះ រួមទាំងការងារអនុវត្តដោយ Fundar នៅក្នុងប្រទេសម៉ិកស៊ិក ដែលទទួលបានជោគជ័យនៃការធ្វើសវនកម្ម លើកម្មវិធីមេរោគអេដស៍/ជំងឺអេដស៍ និងពីអង្គការក្រៅរដ្ឋាភិបាល ដែលមានឈ្មោះថា "ការព្រួយបារម្ភរបស់ប្រជាពលរដ្ឋ ខេត្ត Abra លើអភិបាលកិច្ចល្អ" ដែលជាការត្រួតពិនិត្យលើគម្រោងរបស់រដ្ឋាភិបាលក្នុង ខេត្ត Abra នៃ ភាគខាងជើង ប្រទេសហ្វីលីពីន ដូចជាការកសាងផ្លូវ។

## ៥.៣. ប្រព័ន្ធទិន្នន័យទាក់ទងនឹងថវិកាជាតិ

ជាការបន្ថែមទៅលើធនធានខាងលើ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បានបង្កើតនូវទិន្នន័យមូលដ្ឋានសម្រាប់ទាំងថវិកាជាតិបំរុងទុក និងថវិកាប្រតិបត្តិ ដូចចែងនៅក្នុងច្បាប់ថវិកា និងច្បាប់ទូទាត់ថវិកា ២០០០-២០១៤ និង ២០១៥។ វាធ្វើតាមទ្រង់ទ្រាយនៃច្បាប់ថវិកា និងអនុញ្ញាតឱ្យអ្នកប្រើប្រាស់ ដើម្បីធ្វើការវិភាគថវិកាតាមតំរូវការ។ រចនាសម្ព័ន្ធនៃ ទិន្នន័យនៃថវិកានេះនឹងធ្វើបច្ចុប្បន្នភាព តាមការផ្លាស់ប្តូរនៃរចនាសម្ព័ន្ធនៃប្រាក់ចំណូលនិង ចំណាយក្នុងច្បាប់ថវិកា។ រចនាសម្ព័ន្ធនេះអាចទាញយកបានពីគេហទំព័រថវិការបស់កម្ពុជា: www.cambodianbudget.org។

# ឯកសារយោង


Ballard, B.M. *et al*. *Annual Development Review 2006-07.* Cambodia Development Resource Institute (CDRI). Phnom Penh, Cambodia. February, 2007

Cambodia Economic Forum (CEF). 'A SWOT Analysis of the Cambodian Economy'. A UNDP funded Discussion Paper. January, 2006.

International Monetary Fund (IMF). 'Cambodia: 2006 Article IV Consultation: Staff Report'. July, 2006.

IMF. 'Cambodia: 2007 Article IV Consultation: Staff Report'. August, 2007.

IMF and International Development Association (IDA). 'Joint IMF/World Bank Debt Sustainability Analysis 2007'. July, 2007.

Kingdom of Cambodia. *Constitution of the Kingdom of Cambodia.* 1993

Nelmes, J. 'Public Financial Management Reform Program: Annual Strategic Review Preparatory Retreat'. IMF Resident Representative for Cambodia. 2006

Nelmes, J.2008, remarked "Cambodia: Public Financial Management Reform Program Annual Review 2008". Access from https://www.imf.org/external/country/khm/rr/052808.pdf

Kingdom of Cambodia, Ministry of Economic and Finance (MEF), Tax Department. *Value-Added Tax Guide.* VAT Leaflet No. 01. Phnom Penh, Cambodia. 1998.

Kingdom of Cambodia, MEF. *Budget Management 2001. Part 1.* Phnom Penh, Cambodia. 2001(a).

Kingdom of Cambodia, MEF. *State's General Budget for Management 2001. Part 3: Budget Document for Line Department at Provinces and Municipals.* Phnom Penh, Cambodia. 2001(b).

Kingdom of Cambodia, MEF. *State's General Budget for Management*. *Part 2: Central Administration.* Phnom Penh, Cambodia. 2002(a).

Kingdom of Cambodia, MEF. *State's General Budget for Management 2002. Part 4.* Phnom Penh, Cambodia. 2002(b).

Kingdom of Cambodia, MEF. *Economic and Financial Review.* No. 33, 1st Quarter. Phnom Penh, Cambodia. 2004(a).

Kingdom of Cambodia, MEF. *Economic and Financial Review.* No. 35, 3rd Quarter. Phnom Penh, Cambodia. 2004(b).

Kingdom of Cambodia, MEF. *State's General Budget for Management 2003.* Phnom Penh, Cambodia. 2003(c).

Kingdom of Cambodia, MEF. *Public Financial Management Reform Program, Volume 1*. Phnom Penh, Cambodia. December, 2004.

Kingdom of Cambodia, MEF, Tax Department. *Law on Taxation.* Phnom Penh, Cambodia. 2004.

Kingdom of Cambodia, MEF. *Public Financial Management Reform Program: Summary of First Quarterly Progress for 2006.* Phnom Penh, Cambodia. 2006(a).

Kingdom of Cambodia MEF. 'Context of the Draft Budget Law 2007', H.E. Keat Chhon, 2006(b).

Kingdom of Cambodia, Ministry of Planning. *National Strategic Development Plan 2006-2010".* Phnom Penh, Cambodia. 2006.

Kingdom of Cambodia, National Assembly, Commission on Economy, Finance, Banking and Audit. *Law on Finance for Management 2006.* Phnom Penh, Cambodia. 2006.

Royal Government of Cambodia (RGC). *National Assembly National Budget Law*. Phnom Penh, Cambodia. 2006.

RGC. *National Assembly National Budget Law*. Phnom Penh, Cambodia. 2007.

Schiavo-Campo S. and D. Tommasi. *Managing Government Expenditure.* Asian Development Bank, Manila, Philippines. 1999.

General Secretariat, 2015. Annual Progress Report 2014 Implementation of Action Plan, Platform 2, access from http://pfm.gov.kh/Document/Report/Annual%20Progress%20Report%202014%20English.pdf

Sieng, D. 'Democratic Development through Decentralization in Cambodia: a Progress to be Sustained'. *Economic Review*, Volume 3 No.4, October-December. Economic Institute of Cambodia (EIC). Phnom Penh, Cambodia. 2006.

UNDP Cambodia. *Review of Development Prospects and Options for the Cambodian Oil and Gas Sector.* , Discussion Paper No.2. Phnom Penh, Cambodia. January, 2006.

World Bank. *Cambodia: Sharing Growth: Equity and Development Report*. Phnom Penh, Cambodia. June, 2007.

World Bank and IMF. 'Public Expenditure Management Assessment and Action Plan Cambodia'. Phnom Penh, Cambodia. 2005.

# ឧបសម្ព័ន្ធទី ១: សទ្ទានុក្រម

**ការសងវិលសំណុល:** ការសងបំណុល គឺជាចំនួនតាមកាលកំណត់ ដែលប្រាក់កម្ចីត្រូវគេសងតាមរូបភាពរំលស់។

**ការបំរុងប្រាក់ទុក:** ថវិកាដែលបានអនុម័តដោយ អង្គនិតិបញ្ញត្តិ សម្រាប់ប្រភេទនៃចំណាយ។ ច្បាប់ថវិកា ផ្តល់សាខាប្រតិបត្តិ នូវសិទ្ធិក្នុងការចុះកិច្ចសន្យា ដែលហួសពេលកំណត់ កំឡុងពេលឆ្នាំថវិកា រហូតដល់ចំនួនច្បាស់លាស់ណាមួយ សម្រាប់ គោលបំណងជាក់លាក់មួយក្នុងកំឡុងពេលហិរញ្ញវត្ថុមួយ (ជាធម្មតាឆ្នាំសារពើពន្ធមួយ)។

**ធាតុក្រៅគំពេងចំណាយ:** ទាំងនេះគឺនៅក្រោមបន្ទាត់ ដើម្បីបង្កើតនៃឱនភាពរវាង ចំណូល និងចំណាយដោយឆ្លើយតបនឹង ធាតុក្រោមខ្សែបន្ទាត់ ដែលរួមមានចំណាយ និងចំណូល។ ធាតុក្រៅគំពេងចំណាយដូច្នេះជាធម្មតា ទាក់ទងនឹងឱនភាពនៃ ហិរញ្ញវត្ថុ។

**ថវិកា:** ជាការប៉ាន់ស្មានដោយរដ្ឋាភិបាល ដែលត្រូវអនុម័តដោយរដ្ឋសភា នូវចំណូល និងការទទួលប្រាក់ប្រចាំឆ្នាំ និងបរិមាណនៃចំណាយ ដែលបានកំណត់ និងការចំណាយផ្សេងៗ។

**ថវិកាផ្គត់ផ្គង់:** ចំនួនថវិកាបំរុងដែលស្នើសុំឬអនុម័តសម្រាប់សមាសធាតុពាក់ព័ន្ធ ឬក៏សមាសធាតុធំជាងនេះដូចជា អនុកម្មវិធី កម្មវិធី និងវិស័យ ។ល។

**ចំណូលមូលធន:** ចំណូលពីការលក់នូវទ្រព្យមូលធន ដូចជា ដី ទ្រព្យមិនមែនជាវត្ថុធាត់ដើម ទំនិញដែលរក្សាទុក និងធាតុដ៏ទៅទៀត ដែលមានអាយុកាលចាប់ពី ១ ឆ្នាំឡើងទៅ។

**ការសន្យា:** ការដាក់បញ្ជាទិញ ឬការចុះហត្ថលេខាលើកិច្ចសន្យា ឬលើកិច្ចព្រមព្រៀងដ៏ទៃទៀត សម្រាប់ការផ្តល់ទំនិញ ឬសេវាកម្ម។

**ឥណទានជាប់សន្យា:** ពាក្យប្រើក្នុងច្បាប់ថវិកាជាតិនៃប្រទេសកម្ពុជា ដើម្បីបញ្ជាក់ថា ថវិកាបានស្នើសម្រាប់ហិរញ្ញប្បទានពីម្ចាស់ជំនួយ។ ឥណទានជាប់សន្យា គឺជាធម្មតាច្រើនតែក្រៅពីគម្រោងថវិកាក្នុង ប្រតិបត្តិការ។

**ទុនបម្រុងយថាភាព:** មួយផ្នែកតូចនៃចំនួនថវិកាសរុប ដែលបានកំណត់សម្រាប់ចំណាយ លើតំរូវការដែលមិនបានគ្រោងទុក ឬបន្ទាន់ ដែលមិនសមស្របក្នុងការបញ្ចូលទៅក្នុងជួរថវិកា។

**វិមជ្ឈការ និងវិសហមជ្ឈការ:** ដំណើរការដែលសិទ្ធិ និងការទទួលខុសត្រូវមួយចំនួន និងធនធានត្រូវបានផ្ទេរពីរដ្ឋបាលថ្នាក់ ក្រោមជាតិ ទៅក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលត្រូវបានជ្រើសតាំងតាមលិទ្ធិប្រជាធិប តេយ្យ និងដែលសេវាសាធារណៈ ត្រូវបាន ផ្តល់ឱ្យដោយថ្នាក់ក្រោមជាតិកាន់តែច្រើនឡើង។

**ឱនភាព:** ចំនួនចំណាយលើសចំណូលនៅក្នុងរយៈពេលជាក់លាក់មួយ។

**ពន្ធដោយផ្ទាល់:** ពន្ធដែលត្រូវបានកំណត់ដោយផ្ទាល់ទៅលើអ្នកបង់ពន្ធ ដូចជាពន្ធលើប្រាក់ចំណេញ ពន្ធលើប្រាក់ចំណូល ពន្ធលើអំណោយ និងមរតក។

**សិទ្ធិ:** រាល់ចំណាយគម្រោង ដែលជាចំណាយបើកចំហ (ជាធម្មតាផ្ទេរ/ការបង់ប្រាក់ជំនួយឥតសំណង) និងដែលអ្នកទទួល បាននូវការផ្ទេរ និងជំនួយឥតសំណង បើសិនជាគេអាចបំពេញនូវតាមលក្ខខណ្ឌមួយចំនួន។ ឧទាហរណ៍ជាទូទៅខ្លះៗ អាចឃើញនៅក្នុងកម្មវិធីសន្តិសុខសង្គម កម្មវិធីកាត់បន្ថយភាពគ្មានការងារធ្វើ និងកម្មវិធីកាត់បន្ថយភាពក្រីក្រ។

**មូលធនបន្ថែមថវិកា:** គណនីដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋាភិបាល ប៉ុន្តែមិនត្រូវបានបូកបញ្ចូលទៅក្នុងថវិការបស់រដ្ឋាភិបាល ឡើយការចំណាយដោយគណនីទាំងនេះ ភាគច្រើនបានហិរញ្ញប្បទានដោយ ចំណូលរក្សាទុក ឬចំណូលពីអ្នកប្រើប្រាស់។

**ឆ្នាំសារពើពន្ធ:** ជារយៈពេល ១២ ខែដែលរដ្ឋរៀបចំផែនការចំណូល និងចំណាយ។ នៅកម្ពុជា រយៈពេលនេះ ដូចគ្នានឹងឆ្នាំ ប្រតិទិន (ថ្ងៃទី ១ ខែមករា ដល់ថ្ងៃទី ៣១ ខែធ្នូ)។

**ផលិតផលក្នុងស្រុកសរុប (GDP):** តម្លៃសរុបនៃទំនិញ និងសេវាទាំងអស់ ដែលបានផលិតនៅក្នុងប្រទេសមួយ ក្នុងកំឡុងឆ្នាំ ប្រតិទិនមួយ។

**ប្រាក់ជំនួយឥតសំណង:** ចំនួនមូលនិធិមានកំណត់ ដែលត្រូវបានផ្តល់ឱ្យដោយរដ្ឋាភិបាលទៅអង្គភាពរដ្ឋបាលមូលដ្ឋាន (ស្រុក ឃុំ/សង្កាត់ និងខេត្ត/ក្រុង) យោងទៅតាមវិសមភាពសារពើពន្ធដែលបានវាស់វែង។ សិទ្ធិនេះអាចត្រូវបានទាមទារ ដោយអង្គភាពមូលដ្ឋានទាំងនោះ ដែលមានសមត្ថភាពសារពើពន្ធក្រោមមធ្យម គឺអង្គភាពដែលចំណូលផ្ទាល់របស់ពួកគេ មិនអាចបង្គ្រប់ការចំណាយបាន។

**ពន្ធដោយប្រយោល:** ពន្ធលើទំនិញ និងសេវា ដែលត្រូវបានប្រមូលដោយប្រយោលតាមរយៈភ្នាក់ងារដូចជាអ្នកនាំចូល អ្នកផលិត ឬហាង ឧទាហរណ៍ គឺពន្ធលើអាករបន្ថែម ពន្ធគយ និងពន្ធលើផលរបរ។

**ច្បាប់ថវិកាដើម:** គឺជាច្បាប់មួយដែលបញ្ជាក់ពីកាលវិភាគ និងនិតិវិធី ស្តីពីការរៀបចំ អនុម័ត ប្រតិបត្តិ ទំនួលខុសត្រូវ និងការស្នើ លើកចុងក្រោយលើការអនុម័តថវិកា។

**ទល្មផលជាក់ស្តែង:** ចំណូល និង ចំណាយជាក់ស្តែង។

**ការស្នើសុំការទូទាត់:** ការអនុម័តសម្រាប់ការទូទាត់វិក័យប័ត្រ ដែលធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាលរបស់ បណ្តាក្រសួងពាក់ព័ន្ធ ក្រសួងហិរញ្ញវត្ថុ និង ក្រសួងដ៏ទៃទៀត។

**ឥណទានចំណាយ:** ពាក្យដែលត្រូវបានប្រើក្នុងច្បាប់ថវិកាកម្ពុជា អធិប្បាយអំពីថវិកាអនុម័តដែលរំពឹងទុកពីម្ចាស់ជំនួយ។ មិនមែនគ្រប់កម្មវិធីវិនិយោគ (ឥណទានជាប់កិច្ចសន្យា) ដែលបានស្នើសុំសុទ្ធតែត្រូវបានរំពឹងថា នឹងត្រូវបានអនុម័តទាំងអស់ទេ។

**ផែនការទុនបំរុង:** ផ្នែកតូចមួយ នៃចំណាយថវិកាសរុបដែលបានគ្រោងទុក គឺជា (សញ្ញាណ) ដែលបានកំណត់ដោយក្រសួងហិរញ្ញវត្ថុមុនពេលដែលថវិកាបានបង្កើតឡើង និងបែកចែកទៅកាន់ជាតុរបស់ ចំណាយថវិកា ដោយគណៈរដ្ឋមន្ត្រី បើយោងតាមអាទិភាពគោលនយោបាយ លើវិស័យបុគ្គលកម្មវិធី ។ល។

**ប្រាក់បំរុងទុកបណ្តោះអាសន្ន:** ច្បាប់ដែលអនុញ្ញាតលើការចំណាយមុនពេលដែលការបែងចែកថវិកា ជាក់ស្តែង ដោយមិនមែននិតិវិធីអនុម័តអ្វីបន្ថែមទៀតឡើយ។ នេះជាករណីដែលត្រូវបានប្រើច្រើន នៅពេលចាប់ផ្តើមឆ្នាំសារពើពន្ធ(ឧទាហរណ៍ នៅពេលដែលអ្នកតាក់តែងច្បាប់មិនទាន់បានបញ្ចប់នូវការបង្កើតថវិកា)។

**ឥណទានកម្មវិធី:** ពាក្យប្រើប្រាស់ក្នុងច្បាប់ថវិកាជាតិរបស់ប្រទេសកម្ពុជា ពិពណ៌នាអំពីថវិកាវិនិយោគមូលនិធិសរុប (ហិរញ្ញប្បទានផ្តល់ដោយប្រភពក្នុងស្រុក និង ក្រៅស្រុក)។

**បំណុលសាធារណៈ:** ការជំពាក់បំណុលសរុបរបស់ប្រទេសមួយ ដែលជំពាក់ឥណទានក្នុងប្រទេសឬបរទេសនៅក្នុង ពេលជាក់លាក់ណាមួយ។ នេះគឺជាឱនភាពដែលកើនឡើងក្នុងថវិកាគ្រប់កម្រិត ដែលក្នុងនោះរដ្ឋប្រមូល និងចំណាយធនធាន (ថវិកាជាតិ ថវិការបស់អង្គភាពមូលដ្ឋាន ថវិការបស់មូលនិធិថវិកាបន្ថែម)។

**វិស័យសាធារណៈ**: នេះគឺជាផ្នែកមួយនៃ សេដ្ឋកិច្ចជាតិ ដែលតាមន័យទូលំទូលាយបំផុតគ្របដណ្តប់លើគ្រប់កំរិតនៃ រដ្ឋាភិបាល ប្រព័ន្ធសុខុមាលភាព និងសាជីវកម្មសាធារណៈ។

**ការផ្ទៀងផ្ទាត់**: ជាធម្មតា ដំណើរការនៃការពិនិត្យលើការបញ្ជាទិញ ចេញដោយភ្នាក់ងារ រដ្ឋាភិបាលទៅ នឹងចំណាយជាក់ស្តែងផ្អែកតាម របាយការណ៍ធនាគារ (ការផ្ទៀងផ្ទាត់អាចធ្វើឡើងនៅក្នុងដំណាក់ កាលចំណាយផ្សេងទៀតបាន ដូចជាកិច្ចសន្យាដែលបានធ្វើ និងបញ្ជាទិញដែលបានចេញ)។

**ចំណូល**: លុយដែលត្រូវបានប្រមូលដោយរដ្ឋ។ នេះរាប់បញ្ចូលទាំងពន្ធ ថ្លៃឈ្នួល និងថ្លៃសេវាផ្សេងៗ និងប្រាក់ចំណូលពីការលក់ទ្រព្យមូលធនដែលគ្រប់គ្រងដោយរដ្ឋាភិបាល។

**គណនីពិសេស**: គណនីកាត់ត្រាប្រតិបត្តិការមានលក្ខណៈ "ពិសេស" ដែលត្រូវបង្កើតឡើង ប្រាកចាកពីនិតិវិធីធម្មតាក្នុងការអនុម័ត និងកាត់ត្រាចំណាយ; ភាគច្រើនគឺអោយឈ្មោះថា គណនី បណ្តោះ អាសន្ន (ដូចជាគណនីហិរញ្ញឹក) ឬក៏ប្រតិបត្តិការទាំងឡាយណា ដែលមានការសង្ស័យលើសិទ្ធិ របស់អ្នកស្នើសុំ ឬគណនីរបស់មូលនិធិថវិកាលើសជាផ្លូវការ ឬ គណនី "ក្រៅគំរោងចំណាយ"។

**មូលនិធិពិសេស**: ជាធម្មតាដូចទៅនឹងមូលនិធិថវិកាលើស ដែលពេលខ្លះសំដៅលើមូលនិធិដែល បានហិរញ្ញប្បទានដោយ ប្រាក់ចំណូល/ថ្លៃ សេវា ដែលមាននៅក្នុងថវិការបស់រដ្ឋាភិបាល។

**ការបន្ថែមដោយសមរម្យ**: ដំណើរការបង្កើតច្បាប់កំឡុងពេលឆ្នាំថវិកា ដើម្បីផ្តល់នូវចំណាយថវិកាបន្ថែមលើចំណាយដែលបានគ្រោងទុក។

**គណនីជាប់សង្ស័យ**: ប្រភេទនៃគណនីបណ្តោះអាសន្នពិសេស ប្រើដើម្បីកាត់ត្រាអោយមានសមតុល្យ ឬកែតំរូវកំហុសលើ ចំនួន ដែលមិនទាន់បាន "បញ្ចូន" ទៅកាន់ប្រភេទចំណាយដែលពាក់ព័ន្ធ។ ប្រតិបត្តិការប្រភេទនេះជារឿយៗរួមមានការ កែតំរូវលើការទូទាត់ហិរញ្ញឹក រហូតដល់បានដឹងពីចំនួន ចំណាយជាក់ស្តែង។

**អតិរេក**: ចំណូលលើសនៃចំណូលលើចំណាយនៅក្នុងរយៈពេលជាក់លាក់ណាមួយ។

**ពន្ធ**: ចំណូលសាធារណៈមួយប្រភេទ ដែលត្រូវបានបង្ហាញជាការចំណាយដោយបង្ខំទៅឱ្យរដ្ឋដោយគ្មានអត្ថប្រយោជន៍តបវិញណាមួយ។

**រតនាគារ**: ប្រព័ន្ធនៃការគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុលើចំណូលចំណាយ និងបំណុលសាធារណៈ របស់រដ្ឋាភិបាល។ នេះរាប់បញ្ចូលទាំងការធ្វើផែនការ ការប្រតិបត្តិ ការអភិបាល និងការប្រើប្រាស់ធនធាននៃថវិកា។

**ការផ្ទៀងផ្ទាត់**: នៅពេលដែលបានទទួលនូវវិក័យប័ត្រលើការទិញទំនិញ ឬសេវា ក្រសួងពាក់ ព័ន្ធ/ភ្នាក់ងារចំណាយ ត្រូវបញ្ជាក់ថា វិក័យប័ត្រ គឺត្រឹមត្រូវ និងបានទទួលនូវទំនិញ ឬសេវានោះប្រាកដមែន។ នៅចំនុចនេះ វិក័យប័ត្រនេះ នឹងជាប់ជាបំណុល របស់វិស័យសាធារណៈ នៅក្នុងលក្ខខណ្ឌ គណនេយ្យបង្គរចំណាយនេះនឹងទទួលស្គាល់ បើទោះបីជាចំណាយមិនទាន់បាន ទូទាត់ជាសាច់ប្រាក់នៅឡើយ។

**ការផ្ទេរនៅគណនី**: គឺជាដំណើរការនូវការផ្ទេរនៃ ចំណាយពីគណនីមួយៗទៅគណនីមួយៗទៀត ក្នុងរយៈពេលមួយឆ្នាំ។ ដើម្បីជៀសវាងការ ប្រើប្រាស់មូលនិធិមិនសមស្រប ភ្នាក់ងារចំណាយ ត្រូវតែឆ្លងសំណើអនុលោមតាមនិតិវិធីរដ្ឋបាល ដើម្បីធ្វើការផ្ទេរនេះ។

**ការធានា**: ការបញ្ចេញនូវ ចំណាយបែងចែកប្រចាំឆ្នាំ ទាំងអស់ឬក៏ផ្នែកខ្លះ ក្នុង១ ត្រីមាសម្តង ឬមួយខែមួយដង និងអនុញ្ញាតអោយ ក្រសួងពាក់ព័ន្ធ ឬភ្នាក់ងារចំណាយអាចពិនិត្យឡើងវិញ នូវកិច្ចសន្យា។

# ឧបសម្ព័ន្ធទី ២: ឯកសារសម្រាប់អានបន្ថែម និងគេហទំព័រដែលពាក់ព័ន្ធ និង មានប្រយោជន៍

ឯកសារសម្រាប់អានបន្ថែម

១. ឯកសារច្បាប់ថវិកា (ចាប់ពី ១៩៩៩ មក)

ច្បាប់ថវិកា បង្ហាញពីការព្យាករណ៍អំពីចំណូល/ចំណាយ ដែលបានស្នើសម្រាប់ឆ្នាំ សារពើពន្ធថ្មី និងនិន្នាការនៃចំណាយមូលធនសម្រាប់រយៈពេល ២ ឆ្នាំក្រោយ។ វាក៏បង្ហាញពីការចំណាយ និងចំណូលពីក្នុងឆ្នាំសារពើពន្ធមុនផងដែរ។ ច្បាប់ថវិកាជាទូទៅ មានសម្រាប់សាធារណៈជន នៅដើមឆ្នាំសារពើពន្ធថ្មី។

២. ឯកសារស្តីពីការទូទាត់ឯកសារ (១៩៩៧-២០០៤)

ច្បាប់ស្តីពីការទូទាត់ថវិកា ភាគច្រើនពន្យល់អំពីទិដ្ឋភាពទូទៅលើការចំណាយដែលបានកំណត់ក្នុងថវិកាប្រៀបធៀប ទៅនឹងចំណាយពិតប្រាកដ។ ច្បាប់នេះក៏ផ្តល់បន្ថែមនូវព័ត៌មានអំពីមូលនិធិបន្ថែម ដែលបានចំណាយនៅក្នុងឆ្នាំសារពើរពន្ធចាស់។ មានការកាត់សំគាល់មួយលើកឡើងថា ច្បាស់ស្តីពីការទូទាត់ថវិកាគួរតែបញ្ជាក់អោយច្បាស់អំពីរបៀបលុយត្រូវចំណាយ និងលទ្ធផលដែលទទួលបាន ដែលជាគោលបំណងចំបងមួយរបស់ច្បាប់នេះ។ ច្បាប់ស្តីពីការទូទាត់ថវិកា គឺនៅតែទទួលយកនូវគំនិតកែលំអនានា ដោយសារតែការពន្យល់ទាំងអស់នេះមិនទាន់មាននៅឡើយទេ។ ច្បាប់ស្តីពីការទូទាត់ថវិកា ជាទូទៅគួរតែរៀបចំឡើង ដែលអាចអោយសាធារណជនរកមើលបាន ៩ ខែបន្ទាប់ពីឆ្នាំសារពើពន្ធចាស់ ទោះបីជាយ៉ាងណា ច្បាប់ទូទាត់ថវិការបស់កម្ពុជាគឺនៅមានភាពយឺតយ៉ាវរយៈពេល ៣ ឆ្នាំ។

៣. ការវិភាគច្បាប់ថវិកាឆ្នាំ ២០០៧

ការវិភាគនេះពិនិត្យលើគម្រោងចំណាយរបស់រដ្ឋាភិបាល ពិនិត្យលើចំណាយទាបក្នុងវិស័យអាទិភាព ជាមួយនឹងនិន្នាការក្នុងការចាយវាយលើសក្នុងឆ្នាំ ២០០៦ របស់វិស័យមិនអាទិភាព និងការមិនចាប់អារម្មណ៍លើការប្រើប្រាស់ ថវិកាសម្រាប់ក្រសួង/វិស័យអាទិភាព ក្នុងឆ្នាំ ២០០៧។

៤. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

៥. ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

៦. ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា

៧. ផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិកម្ពុជា (NSDP) ២០០៦-២០១០.

**គេហទំព័រដែលពាក់ព័ន្ធ និងមានប្រយោជន៍**

១. វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

www.ngoforum.org.kh

ផ្នែកបញ្ហាអភិវឌ្ឍន៍ មានឯកសារស្តីពីការអភិវឌ្ឍបច្ចុប្បន្នភាពផ្សេងៗ ដូចជាឯកសារគោលជំហរដាក់ជូនវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា (CDCF) និងទស្សនាវដ្តីឃ្លាំមើលការអភិវឌ្ឍនៅកម្ពុជា ដែលមានអត្ថបទស្តីពី ថវិកា និងបញ្ហាពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ផ្សេងទៀត។

២. វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា

www.eicambodia.org

ផ្នែកបោះពុម្ពផ្សាយរបស់វិទ្យាស្ថានសេដ្ឋកិច្ច ផ្តល់នូវឯកសារភាគច្រើនដែលទាក់ទងនឹងសេដ្ឋកិច្ច រាប់បញ្ចូលទាំង អត្ថបទស្តីពីថវិកាផងដែរ។

៣. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

http://www.mef.gov.kh/

ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ ត្រូវបានបោះពុម្ពផ្សាយជារៀងរាល់ខែ ដោយនាយកដ្ឋានសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញ វត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្សព្វផ្សាយដល់សាធារណជននូវ ព័ត៌មានស្ថិតិស្តីពីបញ្ហាសេដ្ឋ កិច្ចផ្សេងៗ។ ព្រឹត្តិប័ត្រស្ថិតិប្រចាំខែ អាចរកបានជាភាសាខ្មែរ និងអង់គ្លេស។ អ្នកអាន អាចមើលឯកសារនេះជាភាសា ទាំងពីរនៅពេលតែមួយនៅក្នុងទម្រង់ (PDF format) ។

៤. គម្រោងថវិកាអន្តរជាតិ (IBP)

http://www.internationalbudget.org/

គេហទំព័ររបស់គម្រោងថវិកាអន្តរជាតិ មានធនធានមួយចំនួន ដែលអាចជួយដល់ក្រុមមនុស្សរៀនបានច្រើនអំពីការងារថវិកាអនុវត្តន៍ និងទាក់ទងជាមួយក្រុមការងារថវិកាសង្គមស៊ីវិល នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសដែលឆ្លងកាលសម័យអន្តរកាល។ ធនធានទាំងនេះរួមមាន បណ្ណាល័យដ៏ទូលំទូលាយ ព័ត៌មាន និងអាស័យដ្ឋាន ទាក់ទងសម្រាប់មនុស្សមនុស្សជាច្រើននៃក្រុមការងារថវិកា ដែលគម្រោងថវិកាអន្តរជាតិជាមួយ ផ្នែកធនធានដ៏ទូលំទូលាយនិងព័ត៌មានអំពីព្រឹត្តិការណ៍អន្តរ ជាតិរបស់គម្រោងថវិកាអន្តរជាតិ។ គម្រោងថវិកាអន្តរជាតិក៏បោះពុម្ពផ្សាយព្រឹត្តិប័ត្រព័ត៌មានរៀងរាល់ពីរខែម្តងផងដែរ។

៥. សៀវភៅណែនាំស្តីពីការងារថវិកា សម្រាប់អង្គការមិនមែនរដ្ឋាភិបាល

http://www.internationalbudget.org/resources/guide/index.htm សៀវភៅណែនាំអំពីការងារថវិកា គឺជាសៀវភៅណែនាំមួយដែលបានបង្កើតឡើងមុនសៀវភៅណែនាំស្តីពី ការងារលើប្រាក់ចំណូល

នេះ។ សៀវភៅនេះ ផ្តល់នូវព័ត៌មានអំពីគោលការណ៍ និងការអនុវត្តន៍ នៃការងារថវិកាអនុវត្ត និងបញ្ជីធនធានដ៏ទូលំទូលាយសម្រាប់ព័ត៌មានបន្ថែម។

៦. ករណីសិក្សាអំពីក្រុមថវិកាដ៏រឹងមាំប្រាំមួយ

http://www.internationalbudget.org/casestudies.htm

គម្រោងថវិកាអន្តរជាតិ និងវិទ្យាស្ថានសម្រាប់ការសិក្សាពីការអភិវឌ្ឍន៍បានធ្វើការសិក្សាដ៏ទូលំទូលាយមួយលើផលប៉ះ ពាល់នៃការងារថវិកាអនុវត្តនៅក្នុងប្រទេសចំនួន ប្រាំមួយៈ ប្រេស៊ីល ក្រូអាត ឥណ្ឌា មិចស៊ីកូ អាហ្វ្រិចខាងត្បូង និងអ៊ូហ្កានដា។ការសិក្សានេះសន្និដ្ឋានថា ក្រុមថវិកានៅក្នុងប្រទេសទាំងនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងលើផ្នែកមួយចំនួន រាប់បញ្ចូលទាំងការលើកកំពស់តម្លាភាពថវិកា ការបង្កើនធនធានសម្រាប់កម្មវិធីគាំទ្រជនក្រីក្រ និងការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ធនធានទាំងនេះ។

៧. កម្រងសំនួរបើកចំហអំពីថវិកា

http://www.openbudgetindex.org

កម្រងសំណួរថវិកាបើកចំហរបស់គម្រោងថវិកាអន្តរជាតិ ត្រូវបានបង្កើតឡើងដើម្បីវាយតម្លៃលើកម្រិតនៃការទទួល បានព័ត៌មានស្តីពីថវិកា និងភាពបើកចំហនៃដំណើរការថវិកាតាមទស្សនៈ របស់អង្គការសង្គមស៊ីវិល។ កម្រងសំណួរនេះ ផ្តោតជាចំបងលើផ្នែកនៃការចំណាយរបស់ថវិកា។ ប៉ុន្តែ មានសំណួរមួយចំនួនដែលផ្តល់ព័ត៌មានអំពីប្រៀបដែលចំណូលត្រូវគ្នា នឹងដំណើរការថវិកាផងដែរ។

៨. បណ្ណាល័យអេឡិចត្រូនិចនៃគម្រោងថវិកាអន្តរជាតិ

http://ibp.forumone.com/resources/library/index.php

បណ្ណាល័យអេឡិចត្រូនិករបស់គម្រោងថវិកាអន្តរជាតិ ផ្ទុកនូវការភ្ជាប់ទៅនឹងរបាយការណ៍ ការសិក្សា និងឯកសារផ្សេង ទៀតស្តីពីបញ្ហាដែលទាក់ទងនឹងថវិកាដែលមាននៅតាមអ៊ីនធឺណេត។ បណ្ណាល័យនេះមានផ្នែកមួយនិយាយអំពី ″បញ្ហាពន្ធដារ និងចំណូល″។

៩. គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្ម និងនិស្សារណកម្ម (EITI)

http://www.eitransparency.org/

គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម ត្រូវបានដឹកនាំដោយភ្នាក់ងារអភិវឌ្ឍន៍ អន្តរជាតិ (DFID) នៃរាជាណាចក្ររួមអង់គ្លេស សហការជាមួយអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក។ គំនិតផ្តួចផ្តើមតម្លាភាពឧស្សាហកម្មនិស្សារណកម្ម មានគោលបំណងបង្កើតតម្លាភាពនៅក្នុងទំនាក់ទំនងរវាង រដ្ឋាភិបាល និងក្រុមហ៊ុន ឯកជននៅក្នុងឧស្សាហកម្មនិស្សារណកម្ម។ គេហទព័ររបស់គំនិតផ្តួចផ្តើមតម្លាភាព ឧស្សាហកម្មនិស្សារណកម្ម ផ្តល់នូវព័ត៌មានប្រវត្តិស្តីការផ្តួចផ្តើមនេះ ការពិពណ៌នាអំពីគោលការណ៍ របស់គម្រោងផ្តួចផ្តើមគំនិតស្តីពីតម្លាភាព នៃនិស្សារណកម្ម និងព័ត៌មានស្តីពីរដ្ឋាភិបាល ក្រុមហ៊ុន និងអង្គការមិនមែនរដ្ឋាភិបាល ដែលចូលរួមនៅក្នុងការផ្តួចផ្តើមគំនិតនេះ។

១០. គម្រោងបោះពុម្ពផ្សាយអ្វីដែលបានចំណាយ (PWYP)

http://www.publishwhatyoupay.org/

គម្រោងបោះពុម្ពផ្សាយអ្វីដែលបានចំណាយ គឺជាសម្ព័ន្ធភាព នៃអង្គការមិនមែនរដ្ឋាភិបាលជាង ៣០០ ដែលធ្វើការដើម្បីលើកកំពស់តម្លាភាពនៅក្នុងឧស្សាហកម្មនិស្សារណកម្ម។ សម្ព័ន្ធភាពនេះបានតម្រូវឱ្យ ក្រុមហ៊ុន ប្រេង ឧស្ម័ន និងរ៉ែ លាតត្រដាងជាចាំបាច់អំពីការចំណាយរបស់ខ្លួនចំពោះរដ្ឋាភិបាល។ គេហទំព័រនេះគូសបញ្ជាក់អំពីគោលបំណង របស់សម្ព័ន្ធភាព និងផ្តល់នូវធនធានដល់ក្រុមដែលមានបំណងចូលរួម។

១១. វិទ្យាស្ថានឃ្លាំមើលចំណូល (RWI)

http://www.revenuewatch.org/

វិទ្យាស្ថានឃ្លាំមើលចំណូល ធ្វើការជាមួយសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងអ្នកធ្វើគោលនយោបាយនៅក្នុងប្រទេស ដែលរំពឹងផ្អែកធនធាន ដើម្បីលើកកំពស់គណនេយ្យភាពបែបលទ្ធិប្រជាធិបតេយ្យ។ វិទ្យាស្ថាននេះ មានគោលបំណង ផ្តល់ឱ្យប្រជាពលរដ្ឋនូវព័ត៌មាន ការបណ្តុះបណ្តាញ និងមូលធិនិ ដែលពួកគេត្រូវការ ដើម្បីធ្វើអោយពួកគេ ក្លាយជាអ្នក តាមដានចំណូល និងចំណាយរបស់រដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព។

## តារាង ក: ចំណូលជាតិក្នុងឆ្នាំ២០១៥

| អត្រាប្តូរប្រាក់ NBC (រៀល / ដុល្លារ) | | | | | 4050 | |
|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | 2015 ជាលានរៀល | 2015 ជាពាន់ដុល្លារ | ភាគរយនៃសរុបចំណូលថវិកា |
| សរុបចំណូលថវិការបស់រដ្ឋាភិបាល (I+II) | | | | 15,135,230 | 3,737,093 | 100.0% |
| I- សរុបចំណូលឆ្លងកាត់តនាគារជាតិ(ក+ខ) | | | | 11,448,230 | 2,826,723 | 75.6% |
| | ក្នុងនោះចំណូលប្រទេស | | | 11,148,230 | 2,752,649 | 73.7% |
| | A. សរុបចំណូលចរន្ត(ក្រុម1+ក្រុម2) | | | 11,014,644 | 2,719,665 | 72.8% |
| | | ក្រុមទី1 ចំណូលពិត(ប្រភេទទី 1 + ប្រភេទទី 2) | | 11,014,644 | 2,719,665 | 72.8% |
| | | ប្រភេទទី 1: ចំណូលសារពើពន្ធ | | 9,548,391 | 2,357,627 | 63.1% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 7,587,691 | 1,873,504 | 50.1% |
| | 7001 | | ពន្ធផ្ទាល់(ពន្ធលើផលទុន ប្រាក់ចំណេញ) | 2,069,000 | 510,864 | 13.7% |
| | | 70012 | ពន្ធលើប្រាក់ចំណេញ(នីតិបុគ្គល) | 1,565,000 | 386,420 | 10.3% |
| | | 70013 | ពន្ធលើប្រាក់បៀវត្ស | 385,000 | 95,062 | 2.5% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ(រូបវន្តបុគ្គល) | 96,000 | 23,704 | 0.6% |
| | | 70015 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ(នីតិបុគ្គល) | 23,000 | 5,679 | 0.2% |
| | 7002 | | ពន្ធប្រយោល | 3,420,000 | 844,444 | 22.6% |
| | | 70022 | អាករលើតម្លៃបន្ថែម | 1,310,000 | 323,457 | 8.7% |
| | | 70025 | អាករលើតម្លៃបន្ថែមរបបនាំចូល(សហគ្រាសឥន្ទ | 550,000 | 135,802 | 3.6% |
| | | 70026 | អាករលើតម្លៃបន្ថែមរបបនាំចូល(សហគ្រាសផ្សេងៗទៀត) | 1,340,000 | 330,864 | 8.9% |

| អត្រាប្តូរប្រាក់ NBC (រៀល / ដុល្លារ) | | | | | 4050 | |
|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | 2015 ជាលានរៀល | ជាពាន់ដុល្លារ | ភាគរយនៃសរុបចំណូលថវិកា |
| | | 70027 | អាករលើតម្លៃបន្ថែមរបបនាំចូល ទំនិញជាសម្ភារៈកសិកម្ម( ជាបន្ទុករបស់រដ្ឋ ) | 187,000 | 46,173 | 1.2% |
| | 7003 | | អាករពិសេស | 1,953,400 | 482,321 | 12.9% |
| | | 7031 | អាករពិសេសលើទំនិញមួយចំនួន | 517,000 | 127,654 | 3.4% |
| | | 7032 | អាករពិសេសមួយចំនួនរបបនាំចូល( សហគ្រាសប្រេងឥន្ធនៈ ) | 288,200 | 71,160 | 1.9% |
| | | 7033 | អាករពិសេសមួយចំនួនរបបនាំចូល( សហគ្រាសផ្សេងៗទៀត ) | 1,075,200 | 265,481 | 7.1% |
| | | 7034 | អាករពិសេសលើសេវាមួយចំនួន | 73,000 | 18,025 | 0.5% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 95,314 | 23,534 | 0.6% |
| | | 70041 | អាករលើកាស៊ីណូ | 94,114 | 23,238 | 0.6% |
| | | 70042 | អាករលើឆ្នោត | 1,200 | 296 | 0% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តសកម្មភាព | 26,377 | 6,513 | 0.2% |
| | | 70052 | ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | 26,377 | 6,513 | 0.2% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 23,600 | 5,827 | 0.2% |
| | | 70081 | ពន្ធតែមប្រ៍ | 6,100 | 1,506 | 0 |
| | | 70082 | ការផាកពិន័យនិងទោសបញ្ញត្តិសារពើពន្ធ | 17,500 | 4,320 | 0.1% |
| 71 | | | **ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស** | **1,960,700** | **484,123** | **13.0%** |
| | 7100 | | ពន្ធនិងអាករលើការនាំចូល | 1,671,400 | 412,691 | 11.0% |
| | | 71001 | ពន្ធគយលើការនាំចូល | 1,102,000 | 272,099 | 7.3% |
| | | 71003 | ពន្ធគយលើផលិតផលតេលសិលា | 260,000 | 64,198 | 1.7% |
| | | 71004 | អាករបន្ថែមលើផលិតផលតេលសិលាសម្រាប់ | 230,000 | 56,790 | 1.5% |
| | | 71005 | ផលនៃការលក់ផ្នែកគយ | 800 | 197 | 0% |

| អត្រាប្តូរប្រាក់ NBC (រៀល / ដុល្លារ) | | | | | 4050 | |
|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | 2015 ជាលានរៀល | 2015 ជាពាន់ដុល្លារ | ភាគរយនៃសរុបចំណូលថវិកា |
| | | 71006 | ពិន័យផ្សេងៗលើការនាំចូល | 2,600 | 641 | 0% |
| | | 71007 | ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតផលឱសថ(បន្ទុករបស់រដ្ឋ) | 1,600 | 395 | 0% |
| | 7101 | | ពន្ធនិងអាករលើការនាំចេញ | 289,300 | 71,432 | 1.9% |
| | | 71011 | អាករលើការនាំចេញឈើ | 126,000 | 31,111 | 0.8% |
| | | 71012 | អាករលើការនាំចេញកៅស៊ូ | 30,000 | 7,407 | 0.2% |
| | | 71014 | អាករលើការនាំចេញទំនិញផ្សេងៗ | 2,800 | 691 | 0% |
| | | 71015 | កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ | 130,000 | 32,098 | 0.9% |
| | | 71016 | ពិន័យផ្សេងៗពីការនាំចេញ | 500 | 123 | 0% |
| | | **ប្រភេទទី2: ចំណូលមិនមែនសារពើពន្ធ** | | **1,466,253** | **362,038** | **9.7%** |
| 72 | | | **ផលទុននៃទ្រព្យសម្បត្តិរដ្ឋ** | **124,345** | **30,702** | **0.8%** |
| | 7200 | | ផលនៃសម្បទាននិងការជួលដីធ្លី | 113,615 | 28,053 | 0.8% |
| | | 72001 | សម្បទាននេសាទ | 3,000 | 741 | 0.0% |
| | | 72002 | សម្បទានព្រៃឈើ | 39,545 | 9,764 | 0.3% |
| | | 72003 | សម្បទានពីប្រេងកាត | 3,116 | 769 | 0.0% |
| | | 72004 | សម្បទានរ៉ែ | 43,748 | 10,802 | 0.3% |
| | | 72005 | ការជួលដីទំនេរ(មានតែដី) | 24,206 | 5,977 | 0.2% |
| | 7210 | | ផលទុនពីសហគ្រាសសាធារណៈ | 10,730 | 2,649 | 0.1% |
| | | 72012 | ភាគលាភរបស់សហគ្រាសសាធារណៈ | 10,730 | 2,649 | 0.1% |
| 73 | | | **ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា** | **1,255,027** | **309,883** | **8.3%** |
| | 7300 | | ផលទុនសហគ្រាសសាធារណៈរដ្ឋបាល សេវាដំណើរការ(រកចំណេញ) | 474,379 | 117,131 | 3.1% |

| អត្រាប្តូរប្រាក់ NBC (រៀល / ដុល្លារ) | | | | | 4050 | |
|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | 2015 | | |
| | | | | ជាលានរៀល | ជាពាន់ដុល្លារ | ភាគរយនៃសរុបចំណូលថវិកា |
| | | 73001 | ផលទុនរបស់អាកាសចរណ៍ស៊ីវិល | 92,900 | 22,938 | 0.6% |
| | | 73003 | ផលទុននៃសកម្មភាពទេសចរណ៍ | 256,905 | 63,433 | 1.7% |
| | | 73004 | ផលទុននៃសកម្មភាពវប្បធម៌ | 24,888 | 6,145 | 0.2% |
| | | 73005 | ផលទុនពីប្រៃសណីយ៍និងទូរគមនាគមន៍ | 93,418 | 23,066 | 0.6% |
| | | 73006 | ផលទុនពីវិទ្យុនិងទូរទស្សន៍ | 1,754 | 433 | 0.0% |
| | | 73007 | ផលទុននៃសេវាផ្គត់ផ្គង់អគ្គិសនីនិងទឹក | 30 | 7 | 0.0% |
| | | 73008 | ផលទុនផ្សេងៗទៀត | 4,484 | 1,107 | 0.0% |
| | 7301 | | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈ | 32,323 | 7,980 | 0.2% |
| | | 73011 | ការសម្ភារៈបរិក្ខារ សម្ភារៈខូចខាត សម្ភារៈសិក្សា | 128 | 31 | 0% |
| | | 73012 | លក់ឯកសារ លតាប័ត្រ និងលិខិតបោះពុម្ពផ្សេងៗ | 28,290 | 6,985 | 0.2% |
| | | 73013 | ផលបានពីការលក់ទ្រព្យសម្បត្តិកម្ទេចកំទី សត្វពាហនៈ | 9 | 2 | 0% |
| | | 73018 | ការលក់ទ្រព្យសម្បត្តិនៃរដ្ឋបាលសាធារណៈផ្សេងៗទៀត | 3,896 | 961 | 0.3% |
| | 7302 | | ផលពីការគ្រប់គ្រងរដ្ឋបាល | 670,153 | 165,470 | 4.4% |
| | | 73021 | អាករស្ថានទូត( លិខិតឆ្លងដែននិងទិដ្ឋាការ ) | 530,347 | 130,950 | 3.5% |
| | | 73023 | ផលពីការបង្កើតសហគ្រាស | 12,339 | 3,046 | 0.1% |
| | | 73024 | ផលពីការបង់សិទ្ធិប្រឡង | 1,046 | 258 | 0% |
| | | 73025 | ផលពីការលក់ស្លាកលេខ | 25,814 | 6,373 | 0.2% |
| | | 73026 | ចំណូលពីប្រដាប់ក្តី | 3,165 | 781 | 0% |
| | | 73027 | ផលពីការត្រួតពិនិត្យគុណភាពផលិតផល និងការគោរពបទដ្ឋាននិងសេវាត្រួត ពិនិត្យ អនាម័យសត្វ | 95,496 | 23,579 | 0.6% |

| អត្រាប្តូរប្រាក់ NBC (រៀល / ដុល្លារ) | | | | | 4050 | |
|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | 2015 | | |
| | | | | ជាលានរៀល | ជាពាន់ដុល្លារ | ភាគរយនៃសរុបចំណូលថវិកា |
| | | 73028 | ចំណូលពីការអនុញ្ញាតិរដ្ឋបាល ទំរង់រដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលផ្សេងៗ | 1,945 | 480 | 0% |
| | 7303 | | ការជួលទ្រព្យសម្បត្តិអចល័ត | 16,289 | 4,021 | 0.1% |
| | | 73031 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល | 5,245 | 1,295 | 0% |
| | | 73032 | ការជួលសហគ្រាសសាធារណៈនៅថ្នាក់ខេត្ត(មន្ទីរជំនាញ) | 9 | 2 | 0% |
| | | 73033 | ការជួលសម្ភារៈនិងមធ្យោបាយដឹកជញ្ជូន | 2 | 0 | 0% |
| | | 73034 | ការជួលអចលនវត្ថុ(អសង្ហារឹម) | 10,471 | 2,585 | 0.1% |
| | | 73038 | ផលពីការជួលទ្រព្យសម្បត្តិផ្សេងៗ | 560 | 138 | 0% |
| | 7304 | | ការផ្តល់សេវាកម្ម | 61,881 | 15,279 | 0.4% |
| | | 73042 | កម្រៃនៃការថែទាំ | 29,449 | 7,271 | 0.2% |
| | | 73043 | សុរិយោដី | 20,000 | 4,938 | 0.1% |
| | | 73044 | សេវាសំណង់ | 7,233 | 1,785 | 0% |
| | | 73045 | សេវាលិខិតថ្កោលទោស | 1,602 | 395 | 0% |
| | | 73048 | ផលពីសេវាផ្សេងៗទៀត | 3,596 | 887 | 0% |
| **74** | | | **ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម** | **8,864** | **2,189** | **0.1%** |
| | 7401 | | ផលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម | 8,864 | 2,189 | 0.1% |
| **75** | | | **ការឧបត្ថម្ភ អំណោយ** | **671** | **166** | **0.0%** |
| | 7506 | | ចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារ | 671 | 166 | 0.0% |
| | | 75061 | ពីក្រសួងស្ថាប័ន | 671 | 166 | 0.0% |
| **76** | | | **ផលហិរញ្ញវត្ថុ** | **77,364** | **19,102** | **0.5%** |
| | 7601 | | ការប្រាក់នៃការអោយខ្ចី | 77,338 | 19,095 | 0.5% |

| អត្រាប្តូរប្រាក់ NBC (រៀល / ដុល្លារ) | | | | | 4050 | |
|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | 2015 | | ភាគរយនៃសរុបចំណូលថវិកា |
| | | | | ជាលានរៀល | ជាពាន់ដុល្លារ | |
| | | 76011 | ការប្រាក់លើកម្ចី | 77,338 | 19,095 | 0.5% |
| | 7698 | | ផលហិរញ្ញវត្ថុផ្សេងៗ | 8 | 1 | 0 |
| 77 | | | **ផលផ្សេងៗ និងផលពិសេស** | 0 | 0 | 0.0% |
| | 7702 | | ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ | 0 | 0 | 0% |
| | 7704 | | ចំណូលពីការលក់អគារ | 0 | 0 | 0% |
| ខ.សរុបចំណូលមូលធន(ក្រុម១+ក្រុម២) | | | | 433,586 | 107,058 | 2.9% |
| | ក្រុមទី1 ចំណូលពិត(ប្រភេទ1+ ប្រភេទ2) | | | 433,586 | 107,058 | 2.9% |
| | | ប្រភេទទី1 ចំណូលពីប្រភពផ្ទាល់ | | 133,586 | 32,984 | 0.9% |
| 27 | | | **អចលកម្មហិរញ្ញវត្ថុផ្សេងៗ** | 133,586 | 32,984 | 0.9% |
| | 2701 | | ការអោយខ្ចី(ការសងវិញនូវមូលធន) | 133,586 | 32,984 | 0.9% |
| | | 27018 | ការអោយខ្ចីផ្សេងៗ | 133,586 | 32,984 | 0.9% |
| | | ប្រភេទទី2: ចំណូលពីប្រភពខាងក្រៅ | | 300,000 | 74,074 | 2.0% |
| 75 | | | **ការឧបត្ថម្ភអំណោយ** | 90,000 | 22,222 | 0.6% |
| | 7514 | | ឧបត្ថម្ភធនមូលធនពីក្រៅប្រទេសទ្វេភាគីសម្រាប់ចំណាយវិនិយោគ | 49,500 | 12,222 | 0.3% |
| | 7515 | | ឧបត្ថម្ភធនមូលធនពីក្រៅប្រទេសទ្វេភាគីសម្រាប់ចំណាយវិនិយោគិន | 40,500 | 10,000 | 0.3% |
| 50 | | | **ការខ្ចីប្រាក់ និងចំណូលប្រហាក់ប្រហែល** | 210,000 | 51,852 | 1.4% |
| | 5002 | | ការខ្ចីក្រៅប្រទេស ពហុភាគី | 210,000 | 51,852 | 1.4% |
| II- សរុបចំណូលអនុវត្តក្រៅតែនាគាជាតិ(ក+ខ) | | | | 3,687,000 | 910,370 | 24.4% |

| អត្រាប្តូរប្រាក់ NBC (រៀល / ដុល្លារ) | | | | | 4050 | |
|---|---|---|---|---|---|---|
| ជំពូក | គណនី | អនុគណនី | ចំណាត់ថ្នាក់ចំណូល | 2015 | | |
| | | | | ជាលានរៀល | ជាពាន់ដុល្លារ | ភាគរយនៃសរុបចំណូលថវិកា |
| | | ប្រភេទទី2 ចំណូលពីប្រភពខាងក្រៅ | | 3,687,000 | 910,370 | 24.4% |
| 75 | | | ការឧបត្ថម្ភអំណោយ | 537,000 | 132,593 | 3.5% |
| | 7514 | | ឧបត្ថម្ភធនមូលធនពីក្រៅប្រទេសទ្វេភាគីសម្រាប់ចំណាយវិនិយោគ | 537,000 | 132,593 | 3.5% |
| 50 | | | ការខ្ចីប្រាក់និងបំណុលប្រហាក់ប្រហែល | 3,150,000 | 777,778 | 20.8% |
| | 5002 | | ការខ្ចីក្រៅប្រទេស ពហុភាគី | 3,150,000 | 777,778 | 20.8% |

ប្រភព៖ ច្បាប់ថវិកាឆ្នាំ ២០១៥

# តារាង ខ: ចំណាយថវិកាថ្នាក់ជាតិ២០១៥

| អត្រាប្តូរប្រាក់ NBC ( រៀល / ដុល្លារ) | | 4050 | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ក្រសួង/ស្ថាប័ន | | សរុបរួមចំណាយ | | សរុបរួមចំណាយចរន្ត | | សរុបរួមចំណាយមូលធន | | សរុប | ចរន្ត | មូលធន |
| | | លានរៀល | ពាន់ដុល្លារ | លានរៀល | ពាន់ដុល្លារ | លានរៀល | ពាន់ដុល្លារ | ភាគរយនៃក្រសួងដោយចំណាយសរុប | | |
| **សរុបចំណាយរួម** | | **15,035,229.0** | **3,712,402.2** | **9,275,161.0** | **2,290,163.2** | **5,760,068.0** | **1,422,239.0** | **100.00%** | **100.00%** | **100.00%** |
| | រដ្ឋបាលកណ្តាល | 8,832,418.7 | 2,180,844.1 | 6,759,350.0 | 1,668,975.3 | | 0.0 | 58.74% | 72.88% | 0.00% |
| | មន្ទីរជំនាញរាជធានី ខេត្ត | 2,515,810.3 | 621,187.7 | 2,515,810.3 | 621,187.7 | | 0.0 | 16.73% | 27.12% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 3,687,000.0 | 910,370.4 | | 0.0 | 3,687,000.0 | 910,370.4 | 24.52% | 0.00% | 64.01% |
| **ក.** | **វិស័យរដ្ឋបាលទូទៅ** | **1,681,092.4** | **415,084.5** | **1,320,011.9** | **325,928.9** | **361,080.5** | **89,155.7** | **11.18%** | **14.23%** | **6.27%** |
| | រដ្ឋបាលកណ្តាល | 1,223,090.3 | 301,997.6 | 1,223,090.3 | 301,997.6 | | 0.0 | 8.13% | 13.19% | 0.00% |
| | មន្ទីរជំនាញរាជធានី ខេត្ត | 96,921.0 | 23,931.1 | 96,921.0 | 23,931.1 | | 0.0 | 0.64% | 1.04% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 361,080.5 | 89,155.7 | | 0.0 | | 0.0 | 2.40% | 0.00% | 0.00% |
| 01- | ព្រះបរមរាជវាំង | 75,613.0 | 18,669.9 | 75,613.0 | 18,669.9 | | 0.0 | 0.50% | 0.82% | 0.00% |
| 02- | រដ្ឋសភា | 124,474.7 | 30,734.5 | 124,474.7 | 30,734.5 | | 0.0 | 0.83% | 1.34% | 0.00% |
| 03- | ព្រឹទ្ធសភា | 56,171.0 | 13,869.4 | 56,171.0 | 13,869.4 | | 0.0 | 0.37% | 0.61% | 0.00% |
| 04- | ក្រុមប្រឹក្សាធម្មនុញ្ញ | 7,692.3 | 1,899.3 | 7,692.3 | 1,899.3 | | 0.0 | 0.05% | 0.08% | 0.00% |
| 05.1- | ទីស្តីការគណៈរដ្ឋមន្ត្រី | 124,474.7 | 30,734.5 | 124,474.7 | 30,734.5 | | 0.0 | 0.83% | 1.34% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 157,299.9 | 38,839.5 | | 0.0 | 157,299.9 | 38,839.5 | 1.05% | 0.00% | 2.73% |
| 05.4- | ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា | 12,352.0 | 3,049.9 | 12,352.0 | 3,049.9 | | 0.0 | 0.08% | 0.13% | 0.00% |
| 08- | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 24,300.8 | 6,000.2 | 23,360.4 | 5,768.0 | 940.4 | 232.2 | 0.16% | 0.25% | 0.02% |
| | 1. រដ្ឋបាលកណ្តាល | 12,481.4 | 3,081.8 | 12,481.4 | 3,081.8 | | 0.0 | 0.08% | 0.13% | 0.00% |

| អត្រាប្តូរប្រាក់ NBC ( រៀល / ដុល្លារ ) | | 4050 | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ក្រសួង/ស្ថាប័ន | | សរុបរួមចំណាយ | | សរុបរួមចំណាយចរន្ត | | សរុបរួមចំណាយមូលធន | | សរុប | ចរន្ត | មូលធន |
| | | លានរៀល | ពាន់ដុល្លារ | លានរៀល | ពាន់ដុល្លារ | លានរៀល | ពាន់ដុល្លារ | ភាគរយនៃក្រសួងដោយចំណាយសរុប | | |
| | 9. មន្ទីរជំនាញរាជធានី ខេត្ត | 10,879.0 | 2,686.2 | 10,879.0 | 2,686.2 | | 0.0 | 0.07% | 0.12% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 940.4 | 232.2 | | 0.0 | 940.4 | 232.2 | 0.01% | 0.00% | 0.02% |
| 09- | ក្រសួងការបរទេស និងសហប្រតិបត្តិការ អន្តរជាតិ | 83,719.3 | 20,671.4 | 83,719.3 | 20,671.4 | | 0.0 | 0.56% | 0.90% | 0.00% |
| 10- | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | 609,057.4 | 150,384.5 | 412,637.6 | 101,885.8 | 196,419.3 | 48,498.6 | 4.05% | 4.45% | 3.41% |
| | 1. រដ្ឋបាលកណ្តាល | 392,682.6 | 96,958.7 | 392,682.6 | 96,958.7 | | 0.0 | 2.61% | 4.23% | 0.00% |
| | 9. មន្ទីរជំនាញរាជធានី ខេត្ត | 19,955.0 | 4,927.2 | 19,955.0 | 4,927.2 | | 0.0 | 0.13% | 0.22% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 196,419.8 | 48,498.7 | | 0.0 | 196,419.8 | 48,498.7 | 1.31% | 0.00% | 3.41% |
| 14- | ក្រសួងផែនការ | 53,083.7 | 13,107.1 | 47,180.0 | 11,649.4 | 5,903.7 | 1,457.7 | 0.35% | 0.51% | 0.10% |
| | 1. រដ្ឋបាលកណ្តាល | 30,933.0 | 7,637.8 | 30,933.0 | 7,637.8 | | 0.0 | 0.21% | 0.33% | 0.00% |
| | 9. មន្ទីរជំនាញរាជធានី ខេត្ត | 16,247.0 | 4,011.6 | 16,247.0 | 4,011.6 | | 0.0 | 0.11% | 0.18% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 5,903.7 | 1,457.7 | | 0.0 | 5,903.7 | 1,457.7 | 0.04% | 0.00% | 0.10% |
| 28 | ក្រសួងរៀបចំដែនដីនិងនគរូបនីយកម្មនិងសំណង់ | 112,205.4 | 27,705.0 | 112,205.4 | 27,705.0 | | 0.0 | 0.75% | 1.21% | 0.00% |
| | 1. រដ្ឋបាលកណ្តាល | 71,613.6 | 17,682.4 | 71,613.6 | 17,682.4 | | 0.0 | 0.48% | 0.77% | 0.00% |
| | 9. មន្ទីរជំនាញរាជធានី ខេត្ត | 40,591.8 | 10,022.7 | 40,591.8 | 10,022.7 | | 0.0 | 0.27% | 0.44% | 0.00% |
| 30- | គណៈកម្មាធិការរៀបចំការបោះឆ្នោត | 13,299.0 | 3,283.7 | 13,299.0 | 3,283.7 | | 0.0 | 0.09% | 0.14% | 0.00% |
| 31 | អាជ្ញាធរសវនកម្មជាតិ | 9,671.3 | 2,388.0 | 9,671.3 | 2,388.0 | | 0.0 | 0.06% | 0.10% | 0.00% |
| 33- | ស្ថាប័នប្រឆាំងអំពើពុករលួយ | 27,561.4 | 6,805.3 | 27,561.4 | 6,805.3 | | 0.0 | 0.18% | 0.30% | 0.00% |

| អត្រាប្តូរប្រាក់ NBC ( រៀល / ដុល្លារ ) | | 4050 | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ក្រសួង/ស្ថាប័ន | | សរុបរួមចំណាយ | | សរុបរួមចំណាយចរន្ត | | សរុបរួមចំណាយមូលធន | | សរុប | ចរន្ត | មូលធន |
| | | លានរៀល | ពាន់ដុល្លារ | លានរៀល | ពាន់ដុល្លារ | លានរៀល | ពាន់ដុល្លារ | ភាគរយនៃក្រសួងដោយចំណាយសរុប | | |
| 34 | ក្រសួងមុខងារសាធារណៈ | 33,507.2 | 8,273.4 | 32,990.5 | 8,145.8 | | 0.0 | 0.22% | 0.36% | 0.00% |
| | 1. រដ្ឋបាលកណ្តាល | 23,741.7 | 5,862.1 | 23,741.7 | 5,862.1 | | 0.0 | 0.16% | 0.26% | 0.00% |
| | 9. មន្ទីរជំនាញរាជធានី ខេត្ត | 9,248.8 | 2,283.7 | 9,248.8 | 2,283.7 | | 0.0 | 0.06% | 0.10% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 516.7 | 127.6 | | 0.0 | 516.7 | 127.6 | 0.00% | 0.00% | 0.01% |
| **ខ.** | **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់** | **2,441,060.5** | **602,731.0** | **2,316,182.9** | **571,897.0** | **124,877.6** | **30,834.0** | **16.24%** | **24.97%** | **2.17%** |
| | រដ្ឋបាលកណ្តាល | 2,345,052.9 | 579,025.4 | 2,287,052.9 | 564,704.4 | **58,000.0** | 14,321.0 | 15.60% | 24.66% | 1.01% |
| | មន្ទីរជំនាញរាជធានី ខេត្ត | 29,130.0 | 7,192.6 | 29,130.0 | 7,192.6 | | 0.0 | 0.19% | 0.31% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 66,877.6 | 16,513.0 | | 0.0 | 66,877.6 | 16,513.0 | 0.44% | 0.00% | 1.16% |
| 06- | ក្រសួងការពារជាតិ | 1,322,800.0 | 326,617.3 | 1,322,800.0 | 326,617.3 | | 0.0 | 8.80% | 14.26% | 0.00% |
| 07.1- | ក្រសួងមហាផ្ទៃ សន្តិសុខសាធារណៈ | 878,995.0 | 217,035.8 | 878,995.0 | 217,035.8 | 58,000.0 | 14,321.0 | 5.85% | 9.48% | 1.01% |
| 07-2- | ក្រសួងមហាផ្ទៃរដ្ឋបាលទូទៅ | 172,634.5 | 42,625.8 | 105,756.9 | 26,112.8 | 66,877.6 | 16,513.0 | 1.15% | 1.14% | 1.16% |
| | 1. រដ្ឋបាលកណ្តាល | 105,756.9 | 26,112.8 | 105,756.9 | 26,112.8 | | 0.0 | 0.70% | 1.14% | 0.00% |
| | 9. សាលារាជធានីខេត្ត | | 0.0 | | 0.0 | | 0.0 | 0.00% | 0.00% | 0.00% |
| | វិនិយោគសាធារណៈដោយហិរញ្ញប្បទានបរទេស | 66,877.6 | 16,513.0 | | 0.0 | 66,877.6 | 16,513.0 | 0.44% | 0.00% | 1.16% |
| 26- | ក្រសួងយុត្តិធម៌ | 66,631.0 | 16,452.1 | 66,631.0 | 16,452.1 | | 0.0 | 0.44% | 0.72% | 0.00% |
| | យុត្តិធម៌ | 28,434.5 | 7,020.9 | 28,434.5 | 7,020.9 | | 0.0 | 0.19% | 0.31% | 0.00% |
